# ដូចខ្មោចប្ដូរកាយ

## ការសិក្សាអំពីផលប៉ះពាល់នៃការរៀបការដោយបង្ខំក្រោម របបខ្មែរក្រហម



Theresa DE LANGIS, Judith STRASSER, Thida KIM, Sopheap TAING

អង្គការចិត្តសង្គម អន្តរវប្បធម៌
តុលា ២០១៨

ដូចខ្មោចប្ដូរកាយ
ការសិក្សាអំពីផលប៉ះពាល់នៃការរៀបការដោយបង្ខំក្រោម របបខ្មែរក្រហម
តុលា ២០១៨

TPO Transcultural Psychosocial Organization
Community Mental Health Programme
DEUTSCHE ZUSAMMENARBEIT
giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH
zfd Ziviler Friedensdienst

# ដូចខ្មោចប្តូរកាយ

## ការសិក្សាអំពីផលប៉ះពាល់នៃការរៀបការដោយបង្ខំក្រោម
## របបខ្មែរក្រហម

# តារាងមាតិកា


## ❶ សេចក្តីសង្ខេប
១.១. លទ្ធផលសំខាន់ៗ
១.២. អនុសាសន៍

## ❷ សេចក្តីផ្តើម និងសាវតា
២.១. បញ្ញត្តិនៃការរៀបអាពាហ៍ពិពាហ៍តាមបែបប្រពៃណីនៅក្នុងបរិបទនៃប្រទេសកម្ពុជា
២.២. អាពាហ៍ពិពាហ៍ក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩)
២.៣. អាពាហ៍ពិពាហ៍ក្រោយការដួលរលំនៃរបបខ្មែរក្រហម (ក្រោយឆ្នាំ១៩៧៩)
២.៤. "អាពាហ៍ពិពាហ៍ដោយបង្ខំ" ជាការចោទប្រកាន់នៅចំពោះមុខ អ.វ.ត.ក

## ❸ វិធីសាស្ត្រ
៣.១. គោលបំណងនៃការសិក្សាស្រាវជ្រាវ
៣.២. ការរចនាការសិក្សាស្រាវជ្រាវ
៣.៣. ព្រំដែននៃការសិក្សាស្រាវជ្រាវ

## ❹ លទ្ធផល
៤.១ លទ្ធផលបានមកពីការស្ទង់មតិ (បរិមាណវិស័យ)
- ក. លក្ខណៈប្រជាសាស្ត្ររបស់អ្នកផ្តល់សម្ភាស
- ខ. អាពាហ៍ពិពាហ៍មុនរបបប្រល័យពូជសាសន៍ខ្មែរក្រហម (គឺ មុនថ្ងៃទី ១៧ មេសា ១៩៧៥)
- គ. អាពាហ៍ពិពាហ៍ក្នុងអំឡុងពេលរបបខ្មែរក្រហមកាន់កាប់ (១៧ មេសា ១៩៧៥ ដល់ ៧ មករា ១៩៧៩)
- ឃ.អាពាហ៍ពិពាហ៍ក្រោយរបបខ្មែរក្រហម (ក្រោយ ខែមករា ឆ្នាំ១៩៧៩)
- ង. ផលប៉ះពាល់នៃការរៀបការដោយបង្ខំ

៤.២. លទ្ធផលបានមកពីករណីសិក្សា (បែបគុណភាពវិស័យ)
- ក. ការរៀបការមុនរបបខ្មែរក្រហម
- ខ. ការរៀបការដោយបង្ខំ និងទំនាក់ទំនងផ្លូវភេទដោយបង្ខំក្នុងរបបខ្មែរក្រហម
  - i. ពិធីប្តេជ្ញាចិត្ត និងចាត់តាំងគូស្រករ
  - ii. ទំនាក់ទំនងភេទដោយបង្ខំ និងការរំលោភ
  - iii. ការតស៊ូប្រឆាំង និងទោសទណ្ឌ

គ . អាពាហ៍ពិពាហ៍ក្រោយរបបខ្មែរក្រហម
ឃ. ផលប៉ះពាល់នៃការរៀបការដោយបង្ខំ

៥ ការពិភាក្សានិងការផ្តល់អនុសាសន៍
៥.១. លទ្ធផលសំខាន់ៗ
៥.២. អនុសាសន៍

៦ ការខូទ្ទិសនិងសេចក្តីថ្លែងអំណរគុណ

១

# សេចក្ដីសង្ខេប

ជិត៤០ឆ្នាំបន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហមប្រល័យពូជសាសន៍ (១៩៧៥-១៩៧៩) ការរៀបការដោយបង្ខំនិងទំនាក់ទំនងផ្លូវភេទដោយបង្ខំ ដែលប្រជាជនកម្ពុជារាប់សែននាក់បានឆ្លងកាត់ នៅតែបន្តត្រូវបានគេយល់ដឹងតិចតួច ក្នុងសភាពជាចំណែកដ៏សំខាន់មួយនៃវិនាសកម្មទូទៅ។ ការរៀបការទាំងនេះ លុបបំបាត់មិនឲ្យមានជម្រើស ធ្វើឡើងដោយគ្មានការព្រមព្រៀង និងកើតឡើងក្នុងបរិបទមួយនៃការបង្ខំធ្ងន់ធ្ងរ។ ពួកគេបានដកហូតសិទ្ធិជាមូលដ្ឋានក្នុងការស្វ័យសម្រេចក្នុងជីវិត ហើយនៅក្នុងករណីជាច្រើន វាបានបង្កទៅជាការរំលោភបំពានលើផ្លូវកាយនិងផ្លូវភេទ ការប៉ះទង្គិចផ្លូវចិត្ត ការដកហូតសេដ្ឋកិច្ច ការផ្តាច់ចេញពីសាសនា និងការរើសអើងក្នុងសង្គម។ ផលវិបាកជាច្រើនដោយសារតែគោលនយោបាយនៃរបបខ្មែរក្រហមនៅតែបន្តរហូតដល់សព្វថ្ងៃនេះ។ ការសិក្សាស្រាវជ្រាវទ្រង់ទ្រាយតូច និងប្រើប្រាស់វិធីសាស្ត្ររួមគ្នាមួយនេះ ត្រូវបានធ្វើឡើងដើម្បីឲ្យមានការយល់ដឹងកាន់តែប្រសើរឡើងថែមទៀតអំពីផលប៉ះពាល់ដោយសារការរៀបការដោយបង្ខំពីក្នុងរបបខ្មែរក្រហមរហូតមកដល់ពេលបច្ចុប្បន្ននេះ។ ការស្រាវជ្រាវនេះប្រើប្រាស់វិធីសាស្ត្រដែលមានការឆ្លើយតបនឹងយេនឌ័រ និងមានការយល់ដឹងអំពីការប៉ះទង្គិច ក្នុងការផ្តល់នូវការពណ៌នាមួយអំពីរបៀបអនុវត្តគោលនយោបាយរបស់ខ្មែរក្រហម និងអំពីរបៀបដែលជនរងគ្រោះទទួលគោលនយោបាយនោះក្នុងបរិបទវប្បធម៌កម្ពុជា និងជាចំណែកមួយនៃប្រព័ន្ធអត្តសញ្ញាណនិងតួនាទីយេនឌ័រជាក់លាក់មួយ។ របាយការណ៍នេះ សំដៅរួមចំណែកដល់ការស្រាវជ្រាវដែលកំពុងមានការកើនឡើងស្តីពីអំពើហិង្សាយេនឌ័រក្នុងរបបខ្មែរក្រហម ដែលមិនសូវមានគេយកចិត្តទុកដាក់ផ្នែកសិក្សាស្រាវជ្រាវ ផ្នែកច្បាប់ ឬផ្នែកអភិវឌ្ឍន៍ឡើយ ហើយជារឿយៗមិនត្រូវបានលើកឡើងក្នុងកិច្ចពិភាក្សាប្រវត្តិសាស្ត្រជាសាធារណៈអំពីវិនាសកម្មនេះឡើយ។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អវតក) បានបង្កើតឡើងក្នុងឆ្នាំ២០០៦ ដើម្បីកាត់ទោសមេដឹកនាំជាន់ខ្ពស់របបខ្មែរក្រហមដែលនៅរស់រានមានជីវិត។ ការរៀបការដោយបង្ខំ និងការរំលោភផ្លូវភេទដែលកើតឡើងក្នុងការរៀបការនោះ នឹងត្រូវយកមកជំនុំជម្រះដោយ អ.វ.ត.ក នេះ ជា "ទង្វើអមនុស្សធម៌ផ្សេងទៀត" ក្រោមបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលជាចំណែកមួយនៃករណីសំណុំរឿង០០២/០២ ដែលបានចាប់ផ្តើមដោយមានសវនាការដំបូងកាលពីថ្ងៃទី៣០ កក្កដា ២០១៤។ ថ្មីៗនេះ ឧក្រិដ្ឋកម្មដដែលនេះត្រូវបានខាងព្រះរាជអាជ្ញាស្នើសុំឲ្យក្លាយទៅជាចំណែកមួយនៃការស៊ើបអង្កេតសម្រាប់សំណុំរឿង០០៤នៅក្នុង អវតក។

ដូច្នេះវាដល់ពេលវេលានិងមានការជាប់ពាក់ព័ន្ធហើយ ក្នុងការយល់ដឹងឲ្យកាន់តែស៊ីជម្រៅអំពីការរៀបការដោយបង្ខំនិងផលប៉ះពាល់របស់វា។ របាយការណ៍នេះសង្ឃឹមថានឹងរួមចំណែក ឲ្យមានការដឹងកាន់តែច្រើនអំពីការរៀបការទាំងនេះ ក៏ដូចជាផ្តល់ជាមូលដ្ឋានមួយ

សម្រាប់ការពិភាក្សាអំពីសំណងដ៏មានអត្ថន័យសម្រាប់ជនរងគ្រោះដែរ។លទ្ធផលនៃការស្រាវជ្រាវបង្ហាញថា សំណងទាំងនេះគួរសំដៅសម្រេចឲ្យបានការផ្លាស់ប្តូរទំនៀមវប្បធម៌ក្នុងសង្គមដែលបន្តកើតមាន និងដែលចាត់ទុកអំពើហិង្សាយេនឌ័រ និងអំពើហិង្សាផ្លូវភេទក្នុងពេលជម្លោះ និងក្រោយជម្លោះក្នុងប្រទេសកម្ពុជាជាការធម្មតា។

ការសិក្សាស្រាវជ្រាវនេះ ផ្អែកទៅលើការសម្ភាសន៍ជាមួយដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២ ចំនួន១០៦នាក់ អំពីបទពិសោធន៍របស់ពួកគេអំពីការរៀបការដោយបង្ខំក្នុងរបបខ្មែរក្រហម។ អ្នកចូលរួមទាំងអស់ត្រូវបានគេសម្ភាសដោយប្រើប្រាស់ការស្ទង់មតិបែបបរិមាណវិស័យដែលមានឱកាសតិចតួចបំផុតក្នុងការឆ្លើយតបចំពោះសំណួរបើក។ ជាងនេះទៀតអ្នកឆ្លើយតបប្រាំបួននាក់ក្នុងចំណោមសំណាកសរុបត្រូវបានសម្ភាសដោយប្រើប្រាស់សំណួរបើកតាមប្រធានបទ ដើម្បីបង្កើតជាមូលដ្ឋានសម្រាប់ករណីសិក្សាបែបគុណវិស័យ ចំនួន ៨ករណី(ដោយក្នុងនោះមានករណីសិក្សាមួយដែលមានការចូលរួមសម្ភាសរួមគ្នាពីប្តីប្រពន្ធដែលត្រូវគេបង្ខំឲ្យរៀបការជាមួយគ្នាដែរ)។ ការសម្ភាសន៍បានធ្វើឡើងដោយរក្សាការសម្ងាត់និងដោយមានការគាំទ្រផ្លូវចិត្តសង្គម ដើម្បីកាត់បន្ថយការប៉ះទង្គិចផ្លូវចិត្តឡើងវិញ ក្នុងពេលកំពុងពិភាក្សាប្រធានបទដ៏រសើបនេះ។ អង្គការធីភីអូ គឺជាអង្គការដឹកនាំការស្រាវជ្រាវ នេះដោយមានអ្នកឆ្លើយតបជ្រើសរើសចេញពីក្នុងចំណោមក្រុមដើមបណ្តឹងរដ្ឋប្បវេណី និងអតិថិជនរបស់អង្គការធីភីអូ និងអង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ( ស៊ីឌីភី ) ដែលជាផ្នែកមួយនៃកម្មវិធីអនុវត្តរួមគ្នាស្តីពីអំពើហិង្សាយេនឌ័រក្នុងរបបខ្មែរក្រហម។ អ្នកជំនាញឯកទេស អន្តរជាតិផ្នែកអំពើហិង្សាផ្លូវភេទក្នុងពេលមានជម្លោះត្រូវបានផ្តល់បេសកកម្មឲ្យសរសេររបាយការណ៍នេះ ហើយក៏ជាសមាជិកក្រុមស្រាវជ្រាវដែរ។

សេចក្តីផ្តើមនៃរបាយការណ៍នេះ ផ្នែកទី២ រៀបរាប់អំពីការពិនិត្យឡើងវិញទៅលើការស្រាវជ្រាវដែលមានស្រាប់ស្តីពីប្រពៃណីរៀបការមុនរបបខ្មែរក្រហម មុនពេលប្រមូលឯកសារស្រាវជ្រាវដែលបានបោះពុម្ពផ្សាយហើយ អំពីការរៀបការដោយបង្ខំក្នុងរបបនេះ អំពីផលប៉ះពាល់នៃការរៀបការដោយបង្ខំទាំងនេះបន្ទាប់ពីការដួលរលំនៃរបបនេះរហូតមកដល់សព្វថ្ងៃ និងអំពីវិធីសាស្ត្ររបស់ អ.វ.ត.ក និងស្ថាប័នដទៃទៀតទាំងជាតិនិងអន្តរជាតិក្នុងការដោះស្រាយផលប៉ះពាល់ទាំងនេះ។ ការពិនិត្យលើឯកសារទាំងនេះ ផ្តល់បរិបទសម្រាប់លទ្ធផលស្រាវជ្រាវនេះ ទាំងផ្នែកបរិមាណវិស័យនិងគុណវិស័យ ដែលមានបង្ហាញនៅក្នុងផ្នែកទីបួននៃរបាយការណ៍នេះ។ ក្នុងផ្នែកទី៥ របាយការណ៍ធ្វើការសន្និដ្ឋាន ដោយមានការពិភាក្សាអំពីរបៀបដែលលទ្ធផលនៃការស្រាវជ្រាវនេះ ផ្តល់សុពលភាព ញែកចេញពី ឬពង្រីកចំណេះដឹងនាពេលបច្ចុប្បន្នអំពីការប្រតិបត្តិគោលនយោបាយរៀបការដោយបង្ខំក្នុងរបបខ្មែរក្រហមក៏ដូចជារបៀបដែល "អត្ថន័យ" នៃការរៀបការដោយបង្ខំនេះត្រូវបានគេយល់ជ្រួតជ្រាត និងផលប៉ះ

ពាល់ដែលកើតមានទៅលើអ្នកដែលត្រូវគេបង្ខំឲ្យរៀបការទាំងនោះ។ ផ្នែកទី៥ សន្និដ្ឋានដោយមានផ្តល់អនុសាសន៍ដល់ភាគីពាក់ព័ន្ធជាច្រើន ឲ្យពិចារណាអំពីវិធីសាស្ត្រក្នុងការដោះស្រាយផលវិបាករយៈពេលវែងដោយសារតែឧក្រិដ្ឋកម្មយេនឌ័រផ្លូវភេទដែលរីករាលដាលគ្រប់កន្លែងជាផ្នែកមួយនៃយុត្តិធម៌អន្តរកាល និងកិច្ចខិតខំប្រឹងប្រែងក្នុងការអភិវឌ្ឍន៍ទាំងឡាយដែលកំពុងកើតឡើងក្នុងប្រទេសកម្ពុជា។

## ១.១ លទ្ធផលសំខាន់ៗ

លទ្ធផលសំខាន់បំផុតដែលកើតចេញពីការសិក្សានេះ គឺថា ក្នុងនាមជាគោលនយោបាយក្នុងប្រព័ន្ធមួយដែលមានការរីកសាយភាយ របស់របបខ្មែរក្រហម ការរៀបការដោយបង្ខំ និងការរួមភេទដោយបង្ខំ បានដកហូតសិទ្ធិជាមូលដ្ឋានរបស់មនុស្សក្នុងការជ្រើសរើស និងក្នុងការយល់ព្រម។ ការធ្វើបែបនេះ វាបានបន្តឲ្យកើតមាននូវវប្បធម៌រំលោភនិងការបំពានជាពិសេសទៅលើស្ត្រី ដោយសារអំពើហិង្សាយេនឌ័រផ្លូវភេទជាពិសេសតាមរយៈការរៀបការនិងការដាក់ទណ្ឌកម្ម ដែលបានក្លាយទៅជារឿងធម្មតា ដោយសារតែគោលនយោបាយរដ្ឋ និងនិទណ្ឌភាព។ ផលប៉ះពាល់នៃអំពើហិង្សាទាំងនេះ នៅតែបន្តកើតមានទៅលើជនរងគ្រោះរហូតដល់សព្វថ្ងៃនេះ។

លទ្ធផលសំខាន់ៗដទៃទៀត ដែលចេញមកពីការស្រាវជ្រាវនេះមានដូចខាងក្រោម។

*ការរៀបការមុនរបបខ្មែរក្រហម*

- ការរៀបការជាប្រពៃណីក្នុងប្រទេសកម្ពុជា ភាគច្រើនត្រូវបានរៀបចំដោយមានការយល់ព្រមពីឪពុកម្តាយសម្រាប់កូនរបស់ពួកគេ។ សម្រាប់បុរសដែលជាអ្នកចូលដណ្តឹង ត្រូវបានផ្តល់ឲ្យនូវជម្រើស។ ជាទម្លាប់ គេសុំការយល់ព្រមពីបុរសនិងស្ត្រីសម្រាប់ការផ្គូផ្គងមុនពេលរៀបអាពាហ៍ពិពាហ៍។ ទោះបីជាអ្នកឆ្លើយតបពាក់កណ្តាលបានរៀបការមុនរបបខ្មែរក្រហមរៀបរាប់ថាការរៀបការដែលរៀបចំឡើងតាមប្រពៃណីមិនមែនជាជម្រើសរបស់ពួកគេក៏ដោយ ក៏មិនមានអ្នកឆ្លើយតបណារៀបរាប់ថាការរៀបការនោះធ្វើឡើងដោយបង្ខំឡើយ សូម្បីតែគំនាបគ្រួសារមានឥទ្ធិពលខ្លាំងក៏ដោយ។

- ការរៀបការតាមប្រពៃណីខ្មែរ គឺជាមធ្យោបាយមួយសម្រាប់ផ្តល់សុពលភាព និងភាពស្របច្បាប់សម្រាប់សហព័ន្ធក្នុងភ្នែករបស់សហគមន៍ គ្រួសារ និងក្នុងបុព្វបុរស

សម្រាប់ពុទ្ធសាសនិកភាគច្រើន។ ជាប្រពៃណី ពិធីនិងជីវិតអាពាហ៍ពិពាហ៍ គឺជាមធ្យោបាយមួយដើម្បីបង្ហាញអំពីការគោរព និងការស្តាប់ដំបូន្មានរបស់កូនចំពោះឪពុកម្តាយ ហើយទាំងជីវិតនិងពិធីអាពាហ៍ពិពាហ៍ មានអត្ថន័យបែបព្រលឹងនិយមទៀតផង។ សម្រាប់ពុទ្ធសាសនិក នេះរួមមានទាំងផលកម្មពាក់ព័ន្ធនឹងជីវិតក្នុងពេលអតីតកាលនិងអនាគត។

*ការរៀបការដោយបង្ខំក្នុងរបបខ្មែរក្រហម*

- ការអនុវត្តរបស់រដ្ឋនៅគ្រប់កន្លែង និងជាលក្ខណៈប្រព័ន្ធអំពីការរៀបការដោយបង្ខំ និងការរួមភេទដោយបង្ខំដូចដែលអ្នកឆ្លើយតបបានរៀបរាប់ រួមជាមួយនឹងផលប៉ះពាល់ធ្ងន់ធ្ងរទៅលើសុខមាលភាពរាងកាយ និងផ្លូវចិត្តរបស់ជនរងគ្រោះផងនោះ បង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

- យោងតាមការសម្ភាសន៍សម្រាប់ករណីសិក្សា "ការរៀបការដោយបង្ខំ" ត្រូវអ្នកឆ្លើយតបយល់ថាយ៉ាងហោចណាស់មានបទល្មើសច្បាស់ចំនួនបី៖ ការបាត់បង់ជម្រើស និងការយល់ព្រម, ការបាត់បង់ពិធីរៀបការបែបប្រពៃណីជាមួយគ្រួសារនិងការចូលរួមពីព្រលឹងបុព្វបុរស ព្រមទាំង ការបង្ខំឲ្យរួមភេទក្នុងអំឡុងពេលនៃរបបនោះ។

- ពិធីរៀបការរបស់ខ្មែរក្រហម គឺជាការប្រាសចាកទាំងស្រុងពីពិធីនិងជីវិតរៀបការដែលធ្លាប់បានរៀបចំតាមប្រពៃណីដោយមានការព្រមព្រៀងគ្នា។ អង្គការយកតួនាទីជាឪពុកម្តាយរបស់ប្រជាជន។ អង្គការ ចាត់តាំងប្តី/ប្រពន្ធឲ្យ ហើយកម្មាភិបាលខ្មែរក្រហមបានបង្ខំដោយហិង្សាឲ្យចូលរួមក្នុងពិធីរៀបការនិងក្នុងការរួមភេទ ដែលជារឿយៗជាមួយអ្នកស្ទើរមិនដែលធ្លាប់បានស្គាល់គ្នាសោះ។ គេមិនឲ្យមានការចូលរួមពីឪពុកម្តាយនិងពិធីជូនតាឡើយ ហើយនេះនាំឲ្យមានផលកម្ម។

- ការជំទាស់នឹងការរៀបការដោយបង្ខំនិងការរួមភេទដោយបង្ខំជារឿងធម្មតា។ អ្នកឆ្លើយតបភាគច្រើន (៧០,២%) បដិសេធសំណើរៀបការយ៉ាងហោចណាស់ម្តង ប៉ុន្តែចុងក្រោយ ស្ទើរតែទាំងអស់ (៩៧,២%) ត្រូវគេបង្ខំឲ្យរៀបការហើយស្ទើរតែទាំងអស់ (៩៧,០%) លើកឡើងថាការរៀបការនេះមិនមែនជាជម្រើសរបស់ខ្លួនឡើយ។

- ទណ្ឌកម្មសម្រាប់ការបដិសេធមិនរៀបការឬមិនព្រមរួមភេទដោយបង្ខំ រួមមានការគំរាមដោយពាក្យសម្តី ការដាក់ទណ្ឌកម្មលើរាងកាយ ដូចជាការវាយដំ ការរំលោភ

ការឲ្យធ្វើទាសករផ្លូវភេទ និងការស្លាប់។

- ពិធីរៀបការដោយបង្ខំទាំងហ្វូង (រួមមានពីបីទៅរាប់រយគូ) ត្រូវបានរៀបចំឡើងមានលក្ខណៈជាប្រព័ន្ធ និងមាននៅគ្រប់កន្លែង ដូចមានរៀបរាប់ដោយអ្នកឆ្លើយតបក្នុងករណីសិក្សា។

- ការសម្ភាសន៍ជាករណីសិក្សាបង្ហាញថា បុរសជាច្រើនមានឱកាសស្នើសុំសហព័ន្ធក្នុងរបបនោះ ហើយមានអ្នកឆ្លើយតបពាក់កណ្ដាលបានលើកឡើងដូច្នេះ។ ពាក់កណ្ដាលទៀតលើកឡើងថាការផ្គូផ្គងធ្វើឡើងដោយការចាត់តាំងតាមទំនើងចិត្ត។

- ស្ទើរពាក់កណ្ដាល(៤៦,៥%)នៃការស្ទង់មតិបានរៀបរាប់ថាបានស្គាល់គ្នា ឬបានស្គាល់អំពីគ្នានៅពេលរៀបចំពិធីការនេះ ហើយករណីសិក្សាបានលើកឡើងថា ការស្គាល់គ្នានេះគឺមិនស្គាល់ដោយផ្ទាល់ទេ គឺស្គាល់តាមរយៈអ្នកដទៃនៃបណ្ដាញក្នុងសហគមន៍ឬតាមសាច់ញាតិ។ ប្រជាជន "ចាស់" មានគុណសម្បត្តិច្រើនជាងប្រជាជន "ថ្មី" ពាក់ព័ន្ធនឹងការមានបណ្ដាញនេះ ដោយមានការរៀបរាប់ក្នុងករណីសិក្សាផងដែរថាការប្រព្រឹត្តលើប្រជាជនចាស់ មានភាពប្រសើរជាងទៅលើប្រជាជនថ្មីពាក់ព័ន្ធនឹងពិធីរៀបការនេះផ្ទាល់។

- ជម្រើសយុទ្ធសាស្ត្រដើម្បីរស់ ជារឿងធម្មតាក្នុងរបបខ្មែរក្រហម ដោយរួមមានទាំងការអនុលោមតាមការរៀបការដោយបង្ខំនិងការរួមភេទដោយបង្ខំដោយសារតែការភ័យខ្លាចទណ្ឌកម្មឬការស្លាប់។ ជម្រើសទាំងនោះមានផលវិបាកផ្នែកសម្ពាធៈនិងចិត្តសាស្ត្រដែលមានលក្ខណៈប៉ះទង្គិចផ្លូវចិត្តជាពិសេសទៅលើស្ត្រី ដោយសារតែច្បាប់វប្បធម៌បានហាមប្រាម និងឋានៈយេនឌ័រទាបជាងបុរស។

- ការរៀបការដោយបង្ខំ និងការរួមភេទដោយបង្ខំ គឺជាទម្រង់នៃអំពើហិង្សាយេនឌ័រផ្លូវភេទ។ ដូចនេះ ប្រព័ន្ធនៃការរៀបការក្នុងរបបខ្មែរក្រហមត្រូវបានពណ៌នាថា ធ្វើឲ្យមានវប្បធម៌រំលោភផ្លូវភេទពង្រឹងដោយរដ្ឋ គឺថា ការរំលោភត្រូវបានចាត់ទុកជាការធម្មតានិងត្រូវបានប្រព្រឹត្តល្មើសដោយមិនមានទោសពៃរ៍ ជាពិសេសការរំលោភក្នុងអាពាហ៍ពិពាហ៍និងរំលោភជាការដាក់ទណ្ឌកម្ម។ ប្រភេទនៃការរំលោភដែលត្រូវបានពណ៌នានេះរួមមាន ការរំលោភក្នុងអាពាហ៍ពិពាហ៍ ការរំលោភបូក ទាសភាពផ្លូវភេទ និងការរំលោភដែលមានការជ្រោមជ្រែងឬល្មើសដោយស្ថាប័នរដ្ឋ។ ការរៀបការដោយបង្ខំក្នុងរបបខ្មែរក្រហមអាចជាករណីពិសេសផ្សេងពីគេ តាមរយៈការបង្ខំ

ឲ្យប្ដីរំលោភប្រពន្ធរបស់ខ្លួន ជាមធ្យោបាយធានាជីវិតរបស់ខ្លួន។ ករណីសិក្សាមួយពណ៌នាអំពីកម្មាភិបាលខ្មែរក្រហមដែលបានជួយនិងជំរុញ ប្ដីដែលគេបានរៀបចំឡើងនោះឲ្យរំលោភប្រពន្ធ។

- ប្រហែលមួយភាគបួន (២៤,៥%) នៃការរៀបការដោយបង្ខំទាំងអស់ត្រូវគេរៀបរាប់ថាមានការពាក់ព័ន្ធនឹងការបំពានពីសហព័ន្ធ។ ការរៀបការទាំងនេះកើតមានក្នុងអំឡុងពេលដែលមានការលំបាកជាទីបំផុតនៃវិនាសកម្មក្នុងរបបនោះ ដែលមានរយៈពេលក្រោយរបបនោះ ហើយខ្លះទៀតនៅបន្តកើតមានដល់សព្វថ្ងៃ។

- ការរៀបការដោយបង្ខំភាគច្រើន (៧៦,២%) ត្រូវបានគេរាយការណ៍ថា បានផ្ដល់កំណើតកូនទៀតផង ដោយក្នុងនោះ អ្នកឆ្លើយតបជិតពាក់កណ្ដាល (៤៤,៩%) មានកូនបួននាក់ឬច្រើនជាងបួននាក់។ ប្ដីគឺជាអ្នកផ្ដល់ការគាំទ្រជីវិតយ៉ាងសំខាន់ក្នុងអំឡុងពេលប្រពន្ធមានគភ៌។

- ករណីសិក្សាបានលើកឡើងនូវការកើនឡើងខ្លាំងនៃការរៀបការដោយបង្ខំនេះក្នុងរយៈពេលប្រាំមួយខែចុងក្រោយ ក្នុងឆ្នាំ១៩៧៨។

- ករណីសិក្សាលើកឡើងថា ការបង្កើតមនុស្ស គឺជាកត្តាជំរុញឲ្យមានការរៀបការដោយបង្ខំនេះ។ ប្រការគួរឲ្យកត់សម្គាល់នោះ គឺ អ្នកឆ្លើយតបក្នុងករណីសិក្សាមួយបានលើកឡើងអំពីមហិច្ឆតានយោបាយរបស់មេដឹកនាំខ្មែរតាមមូលដ្ឋាន ជាកត្តាជំរុញឲ្យមានការរៀបការដោយបង្ខំនិងការរួមភេទដោយបង្ខំ ដោយបានលើកឡើងថាមេដឹកនាំថ្នាក់លើបានដឹងអំពីការអនុវត្តគោលនយោបាយនេះ និងបានផ្ដល់ការលើកទឹកចិត្តសម្រាប់ការអនុវត្តគោលនយោបាយនេះទៀតផង។

*ការរៀបការក្រោយការដួលរលំនៃរបបខ្មែរក្រហម*

- បន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហម មិនមានគោលនយោបាយជាតិទូទៅណាមួយសម្រាប់ដោះស្រាយស្ថានភាពនិងផលវិបាកដោយសារការរៀបការដោយបង្ខំនេះទេ។ ក៏ប៉ុន្តែ ការរៀបការដែលខ្មែរក្រហមបានបង្ខំ មានផលប៉ះពាល់យ៉ាងខ្លាំងទៅលើការអនុវត្តផ្នែកអាពាហ៍ពិពាហ៍ ភ្លាមបន្ទាប់ពីការដួលរលំនៃរបបនេះ និងច្រើនទសវត្សក្រោយមកទៀត។

- ការស្រាវជ្រាវនេះបង្ហាញថា ការរៀបការដោយបង្ខំគឺជាកត្តាមួយក្នុងចំណោមកត្តារួមចំណែកជាច្រើនទៅដល់ការបំពានក្នុងគ្រួសារដែលមានកើតឡើងច្រើន (នៅក្នុងបរិបទនៃការបន្តកើតឡើងនៃសង្គ្រាមស៊ីវិល និងការកែនប្តី) និងទៅដល់អាត្រាខ្ពស់នៃការរត់ចោលគ្នា ពហុព័ន្ធភាព ការរៀបការឡើងវិញ និងមេគ្រួសារជាស្ត្រីក្រោយការដួលរលំរបបនេះ។

- អ្នកឆ្លើយតបច្រើនជាងពាក់កណ្តាល (៥៣,១%) បន្តរស់នៅជាមួយគ្នាបន្ទាប់ពីការដួលរលំនៃរបបនេះ ភាគច្រើនគឺដោយសារតែមានកូនកើតក្នុងអាពាហ៍ពិពាហ៍នោះ។ កត្តាជំរុញផ្សេងទៀតក្នុងការរស់នៅជាមួយគ្នានេះ គឺដោយសារការអាណិតអាសូរ ផលកម្មពីជាតិមុន ភាពសំខាន់នៃបទពិសោធន៍ប៉ះទង្គិចផ្លូវចិត្តរួមគ្នាក្នុងរបបនោះ និងសំខាន់បំផុតនោះគឺការស្រលាញ់។ ការរៀបការដោយបង្ខំដែលមិនអាចបំបែកបានមួយចំនួនដែលបន្តរស់នៅជាមួយគ្នា គឺដោយសារតែការបំពាន ដោយសហព័ន្ធម្ខាងមិនអាចគេចទៅណាបាន។

- ការរៀបការដោយបង្ខំជាច្រើនដែលនៅមិនអាចព្រាត់គ្នាបានគឺដោយសារតែការខូចខាតមុខងារ ដោយក្នុងនោះច្រើនជាងពាក់កណ្តាល (៥២,៩%) ក្នុងសំណាកស្ទង់មតិនេះលើកឡើងអំពីការបំពានរបស់សហព័ន្ធ ដូចមានពិភាក្សាក្នុងការវិភាគករណីសិក្សា មានម្នាក់ទទួលរងការរំលោភពីប្តីជាបន្តរហូតមកដល់សព្វថ្ងៃនេះ។

- ភាគច្រើន (៧០,០%) នៃអ្នកដែលបានរំលាយការរៀបការដោយបង្ខំបន្ទាប់ពីរបបនោះបានរៀបការឡើងវិញម្តងទៀត។ ក្នុងចំណោមអ្នកដែលមិនបានរៀបការឡើងវិញក្រោយរបបខ្មែរក្រហម មាន៧២,២% បានលើកឡើងថាពួកគេមិនចង់រៀបការម្តងទៀតទេដោយសារតែមានបទពិសោធន៍ក្នុងការរៀបការដោយបង្ខំនោះ។ ខណៈដែលអ្នកឆ្លើយតបមានទាំងបុរសនិងស្ត្រី លទ្ធផលនៃការស្រាវជ្រាវមានភាពគួរឲ្យចាប់អារម្មណ៍ខ្លាំង នៅពេលប្រៀបធៀបទៅនឹងការរៀបការរបស់ស្ត្រីស្ទើរតែទាំងអស់មុនរបបខ្មែរក្រហម ដូចមានរៀបរាប់ក្នុងការសិក្សាស្រាវជ្រាវមុនៗ

*ផលប៉ះពាល់នៃការរៀបការដោយបង្ខំក្នុងរបបខ្មែរក្រហម*

- ប្រព័ន្ធរៀបការដោយបង្ខំក្នុងរបបខ្មែរក្រហម បង្កឲ្យមានការផ្តាច់ចេញពីសង្គម និងការរើសអើងក្នុងសង្គម ជាពិសេសសម្រាប់ស្ត្រីដែលត្រូវបានគេបោះបង់ចោល ត្រូវបានលែងលះ រស់នៅក្នុងអាពាហ៍ពិពាហ៍ពហុព័ន្ធភាព ឬជាស្ត្រីមេម៉ាយ។ ករណី

សិក្សាបង្ហាញថា ផលប៉ះពាល់ទាំងនេះ បន្តឲ្យមានផលប៉ះពាល់ធ្ងន់ធ្ងរ និងបង្កឲ្យមានភាពលំបាកផ្នែកសេដ្ឋកិច្ចនៅក្នុងករណីជាច្រើន។

- អ្នកឆ្លើយតបភាគច្រើន (៧០,២%) បានរៀបរាប់អំពីបញ្ហាសុខភាពផ្លូវចិត្តជាប់ជានិច្ចដោយសារតែការរៀបការដោយបង្ខំនោះ ដោយមានរៀបរាប់អំពីការតានតឹងចិត្ត និងកំហឹងដែលត្រូវគេបង្ខំឲ្យរៀបការ។ ជាងនេះទៀតច្រើនជាងមួយភាគបី(៣៥,៤%) បានរៀបរាប់អំពីផលវិបាកសេដ្ឋកិច្ចធ្ងន់ធ្ងរដោយសារតែការរៀបការដោយបង្ខំនេះ។

- ទោះបីជាអ្នកឆ្លើយតបភាគច្រើនលើកឡើងថាមិនបានលាក់រឿងរៀបការដោយបង្ខំនោះមិនឲ្យអ្នកដទៃដឹងក៏ដោយ ក៏ករណីសិក្សាបានរកឃើញថាជនរងគ្រោះជាច្រើនមានការខកចិត្តនិងភាពអាម៉ាស់ជាប់ខ្លួន ដោយសារតែការផ្គូផ្គងដែលគេបានចាត់តាំងឡើងនោះ។ ជាពិសេសឪពុកម្តាយ បានលើកឡើងក្នុងករណីសិក្សាជាច្រើនអំពីការលំបាកក្នុងការនិយាយប្រាប់ការពិតអំពីការរៀបការដោយបង្ខំនេះឲ្យកូនដែលបានកើតមកដោយសារចំណងនៃការរៀបការដោយបង្ខំនេះបានដឹងណាស់។ ក្នុងចំណោមអ្នកដែលមិនបាននិយាយអំពីបទពិសោធន៍នេះប្រាប់អ្នកដទៃ ច្រើនជាងពាក់កណ្តាល (៥២,៦%) លើកឡើងអំពីអារម្មណ៍អាម៉ាស់ ខណៈដែលមានច្រើនជាងមួយភាគបី (៣៦,៨%) លើកឡើងអំពីការភ័យខ្លាចស្លាកស្នាមទុរយស និងការរើសអើង។

- ការរៀបការដោយបង្ខំបន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហម បានរួមចំណែកបង្កឲ្យមានការផ្លាស់ប្តូរទាំងស្រុងចំពោះតួនាទីនិងការទទួលខុសត្រូវយេនឌ័រ។ ជាពិសេសស្ត្រីក្នុងគ្រួសារដែលមានមេគ្រួសារជាស្ត្រី ទទួលបន្ទុកបន្ថែម សូម្បីតែនៅពេលចរចារអំពីការលំបាកខាងផ្នែកសង្គមនិងសេដ្ឋកិច្ច ការចិញ្ចឹមកូន និងការថែទាំមនុស្សចាស់។

- លទ្ធផលនៃការស្រាវជ្រាវនេះ បង្ហាញថាជនរងគ្រោះនៅតែត្រូវការការគាំទ្រ និងសេវាសង្គមរយៈពេលវែង។ ការប្តេជ្ញាចិត្តរបស់ម្ចាស់ជំនួយ និងសហគមន៍អន្តរជាតិនៅតែជាសេចក្តីត្រូវការយ៉ាងសំខាន់សម្រាប់គម្រោងកម្មវិធីនិងគម្រោងផ្អែកលើការស្រាវជ្រាវ ដើម្បីគាំទ្រដល់អង្គការមិនមែនរដ្ឋាភិបាលនិងអ្នកផ្តល់សេវានានា។

## ១.២ អនុសាសន៍

ការរៀបការគឺជាស្ថាប័នបំពេញមុខងារមួយ គឺវាផ្លាស់ប្តូរឋានៈ តួនាទី សិទ្ធិ និងការ

ទទួលខុសត្រូវ តាមរយៈការកំណត់ដោយការអនុវត្តតាមប្រពៃណីនិងអត្តសញ្ញាណយេនឌ័រ។ ការរៀបការដោយបង្ខំដែលបង្កើតឡើងដោយរបបខ្មែរក្រហម តំណាងឲ្យអំពើហិង្សាយេនឌ័រផ្លូវភេទដែលបង្កផលប៉ះពាល់ធំទូលំទូលាយ។ គោលនយោបាយខ្មែរក្រហមគឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ សម្រាប់ អ.វ.ត.ក យកមកកាត់សេចក្ដី និងតាមរយៈការផ្ដល់សំណងប្រកបដោយប្រសិទ្ធភាព។ ជាងនេះទៀត ការរៀបការដោយបង្ខំគឺជាទ្វេគ្រោះខាងផ្នែកអភិវឌ្ឍន៍សម្រាប់រដ្ឋាភិបាលកម្ពុជា ដោយសារតែការរៀបការដោយបង្ខំទាំងបំពាននោះបន្តជាប់មកមិនដាច់ដូចដែលស្រីមេម៉ាយនិងគ្រួសារដែលមានមេគ្រួសារជាស្ត្រីបន្សល់ពីការរៀបការដោយបង្ខំនោះ កំពុងមានវ័យចំណាស់ដោយគ្មានបណ្ដាញសន្តិសុខគ្រប់គ្រាន់ឡើយ ហើយដូចដែលកូនដែលបានកើតមកពីការរៀបការដោយបង្ខំនោះ ទទួលរងការប៉ះទង្គិចផ្លូវចិត្តធ្ងន់ធ្ងរ និងផលវិបាកខាងផ្នែកសង្គមសេដ្ឋកិច្ចធ្ងន់ធ្ងរផ្សេងៗទៀត។

### ក. រាជរដ្ឋាភិបាលកម្ពុជា

- បង្កើតឲ្យមានសំណងសម្រាប់ជនរងគ្រោះដោយសារការរៀបការដោយបង្ខំ ដោយរាប់បញ្ចូលទាំងសំណងជាលុយ និងសេវាចិត្តសង្គមនិងសេវាគាំទ្រដទៃទៀតសម្រាប់ជននៅរស់ជីវិតពីការរៀបការដោយបង្ខំក្នុងរបបខ្មែរក្រហម ឲ្យស្របតាមគោលការណ៍មូលដ្ឋាននិងការណែនាំរបស់អង្គការសហប្រជាជាតិស្ដីពីសិទ្ធិក្នុងការទទួលបានដំណោះស្រាយនិងសំណងសម្រាប់ជនរងគ្រោះនៃការរំលោភបំពានធ្ងន់ធ្ងរទៅលើច្បាប់សិទ្ធិមនុស្សអន្តរជាតិនិងការរំលោភបំពានធ្ងន់ធ្ងរទៅលើច្បាប់មនុស្សធម៌អន្តរជាតិ ក៏ដូចជាសេចក្ដីប្រកាសក្រុងណៃរ៉ូប៊ីស្ដីពីសិទ្ធិស្ត្រី និងកុមារីក្នុងការទទួលបានដំណោះស្រាយនិងសំណង។

- ចងក្រងឯកសារអំពីការវិវត្តន៍ក្នុងការធ្វើរបាយការណ៍សម្រាប់អនុសញ្ញាស្ដីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងទៅលើស្ត្រី (ស៊ីដ) និងរបាយការណ៍សម្រាប់អនុសញ្ញាសិទ្ធិមនុស្សដទៃទៀត អំពីការរីកចម្រើនទាក់ទងនឹងឋានៈស្ត្រីកម្ពុជា និងសមភាពយេនឌ័រ ជាពិសេសពាក់ព័ន្ធនឹងការលុប បំបាត់ការវាយតម្លៃខុសឆ្គងលើយេនឌ័រតាមប្រពៃណីដែលមានការរឹតបន្តឹង ព្រមទាំងក្នុងការអនុវត្តសំណង ដូចមានអំពាវនាវក្នុងសេចក្ដីសង្កេតសន្និដ្ឋានរបស់គណៈកម្មការស៊ីដ ឆ្នាំ២០១៣។

- ប្ដេជ្ញាចិត្តកុំឲ្យមានការកើតឡើងវិញនូវឧក្រិដ្ឋកម្មយេនឌ័រក្នុងពេលមានជម្លោះ និងក្រោយពេលជម្លោះ តាមរយៈការបង្កើតឲ្យមានផែនការសកម្មភាពជាតិស្ដីពីស្ត្រី សន្តិភាព និងសុវត្ថិភាព ស្របតាមសេចក្ដីសម្រេចរបស់អង្គការសហប្រជាជាតិលេខ

១៣២៥ និងសេចក្តីសម្រេចស្រដៀងគ្នានោះ ព្រមទាំងប្តេជ្ញាចិត្ត ដូចដែលបានអំពាវនាវក្នុងសេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មការស៊ីដ ឆ្នាំ២០១៣។

- ធ្វើសមាហរណកម្មការរៀបការដោយបង្ខំនេះចូលទៅក្នុងវិស័យស្នូលក្នុងផែនការអភិវឌ្ឍន៍ ដោយរាប់បញ្ចូលទាំងផែនការសកម្មភាពជាតិស្តីពីការរីកចម្រើនរបស់ស្ត្រី និងផែនការសកម្មភាពជាតិស្តីពីអំពើហិង្សាទៅលើស្ត្រីដែរ។ ត្រូវសង្កត់ធ្ងន់ទៅលើការគាំទ្រចិត្តសង្គមនិងសេដ្ឋកិច្ចសម្រាប់ក្រុមជនរងគ្រោះវ័យចំណាស់និងកូនរបស់ពួកគេ។

*ទាំងក្នុងកម្មវិធីសំណង និងយុទ្ធសាស្ត្រអភិវឌ្ឍន៍បន្តបន្ទាប់៖*

- ត្រូវពង្រឹងសេវាចិត្តសង្គមនិងសេវាគាំទ្រសង្គមនានា និងកសាងសមត្ថភាពរបស់អ្នកផ្តល់សេវា ដោយធ្វើសមាហរណកម្មអំពើហិង្សាយេនឌ័រនិងការរៀបការដោយបង្ខំក្នុងរបបខ្មែរក្រហមចូលទៅក្នុងការអប់រំដល់វេជ្ជបណ្ឌិត ចិត្តវិទូ សង្គមវិទូ និងមេធាវី។

- ត្រូវសម្រួលឲ្យមានការជ្រើសរើសបុគ្គលិកក្នុងមន្ទីរពេទ្យនិងមណ្ឌលសុខភាពដែលជាអ្នកចិត្តសាស្ត្រ អ្នកប្រឹក្សាយោបល់ការប៉ះទង្គិចផ្លូវចិត្ត និងសង្គមវិទូ ក្នុងការផ្តល់ការព្យាបាលដល់បុគ្គល ក្រុម និងគ្រួសារ ដល់ជនរងគ្រោះដោយសារការរៀបការដោយបង្ខំក្នុងរបបខ្មែរក្រហមនិងដល់គ្រួសាររបស់ពួកគេ។

- ត្រូវផ្តល់សេវាផ្នែកច្បាប់និងសេវាគាំទ្រដទៃទៀត ដល់ជនរងគ្រោះឲ្យបានចំនួនច្រើនតាមដែលអាចធ្វើទៅបាន ជាពិសេសដល់ស្ត្រី ដែលមានសេចក្តីប្រាថ្នាចង់បញ្ចប់ការរៀបការដោយបង្ខំ ប៉ុន្តែជួបឧបសគ្គក្នុងការធ្វើបែបនេះ ដូចជាដោយសារតែការពឹងផ្អែកខាងផ្នែកសេដ្ឋកិច្ច ការគាបសង្កត់ពីគ្រួសារនិងបុព្វហេតុដទៃមួយចំនួនទៀត។

- ត្រូវប្រើប្រព័ន្ធផ្សព្វផ្សាយឲ្យមានប្រសិទ្ធភាពក្នុងការលើកកម្ពស់ការយល់ដឹងអំពីការរៀបការដោយបង្ខំក្នុងរបបខ្មែរក្រហម អំពីសិទ្ធិមនុស្សរបស់បុរសនិងស្ត្រីក្នុងការទទួលបានការរៀបការនិងការរួមភេទដោយមានការព្រមព្រៀង និងអំពីផលប្រយោជន៍នៃទំនាក់ទំនងដែលមានស្ថានភាពល្អនិងមានភាពស្មើគ្នា។

## ខ. អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

- សម្រាប់អង្គជំនុំជម្រះសាលាដំបូង ត្រូវធានាថាមានការពិភាក្សាពេញលេញអំពីលក្ខណៈ ការអនុវត្ត និងទំហំនៃការរៀបការដោយបង្ខំក្នុងរបបខ្មែរក្រហម ក្នុងសំណុំរឿង០០២/០២ របស់ អ.វ.ត.ក ដូចមានចែងក្នុងសាលក្រមនៃសំណុំរឿង០០២/០១។

- សម្រាប់ការិយាល័យសហចៅក្រមស៊ើប ត្រូវស៊ើបអង្កេតឧក្រិដ្ឋកម្មទាំងនេះ ឲ្យបានពេញលេញសម្រាប់យកមកកាត់សេចក្ដី ដូចមាននៅក្នុងដីកាសំណុំរឿង០០៣ និង០០៤។

- សម្រាប់សហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណីនិងផ្នែកគាំទ្រជនរងគ្រោះ ត្រូវរៀបចំក្នុងភាពជាដៃគូជាមួយអង្គការសង្គមស៊ីវិលនិងតំណាងជនរងគ្រោះ បង្កើតគម្រោងសំណងដ៏មានអត្ថន័យនិងទូលំទូលាយ ដើម្បីដោះស្រាយផលប៉ះពាល់ផ្នែកសម្ភារៈ ចិត្តសង្គម និងផលប៉ះពាល់ធ្ងន់ធ្ងរដទៃទៀតដោយសារការរៀបការដោយបង្ខំ និងការរួមភេទដោយបង្ខំនេះឲ្យបានគ្រប់វិសាលភាពពេញលេញ។ ត្រូវផ្ដល់អាទិភាពដល់កម្មវិធីនិងគំនិតផ្ដួចផ្ដើមទាំងឡាយដែលសំដៅលើកូនដែលកើតចេញមកពីការរៀបការដោយបង្ខំនេះ។

- សម្រាប់គ្រប់ផ្នែកទាំងអស់នៃតុលាការ ត្រូវធ្វើសមាហរណកម្មចូលទៅក្នុងផែនការកេរដំណែលរបស់ខ្លួន នូវស្នូលអាទិភាពទៅលើការផ្ទេរការអនុវត្តល្អបំផុតសម្រាប់ដោះស្រាយអំពើហិង្សាយេនឌ័រនិងអំពើហិង្សាផ្លូវភេទទៅក្នុងប្រព័ន្ធយុត្តិធម៌អន្តរកាលជាតិរបស់ប្រទេសកម្ពុជា ជាមធ្យោបាយមួយសម្រាប់ធ្វើឲ្យសម្រេចបាននូវការមិនកើតឡើងវិញតាមរយៈការផ្លាស់ប្ដូរការអនុវត្តលក្ខណៈប្រពៃណីដែលធ្វើឲ្យបន្តកើតឡើងនិងចាត់ទុកអំពើហិង្សាយេនឌ័រនិងសមភាពយេនឌ័រជាការធម្មតា។

- សម្រាប់អង្គភាពគាំទ្រជនរងគ្រោះ ត្រូវរៀបចំក្នុងភាពជាដៃគូជាមួយអង្គការសង្គមស៊ីវិលនិងតំណាងជនរងគ្រោះ បង្កើតវិធានការមិនពាក់ព័ន្ធបច្ចេកទេសតុលាការដែលស្វែងរកឲ្យមានការពង្រឹងសិទ្ធិអំណាចអ្នកនៅមានជីវិត និងទទួលស្គាល់បទពិសោធន៍នៃការរៀបការដោយបង្ខំនិងការរួមភេទដោយបង្ខំដែលកើតឡើងទៅលើពួកគេ។ គម្រោងគួរត្រូវរចនាបង្កើតឡើងដោយមានការពិគ្រោះយោបល់ជាមួយអ្នកនៅរស់រានមានជីវិតផ្ទាល់ និងគួរប្រើជាមធ្យោបាយសម្រាប់លើកកម្ពស់ការយល់ដឹងអំពីអំពើហិង្សាយេនឌ័រនៅថ្នាក់ជាតិនិងថ្នាក់មូលដ្ឋាន។

- សម្រាប់ផ្នែកកិច្ចការសាធារណៈរបស់តុលាការ ត្រូវផ្តល់ព័ត៌មានដល់សាធារណជនអំពីរបៀបដែលតុលាការឆ្លើយតបចំពោះឧក្រិដ្ឋកម្មយេនឌ័រក្នុងរបបខ្មែរក្រហមជាទូទៅ និងជាពិសេសចំពោះការរៀបការដោយបង្ខំនិងការរួមភេទដោយបង្ខំ។ ត្រូវបញ្ចូលការពន្យល់ច្បាស់លាស់និងត្រឹមត្រូវមួយអំពីឧក្រិដ្ឋកម្មយេនឌ័រ ដែលត្រូវកាត់កាត់សេចក្តីនៅតុលាការ ក៏ដូចជាព័ត៌មានលម្អិតអំពីឧក្រិដ្ឋកម្មទាំងនោះដែលកំពុងត្រូវបានកាត់សេចក្តី ព្រមជាមួយនឹងមូលហេតុ ទាំងផ្នែកច្បាប់និងមូលហេតុផ្សេងទៀត អំពីករណីនេះ។ ការចែករំលែកព័ត៌មានបែបនេះ នឹងឈានទៅដល់ការបង្កន់ការយល់ឃើញជាសាធារណៈអំពីនិទណ្ឌភាពសម្រាប់ឧក្រិដ្ឋកម្មទាំងនោះ ជាពិសេសក្នុងចំណោមជនរងគ្រោះនៃអំពើហិង្សាយេនឌ័រក្នុងរបបខ្មែរក្រហម ហើយវានឹងបង្កើតជាឧទាហរណ៍ដ៏សំខាន់មួយអំពីរបៀបដោះស្រាយ អំពើហិង្សាយេនឌ័រក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន ដោយតុលាការ រដ្ឋាភិបាល និងអ្នកធ្វើគោលនយោបាយ។

គ. អង្គការមិនមែនរដ្ឋាភិបាលនិងអ្នកអនុវត្ត

- ត្រូវលើកទឹកចិត្តឲ្យមានការអភិរក្សនិងផ្សព្វផ្សាយចំណេះដឹងអំពីការរៀបការដោយបង្ខំនិងផលប៉ះពាល់របស់វា តាមរយៈការធ្វើសមាហរណកម្មឲ្យបានពេញលេញទៅក្នុងការពិភាក្សាប្រវត្តិសាស្ត្រនៃវិនាសកម្មក្នុងរបបខ្មែរក្រហម នៅថ្នាក់ជាតិ។ ត្រូវបញ្ចូលយុវជនក្នុងកិច្ចខិតខំប្រឹងប្រែងបែបនេះ ជាពិសេសក្នុងការចងក្រងឯកសារសាច់រឿងពិតនិងក្នុងការដឹកនាំការពិភាក្សាក្នុងសហគមន៍អំពីសិទ្ធិមនុស្សជាសកល និងសមភាពយេនឌ័រក្នុងពេលមានសន្តិភាពនិងក្នុងពេលមានជម្លោះ។

- ទទួលស្គាល់និងដោះស្រាយបញ្ហាប្រឈមពិសេសរបស់ជនរងគ្រោះដោយសារការរៀបការដោយបង្ខំនិងការរួមភេទដោយបង្ខំ ដូចជា ការបំពានក្នុងគ្រួសារ ការដកហូតផ្នែកសេដ្ឋកិច្ច និងការផ្តាច់ចេញពីសង្គមជាដើមនោះ ក្នុងការផ្តល់សេវានិងការការពារជនរងគ្រោះនៃអំពើហិង្សាយេនឌ័រ។

- ពង្រឹងសិទ្ធិអំណាចជនរងគ្រោះ តាមរយៈការបង្កើតក្រុមជួយខ្លួនឯងនៅតាមសហគមន៍សម្រាប់អ្នករស់រានមានជីវិតពីការរៀបការដោយបង្ខំក្នុងរបបខ្មែរក្រហម ដើម្បីជួយឲ្យពួកគេដោះស្រាយជាមួយនឹងផលប៉ះពាល់ចិត្តសាស្ត្រនិងសង្គមដោយសារឧក្រិដ្ឋកម្មនេះ។ កសាងសមត្ថភាពរបស់អ្នករស់រានមានជីវិតពីការរៀបការដោយបង្ខំនិងការរួមភេទដោយបង្ខំ ដើម្បីឲ្យពួកគេអាចកំណត់រកឃើញនិងតស៊ូមតិសម្រាប់

ផលប្រយោជន៍របស់ខ្លួនក្នុងដំណើរការយុត្តិធម៌អន្តរកាលក្នុងប្រទេសកម្ពុជា។

- លើកកម្ពស់ការយល់ដឹងក្នុងសហគមន៍ដែលមានសេចក្តីត្រូវការក្នុងការបញ្ចប់ការបន្ទោសជនរងគ្រោះ សម្រាប់ការកើតឡើងនូវអំពើហិង្សាយេនឌ័រ ដោយរាប់បញ្ចូលទាំងការរៀបការដោយបង្ខំ ការកែទម្រង់ការអនុវត្តតាមបែបប្រពៃណីដែលរឹតបន្តឹងសេរីភាពក្នុងការធ្វើស្វ័យសម្រេចនិងសមភាពយេនឌ័រ និងដើម្បីពង្រឹងការទទួលស្គាល់ការចូលរួមចំណែករបស់ស្ត្រីក្នុងការធ្វើឲ្យមានគ្រួសារនិងសង្គមមានស្ថិរភាព។

- ស្រាវជ្រាវបន្ថែមអំពីផលប៉ះពាល់និងជាតុខុសគ្នាទាំងឡាយនៃការរៀបការដោយបង្ខំ ដោយរាប់បញ្ចូលទាំងតាមរយៈការផ្តល់ការយកចិត្តទុកដាក់ឲ្យកាន់តែច្រើនទៅលើបទពិសោធន៍របស់បុរសដែលទទួលរងឧក្រិដ្ឋកម្មទាំងនេះ និងការរំខានដែលកើតឡើងទៅលើតួនាទីនិងអត្តសញ្ញាណយេនឌ័រ ភាពជាបុរស និងការប៉ះទង្គិចផ្លូវចិត្តទៅលើមនុស្សប្រុស។

## ២

# សេចក្តីផ្តើម និងសារវ័តា

នៅចន្លោះថ្ងៃទី១៧មេសាឆ្នាំ១៩៧៥និងថ្ងៃទី៧មករាឆ្នាំ១៩៧៩ប្រទេសកម្ពុជាត្រូវបានគ្រប់គ្រងដោយរបបខ្មែរក្រហម[1] យ៉ាងព្រៃផ្សៃ ហើយជាលទ្ធផលបានបង្កើតឲ្យមានភាពដ៏សាហាវយង់ឃ្នងបំផុតមួយ នៅក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ។ រដ្ឋដែលមានទំនោរតាមលទ្ធិម៉ៅនិយមយ៉ាងស្លុងនោះ បានរៀបចំនូវគោលនយោបាយជាច្រើនដើម្បីសម្រេចបំណងនៃមនោគមវិជ្ជារបស់ខ្លួន ក្នុងការបង្កើតភាពស្រមើស្រម៉ៃដល់ផ្ទៃដីកសិកម្មមួយដែលល្អឥតខ្ចោះ។ ហើយវាបានបង្កឲ្យមានសោកនាដកម្មដល់ការស្លាប់បាត់បង់អាយុជីវិតមនុស្សប្រហែលជា ១ ភាគ ៤ នៃចំនួនប្រជាជនសរុបដោយសារតែភាពអត់ឃ្លាន ជម្ងឺ ការធ្វើការងារហួសកំលាំង ការជម្លៀសដោយបង្ខំ ការធ្វើទារុណកម្ម និងការសម្លាប់ជាដើម។ ទីក្រុងទាំងមូលត្រូវជម្លៀសដោយបង្ខំ ហើយប្រជាជនត្រូវបែងចែកជា ប្រជាជនចាស់ ឬប្រជាជនមូលដ្ឋាន(ប្រជាជននៅតាមទីជនបទដែលភាគច្រើនជាប្រជាកសិករ ពេលខ្លះត្រូវបានហៅថាជាប្រជាជនដែលមានសិទ្ធិសេរីភាពពេញលេញ) និងប្រជាជនថ្មី ឬប្រជាជន១៧មេសា (ប្រជាជននៅទីក្រុងដែលមានទំនាក់ទំនងជាមួយនឹងអំពើអសីលធម៌នៃទីក្រុងមូលធននិយម ដែលត្រូវមានកាតព្វកិច្ចផ្លាស់ប្តូរទីកន្លែងទៅកាន់ទីជនបទ)។ សាសនា និងការប្រតិបត្តិតាមវប្បធម៌ ប្រពៃណីត្រូវចាត់ទុកជាអំពើខុសច្បាប់។ ប្រាក់កាស និងទ្រព្យសម្បត្តិឯកជនត្រូវបានលុបបំបាត់ ហើយប្រជាជនស៊ីវិលទាំងអស់ ត្រូវបង្ខំទៅធ្វើជាកំលាំងទាសករទៅតាមកន្លែងការងារជាក្រុមដូចជាខាងវិស័យកសិកម្ម និងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធជាដើម[2]។

ប្រហែលការផ្លាស់ប្តូរដ៏ខ្លាំងក្លាមួយនៃរបបខ្មែរក្រហមនោះ គឺជាការលុបបំបាត់នូវសង្គមគ្រួសារដែលរំលាយទៅជាការរស់នៅរួមគ្នាជាក្រុមៗវិញ។ សមាជិកគ្រួសារត្រូវដាក់ឲ្យនៅដាច់ដោយឡែកពីគ្នាទៅតាម អាយុ និងភេទ នៅក្នុងការដ្ឋានការងារជាក្រុមការងារចល័ត។ រាល់ការចំអិនម្ហូប និងការបរិភោគអាហារត្រូវធ្វើឡើងរួមគ្នាជាលក្ខណៈសហករណ៍ រីឯអ្នកមើលថែកូនក្មេង មានភារៈជាអ្នកមើលថែក្មេងៗទាំងនោះ នៅពេលដែលឪពុកម្តាយទៅធ្វើការ។ ចំណែកក្មេងធំៗត្រូវរស់នៅឆ្ងាយពីឪពុកម្តាយ និងមានសិទ្ធិតិចតួចក្នុងការមកលេងជាមួយនឹងឪពុកម្តាយរបស់ខ្លួន។ អង្គការ (តាមន័យត្រង់ជា "ស្ថាប័ន" និងសំដៅដល់អង្គការក្នុងការសម្រេចចិត្តថ្នាក់ខ្ពស់បំផុតនៃរបបខ្មែរក្រហម) បានដើរតួនាទីជាឪពុកម្តាយសម្រាប់ប្រជាជនទាំងអស់ ដែលទាមទារឲ្យមាននូវភក្តីភាពយ៉ាងសំរិតសំរាំង ឥតប្រួលប្រែ ហើយថែមទាំងបានបង្ខំបុគ្គលឲ្យរៀបការ និងត្រូវមានទំនាក់ទំនងជាប្តីប្រពន្ធដោយមិនមានជម្រើស ឬការព្រម

[1] ឈ្មោះជាផ្លូវការនៃរបបនេះ គឺកម្ពុជាប្រជាធិបតេយ្យ ដឹកនាំដោយបក្សកុម្មុយនីស្តកម្ពុជា។ ខ្មែរក្រហមនិងរបបខ្មែរក្រហមជាពាក្យដែលប្រជាជនកម្ពុជាប្រើជាទូទៅ ហើយត្រូវបានប្រើពេញរបាយការណ៍នេះដើម្បីជួយដល់អ្នកអានទូទៅ។
[2] សម្រាប់ព័ត៌មានពេញលេញនៃរបបនេះ ជាទូទៅ សូមអាន David Chandler ប្រវត្តិសាស្ត្រកម្ពុជា បោះពុម្ពផ្សាយលើកទី៤ (Chiang Mai: Silkworm Books, 2008); Ben Kiernan, របបប៉ុលពត៖ ការប្រណាំងប្រជែង អំណាច និងប្រល័យពូជសាសន៍ក្នុងប្រទេសកម្ពុជាក្នុងរបបខ្មែរក្រហម ១៩៧៥-១៩៧៩ (New Haven: Yale University Press, 1996); និង Elizabeth Becker, ពេលសង្គ្រាមរលត់ទៅ៖ កម្ពុជានិងបដិវត្តខ្មែរក្រហម (New York: Public Affairs Press, 1998).

ព្រៀងគ្នាអ្វីឡើយ[3] ។

ការសិក្សាស្រាវជ្រាវទ្រង់ទ្រាយតូចនេះ ពិនិត្យមើលទៅលើផលវិបាកនៃប្រព័ន្ធរៀបអាពាហ៍ពិពាហ៍ដោយបង្ខំដែលធ្វើឡើងដោយរបបខ្មែរក្រហម។ នៅចន្លោះឆ្នាំ១៩៧៥ និងឆ្នាំ ១៩៧៩ បុរស និងស្ត្រីរាប់ពាន់នាក់ត្រូវតម្រូវឲ្យឆ្លងកាត់នូវពិធីសន្យាជាទ្រង់ទ្រាយធំជាមួយនឹងប្តី ឬប្រពន្ធដែលរៀបចំដោយភ្នាក់ងាររដ្ឋខ្មែរក្រហម។ ស្ថិតក្រោមការតាមដានពីពួកយកការណ៍ខ្មែរក្រហម គូស្រករដែលគេបានរៀបចំទុកដាក់ឲ្យ ត្រូវបានបង្ខំឲ្យរៀបអាពាហ៍ពិពាហ៍នេះសម្រេចតាមរយៈទំនាក់ទំនងផ្លូវភេទនៅថ្ងៃបន្ទាប់ពីពិធីនេះបានចប់សព្វគ្រប់។ បន្ទាប់មកប្តីនិងប្រពន្ធត្រូវបំបែកឲ្យទៅតាមការដ្ឋានការងាររៀងៗខ្លួនវិញ ដោយមិនបានមកលេងជាមួយនឹងគ្នាញឹកញាប់ឡើយ។ យោងទៅតាមសំណាកនៃការស្រាវជ្រាវនេះ មានករណីជាច្រើនដែលប្តី ឬប្រពន្ធដែលគេរៀបចំទុកដាក់ឲ្យនោះ ជាមនុស្សប្លែកមុខទាំងស្រុងចំពោះគ្នាទៅវិញទៅមក ហើយភាគច្រើនជាការរួមសម្ព័ន្ធមេត្រីដោយមិនមានជម្រើស និងការព្រមព្រៀងគ្នាជាមុននោះឡើយ។ លើគ្រប់ករណីទាំងអស់ប្រព័ន្ធនេះត្រូវអនុវត្តដោយបង្ខំ តាមរយៈការធ្វើទារុណកម្ម ឬការបំភ័យធ្វើទារុណកម្ម "អប់រំសារជាថ្មី ដាក់គុក អំពើហិង្សាលើផ្លូវភេទ និងទណ្ឌកម្ម ឬក៏សម្លាប់"។

ឧក្រិដ្ឋកម្មដែលពាក់ព័ន្ធនឹង អំពើដ៏ព្រៃផ្សៃរបស់ខ្មែរក្រហម ឥឡូវនេះកំពុងស្ថិតនៅក្រោមកិច្ចពិភាក្សាយ៉ាងល្អិតល្អន់ដោយសាលាក្តីឧក្រិដ្ឋកម្មសង្គ្រាមកូនកាត់ អ.វ.ត.ក ដោយមានការគាំទ្រពីអង្គការសហប្រជាជាតិ។ អ.វ.ត.ក ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ២០០៦ ដើម្បីនាំយកមេដឹកនាំកំពូលនៃរបបខ្មែរក្រហមមកកាត់ទោសទៅតាមផ្លូវច្បាប់។ ជាការពិតអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភបំពានក្នុងអាពាហ៍ពិពាហ៍ទាំងអស់នោះ នឹងត្រូវចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលមាននៅក្នុងផ្នែកបន្ទាប់នៃករណីថ្មីរបស់ អ.វ.ត.ក ដូចជាសំណុំរឿង០០២ ដែលនឹងចាប់ផ្តើមនាចុងឆ្នាំ២០១៤ខាងមុខនេះ។ អាពាហ៍ពិពាហ៍ដោយបង្ខំ ស្របជាមួយនឹងទម្រង់ផ្សេងៗនៃអំពើហិង្សាលើផ្លូវភេទក្រៅពីករណីរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ត្រូវបានបន្ថែមលើសំណើនាពេលថ្មីៗនេះ សម្រាប់ការស៊ើបអង្កេតលើសំណុំរឿង ០០៤ នៃ អ.វ.ត.ក។ ប្រសិនបើ និងនៅពេលលទ្ធផលនៃការកាត់ទោស អ.វ.ត.ក នឹងបញ្ជាឲ្យមានជាសំណងសមូហភាព និងជានិមិត្តរូបដែលពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មទាំងនោះ។ របាយការណ៍នេះសង្ឃឹមថានឹងបានរួមចំណែកអំពីជម្រៅ និងទំហំនៃការយល់ដឹងជាទូទៅចំពោះឧក្រិដ្ឋកម្មនៃអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលបង្កើតជាគោលនយោបាយមានលក្ខណៈ

[3] សម្រាប់ការពណ៌នាលម្អិតអំពីការបែកបាក់គ្រួសារ សូមអាន ម៉ម កល្យាណី "ភាពអត់ធ្មត់នៃគ្រួសារកម្ពុជាក្រោមរបបខ្មែរក្រហម៖ ប្រវត្តិសាស្តផ្ទាល់មាត់, "ប្រល័យពូជសាសន៍ក្នុងប្រទេសកម្ពុជានិងរ៉ាន់ដា៖ ទស្សនទានថ្មីៗ Susan E. Cook, ed. (New Brunswick: Transaction Publishers, 2006): ទំព័រ ១១៩-៦២។ ការពណ៌នាទូទៅបន្ថែមទៀត សូមអាន Elizabeth Becker, ពេលសង្គ្រាមរលត់ទៅ

ទូលំទូលាយ និងជាប្រព័ន្ធក្នុងរបបខ្មែរក្រហម។ អាពាហ៍ពិពាហ៍ដោយបង្ខំជាទម្រង់មួយនៃអំពើហិង្សាលើផ្លូវភេទ ដូចនេះហើយការវិភាគលើរបាយការណ៍នេះប្រើប្រាស់នូវទស្សនៈមានការឆ្លើយតបចំពោះចំពោះយេនឌ័រ និងជ្រួតជ្រាបអំពីការប៉ះទង្គិចផ្លូវចិត្ត[4]។ នៅពេលដែលអាពាហ៍ពិពាហ៍មានតួនាទីជាអ្នកបង្កើតយេនឌ័រ គឺវានាំមកនូវផលវិបាក និងអត្ថន័យផ្សេងៗគ្នាចំពោះ បុរសនិងស្ត្រី។ ការវិភាគលើយេនឌ័រនាំឲ្យយល់កាន់តែប្រសើរ ថាតើតួនាទី យេនឌ័រ និងអំណាចនៃការបែងចែក យេនឌ័រ បានរំលឹកពីបទពិសោធន៍នៃអាពាហ៍ពិពាហ៍ដោយបង្ខំចំពោះប្តី ឬប្រពន្ធនៅក្នុងវិធីសាស្ត្រផ្សេងគ្នា ក៏ដូចជាផលប៉ះពាល់ជាបន្តបន្ទាប់ដែលបណ្តាលពីសម្ព័ន្ធភាពទាំងនេះ។ ការសិក្សាស្រាវជ្រាវនេះ គឺជាការរំលឹកដល់ផលប៉ះពាល់ដែលវានឹងបង្ហាញពីការវិភាគបែបពន្យល់បកស្រាយអំពីការសម្រេចចិត្តនៅក្នុងបរិបទនៃការរំលោភបំពានដោយអយុត្តិធម៌ជារឿយៗលើបញ្ហាផ្លូវភេទតែម្តង។

សេចក្តីផ្តើមនឹងផ្តល់ការពិភាក្សាយ៉ាងលម្អិត អំពីការសិក្សាស្រាវជ្រាវ ដែលអាចអនុវត្តបានទៅលើការប្រតិបត្តិចំពោះការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីនៅកម្ពុជានាមុនសម័យកាលខ្មែរក្រហម ដែលជាចំណុចសម្រាប់ការសិក្សាប្រៀបធៀបជាមួយនឹងបទពិសោធន៍នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ បន្ទាប់មកវានឹងក្លាយជាឯកសារសារពើភ័ណ្ឌនៃអ្វីដែលត្រូវបានស្គាល់ ពីការសិក្សាស្រាវជ្រាវដែលបានបោះពុម្ពផ្សាយ អំពីអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងរបបនោះ ក៏ដូចជាផលវិបាកទាំងឡាយនៃអាពាហ៍ពិពាហ៍ដោយបង្ខំក្រោយពីការដួលរលំនៃរបបនោះ រហូតមកទល់នឹងពេលបច្ចុប្បន្ន និងដំណោះស្រាយរបស់ អ.វ.ត.ក និងស្ថាប័នដទៃទៀតទាំងជាតិ និងអន្តរជាតិដើម្បីកំណត់ពីផលវិបាកទាំងនេះ។ ការពិភាក្សាលម្អិតបានផ្តល់នូវបរិបទក្នុងការស្វែងរកអំពីការសិក្សាស្រាវជ្រាវដែលប្រើវិធីសាស្ត្ររួមគ្នានាពេលបច្ចុប្បន្ន ហើយលទ្ធផលរបស់វាត្រូវបង្ហាញនៅក្នុងតួនៃរបាយការណ៍ក្នុងផ្នែកទី៤។

## ២.១ បញ្ញត្តិនៃការរៀបអាពាហ៍ពិពាហ៍តាមបែបប្រពៃណីនៅក្នុងបរិបទនៃប្រទេសកម្ពុជា

ដើម្បីឲ្យយល់កាន់តែច្បាស់អំពីអាពាហ៍ពិពាហ៍ដោយបង្ខំ រៀបចំដោយរបបខ្មែរក្រហម ផ្នែកនេះនឹងផ្តល់នូវចំណុចប្រៀបធៀបជាមួយនឹង ទំនៀមទម្លាប់រៀបអាពាហ៍ពិពាហ៍តាមប្រពៃណីរបស់ប្រជាជនកម្ពុជា។ ការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី នាមុនឆ្នាំ១៩៧៥ ត្រូវធ្វើឡើងដោយការព្រមព្រៀងជាមុនតាមភាពចាំបាច់នៃសាសនា (សម្រាប់ប្រជាជនដែល

[4] សូមអានជាទូទៅ Bridgette A. Toy-Cronin, "អ្វីទៅជាការរៀបការដោយបង្ខំ?" ទស្សនាវដ្តីស្រាវជ្រាវ Columbia អំពីយេនឌ័រ និងច្បាប់ 19:2 (2010) និង Morten Bergsmo, Alf Butenschon Skre និង Elisabeth J. Wood, editors, ការយល់ដឹងនិងការបង្ហាញអំពីឧក្រិដ្ឋកម្មផ្លូវភេទអន្តរជាតិ (Beijing: Torkel Opsahl Academic EPublisher, 2012).

ភាគច្រើនជាពុទ្ធសាសនិកជន ជាពិសេសលើហេតុផលនៃកម្ម) និងមានផលវិបាកយេនឌ័រ ដោយឡែកទៅលើបុរសនិងស្ត្រី។ និក្ខេបបទឆ្នាំ១៩៦៨ ដែលមានពីរវគ្គរបស់អ្នកស្រី Ebihara ផ្តល់នូវការស្ទង់មតិនៃនរវិទ្យាយ៉ាងសំខាន់បំផុតមួយលើជីវិតរស់នៅក្នុងភូមិ នាមុនសម័យខ្មែរក្រហមរួមមានទាំងពិធី និងការរៀបអាពាហ៍ពិពាហ៍។ អ្នកស្រីថែមទាំងពន្យល់អំពី ពិធីរៀបអាពាហ៍ពិពាហ៍ថាជាពិធីរៀបចំយ៉ាងលម្អិត និងយកចិត្តទុកដាក់សម្រាប់រយៈពេលជាច្រើនថ្ងៃ ដែលមានអត្ថន័យដ៏ជ្រៅទៅតាមបែបវប្បធម៌។ ពិធីរៀបអាពាហ៍ពិពាហ៍តាមបែបប្រពៃណី "រៀបការ" គឺជាពេលវេលាដែលមានសុភមង្គល និងរីករាយបំផុត (អាស្រ័យលើកម្មផល) និងជាការចំណាយធនធានដ៏ច្រើនលើសលុប...ក្នុងចំណោមពិធីទាំងឡាយនៅក្នុងឆាកជីវិតមនុស្ស ដោយរួមទាំងពិធីអធឹកអធមដែលបានរៀបចំយ៉ាងយកចិត្តទុកដាក់ និងសម្លៀកបំពាក់បែបប្រពៃណីយ៉ាងប្រណិត សម្រាប់កូនក្រមុំ និងកូនកម្លោះ។ ហើយពិធីនេះបានចំណាយពេលជាច្រើនថ្ងៃផងដែរ។ តួអង្គនៃការរៀបចំក្នុងពិធីអាពាហ៍ពិពាហ៍នេះមានដូចជា ឪពុកម្តាយ សាច់ញាតិ មិត្តភ័ក្រ ចាស់ទុំ ព្រះសង្ឃ គ្រូទាយ តន្ត្រីករ និងអ្នកភូមិដែលអាចមាននៅក្នុងផ្នែកខ្លះ ឬគ្រប់ផ្នែកទាំងអស់នៃទំនៀមទម្លាប់វប្បធម៌ និងការប្រារព្ធពិធី។ ការរៀបការត្រូវបានរៀបចំយ៉ាងអឹកធឹកដោយឪពុកម្តាយ ជាពិសេសអ្នកម្តាយ ហើយភាគច្រើនកើតចេញពីទំនោរចិត្ត និងបំណងប្រាថ្នារបស់កូនផ្ទាល់ដែលត្រូវយកមកធ្វើការពិចារណា និងពួកគេមិនត្រូវបានបង្ខំឲ្យធ្វើនូវអ្វីដែលមិនពេញចិត្តឡើយ។ តែផ្ទុយទៅវិញ ជាទូទៅឪពុកម្តាយបានទទួលនូវការគោរព ការឱនលំទោន និងការលះបង់ដើម្បីកូនរបស់ពួកគេ។ ទំនាក់ទំនងអាពាហ៍ពិពាហ៍កើតចេញពីភាពចាំបាច់ ឬពេលវេលាដ៏សមស្របចំពោះ "សេចក្តីគោរព និងមនោសញ្ចេតនា" ដ៏ជ្រាលជ្រៅទាំងសងខាង និងត្រូវបានពិពណ៌នាយ៉ាងត្រឹមត្រូវបំផុតថាជាសម្ព័ន្ធមេត្រីភាពរវាងគ្រួសារទាំងមូល ជាជាងការព្រមព្រៀងរវាងតែបុគ្គលនិងបុគ្គល។ ការរួបរួមគ្នានៅក្នុងសង្គមគ្រួសារត្រូវចាត់ទុកជាមូលដ្ឋានគ្រឹះនៃសង្គមដែលមានភាពសុខដុមរមនាមួយ[5] ។

ដោយយោងទៅតាមហេតុផលនៃកម្ម ការចរចារអំពីអាពាហ៍ពិពាហ៍ និងការរៀបចំពិធីឡើង គឺមិនត្រឹមតែជាប់ពាក់ព័ន្ធជាមួយនឹងសមាជិកគ្រួសារនៅរស់ប៉ុននោះទេ ប៉ុន្តែវាជាប់ពាក់ព័ន្ធនឹងបុព្វការីជនផងដែរ។ អ្នកស្រី Ebihara បានចង្អុលបង្ហាញពី "ភាពចាំបាច់បំផុត" នៃការទស្សន៍ទាយរបស់គូស្រករត្រូវបានពិនិត្យដោយលោកអាចារ្យ (អ្នកតំណាងសាសនា) ដើម្បីប្រមើលមើលលើភាពត្រូវគ្នាតាមបែបតារាសាស្ត្រ និងដើម្បីកំណត់នូវថ្ងៃអាពាហ៍ពិពាហ៍ដ៏មហានក្ខត្តឫក្ស[6] ។ លោក LeVine បានពិភាក្សាពីសារៈសំខាន់នៃកាតព្វកិច្ចសាសនាក្នុងអំឡុង

---

[5] និក្ខេបបទរបស់ Ebihara បង្ហាញអំពីពិធីរៀបការនិងប្រពៃណីរៀបការពីឆ្នាំ១៩៥៩ ដល់១៩៦០ ក្នុងភូមិស្វាយ ខេត្តកណ្តាល។ ក្រោយមក អ្នកស្រាវជ្រាវរូបនេះ បានត្រឡប់មកភូមិដដែលនេះក្នុងឆ្នាំ១៩៩០-១៩៩១ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ។ May Ebihara, ស្វាយ, ភូមិខ្មែរមួយក្នុងប្រទេសកម្ពុជា (និក្ខេបបទ សាកលវិទ្យាល័យកូឡុំប៊ី, ១៩៦៨) 112-117; 474-475។ សូមអាន Henri Locard កូនសៀវភៅក្រហមរបស់ប៉ុលពត៖ សម្តីរបស់អង្គការ (Chiang Mai: Silkworm Books, 2005): 379-385.

[6] May Ebihara, ស្វាយ, ភូមិខ្មែរមួយក្នុងប្រទេសកម្ពុជា ទំ. ៤៧៣

ពេលពិធីរៀបអាពាហ៍ពិពាហ៍ដោយការសែនព្រេនចំពោះបុព្វការីជន ក្នុងអត្ថន័យប្រសិទ្ធិពរជ័យមង្គលដល់ការរៀបអាពាហ៍ពិពាហ៍[7]។ អ្នកស្រាវជ្រាវថែមទាំងចង្អុលបង្ហាញពីសារៈសំខាន់នៃកម្មចំពោះពិធីរៀបអាពាហ៍ពិពាហ៍ និងការរៀបអាពាហ៍ពិពាហ៍ ជាមួយសម្ព័ន្ធភាពដែលជោគជ័យថាជាសញ្ញានៃភាពល្អប្រពៃក្នុងជីវិតអតីតកាល និងជាវិធីសម្រាប់ភាពល្អប្រពៃសម្រាប់ជីវិតនាអនាគតកាល[8]។ ដោយប្រទេសកម្ពុជាជាប្រទេសគោរពពុទ្ធសាសនាហេតុនេះហើយទិដ្ឋភាពនៃសាសនាបានដើរតួនាទី និងមានឥទ្ធិពលយ៉ាងខ្លាំងក្នុងសង្គម។ ការស្រាវជ្រាវមួយចំនួនតូច គឺមានភាពមិនស្របគ្នាដោយសារតែកត្តាក្រុមជនជាតិភាគតិច សាសនា និងតាមតំបន់ (ឧទាហរណ៍ ក្នុងចំណោមជនជាតិចាម ក្រុមជនជាតិដើម និងជនជាតិវៀតណាម និងក្រុមជនជាតិភាគតិចដទៃទៀត) សម្រាប់ពិធីរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី។ ប៉ុន្តែទោះបីមានភាពខុសគ្នាខ្លះក្តី ការសិក្សាស្រាវជ្រាវនេះ បានបង្ហាញថាអាពាហ៍ពិពាហ៍ដែលរៀបចំឡើងគឺមានលក្ខណៈទូទៅ និងទូលំទូលាយណាស់។ Heuveline និង Poch ពិពណ៌នាអាពាហ៍ពិពាហ៍បែបនេះថាជា "អាពាហ៍ពិពាហ៍ដែលរៀបចំឡើងដោយមានការចូលរួមពីសំណាក់ប្រជាជនទាំងឡាយ" តាមរយៈនេះអាផ្វាធរត្រូវ អ្នកដែលមានបំណងចង់រៀបការ ចាត់ទុកថាជាមេអណ្តើក ហើយការផ្គូផ្គងត្រូវធ្វើឡើងដោយយោងទៅលើកត្តាមួយចំនួនដើម្បីវាយតម្លៃទៅលើភាពសក្តិសម និងភាពចុះសម្រុងជាមួយគ្នា[9]។ ដើម្បីឲ្យអាពាហ៍ពិពាហ៍អាចកើតឡើងបាន ដរាបណាការព្រមព្រៀងពីភាគីដែលមានបំណងចង់រៀបការ ជាពិសេសកូនស្រីនឹងត្រូវបានបញ្ជាក់នៅក្នុងកិច្ចការស្រាវជ្រាវនេះ[10]។ អាពាហ៍ពិពាហ៍នៅវ័យក្មេងត្រូវបានអនុវត្ត ហើយសម្ព័ន្ធភាពបែបហ្នឹងត្រូវបានហាមប្រាមនៅពេលដែលអនីតិជនមិនត្រូវបានចាត់ទុកថាអាចមានសមត្ថភាពគ្រប់គ្រាន់ក្នុងការសម្រេចចិត្តត្រឹមត្រូវ។ ប៉ុន្តែជាទូទៅ អាពាហ៍ពិពាហ៍ដែលឪពុកម្តាយរៀបចំទុកដាក់ឲ្យ តាមលក្ខណៈប្រពៃណីនៅក្នុងប្រទេសកម្ពុជា មុនសម័យខ្មែរក្រហមត្រូវបានពិពណ៌នាយ៉ាងទូលំទូលាយនៅក្នុងឯកសារថា ជាការនៅចន្លោះរវាងការយល់ព្រមរបស់យុជន។ការយល់ព្រមនិងសិទ្ធិក្នុងការជ្រើសរើសគូស្រករគឺត្រូវបានបញ្ជាក់ស្រដៀង

---

[7] Peg LeVine, ស្នេហានិងការភ័យខ្លាចក្នុងប្រទេសកម្ពុជា៖ អាពាហ៍ពិពាហ៍ កំណើត និងការខូចខាតពិធីក្រោមរបបខ្មែរក្រហម (Singapore: National University of Singapore Press, 2010): 25។ Peg LeVine អះអាងថា ប្រជាជនកម្ពុជាបានជួបប្រទះនូវ "អំពើប្រល័យពូជសាសន៍វប្បធម៌" ក្នុងរបបខ្មែរក្រហម ដោយសារតែមិនមានសិទ្ធិវប្បធម៌ក្នុងការបន់ស្រន់ដល់បុព្វបុរសក្នុងអំឡុងពេលរៀបការដោយបង្ខំនោះ។

[8] សូមមើល May Ebihara, ស្វាយ, ភូមិខ្មែរមួយក្នុងប្រទេសកម្ពុជា; Peg LeVine, ស្នេហានិងការភ័យខ្លាចក្នុងប្រទេសកម្ពុជា; និង Katherine Bricknell, "'ចានក្នុងរាវតែងរណ្តំ': ការរំលាយអាពាហ៍ពិពាហ៍និងការមិនបង្កើតគ្រួសារក្នុងប្រទេសកម្ពុជាទំនើប" Geoforum 51 (2014): 262-272.

[9] Patrick Heuveline និង ប៉ុច ប៊ុនណាក់, តើអាពាហ៍ពិពាហ៍បំភ្លេចអតីតកាលបានទេ? ទំ. ១០១។ សូមមើលការវិភាគបែបរិះគន់មួយអំពីការរៀបការដែលរៀបចំតាមប្រពៃណីនិងការរៀបការដោយបង្ខំ រួមជាមួយនិងការអនុវត្តការរៀបការដោយបង្ខំជាមួយអ្នកចាប់រំលោភ, Rebecca Surtees, "ការរំលោភនិងការបំពានផ្លូវភេទក្នុងសង្គមកម្ពុជា" អំពើហិង្សាលើស្ត្រីក្នុងសង្គម អាស៊ី, Lenore Manderson and Linda Rae Bennett, editors (London: Routledge Curzon, 2003): 93-113.

[10] Ebihara, ស្វាយ, ភូមិខ្មែរមួយក្នុងប្រទេសកម្ពុជា ទំ. ៣១៥-៣១៦; Judith Ledgerwood, ការផ្លាស់ប្តូរការយល់ឃើញរបស់ខ្មែរទៅលើយេនឌ័រ៖ ស្ត្រី សាច់រឿង និងសណ្តាប់ធ្នាប់សង្គម (និក្ខេបបទ Cornell University, 1990): 177; Patrick Heuveline និង ប៉ុច ប៊ុនណាក់, "តើអាពាហ៍ពិពាហ៍បំភ្លេចអតីតកាលបានទេ? ស្ថិរភាពអាពាហ៍ពិពាហ៍ក្នុងប្រទេសកម្ពុជាក្រោយរបបខ្មែរក្រហម" ប្រជាសាស្ត្រ 43:1 (2006): 101; និង Toy-Cronin, "អ្វីទៅជាការរៀបការដោយបង្ខំ?" ទំ.៥៤៧

គ្នា នៅក្នុងការរៀបចំអាពាហ៍ពិពាហ៍ ខ្មែរ ចាម (ជនជាតិមូស្លីម)[11]។ ដូចគ្នាដែរ Toy-Cronin ចង្អុលបង្ហាញថាក្រមរដ្ឋប្បវេណីដែលបានអនុវត្តពីមុនរហូតដល់ឆ្នាំ១៩៧៥ បានសន្មត់ការបង្កើតអាពាហ៍ពិពាហ៍ជាមូលដ្ឋាន ដោយយោងទៅតាមការឯកភាពពីភាគីទាំងសងខាងទោះបីជាវាបានផ្តល់តួនាទីទៅឲ្យឪពុកម្តាយក៏ដោយ[12]។

អ្នកស្រី Ebihara ពិពណ៌នាពីសំណើអាពិពាហ៍ពិពាហ៍តាមគំរូប្រពៃណី៖

> យោងតាមទំនៀមទម្លាប់ដ៏ល្អវិសេស កូនកម្លោះត្រូវជ្រើសរើសដោយខ្លួនឯងថាអ្នកណាដែលគេនឹងត្រូវរៀបការជាមួយ ហើយនៅពេលធ្វើការសម្រេចចិត្តរួចរាល់ កូនកម្លោះត្រូវសុំឲ្យឪពុកម្តាយចាប់ផ្តើមធ្វើការចចារជាមួយនឹងគ្រួសារខាងកូនស្រី។ បន្ទាប់ពីទទួលបានសំណើរអាពាហ៍ពិពាហ៍រួច កូនក្រមុំផ្ទាល់ត្រូវបានពិគ្រោះយោបល់ជាមុនសិន។ ជាថ្មីម្តងទៀតដោយយោងតាមទំនៀមទម្លាប់ កូនក្រមុំមានសិទ្ធិក្នុងការយល់ព្រម ឬក៏បដិសេធនូវសំណើនោះ[13]។

អាពាហ៍ពិពាហ៍ជាការចាប់ផ្តើមប្រគល់ឲ្យនូវសិទ្ធិ និងទំនួលខុសត្រូវ និងឋានៈតួនាទីនៃភាគីដែលពាក់ព័ន្ធ។ អាពាហ៍ពិពាហ៍ថែមទាំងជាការបង្កើតនូវយេនឌ័រដែលនាំមកនូវសារៈសំខាន់ផ្សេងៗ និងផលវិបាកចំពោះមនុស្សបុរស និងស្ត្រី ជាពិសេសអាពាហ៍ពិពាហ៍ត្រូវបង្កើតជាតួនាទីយេនឌ័រដែលបានកំណត់ដោយសង្គម។ Ledgerwood និងអ្នកផ្សេងទៀតបានបង្ហាញពីរបៀប ថាតើអាពាហ៍ពិពាហ៍ជាប្រភពដែលមានសារៈសំខាន់បំផុតតែមួយគត់នៃអំណាច និងតម្លៃសម្រាប់វប្បធម៌នៅក្នុងប្រទេសកម្ពុជាយ៉ាងណាខ្លះជាពិសេសចំពោះស្ត្រី[14]។ ការសិក្សាស្រាវជ្រាវភាគច្រើនបង្ហាញថាស្ត្រីមិនទាន់រៀបការរួមបញ្ចូលទាំងស្ត្រីដែលមិនធ្លាប់រៀបការសោះ លែងលះ ឬស្ត្រីមេម៉ាយបានធ្វើឲ្យមានការយល់ក័ន្តច្រឡំទៅលើតួនាទីនៃយេនឌ័រយ៉ាងខ្លាំង។ លើសពីនេះខណៈពេលពិចារណា ស្ត្រីមិនទាន់រៀបការត្រូវទទួលនូវគំនាបសង្កត់យ៉ាងខ្លាំងដើម្បីឲ្យរៀបការដែលជាលទ្ធផលស្ទើរតែ ដូចអាពាហ៍ពិពាហ៍របស់ស្ត្រីជាសកលនៅសម័យមុនរបបខ្មែរក្រហម[15]។

---

11 សូមមើលជាទូទៅ Ysa Osman, Navigating the Rift: Muslim-Buddhist Intermarriage in Cambodia (Phnom Penh, np, 2010).

12 Toy-Cronin, "អ្វីទៅជាការរៀបការដោយបង្ខំ?" ទំ.៥៤៧

13 Ebihara, ស្វាយ, ភូមិខ្មែរមួយក្នុងប្រទេសកម្ពុជា ទំ. ៤៦៧

14 សូមមើល Henri Locard កូនសៀវភៅក្រហមរបស់ប៉ុលពត ទំ.៤៨៩៖ "ការរៀបការបង្ហាញអំពិការផ្លាស់ប្តូរឋានៈដ៏ធំមួយជាពិសេសសម្រាប់កូនក្រមុំ"។ សូមមើល Trudy Jacobsen, Lost Goddesses: ការបដិសេធអំណាចស្ត្រីក្នុងប្រវត្តិសាស្ត្រកម្ពុជា (Copenhagen: Nordic Institute of Asian Studies, 2008): 97, "ការរៀបការផ្តល់ឲ្យស្ត្រីនូវឋានៈនិងការការពារផ្លូវច្បាប់"

15 សូមមើលជាទូទៅ Bricknell, "ចានក្នុងរតែងរណ្តំ'; Ebihara, ស្វាយ, ភូមិខ្មែរមួយក្នុងប្រទេសកម្ពុជាLedgerwood, ការផ្លាស់ ប្តូរការយល់ឃើញរបស់ខ្មែរទៅលើយេនឌ័រ; និង Judy Ledgerwood, "ការវិភាគស្ថានភាពស្ត្រីក្នុងប្រទេសកម្ពុជា៖ កាស្រាវជ្រាវអំពីស្ត្រីក្នុងសង្គមខ្មែរ" (ភ្នំពេញ: UNICEF, 1992).

អាពាហ៍ពិពាហ៍ដែលឲ្យនិយមន័យតាមបែបប្រពៃណី ត្រូវបានកំណត់ដោយវិសមភាពនៃអំណាចយេនឌ័ររវាងប្តីនិងប្រពន្ធ។ ទោះបីជាអំណាចសំខាន់ស្ថិតនៅក្នុងកណ្តាប់ដៃរបស់ភរិយាក៏ពិតមែន ឧទាហរណ៍ដូចជាការគ្រប់គ្រងសេដ្ឋកិច្ចក្នុងគ្រួសារក៏ដោយ ក៏សង្គមដែលមានឋានានុក្រមខ្ពស់នៃប្រទេសកម្ពុជាបានចាត់ទុកស្ត្រីមានឋានៈទាបជាងបុរស[16]។ ជាឧទាហរណ៍ភរិយាបានហៅស្វាមីរបស់គាត់ថាបង បើទោះបីជាស្វាមីរបស់គាត់ក្មេងជាងគាត់ក៏ដោយ ហើយគាត់ត្រូវតែគោរពតាមសំណើក្នុងទំនាក់ទំនងផ្លូវភេទ ដែលជាទំនួលខុសត្រូវយ៉ាងសំខាន់របស់ភរិយា[17]។

ទំនួលខុសត្រូវដ៏ល្អវិសេសរបស់ភរិយាត្រូវបានចងក្រងនៅក្នុងច្បាប់ស្រី ឬក្រមសីលធម៌របស់ស្ត្រីដែលជាកំណាព្យប្រពៃណីខ្មែរនៅក្នុងទំនៀមទម្លាប់ព្រះពុទ្ធសាសនា[18]។ ស្ត្រីដែលល្អឥតខ្ចោះត្រូវពិពណ៌នាថាជាភរិយា ឬកូនស្រីដែលប្រកបដោយគន្លងធម៌។ នាងមានទំនួលខុសត្រូវលើភាពសុខដុមរមនា និងកិត្តិយសរបស់គួស្រារជាមួយនឹងការប្រើពាក្យពេចន៍សមរម្យនិងភាពបរិសុទ្ធរបស់ស្ត្រីនៅក្នុងគ្រួសារ[19]។ Ledgerwood បង្ហាញថាវាស្ទើរតែមិនអាចទៅរួចក្នុងការសង្កត់ធ្ងន់ទៅលើ "សារៈសំខាន់ក្រៃលែង" ដែលខ្មែរឲ្យតម្លៃទៅលើ " ភាពបរិសុទ្ធរបស់ស្ត្រីនៅពេលរៀបអាពាហ៍ពិពាហ៍" ហើយការរៀបចំពិធីអាពាហ៍ពិពាហ៍ដែលត្រឹមត្រូវនោះ គឺត្រូវធ្វើឡើងដោយឪពុកម្តាយ" ដើម្បីបញ្ជាក់អំពីកិត្តិយស និងកេរ្តិ៍ឈ្មោះនៅក្នុងគ្រួសារ[20]។ Natale សរសេរពីច្បាប់ស្រីថា "ទំនាក់ទំនងផ្លូវភេទក្រៅចំណងអាពាហ៍ពិពាហ៍ អាចនឹងធ្វើឲ្យមានការភ័យព្រួយលើការផ្លាស់ប្តូរចិត្តរបស់កូនកម្លោះចំពោះអាពាហ៍ពិពាហ៍និងជីវិតគ្រួសារ"[21]។ ផ្ទុយទៅវិញអាពាហ៍ពិពាហ៍ដ៏យូរអង្វែង គឺជាសញ្ញាវិជ្ជមាននៃផលកម្មរបស់សង្គមគ្រួសារទាំងមូល[22]។

---

16 Edward B. Fiske, "ការប្រើដៃទាំងពីរ៖ ស្ត្រីនិងការអប់រំក្នុងប្រទេសកម្ពុជា" (Manila: Asia Development Bank, 1995): 21, ដោយដកស្រង់ Ebihara: "ទោះបីជាកម្ពុជាមិនមានប្រពៃណីជារបបបិតាធិតេយ្យក៏ដោយ ក៏វាមានឋានានុក្រមខ្ពស់ណាស់ ហើយស្ត្រីត្រូវទាបជាងបុរស"

17 Jan Ayako, "ឆ្ពោះទៅកាន់យុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាពសម្រាប់ការពង្រឹងសិទ្ធិអំណាចស្ត្រី៖ បទពិសោធន៍ស្ត្រីក្នុងគម្រោងកែលម្អជីវភាពរស់នៅ, ខេត្តតាកែវ, កម្ពុជា" (សារណាថ្នាក់អនុបណ្ឌិត,Ritsumeikan Asia Pacific University, 2008): 41.

18 សម្រាប់ការពិភាក្សាបន្ថែមអំពីការត្រួតត្រាតាមច្បាប់ស្រី ដោយសារតែវាបានជះឥទ្ធិពលទៅលើឋានៈស្ត្រីក្នុងប្រទេសកម្ពុជាពេញពេញប្រវត្តិសាស្ត្រកម្ពុជារហូតដល់សព្វថ្ងៃ, សូមមើល Nakagawa Kasumi, "លើសពីកំណត់ស? សិទ្ធិស្ត្រីក្នុងប្រទេសកម្ពុជា (ភ្នំពេញ៖ អង្គការស៊ីឌីភី,ណ ២០០៦)។ សូមមើល Katherine Bricknell, "'យើងមិនភ្លេចឆ្នាំងចាស់ទេ ពេលដែលយើងមានឆ្នាំងថ្មី"៖ ការពិភាក្សាអំពីភាពល្អឥតខ្ចោះនិងការអនុវត្តអំពីស្ត្រីក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន" សញ្ញា៖ ទស្សនាវដ្តីអំពីស្ត្រីក្នុងវប្បធម៌និងសង្គម, 36:2 (2011): 437-462.

19 Judy Ledgerwood, "ការវិភាគស្ថានភាពស្ត្រីក្នុងប្រទេសកម្ពុជា"ទំ.២២: "ស្ត្រីបង្ហាញអំពីឋានៈខ្ពស់របស់ខ្លួន (ភាពបរិសុទ្ធនិងកិត្តិយស) តាមរយៈអាកប្បកិរិយាសមរម្យ"; Jacobsen, Lost Goddesses, 119-122

20 Ledgerwood, ការផ្លាស់ប្តូរការយល់ឃើញរបស់ខ្មែរទៅលើយេនឌ័រ, ទំ.២៤។ សូមមើល . Fiske, "ការប្រើដៃទាំងពីរ" ទំ.២៣

21 Katrina Natale, "'ខ្ញុំអាចមានអារម្មណ៍ថាព្រលឹងខ្ញុំកំពុងហោះចេញពីក្នុងខ្លួនរបស់ខ្ញុំ'៖ ការសិក្សាអំពីអំពើហិង្សាយេនឌ័រក្នុងរបបកម្ពុជាប្រជាធិបតេយ្យក្នុងខេត្តបាត់ដំបងនិងស្វាយរៀង" (ភ្នំពេញ, អង្គការស៊ីឌីភី, ២០១១) ទំ.១៩

22 Bricknell, Bricknell, "ចានក្នុងរាវតែងរណ្តំ" ទំ. ២៦៥-២៦៨

ជាសង្ខេប ការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី នៅមុនសម័យខ្មែរក្រហម គឺធ្វើឡើងដោយផ្អែកលើសារៈសំខាន់យ៉ាងពិសេសសម្រាប់គូស្វាមីភរិយា គ្រួសារ និងសហគមន៍ទាំងមូលដោយរួមមានទាំងព្រលឹងបុព្វការីជនទៀតផង។ អាពាហ៍ពិពាហ៍ទាំងនោះត្រូវបានរៀបចំឡើង ជាទូទៅដោយមានការឯកភាពពីអ្នកមានបំណងចង់រៀបអាពាហ៍ពិពាហ៍ ហើយបើតាមទំនៀមទម្លាប់ កម្រនឹងមានការបង្ខិតបង្ខំណាស់ នេះបើយោងតាមការសិក្សាស្រាវជ្រាវដែលមានកន្លងមក។ ឪពុកម្ដាយ ចាស់ទុំ និងសហគមន៍បានធ្វើឲ្យមានសុពលភាពចំពោះការផ្សំផ្គុំក្នុងពិធីរៀបអាពាហ៍ពិពាហ៍តាម រយៈការបានដឹងឮពីព្រលឹងបុព្វការីជន។ ការផ្សំផ្គុំត្រឹមត្រូវមានការជាប់ទាក់ទងទៅលើអត្តសញ្ញាណវប្បធម៌ ជាតិ និងសង្គមនៃអ្នក ចង់រៀបការ ក៏ដូចជាជាប់ទាក់ទងទៅលើសភាព ដែលអាចកើតមាននៃកម្មផលសម្រាប់ការបង្កើតប្រយោជន៍ចំពោះជីវិតនាពេលអនាគតនៅក្នុងបរិបទព្រះពុទ្ធសាសនា។

## ២.២ អាពាហ៍ពិពាហ៍ក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩)

Dy នៃមជ្ឈមណ្ឌលឯកសារនៃកម្ពុជា ផ្ដល់នូវការរៀបរាប់យ៉ាងសង្ខេបដែលមានសារៈប្រយោជន៍មួយលើ ភាពខុសប្លែកគ្នាយ៉ាងសម្បើមចំពោះ ពិធីរៀបអាពាហ៍ពិពាហ៍នៅក្នុងសម័យខ្មែរក្រហម បើប្រៀបធៀបទៅនឹងពិធីរៀបអាពាហ៍ពិពាហ៍តាមលក្ខណៈប្រពៃណី។ ភាគច្រើនបុរសនិងស្ត្រីមិនត្រូវបានអនុញ្ញាតឲ្យជ្រើសរើសដៃគូរបស់ពួកគេឡើយ ហើយជំនួសមកវិញ អង្គការដែលត្រូវចាត់ទុកថាជាឪពុកម្ដាយរបស់ពួកគេ ជាអ្នករៀបចំទុកដាក់គូស្រករឲ្យទៅវិញ។ អ្នករងគ្រោះរួមមានទាំងបុរសនិងស្ត្រី។ ជារឿយៗ គូស្រករជាអ្នកមិនដែលស្គាល់គ្នាសោះដែលត្រូវបង្ខំឲ្យរៀបការជាមួយគ្នាក្នុងពិធីអាពាហ៍ពិពាហ៍ជាទ្រង់ទ្រាយធំ ដែលស្ថាប័នរដ្ឋខ្មែរក្រហមធ្វើជាអធិបតី។ សមាជិកគ្រួសារមិនត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងពិធីនិងមិនត្រូវបានពិគ្រោះយោបល់ទៅលើការរៀបចំ ឬការផ្គូផ្គងទាំងនោះឡើយ។ សម្លៀកបំពាក់បែបប្រពៃណី ការរាំ ការច្រៀងកំសាន្តរួមទាំងពិធីតាមបែបសាសនាត្រូវបានហាមឃាត់។ គូស្រករត្រូវបានរៀបអាពាហ៍ពិពាហ៍ ឲ្យទៅតាមទំនៀមទម្លាប់គំរូរបស់ខ្មែរក្រហមជាមួយនឹងឯកសណ្ឋានពណ៌ខ្មៅ និងស្បែកជើងសង្រែកកង់ឡាន។ នៅក្នុងផ្នែកមួយនៃពិធីរៀបអាពាហ៍ពិពាហ៍នេះ ដែលបានធ្វើឡើងមិនលើសពីរយៈពេលប្រាំនាទី គឺបានប្រគល់ឲ្យស្វាមី និងភរិយាសន្យាជាសាធារណៈថាពួកគេនឹងមានកូននៅក្នុងរយៈពេលមួយឆ្នាំ។គូស្រករដែលរៀបការរួចត្រូវរស់នៅជាមួយគ្នាប៉ុន្មានថ្ងៃក្រោយពីរៀបការរួច ជាញឹកញាប់ដោយមានអ្នកយកការណ៍ ឬពួកឈ្លបដើម្បីបញ្ជាក់ថាពួកគេ ធ្វើឲ្យសម្រេចចំណងអាពាហ៍ពិពាហ៍តាមរយៈការមានទំនាក់ទំនងផ្លូវភេទ។ បន្ទាប់មកពួកគេត្រូវត្រឡប់ទៅតាមក្រុមការងាររបស់ពួកគេរៀងៗខ្លួនវិញ ហើយការជួបជុំសម្រាប់ការមកលេងប្ដីប្រពន្ធ គឺរៀងរាល់ប្រាំពីរទៅដប់ថ្ងៃម្ដង ឬអាចបែកគ្នាដល់រាប់ខែឯណោះ។ គោលបំណងសំខាន់នៃអាពាហ៍ពិពាហ៍មិនមែនគ្រាន់តែដើម្បីបង្កើតជាគ្រួសារ

ឯកជន ដូចក្នុងបរិបទប្រពៃណីប៉ុននោះទេ ប៉ុន្តែ "ត្រូវបង្កើតកូនដើម្បីបម្រើដល់បដិវត្តន៍២.២ អាពាហ៍ពិពាហ៍ក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩)"[23]។នៅក្នុងគំនិតរបស់បដិវត្តន៍ គូស្រករតម្រូវឲ្យហៅគ្នាទៅវិញទៅមកថាមិត្តប្តី និងមិត្តប្រពន្ធ[24]។

ជាទូទៅការសិក្សាស្រាវជ្រាវ បានបរិយាយពីការផ្សាភ្ជាប់អាពាហ៍ពិពាហ៍ដោយបង្ខំថាជាអំពើតាមទំនើងចិត្តដែលនេះជាឱកាសពិសេស សម្រាប់ការពិនិត្យមើលប្រវត្តិរូបបែបប្រញាប់ញាល់ពីសំណាក់មន្ត្រីខ្មែរក្រហម ដើម្បី ផ្គូផ្គងអ្នកដែលមានជីវប្រវត្តិស្រដៀងគ្នា រួមទាំងការដាក់ឲ្យនៅដាច់ដោយឡែករវាងប្រជាជនថ្មី និងប្រជាជនចាស់។ តាមការលុបបំបាត់នូវសាសនាទាំងអស់ក្នុងរបបនោះ ខ្មែរឥស្លាម និងខ្មែរពុទ្ធសាសនិកត្រូវបានធ្វើឲ្យក្លាយជាគូនឹងគ្នា[25]។ ភាពមិនខុសគ្នានិងសេចក្តីលម្អិតផ្សេងៗដែលលើកឡើងដោយអ្នកស្រាវជ្រាវ គឺជាការអនុវត្តនូវការរៀបអាពាហ៍ពិពាហ៍រវាងស្ត្រីវ័យក្មេងស្រស់ស្អាតទៅឲ្យពួកទាហានខ្មែរក្រហមដែលជាជនពិការ។ ស្ត្រីដែលបានបដិសេធត្រូវយកទៅដាក់គុក ធ្វើទារុណកម្ម និងបង្ខំឲ្យធ្វើការងារធ្ងន់ដែលនៅឆ្ងាយពីផ្ទះសម្បែងរបស់ពួកគេ។ មានស្ត្រីមួយចំនួនបានសម្លាប់ខ្លួន[26]។ ភាពមិនសមស្របដទៃទៀតនៅក្នុងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំមាននៅក្នុងការសិក្សាស្រាវជ្រាវរបស់ Toy-Cronin ដែលបានសរសេរថា ពិធីអាពាហ៍ពិពាហ៍ទាំងនោះ គឺមានភាពល្ងឹងល្ងូរចត់យ៉ាងខ្លាំងចំពោះប្រជាជន១៧មេសា[27] ខណៈពេល Huy លើកឡើងថាអាពាហ៍ពិពាហ៍នៃប្រជាជនមូលដ្ឋានគឺ មានលក្ខណៈខុសគ្នាបន្តិចបន្តួចពីពិធីអាពាហ៍ពិពាហ៍ក្រុមមនុស្សដែលគេបង្ហាត់សម្រាប់ធ្វើការងារពិសេស[28]។ Braaf រកឃើញភស្តុតាងថា អាពាហ៍ពិពាហ៍ដោយបង្ខំរបស់ពួកខ្មែរក្រហមត្រូវបានប្រើប្រាស់ដើម្បីប្រឆាំងនឹង ក្រុមជនជាតិភាគតិចមួយចំនួនក្នុងការលុបបំបាត់ចោលនូវសហគមន៍នៅក្នុងប្រជាជនខ្មែរ[29]។

---

23 ខាំប៉ូលី ឌី, ប្រវត្តិកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) (ភ្នំពេញ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា, ២០០៧) ទំ៣២-៣៥។ សូមមើល ជាទូទៅ, Nakagawa Kasumi, អំពើហិង្សាយេនឌ័រក្នុងរបបខ្មែរក្រហម៖ រឿងរ៉ាវរបស់អ្នករស់រានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) (ភ្នំពេញ: np, 2008); Sotheary Yim, "អតីតកាលនិងបច្ចុប្បន្នកាលរបស់អ្នករស់រាន មានជីវិតពីការរៀបការដោយបង្ខំ៖ បទពិសោធន៍ឆ្ពោះទៅរកការព្យាបាល" (ភ្នំពេញ៖ អង្គការស៊ីឌីភី និង Medica Mondiale, nd)។ ទោះជាមានពាក់ព័ន្ធនឹងការរៀបការដោយបង្ខំក៏ដោយ សូមមើល អង្គការយុវសន្តិភាព, នារីបដិវត្តន៍៖ រឿងរ៉ាវខ្មែរក្រហមតាមរយៈកម្មាភិបាលស្រី (ភ្នំពេញ, ២០១២)។

24 Jacobson, Lost Goddesses, 223.

25 សូមមើលជាទូទៅ Farina So, The Hijab of Cambodia: ការចងចាំរបស់ស្ត្រីចាមបន្ទាប់ពីរបបខ្មែរក្រហម (ភ្នំពេញ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា, ២០១១); និង Rochelle Braaf, "អំពើហិង្សាផ្លូវភេទទៅលើនិគមជនភាគតិចក្នុងរបបខ្មែរក្រហម" (ភ្នំពេញ៖ អង្គការស៊ីឌីភី, ២០១៤)

26 សូមមើល Jacobson, Lost Goddesses, 230, អំពីទាហានពិការដែលត្រូវបានផ្តល់ស្ត្រីក្មេងជាអំណោយ សម្រាប់ការខំប្រឹងប្រែងដើម្បីបដិវត្តន៍។ សូមមើល ខាំប៉ូលី ខាំប៉ូលី ឌី, ប្រវត្តិកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) (ភ្នំពេញ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា, ២០០៧) ទំ៣៣ អំពី ទារុណកម្មសម្រាប់ការបដិសេធមិនព្រមរៀបការជាមួយទាហាន និងការធ្វើអត្តឃាតរបស់កូនក្រមុំ

27 Toy-Cronin, "អ្វីទៅជាការរៀបការដោយបង្ខំ?" ទំ.៥៤៨

28 Ratana C. Huy, "អាពាហ៍ពិពាហ៍របស់ខ្មែរក្រហម" ស្វែងរកការពិត 25 (2002): 26-28.

29 Braaf, "អំពើហិង្សាផ្លូវភេទទៅលើនិគមជនភាគតិច" x

ទំនងជាមានភាពមិនខុសគ្នាតាមតំបន់ អំពីគោលនយោបាយខ្មែរក្រហមចំពោះអាពាហ៍ពិពាហ៍ដោយបង្ខំត្រូវបានយកមកអនុវត្ត[30]។ នេះវាប្រហែលជាអាចជួយពន្យល់ពីការនិយាយប្រាប់របស់ Ponchaund ចំពោះរបៀបដែលបុរស និងស្ត្រីវ័យក្មេងនៅក្នុងសហគមន៍ទូទៅថាមាន "សមភាព និងសិទ្ធិសេរីភាពក្នុងការជ្រើសរើសដៃគូរបស់ពួកគេ" ហើយពេលដែលមានយ៉ាងហោចណាស់១០គូ ត្រូវឆ្លងកាត់ជាផ្លូវការតាមសំណើសុំអនុញ្ញាតពីអង្គការ។ ម្ចាស់ស្រុកជាអ្នកកំណត់កាលបរិច្ឆេទ និងទីកន្លែងសម្រាប់ការរៀបអាពាហ៍ពិពាហ៍បែបសហគមន៍នេះ[31]។ ភាពផ្សេងគ្នាដែលគួរឲ្យកត់សម្គាល់មួយទៀតនៅក្នុងឯកសារ គឺការរៀបរាប់របស់ Le Vine អំពីលក្ខណៈអាពាហ៍ពិពាហ៍ទាំងនេះថាជា "ការប្រមូល" ជាជាងការបង្ខិតបង្ខំដែលលើកឡើងថាការរៀបចំអាពាហ៍ពិពាហ៍របស់ខ្មែរក្រហម មិនខុសគ្នាពីការរៀបចំទុកដាក់ដោយឪពុកម្តាយទៅតាមប្រពៃណីនោះឡើយ[32]។ ផ្ទុយទៅវិញ អ្នកស្រាវជ្រាវជាទូទៅយល់ស្របថាអាពាហ៍ពិពាហ៍ដោយពួកខ្មែរក្រហម គឺវាខុសទាំងស្រុងពីអាពាហ៍ពិពាហ៍តាមប្រពៃណីដែលថាអាពាហ៍ពិពាហ៍ទាំងអស់នោះ ភាគច្រើនមិនមានជម្រើសពីសំណាក់ដៃគូ ដោយមិនមានការឯកភាពត្រឹមត្រូវ និងបានបង្ខំនៅក្នុងបរិស្ថានដែលតានតឹងចំពោះការគំរាមសម្លាប់ ឬដាក់ទណ្ឌកម្មជាប្រចាំ។

អាពាហ៍ពិពាហ៍ដោយបង្ខំ រួមមានទាំង អំពើហិង្សាលើផ្លូវភេទក្នុងទំនាក់ទំនងផ្លូវភេទដើម្បីធ្វើឲ្យសម្រេចអាពាហ៍ពិពាហ៍នោះ ហើយថែមទាំងត្រូវបានបង្ខិតបង្ខំ។ អ្នកស្រាវជ្រាវបានបង្ហាញពីឯកសារចំពោះការអនុវត្តវិធីសាស្ត្រនេះ។ Em ពិពណ៌នាពីផ្ទះតូចៗរៀបចំសម្រាប់គូស្រករដែលគោរពតាមអាពាហ៍ពិពាហ៍សម័យខ្មែរក្រហម និងទណ្ឌកម្ម ឬក៏ការបាត់ខ្លួនដែលប្រឈមដោយគូសាម៉ីភរិយាដែលបានបដិសេធមិនព្រមទទួលយកគ្នា នាពេលរាត្រីបន្ទាប់ពីអាពាហ៍ពិពាហ៍ចប់រួចរាល់[33]។ Ye ពិភាក្សាពីរបៀបដែលបទបញ្ជាដើម្បីឲ្យអាពាហ៍ពិពាហ៍សម្រេចបាន ឈានទៅដល់ការរំលោភ និងអំពើហិង្សាលើផ្លូវភេទលើស្ត្រីពីសំណាក់ស្វាមីដែលបានរៀបចំទុកដាក់ឲ្យ[34]។ ប្រធានបទនេះ ថែមទាំងត្រូវរក្សាទុកនៅក្នុងឯកសារភាពយន្តខ្នាតវែងមានឈ្មោះថា អាពាហ៍ពិពាហ៍ពណ៌ក្រហមដែលផលិតដោយលោក ប៉ាន់ រិទ្ធី សម្រាប់មជ្ឈមណ្ឌលបុប្ផាណាភ្នំពេញនៅក្នុងឆ្នាំ ២០១២[35]។

---

30 សូមមើលជាទូទៅ, Katrina Natale, "'ខ្ញុំអាចមានអារម្មណ៍ថាព្រលឹងខ្ញុំកំពុងហោះចេញពីក្នុងខ្លួនរបស់ខ្ញុំ"; Braaf, "អំពើហិង្សាផ្លូវភេទទៅលើនិគមជនភាគតិច

31 Francois Ponchaund, កម្ពុជាឆ្នាំសូន្យ (New York: Holt, Rinehart and Winston, 1978): 125-126.

32 Peg LeVine, ស្នេហានិងការភ័យខ្លាច, 29.

33 Sokhym Em, "អ្នកគ្រូពេទ្យបដិវត្តក្នុងស្រុកត្រាំកក់" ស្វែងរកការពិត 35 (2002): 17-19

34 Beini Ye, "ការរៀបការដោយបង្ខំជាកញ្ចក់នៃការផ្លាស់ប្តូរជម្លោះក្នុងប្រទេសកម្ពុជា" Peace Review 23:4 (2011): 470.

35 ដដែល

អ្នកស្រាវជ្រាវលើកសំអាងឡើងថាបុរសនិងស្ត្រី ជានិច្ចកាល បង្កើតជាជម្រើសបែប យុទ្ធសាស្ត្រដើម្បីឲ្យបានរស់រានមានជីវិត តាមការទទួលយកដោយគ្មានជំទាស់ចំពោះអាពាហ៍ពិពាហ៍ដោយបង្ខំនេះ។ ហើយការប្រឆាំងយ៉ាងហោចណាស់ព្យាយាមបដិសេធ វាគឺជារឿងធម្មតា។ ច្បាស់ណាស់ ការសម្លាប់ខ្លួនរបស់ស្ត្រីអាចត្រូវមើលឃើញនៅក្នុងខ្សែភាពយន្តនេះ។ Toy-Cronin ចង្អុលបង្ហាញពីរបៀបដែលអ្នកផ្តល់សម្ភាសន៍ជាច្រើនរបស់នាងត្អូញត្អែរយ៉ាងជូរចត់ថាឪពុកម្តាយរបស់ពួកគេមិនត្រូវបានអនុញ្ញាតឲ្យបំពេញតួនាទីតាមប្រពៃណីក្នុងការរៀបចំអាពាហ៍ពិពាហ៍នោះ ក៏ដូចជាមិនបានចូលរួមក្នុងពិធីនោះឡើយ[36]។ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំត្រូវចាត់ទុកដោយអ្នករងគ្រោះជាច្រើនថាជាទង្វើមិនគោរពចំពោះដូនតា និងឪពុកម្តាយ។ ចំពោះស្ត្រីដែលធំដឹងក្តីឡើងដើម្បីរក្សាភាពបរិសុទ្ធឲ្យខាងតែបាននោះ គិតថាការរួមភេទនៅក្នុងអាពាហ៍ពិពាហ៍ទាំងនេះគឺពិតជាប៉ះទង្គិចដល់ផ្លូវចិត្តយ៉ាងធ្ងន់ក្រៃលែង។

ទោះបីជាអាពាហ៍ពិពាហ៍ដោយបង្ខំរបស់ខ្មែរក្រហម ជាគោលនយោបាយជាតិ និងស្ទើរតែត្រូវបានអនុវត្តជាទូទៅ បើយោងទៅតាមការសិក្សាស្រាវជ្រាវនោះក៏ដោយ គេមិនអាចកំណត់ បាននូវភាពរីករាលដាលប៉ុនណានោះឡើយ។ McGrew ផ្តល់នូវការវាយតម្លៃយ៉ាងម៉ត់ចត់មួយនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ផ្អែកលើការគណនាចំនួនប្រជាជន និងការស្រាវជ្រាវ របស់នាង៖

> តើការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំមានភាពទូលំទូលាយដោយរបៀបណា? តាមវិធីប្រៀបធៀប បានគេវាយតម្លៃថា ស្ត្រីសម្រាប់បម្រើការសប្បាយច្រើនជាង ២០០.០០០នាក់ ត្រូវបានយកធ្វើជាទាសករដោយទាហានជប៉ុន ក្នុងអំឡុងពេលសង្គ្រាមលោកលើកទី២។ បើទោះបីជាការអនុវត្តទាំងពីរមានលក្ខណៈខុសគ្នាទាំងស្រុងក៏ពិតមែន តែចំនួនមនុស្សប្រហែលជាអាចស្មើគ្នា។ ប្រសិនបើនៅក្នុងភូមិដែលមានប្រជាជនចំនួន ១.០០០នាក់ មានមធ្យមភាគនៃការរៀបអាពាហ៍ពិពាហ៍ពីរក្រុមក្នុងអំឡុងពេល៤ឆ្នាំ ដែលខ្មែរក្រហមកាន់កាប់អំណាច ដោយមានស្ត្រី១៥នាក់ត្រូវចូលរួមក្នុងពិធីនីមួយៗ នោះបានសេចក្តីថាមានស្ត្រី២១០.០០០នាក់ ប្រហែលជាត្រូវបានបង្ខំឲ្យរៀបអាពាហ៍ពិពាហ៍នៅក្នុងចំណោម ប្រជាជន៧លាននាក់ ។
>
> ទោះបីជាយ៉ាងណា អាពាហ៍ពិពាហ៍ជាច្រើនត្រូវបានបង្ខំនៅក្នុងរបបខ្មែរក្រហម (ហើយវាច្បាស់ជានៅក្នុងចំនួនមនុស្សរាប់ពាន់នាក់)។ អ្នកស្រាវជ្រាវពិពណ៌នាយ៉ាងច្រើនអំពីគោលនយោបាយជាមួយការអនុវត្តជាប្រព័ន្ធ ទូលំទូលាយ និងបង្ខិតបង្ខំ

[36] Toy-Cronin, "អ្វីទៅជាការរៀបការដោយបង្ខំ?" ទំ.៥៤៨

ដោយហិង្សា។ គោលនយោបាយនេះ គឺជាការបំផ្លាញនូវភាពថ្លៃថ្នូររបស់មនុស្ស និងលុបបំបាត់ចោលនូវជំនឿវប្បធម៌ទាំងស្រុង ដោយរួមទាំងការមិនបានចូលរួមពីគ្រួសារ និងដូនតាជាដើម។ ជនរងគ្រោះភាគច្រើនមិនមានជម្រើសក្នុងការជ្រើសរើសដៃគូ និងមិនបានផ្ដល់ឲ្យនូវបរិស្ថានដែលជាកន្លែងសម្រាប់ការព្រមព្រៀងនិងមានសារៈសំខាន់កើតមានឡើយ និងត្រូវបានបង្ខំនៅពេលដែលការយល់ព្រមត្រូវបានបដិសេធន៍។ គូស្វាមីភរិយាដែលគេរៀបចំឲ្យ ត្រូវបង្ខំឲ្យមានទំនាក់ទំនងជាប្ដីប្រពន្ធ ដែលបណ្ដាលឲ្យមានការរំលោភបំពានលើផ្លូវភេទ និងទម្រង់ផ្សេងៗនៃអំពើហិង្សាលើផ្លូវភេទក៏ដូចជាការប៉ះទង្គិចផ្នែកសតិអារម្មណ៍ផងដែរ។

## ២.៣ អាពាហ៍ពិពាហ៍ក្រោយការដួលរលំនៃរបបខ្មែរក្រហម (ក្រោយឆ្នាំ ១៩៧៩)

របបខ្មែរក្រហមបានបរាជ័យក្រោមស្នាដៃកងទ័ពវៀតណាមនៅថ្ងៃទី៧ មករា ១៩៧៩។ ប៉ុន្មានថ្ងៃបន្ទាប់ពីការដួលរលំ ត្រូវបានចាត់ទុកជាអំឡុងពេលនៃភាពចលាចល និងលំហូរចូលនៃប្រជាជនទាំងអស់ ខណៈពេលដែលប្រជាជនបានវិលត្រឡប់ទៅកាន់លំនៅដ្ឋានដើមរបស់ពួកគេវិញ ហើយគ្រួសារបានចាប់ផ្ដើមកិច្ចការបង្កបង្កើនផលឡើងវិញជាមួយនឹងសមាជិកដែលនៅរស់។ គោលនយោបាយអាពាហ៍ពិពាហ៍ដោយបង្ខំរបស់ខ្មែរក្រហមកាន់តែធ្វើឲ្យមានភាពចលាចលកាន់តែខ្លាំង។ ការសិក្សាស្រាវជ្រាវ ចង្អុលបង្ហាញថា មិនមានគោលនយោបាយថ្នាក់ជាតិណាមួយដែលបង្កើតឡើង ដោយរដ្ឋាភិបាលបណ្ដោះអាសន្នក្រោយការដួលរលំនៃរបបនេះ ដោយបានបង្ហាញច្បាស់លាស់ពី ឋានៈអាពាហ៍ពិពាហ៍ដោយបង្ខំ ឬក៏ជម្រើសក្នុងការរំលាយចោលណាមួយនោះទេសម្រាប់គូស្វាមីភរិយា[37]។ ហេតុនេះ គូស្វាមីភរិយាទាំងអស់គួរត្រូវបានផ្ដល់សិទ្ធិក្នុងការពិភាក្សាពីឋានៈនៃអាពាហ៍ពិពាហ៍របស់ពួកគេ។

នៅដើមទសវត្សឆ្នាំ១៩៩០ និងទសវត្សឆ្នាំ២០០០ មិនបានបញ្ជាក់ពីភាពច្បាស់លាស់នៃអាពាហ៍ពិពាហ៍ដោយបង្ខំនោះទេ។ តែផ្ទុយមកវិញ វាបានចង្អុលបង្ហាញពីអត្រាដ៏ខ្ពស់នៃមេគ្រួសារជាស្ត្រីភេទក្នុងសម័យនោះទៅវិញ។ ក្ដីបារម្ភខ្លាំងមួយនៅក្នុងទសវត្សឆ្នាំ ១៩៩០ គឺជាសមាមាត្រនៃគ្រួសារនៅតាមជនបទដែលគ្រប់គ្រងដោយស្ត្រី មានអត្រាខ្ពស់

---

[37] ការស្រាវជ្រាវរបស់ Toy-Cronin លើកឡើងថាការរៀបការមិនបានធ្វើតាមនីតិវិធីចុះបញ្ជីស្របច្បាប់ណាមួយទេ (សូមមើល "អ្វីទៅជាការរៀបការដោយបង្ខំ?" ទំ.៥៩៨)។ គេមិនឃើញមានការលើកឡើងអំពីគោលនយោបាយថ្នាក់ជាតិណាមួយក្នុងឯកសារស្ដីពីការអភិវឌ្ឍន៍នៅក្នុងរបបនោះទេ ដូចជារបាយការណ៍របស់ Ledgerwood សម្រាប់ UNICEF ("ការវិភាគស្ថានភាពស្ត្រីក្នុងប្រទេសកម្ពុជា" [1992]); Peter Utting ចន្លោះក្ដីសង្ឃឹមនិងអសន្តិសុខ៖ ផលវិបាកសង្គមនៃដំណើរការសន្តិភាពនៅកម្ពុជា, (New York: United Nations Research Institute for Social Development [UNRISD], 1994); របាយការណ៍ឆ្នាំ១៩៩៥ របស់អង្គការ UNICEF, "ឆ្ពោះទៅកាន់អនាគតកាន់តែប្រសើរ៖ ការវិភាគស្ថានភាពកុមារនិងស្ត្រីក្នុងប្រទេសកម្ពុជា"

រហូតដល់៣០% ទៅ ៣៥%នៃគ្រួសារសរុប និងកើនដល់៥០% នៅតាមភូមិមួយចំនួន[38]។ តាមពិតទៅ នៅពេលដែល Ebihara បានត្រឡប់ទៅកាន់ភូមិសិក្សារបស់គាត់នៅដើមទសវត្ស ឆ្នាំ១៩៩០ ដោយមានស្ត្រី ៨០.៥% នៃប្រជាជនសរុប[39]។ ចំនួនដ៏ច្រើនលើសលុបនៃស្ត្រីមេម៉ាយ នាពេលនោះ បានសបញ្ជាក់ឲ្យឃើញពីអត្រាមរណៈយ៉ាងច្រើនរបស់បុរសក្នុងអំឡុងពេលមាន ជម្លោះ និងនៅពេលដែលស្ថិតនៅក្រោមរបបខ្មែរក្រហម ក៏ដូចជាការកៀសខ្លួនរបស់បុរសដើម្បី ស្វែងរកការងារធ្វើ និងបុរសដែលមានកាយសម្បទាគ្រប់គ្រាន់ត្រូវកេណ្ឌធ្វើជាទាហាន[40]។

អ្វីដែលមិនបានបញ្ជាក់នៅក្នុងឯកសារទាំងនោះ គឺទំនាក់ទំនងដែលអាចទៅរួចរវាង ចំនួនដ៏ច្រើនលើសលុបរបស់ស្ត្រីជាមេគ្រួសារ និងអាពាហ៍ពិពាហ៍ដោយបង្ខំដែលត្រូវរំលាយ ចោល។ ជាពិសេសស្ត្រីមេម៉ាយត្រូវបានប្រើនៅក្នុងភាសាខ្មែរ ដើម្បីចង្អុលបង្ហាញពីស្ត្រីដែល ធ្លាប់រៀបអាពាហ៍ពិពាហ៍ ប៉ុន្តែមិនមានអាពាហ៍ពិពាហ៍ទៀតទេដោយសារតែការស្លាប់ ការរស់ នៅផ្សេងគ្នា ឬការលែងលះជាដើម។ ទោះជាមិនបានបញ្ជាក់ពីអាពាហ៍ពិពាហ៍ដោយបង្ខំក៏ ដោយ តែតាមការសិក្សាស្រាវជ្រាវរបស់ Sato រកឃើញថា ប្រទេសកម្ពុជាមិនមានកម្មវិធីរដ្ឋា ភិបាលគាំទ្រដល់ស្ត្រីមេម៉ាយដែលមានកូនឡើយនៅចុងទសវត្សឆ្នាំ១៩៩០។ ទោះបីជាការ ពិតថា តាមទម្លាប់ស្ត្រីជាម្តាយបានយកកូនមកចិញ្ចឹមនៅពេលលែងលះ ហើយជាតួយ៉ាងគ្មាន ស្ត្រីជាម្តាយណាម្នាក់បានទទួលប្រាក់ចិញ្ចឹមកូនពីស្វាមីមុនរបស់ពួកគាត់ឡើយ[41]។ ជាថ្មីម្តង ទៀត ខណៈដែលមិនបានដោះស្រាយជាមួយនឹងអាពាហ៍ពិពាហ៍ដោយបង្ខំធ្វើឡើងដោយខ្មែរ ក្រហម មានរបាយការណ៍ដទៃទៀតនៅដើមទសវត្សឆ្នាំ២០០០ ពិភាក្សាទៅលើកេរ តំណែល នៃភាពកំណាចឃោរឃៅនៃការកើនឡើងនៃអំពើហិង្សាក្នុងគ្រួសារ ពហុពន្ធភាព និងការចាក ចោលបន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហម[42]។ ហើយលទ្ធផលនៃចំនួនដ៏សម្បើមរបស់ស្ត្រីជា

38 Jacqueline Desbarats, "អ្នករស់រានមានជីវិតកាន់តែច្រើនឡើង៖ ការផ្លាស់ប្តូរចំនួនប្រជាជនក្នុងប្រទេសកម្ពុជា ១៩៧៥-១៩៩៣" អត្ថបទសម្រាប់កម្មវិធីការសិក្សាអំពីអាស៊ាននៃ Temple Arizona State University (១៩៩៥) ទំ.១២៦

39 Alexander Hinton, "'ហួសពីការឈឺចាប់--ភាពភ័យខ្លាចអំពើប្រល័យពូជសាសន៍ក្រោមរបបខ្មែរក្រហម៖ ទស្សនៈចេញពីការងាររបស់ May Ebihara,"នរវិទ្យានិងសហាគមន៍ក្នុងប្រទេសកម្ពុជា៖ ការឆ្លុះបញ្ចាំងអំពីការងាររបស់ May Ebihara, John Marston, ed. (Caulfield: Monash University Press, 2011): ដោយដកស្រង់ Ebihara, ៥៩។ គួរឲ្យភ្ញាក់ផ្អើលណាស់ ដែល Ebihara មិនបានពិនិត្យមើលទៅលើការរៀបការដោយបង្ខំក្នុងអំឡុងពេលដែលគាត់ត្រឡប់មកភូមិស្វាយក្នុងអំឡុងទសវត្សឆ្នាំ១៩៩០។

40 Utting, ចន្លោះរវាងក្តីសង្ឃឹមនិងអសន្តិសុខ, ទំ.៩៣-៩៤

41 Nao Sato, "សមាសភាពនិងរចនាសម្ព័ន្ធការងាររបស់មេគ្រួសារជាស្ត្រី៖ ករណីសិក្សានៅភូមិជនបទក្នុងខេត្តសៀមរាប ប្រទេសកម្ពុជា" ស៊េរីអត្ថបទលេខ ១១, Afrasian Center for Peace and Development Studies, Singha, Japan, 2006: 21-22។ សូមមើល Desbarats, "អ្នករស់រានមានជីវិតកាន់តែច្រើនឡើង" ដែលពិភាក្សាអំពីរបៀបដែលប្រជាជនជនបទជាង៩៧% ក្នុងឆ្នាំ១៩៨៦ ក្លាយទៅជាក្រុមសាមគ្គីដែលមានប្រយោជន៍ក្នុងការផ្តល់នូវសំណាញ់សុវត្ថិភាពសម្រាប់ស្ត្រីមេម៉ាយនិងកុមារកំព្រាដ៏ច្រើនលើសលប់។ មុនឆ្នាំ១៩៨៩ គោលនយោបាយទាំងនេះត្រូវបានគេបោះបង់ចោល ដោយសារតែការវត្តមានកម្មវិធីសេដ្ឋកិច្ចសេរី ធ្វើឲ្យស្ត្រីទទួលយកការងាររបស់បុរសត្រូវជួលកម្លាំងការងាររបស់មនុស្សប្រុស។ មិនមានគ្រូបដណ្តប់អំពីការរៀបការដោយបង្ខំទេ។

42 Cathy Zimmerman, "'ចានក្នុងរាវតែងរណ្តំ': អំពើហិង្សាក្នុងគ្រួសារក្នុងប្រទេសកម្ពុជា" (ភ្នំពេញ៖ មូលនិធិអាស៊ីប្រចាំនៅកម្ពុជា, ១៩៩៤); Jan Ovesen, Ing-Britt Trankell, and Joakim Ojendal, "នៅពេលដែលផ្ទះក្លាយជាកោះ៖ ការរៀបចំសង្គមនិងរចនាសម្ព័ន្ធអំណាចនៅតំបន់ជនបទក្នុងប្រទេសកម្ពុជា" របាយការណ៍ស្រាវជ្រាវផ្នែកនរវិទ្យាវប្បធម៌ Uppsala លេខ១៥ (១៩៩៦)។

មេគ្រួសារ បានធ្វើឲ្យឈានដល់ការឲ្យនិយមន័យជាថ្មីទាំងស្រុងចំពោះតួនាទីយេនឌ័រ ដោយសារតែស្ត្រីបានបំពេញតួនាទីទាំងជាអ្នកផ្គត់ផ្គង់ និងអ្នកថែរក្សាផ្ទះសម្បែង ក៏ដូចជាអ្នកធ្វើការសម្រេចចិត្តនៅក្នុងគ្រួសារទាំងមូល[43]។

ការសិក្សាស្រាវជ្រាវរបស់ Bricknell គឺជាការសិក្សាមួយដែលពិនិត្យមើលទៅលើផលវិបាកនៃអាពាហ៍ពិពាហ៍ដោយបង្ខំ បន្ទាប់ពីការដួលរលំរបបខ្មែរក្រហម។ សារណារបស់គាត់ ពិនិត្យទៅលើការរៀបអាពាហ៍ពិពាហ៍សារជាថ្មី និងការលែងលះនៅដោយសារតែការចាកចោល ពហុពន្ធភាព និងការរំលោភបំពាននៅក្នុងបរិបទនៃភាពច្របូកច្របល់សង្គមដែលបន្តរហូតដល់ឆ្នាំ១៩៩៨ និងជាលទ្ធផលនៃចំនួនដ៏ច្រើនលើសលុបនៃសមាមាត្ររបស់ស្ត្រីទៅនឹងបុរសនៅពេលដួលរលំរបបនោះ។ ការលើកសំអាងអំពីតួនាទីសង្គមរបស់ស្ត្រីនៅតែបន្តចាត់ទុកជាការប្រឆាំងនឹងទំនាក់ទំនងជាឪពុកម្តាយ និងទំនាក់ទំនងរវាងប្តីប្រពន្ធដែលមានសុខដុមមេនា។ ការលែងលះ និងភាពជាស្ត្រីមេម៉ាយបានបន្សល់នូវស្លាកស្នាមទុរយសក្នុងសង្គម និងរឹតត្បិតដល់ការទទួលបានប្រកពសំខាន់នៃអំណាចនិងឋានៈ។ "ស្ត្រីមេម៉ាយ" ត្រូវបានឲ្យតម្លៃក្នុងសង្គមថាជានិមិត្តសញ្ញាមិនល្អចំពោះអនាគត ពីព្រោះតាមនិយមន័យ ស្ត្រីទាំងនេះបានងាកចេញពីច្បាប់ស្រីក្នុងទំនាក់ទំនងគ្រួសារដែលមានសុខដុម និងភាពរួបរួមគ្នា។ ការរៀបអាពាហ៍ពិពាហ៍ជាថ្មីក្រោយការដួលរលំនៃរបបនេះ ត្រូវបានសង្កេតឃើញថាជាការសង្គ្រោះពីភាពមិនល្អសម្រាប់គោលបំណងជាច្រើន។ Bricknell លើកឡើងថា ក្រោយរបបនោះ ស្ត្រីបានបន្តបង្កើតជម្រើសជាយុទ្ធសាស្ត្ររួមមានទាំងយល់ព្រមធ្វើជាប្រពន្ធទីពីរ ឬទីបីជាមួយនឹងឋានៈទាប។ ស្ត្រីផ្សេងទៀតបានព្យាយាមរកមធ្យោបាយដោះស្រាយហេតុផលកម្មពៀរនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ តាមរយៈការរៀបអាពាហ៍ពិពាហ៍ជាថ្មីតាមការជ្រើសរើស និងមានការចូលរួមពីជូនតា និងឪពុកម្តាយតាមរយៈពិធីប្រពៃណីផ្សេងៗ[44]។

យោងតាមការសិក្សាស្រាវជ្រាវសរុប អាពាហ៍ពិពាហ៍ដោយបង្ខំបានបង្កើតឲ្យមានផលវិបាកលើយេនឌ័រ និងផលប៉ះពាល់ទៅលើវប្បធម៌ សេដ្ឋកិច្ច និងសង្គមយ៉ាងធ្ងន់ធ្ងរទាំងទៅលើស្ត្រី និងកូនរបស់ពួកគាត់។ ផលវិបាកទាំងនេះ រួមមានទាំងផ្នែកផ្លូវចិត្តផងដែរ។ Ye បង្ហាញពីភាពឯកោផ្លូវអារម្មណ៍ ដែលអ្នកនៅរស់រានមានជីវិតពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំបានឆ្លងកាត់ ជាពិសេសគឺស្ត្រី និងរបៀបដែលការប៉ះទង្គិចនេះបានផ្ទេរទៅកាន់កូនរបស់ពួកគាត់[45]។ Kogure បានពិភាក្សាផលប៉ះពាល់អវិជ្ជមានលើការសិក្សារបស់ក្មេងដោយសារ

[43] Desbarats, "អ្នករស់រានមានជីវិតកាន់តែច្រើនឡើង" ទំ.២០។
[44] Bricknell, Bricknell, "'ចានក្នុងរាវតែងរណ្តំ'" ទំ.២៦៥-៧០។
[45] Ye, "ការរៀបការដោយបង្ខំជាកញ្ចក់" ទំ.៤៧១

អាពាហ៍ពិពាហ៍ដោយបង្ខំ[46]។ ការសិក្សាស្រាវជ្រាវកន្លងមកមិនបានពិភាក្សាពីការផ្លាស់ប្តូរមនោសញ្ចេតនា សតិអារម្មណ៍ ឬឥរិយាបថ និងផលប៉ះទង្គិចទៅលើបុរស អត្តសញ្ញាណបុរស ឬការឲ្យនិយមន័យភាពជាបុរសដោយយោងតាមគោលនយោបាយនៃអាពាហ៍ពិពាហ៍ និងទំនាក់ទំនងជាប្តីប្រពន្ធដោយបង្ខិតបង្ខំទេ។

វាបង្ហាញមិនច្បាស់លាស់ទេថា មានអាពាហ៍ពិពាហ៍ដោយបង្ខំចំនួនប៉ុន្មានដែលនៅតែមិនមានការបាក់បែក និងចំនួនប៉ុន្មានត្រូវរំលាយបន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហម។ ភស្តុតាងតាមការរៀបរាប់ បង្ហាញថាប្រហែលជាពាក់កណ្តាលនៃអាពាហ៍ពិពាហ៍ទាំងអស់នោះត្រូវបានរំលាយចោល[47]។ ផ្ទុយទៅវិញ បើតាមសំណាករបស់ LeVine បង្ហាញពីលទ្ធផលលើសពី៨០% (១៥៨ នៃ ១៩២ករណី) នៃអ្នកផ្តល់សម្ភាសន៍បានគិតថាអាពាហ៍ពិពាហ៍របស់ពួកគេដោយខ្មែរក្រហម ជាការរៀបចំដោយមានតម្លៃអាចទទួលយកបានតាមច្បាប់ ជាមួយនឹងចំនួនដូចគ្នានៃអ្នកបន្តរស់នៅជាមួយគ្នារហូតដល់សព្វថ្ងៃ[48]។អត្រានេះគឺខ្ពស់ជាងច្រើនលើសពីការបង្ហាញរបស់អ្នកសិក្សាស្រាវជ្រាវដទៃទៀត។

ការសិក្សាស្រាវជ្រាវរបស់ Toy-Cronin ពិភាក្សាពីមូលហេតុជាច្រើនថាហេតុអ្វីបានជាគូប្តីប្រពន្ធជាច្រើននៅតែបន្តរស់នៅជាមួយគ្នា ដោយផ្តោតសំខាន់លើការយកចិត្តទុកដាក់ចំពោះស្ត្រី៖ បំណងប្រាថ្នាដើម្បីរក្សាគ្រួសាររហូតដល់ពេលកូនកើតមកដោយចំណងអាពាហ៍ពិពាហ៍ ភាពចាំបាច់ហិរញ្ញវត្ថុ និងតម្រូវការការពារ និងការថែរក្សាទៅវិញទៅមក ឬការជះឥទ្ធិពលទៅលើវប្បធម៌ប្រឆាំងនឹងការបែកបាក់គ្នា។ ប៉ុន្តែគាត់បានលើកឡើងថា ភស្តុតាងដែលគូស្រករបន្តរស់នៅជាមួយគ្នា មិនបានលុបបំបាត់ចោលនូវការពិតដែលគូស្វាមីភរិយា គឺជាជនរងគ្រោះ នៃគោលនយោបាយអាពាហ៍ពិពាហ៍ដោយបង្ខំរបស់រដ្ឋាភិបាលខ្មែរក្រហមឡើយ៖ "ចំពោះប្រជាជនកម្ពុជា ឥទ្ធិពលនៅតែបន្តនៅលើការពិភាក្សាអំពីឋានៈនៃអាពាហ៍ពិពាហ៍នេះ បង្កប់នូវភាពឃោរឃៅដែលគេបានប្រើប្រាស់ ដើម្បីបង្ខិតបង្ខំក្នុងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងក្តីឈឺចាប់ដែលជាលទ្ធផលនៃការមិនមានប្រារព្ធពិធីសំខាន់ៗនៅក្នុងវប្បធម៌កម្ពុជា[49]។ ការរកឃើញនេះត្រូវបានសន្មត់ថាកើតមានឡើងទាំងទៅលើបុរសនិងស្ត្រី

---

[46] Katsuo Kogure, "ផលប៉ះពាល់នៃការរៀបការដោយបង្ខំក្នុងប្រទេសកម្ពុជាក្រោមរបបប៉ុលពត" អត្ថបទលេខ ៨០៥, វិទ្យាស្ថានស្រាវជ្រាវសង្គមនិងសេដ្ឋកិច្ច, Osaka University, ខែមិនា ២០១១។ សូមមើលជាទូទៅ Nigel P. Field, "ការផ្ទេរការប៉ះទង្គិចផ្លូវចិត្តឆ្លងជំនាន់ ដែលកើតចេញពីរបបខ្មែរក្រហម៖ ទស្សនៈចំណងភ្ជាប់" ស្នាមរបួសលាក់មុខរបស់កម្ពុជា៖ ចិត្តវិទ្យានៃការប៉ះទង្គិចផ្លូវចិត្តក្នុងក្រោយរបបខ្មែរក្រហម, Beth Van Schaack, Daryn Reicherter និង Youk Chhang, editors (ភ្នំពេញ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា, ២០១១)៖ ទំ.៧០-៨៥។

[47] McGrew, "ស្ត្រីកម្ពុជានៅឆ្នាំសូន្យ"

[48] LeVine, ស្នេហានិងការភ័យខ្លាច, ទំ.២៦, ៨៧

[49] Toy-Cronin, "អ្វីទៅជាការរៀបការដោយបង្ខំ?" ទំ.៥៥៥, ៥៨៦

ដែលនៅរស់រានមានជីវិតពីគោលនយោបាយខ្មែរក្រហម ចំពោះការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងទំនាក់ទំនងជាប្តីប្រពន្ធនេះ។

## ២.៤ "អាពាហ៍ពិពាហ៍ដោយបង្ខំ" ជាការចោទប្រកាន់នៅចំពោះមុខ អ.វ.ត.ក

អ.វ.ត.ក ត្រូវបង្កើតឡើងនៅក្នុងឆ្នាំ ២០០៦ ដើម្បីកាត់ទោសមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិប្រព្រឹត្តដោយរបបខ្មែរក្រហមនៅរវាងថ្ងៃ១៧មេសាឆ្នាំ១៩៧៥និងថ្ងៃ៧មករាឆ្នាំ១៩៧៩[50]។តុលាការនេះបានសម្រេចសំណុំរឿងមួយ ក្នុងចំណោម៤សំណុំរឿងដែលក្នុងនោះ សំណុំរឿង០០២ត្រូវបានបំបែកជាការជំនុំជម្រះតូចៗដើម្បីពន្លឿនដំណើរការនីតិវិធី អាស្រ័យដោយអាយុបុគ្គលត្រូវចោទកាន់តែជរាណាស់ទៅហើយ (បច្ចុប្បន្ន នៅក្នុងវ័យ៨០ឆ្នាំ)។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះចំពោះសំណុំរឿង ០០២ រួមមានអាពាហ៍ពិពាហ៍ដោយបង្ខំដែលជាគោលនយោបាយមួយក្នុងចំណោមគោលនយោបាយទាំង៥ ប្រើប្រាស់ក្នុងរបបនោះ ដើម្បីអនុវត្តគោលបំណងឧក្រិដ្ឋរបស់ខ្លួន។ ការចោទប្រកាន់ទៅលើអាពាហ៍ពិពាហ៍ដោយបង្ខំ និងការចាប់រំលោភនៅក្នុងអាពាហ៍ពិពាហ៍ទាំងនោះ ដែលបានដាក់ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះថាជា "បទបញ្ជារៀបអាពាហ៍ពិពាហ៍" នោះ នឹងត្រូវបញ្ចូលនៅក្នុងសំណុំរឿងបន្ទាប់០០២-០២ ជា "អំពើអមនុស្សធម៌ផ្សេងៗ" ក្រោមបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[51]។ អាពាហ៍ពិពាហ៍ដោយបង្ខំមានចំនួនដើមបណ្តឹងរដ្ឋប្បវេណីច្រើនបំផុតទី២ ក្នុងសំណុំរឿង០០២ បន្ទាប់ពីសំណុំរឿងផ្លាស់ប្តូរទីកន្លែងរស់នៅដោយបង្ខំ។ ថ្មីៗនេះ ព្រះរាជអាជ្ញាបានស្នើឲ្យមានការស៊ើបអង្កេតទៅលើករណីអាពាហ៍ពិពាហ៍ដោយបង្ខំ ក៏ដូចជាការរំលោភនៅក្នុងនិងនៅក្រៅអាពាហ៍ពិពាហ៍ដោយបង្ខំសម្រាប់សំណុំរឿង ០០៤។ បញ្ហានេះ បង្ហាញពីការយល់ដឹងកាន់តែខ្លាំងឡើងចំពោះវិសាលភាពនៃអំពើហិង្សាផ្លូវភេទថាជាឧបករណ៍ប្រើប្រាស់ដោយរបបនោះដើម្បីដាក់ការត្រួតត្រា និងធ្វើឲ្យមានការភ័យខ្លាចដែលជាផ្នែកមួយនៃវិនាសកម្មជាទូទៅ[52]។

Toy-Cronin បានបង្ហាញពីរបៀបដែលអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងប្រទេសកម្ពុជាមានលក្ខណៈពិសេស ដោយហេតុថាជនរងគ្រោះមានទាំងបុរសនិងស្ត្រី បើទោះបីជា

---

50 កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជា ពាក់ព័ន្ធនឹងការកាត់ទោសតាមច្បាប់កម្ពុជាទៅលើឧក្រិដ្ឋកម្មដែលបង្កឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (កក្កដា ២០០៣, ផ្តល់សច្ចាប័ននៅថ្ងៃទី១៩ តុលា ២០០៤), ចូលយកឯកសារនៅថ្ងៃទី២៨ កក្កដា ២០១៤ http://www.eccc.gov.kh/english/cabinet/agreement/5/។ សម្រាប់សាវតាព័ត៌មានអំពី អ.វ.ត.ក សូមមើល John D.Ciorciari, ed., តុលាការខ្មែរក្រហម (ភ្នំពេញ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា, ២០០៦)។

51 ដីកាដំណោះស្រាយ សំណុំរឿង 002/19-9-2007-ECCC-OCIJ, កថាខណ្ឌ 843-44, 1430, 1441.

52 សេចក្តីប្រកាសព័ត៌មាន, "សហព្រះរាជអាជ្ញាអន្តរជាតិសំណូមពរឲ្យមានការស៊ើបអង្កេតអំពើហិង្សាយេនឌ័រនិងផ្លូវភេទក្នុងសំណុំរឿង០០៤" (ថ្ងៃ២៤ មេសា ២០១៤) ចូលមើលឯកសារនៅថ្ងៃទី២៥ មេសា ២០១៤ www.eccc.gov.kh/en/articles/internationalco-prosecutor-requests-investigation-alleged-sexual-and-gender-based-violence

គាត់បានកំណត់ឧក្រិដ្ឋកម្ម ក្រោមរបបខ្មែរក្រហមនេះ នៅក្នុងបរិបទនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ និងករណីដែលធ្លាប់កើតមានពីមុនជាពិសេសនៅក្នុងតុលាការពិសេសនៃប្រទេសសេរ៉ាឡអូន និងសាលាក្តីអន្តរជាតិប្រទេសរ៉វ៉ាន់ដាក៏ដោយ។ ដូចគ្នាដែរ N. Anderson បង្ហាញពីទស្សនៈខាងផ្លូវច្បាប់លើភស្តុតាងជាឯកសារដែលបានចងក្រងទាំងឡាយ ដែលមានរហូតមកដល់ឆ្នាំ២០១០ ពាក់ព័ន្ធនឹងការចោទប្រកាន់អាពាហ៍ពិពាហ៍ដោយបង្ខំនៅ អ.វ.ត.ក[53]។ N. Anderson បានលើកឡើងអំពីករណីនេះតាំងពីដើមមក (នៅមុនពេល អ.វ.ត.ក មិនទាន់ត្រូវបានបង្កើតឡើងនៅឡើយ) ថាហេតុអ្វីបានជាឧក្រិដ្ឋកម្មយេនឌ័រ គួរត្រូវបានបញ្ជាក់ឲ្យច្បាស់ និងសង្កត់ធ្ងន់នៅក្នុងការស៊ើបអង្កេតនិងការយកមកកាត់សេចក្តី[54]។ Natale ពិនិត្យមើលទៅលើឧក្រិដ្ឋកម្មផ្លូវភេទនិងឧក្រិដ្ឋកម្មយេនឌ័រ ដែល អ.វ.ត.ក មិនបានគ្របដណ្តប់ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះសម្រាប់សំណុំរឿង ០០២-០២ (ដូចជាការរំលោភនៅក្រៅអាពាហ៍ពិពាហ៍ដោយបង្ខំ[55]) ប៉ុន្តែ វាជាអ្វីដែលមានសារៈសំខាន់ក្នុងការយល់ដឹងឲ្យបានកាន់តែពេញលេញអំពីបរិបទនៃអំពើហិង្សាយេនឌ័រក្នុងរបបនោះ។ Braaf ពង្រីកការសិក្សាស្រាវជ្រាវដើម្បីបញ្ចូលអំពើហិង្សាផ្លូវភេទប្រឆាំងនឹងជនជាតិដើមភាគតិចក្នុងរបបខ្មែរក្រហម ដោយបានលើកសំអាងថា "មានភស្តុតាងបញ្ជាក់ពីការអនុវត្តលើការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំត្រូវបានប្រើដើម្បីប្រឆាំងនឹង ក្រុមជនជាតិដើមភាគតិច ក្នុងការលុបបំបាត់សហគមន៍នោះឲ្យទៅជាប្រជាជនខ្មែរទាំងអស់" ដែលការអនុវត្តបែបនេះត្រូវបានផ្តល់និយមន័យតាមអន្តរជាតិថាជាអំពើប្រល័យពូជសាសន៍[56]។

ក្រុមអ្នកស្រាវជ្រាវនិងអ្នកអនុវត្ត គឺជាអ្នករិះគន់យ៉ាងចាស់ដៃ អំពីរបៀបដែល អ.វ.ត.ក ចាត់ការចំពោះឧក្រិដ្ឋកម្មយេនឌ័រក្នុងភាពទូលំទូលាយខ្លាំង និងចាត់ទុកករណីអាពាហ៍ពិពាហ៍ដោយបង្ខំជាករណីដោយឡែក។ De Langis ពិនិត្យឡើងវិញទៅលើដំណើរការដែលតូចចង្អៀត និងពោរពេញដោយភាពស្ទាក់ស្ទើរនៅក្នុងការវិនិច្ឆ័យលើឧក្រិដ្ឋកម្មយេនឌ័ររួមទាំងអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុង អ.វ.ត.ក ផងដែរ ហើយគាត់ថែមទាំងបង្ហាញអំពីស្តង់ដាអន្តរជាតិដែលធានាអំពីសិទ្ធិក្រោមអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃរើសអើងប្រឆាំងនឹងស្ត្រី (CEDAW) និង សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខ អំពីស្ត្រី សន្តិភាព និងសន្តិសុខក្នុងពេលជម្លោះ និងក្នុងពេលស្ថិតនៅក្រោមរបបដែលមានការជិះជាន់[57]។

---

53 Natalae Anderson, "អនុស្សារណៈ ស្តីពី៖ ការចោទប្រកាន់ការរៀបការដោយបង្ខំជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" មជ្ឈមណ្ឌលឯកសារកម្ពុជា, ថ្ងៃទី២២ កញ្ញា ២០១០, ចូលមើលឯកសារនៅថ្ងៃទី២៧ កក្កដា ២០១៤ http://www.d.dccam.org/Abouts/Intern/Natalae_Forced_marriage.pdf.

54 Katrina Anderson, "ការប្រើប្រាស់ការផ្សះផ្សាមិនត្រឹមត្រូវ៖ ការឆ្លើយតបចំពោះអំពើហិង្សាផ្លូវភេទក្រោមរបបខ្មែរក្រហម" ទស្សនាវដ្តីយុត្តិធម៌សង្គម Seattle 3:2 (2005): 785-832.

55 Natale, "'ខ្ញុំអាចមានអារម្មណ៍ថាព្រលឹងខ្ញុំកំពុងហោះ"

56 Braaf, "អំពើហិង្សាផ្លូវភេទទៅលើនិគមជនភាគតិច" x.

57 Theresa de Langis, "ឱកាសដែលបាត់បង់មួយ, ក្តីសង្ឃឹមចុងក្រោយ? ការកាត់ទោសឧក្រិដ្ឋកម្មផ្លូវភេទក្រោមរបបខ្មែរ

Studzinsky ដែលបំពេញការងារជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណីនៅ អ.វ.ត.ក សម្រាប់រយៈមួយនោះបានរិះគន់ទៅលើការប្រើពាក្យ "បទបញ្ញារៀបអាពាហ៍ពិពាហ៍" នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង០០២ ជាជាងការប្រើពាក្យ "អាពាហ៍ពិពាហ៍ដោយបង្ខំ" ដោយបានលើកជាទឡ្ហីករណ៍ថាពាក្យបែបហ្នឹងធ្វើឲ្យថយភាពធ្ងន់ធ្ងរចំពោះ "ឧក្រិដ្ឋកម្មទ្រង់ទ្រាយធំ និងជាប្រព័ន្ធប្រឆាំងនឹងប្រជាជនស៊ីវិល"។ គាត់បន្តលើកឡើងថា ចំណាត់ថ្នាក់តាមផ្លូវច្បាប់ចំពោះអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភនៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំថាជា "អំពើអមនុស្សធម៌ផ្សេងទៀត" ក្រោមឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិគឺ "មិនទាន់គ្រាប់គ្រាន់" និង "មិនបានពិចារណាឲ្យគ្រប់ជ្រុងជ្រោយអំពីផលវិបាកនៃការមានផ្ទៃពោះ និងភាពជាទាសករផ្លូវភេទ" ទេ[58]។

បញ្ហានេះ មិនមែនគ្រាន់តែជាការពិចារណាផ្លូវច្បាប់សាមញ្ញនោះទេ តែថែមទាំងមានការពាក់ព័ន្ធដល់សិទ្ធិ មនុស្ស សន្តិភាព និងសន្តិសុខ និងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍នៅក្នុងប្រទេសកម្ពុជាផងដែរ។ នៅក្នុងរបាយការណ៍ប្រចាំឆ្នាំចាប់ពីឆ្នាំ២០១១មក ការិយាល័យតំណាងពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកលើអំពើហិង្សាលើផ្លូវភេទនៅក្នុងពេលមានជម្លោះបានជម្រុញឲ្យតុលាការប្រើប្រាស់នូវរាល់ធនធានទាំងអស់ដើម្បីលាតត្រដាងពីឧក្រិដ្ឋកម្មផ្លូវភេទ រួមមានទាំងការស៊ើបអង្កេត និងការពង្រីកវិសាលភាពដែលអាចធ្វើការកាត់ទោសបាន ក៏ដូចជាការផ្តល់នូវការទទួលស្គាល់ឲ្យបានគ្រប់គ្រាន់ និងសំណងខូចខាតដល់ជនរងគ្រោះ[59]។លើសពីនេះនៅក្នុងការអង្កេតសន្និដ្ឋានលើរបាយការណ៍បោះពុម្ពលើកទី៤ និងទី៥ របស់កម្ពុជានៅក្នុងឆ្នាំ២០១៣ គណៈកម្មការនៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី (CEDAW) អំពាវនាវឲ្យរាជរដ្ឋាភិបាលកម្ពុជារៀបចំបង្កើត ផែនការសម្មភាពថ្នាក់ជាតិសម្រាប់ស្ត្រី សន្តិភាព និងសន្តិសុខស្របជាមួយនឹងសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិលេខ ១៣២៥ និងសេចក្តីសម្រេចភ្ជាប់ជាមួយ

---

ក្រហម" ទស្សនាវដ្តីច្បាប់និងគោលនយោបាយកម្ពុជា ២ (២០១៤)៖ ទំ.៣៩-៤៣។ សូមមើលអត្ថបទដោយអ្នកនិពន្ធដដែល អំពី "លទ្ធផលនៃការសិក្សាអង្កេតបឋមទៅលើ អ.វ.ត.ក អំពីវិញ្ញាចយេនឌ័រក្នុងដំណើរការយុត្តិធម៌អន្តរកាលក្នុងប្រទេសកម្ពុជា" (ភ្នំពេញ៖ អង្គការស៊ីឌីភី, ២០១១), ចូលមើលឯកសារនៃថ្ងៃទី២៨ កក្កដា ២០១៤ http://gbvkr.org/wp-content/uploads/2013/01/Results-of-the-ECCC-Baseline-on-Gender-Sensitivity-in-Transitional-Justice-Processes-in-Cambodia-20121.pdf

[58] Silke Studzinsky, "ខ្វាក់ភ្នែកម្ខាង? តើ អ.វ.ត.ក ជាគម្រូសម្រាប់ការស៊ើបអង្កេតនិងការដំណើរការទៅលើឧក្រិដ្ឋកម្មអំពើហិង្សាផ្លូវភេទឬ? វិទ្យាស្ថាន Gerda Werner៖ ស្ត្រីនិយមនិងប្រជាធិបតេយ្យ (២០១២), ចូលមើលឯកសារនៃថ្ងៃទី២៨ កក្កដា ២០១៤ http://www.gwi-boell.de/en/2012/04/16/blind-one-eye-icc-model-how-sexual-crimes-should-be-investigated-and-treated

[59] របាយការណ៍របស់អគ្គលេខាធិការស្តីពីអំពើហិង្សាផ្លូវភេទពាក់ព័ន្ធនឹងជម្លោះ, ឯកសារអង្គការសហប្រជាជាតិS/2014/181 (Mar. 13, 2014): "ចាប់តាំងពីចេញរបាយការណ៍របស់ខ្ញុំស្តីពីអំពើហិង្សាផ្លូវភេទនៅពេលមានជម្លោះមក មិនមានប្រព័ន្ធណាមួយរបស់រដ្ឋាភិបាល ចាត់វិធានការក្នុងការឆ្លើយតបចំពោះអនុសាសន៍របស់ខ្ញុំក្នុងការចាត់ការទៅលើការកាត់ទោសជនដៃដល់ឲ្យមានប្រសិទ្ធភាពនៅឡើយទេ"។

នោះ។ គណៈកម្មការថែមទាំងផ្តល់ជាអនុសាសន៍ចំពោះការផ្តល់សំណងដ៏មានប្រសិទ្ធភាពដល់ជនរងគ្រោះ។ សំណង រួមមានការជួសជុលការខូចខាតគ្រប់គ្រាន់ និងការបញ្ចូលបញ្ហាទាំងនេះទៅក្នុងគោលនយោបាយនិងយុទ្ធសាស្ត្រជាតិ ក្នុងគោលបំណងដោះស្រាយអំពើហិង្សាប្រឆាំងនឹងស្ត្រី និងវិសមភាពយេនឌ័រនាពេលបច្ចុប្បន្ន[60]។ អស់រយៈពេលច្រើនជាង ៣០ឆ្នាំចាប់តាំងពីការដួលរលំនៃរបបនេះ និងផលវិបាកដែលមិនងាយនឹងសាបរលាបបាត់នៃអាពាហ៍ពិពាហ៍ដោយបង្ខំលើតួនាទីនិងសុខមាលភាពរបស់បុរសនិងស្ត្រីជាច្រើននោះ សំណងសម្រាប់ឧក្រិដ្ឋកម្មនៃអាពាហ៍ពិពាហ៍ដោយបង្ខំត្រូវដាក់បញ្ចូលនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក ជា "សំណងសមូហភាពនិងនិមិត្តរូប"។ សំណងអាចធ្វើឡើងក្នុងទម្រង់ជាគម្រោងក្រៅផ្លូវច្បាប់ដើម្បីដោះស្រាយតម្រូវការសម្រាប់ប្រជាជនដែលមានអាយុកាន់តែជរា និងដែលមិនបានយកចិត្តទុកដាក់ជាយូរមកហើយ តាមរយៈការពិចារណាទាក់ទងនឹងបញ្ហា សន្តិភាព យុត្តិធម៌ និងការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពនៅក្នុងប្រទេសកម្ពុជា។

---

[60] សេចក្តីសង្កេតសន្និដ្ឋានស្តីពីរបាយការណ៍តាមកាលកំណត់លើកទី៤និងទី៥សម្រាប់ប្រទេសកម្ពុជា, គណៈកម្មាធិការស៊ីដសម័យប្រជុំ៥៦, ឯកសារអង្គការសហប្រជាជាតិ CEDAW/C/KHM/CO/4-5 at 3-4 (2013).

៣

# វិធីសាស្ត្រ

## ៣.១ គោលបំណងនៃការសិក្សាស្រាវជ្រាវ

គោលបំណងសំខាន់នៃការសិក្សាស្រាវជ្រាវនេះគឺ ដើម្បីឲ្យយល់កាន់តែច្បាស់អំពីបទពិសោធន៍ និងផលប៉ះពាល់នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្រោមរបបខ្មែរក្រហមរហូតមកដល់បច្ចុប្បន្ន តាមរយៈទិដ្ឋភាព ការឆ្លើយតបយេនឌ័រ និងការដឹងអំពីការប៉ះទង្គិចផ្លូវចិត្ត។

## ៣.២ រចនាបទនៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ មានអ្នកចូលរួមឆ្លើយសំណួរចំនួន ១០៦នាក់ ដែលពួកគាត់ជាភាគីដើមបណ្តឹងរដ្ឋប្បវេណីក្នុងករណី០០២ នៃ អ.វ.ត.ក។ ការសិក្សាស្រាវជ្រាវនេះបានប្រើវិធីសាស្ត្ររួមសម្រាប់ការប្រមូលទន្និន័យនិងការវិភាគ ដោយរួមបញ្ចូលនូវការស្ទង់មតិលក្ខណៈស្តង់ដារបែបបរិមាណវិស័យដែលមានកំរងសំនួរចំនួន ៩៣ (ជាមួយឪកាសឆ្លើយបែបគុណវិស័យបន្តិចបន្តួច)រួមជាមួយនឹងការធ្វើបទសម្ភាសបែបគុណវិស័យលើករណីសិក្សាចំនួន៨។ ការប្រមូលទន្និន័យបែបបរិមាណវិស័យ មានបំណងកំណត់អំពី ភាពរាលដាលគំរូនិងប្រភេទនានានៃអ្នកផ្តល់សម្ភាសន៍ ("តើមានចំនួនប៉ុន្មាន" និង "មានទំហំប៉ុណ្ណា") រីឯការប្រមូលទិន្នន័យបែបគុណវិស័យ មានបំណងពិពណ៌នាអំពី ការលើកឧទាហរណ៍ និងទស្សនៈជាក់លាក់ ស៊ីជម្រៅ នៅក្នុងបរិបទប្រវត្តិសាស្ត្រសង្គមដែលមានកន្លងមក("ដោយរបៀបណា" "ហេតុអ្វី" និង "អ្វីបានកើតឡើងបន្ទាប់" )។

មូលហេតុដែលប្រើវិធីសាស្ត្ររួមក្នុងការស្រាវជ្រាវ គឺមានបំណង ដើម្បីចងក្រងជារូបភាពទូលំទូលាយមួយអំពីផលវិបាកផ្សេងៗ នៃគោលនយោបាយអាពាហ៍ពិពាហ៍ដោយបង្ខំរបស់ខ្មែរក្រហម នៅក្នុងបរិបទសង្គមកម្ពុជា។ ប្រការនេះ រួមបញ្ចូលទាំងឥទ្ធិពលនៃតួនាទីយេនឌ័រ និងការអនុវត្តតាមវប្បធម៌ លើការជម្រុញទឹកចិត្តបុគ្គល ការសម្រេចចិត្ត និងការបង្កើតអត្ថន័យនៅក្នុងជីវិត។ លើសពីនេះ វិធីសាស្ត្ររួមអាចអនុញ្ញាតឲ្យមានការលេចឡើងនូវចម្លើយដោយមិនមានការគ្រោងទុកជាមុន ដូច្នេះនឹងផ្តល់នូវគំនិតយល់ឃើញទូលំទូលាយជាងអ្វីដែលប្រើនៅក្នុងវិធីសាស្ត្រតែមួយបែបការស្ទង់មតិស្តង់ដារ និងនាំឲ្យមានការយល់ដឹងកាន់តែជ្រៅជ្រះពីភ្នាក់ងារតាមដានបុគ្គលនៅក្នុងប្រព័ន្ធទាំងស្រុង។ ជាចុងក្រោយ រចនាបទនៃការសិក្សាស្រាវជ្រាវតាមវិធីសាស្ត្ររួមនេះ បាននាំមកនូវសារៈសំខាន់ច្បាស់ទៅលើពហុវិសាលភាពនៃផលប៉ះពាល់នានាក្នុងទម្រង់ពាក់ព័ន្ធនឹងច្បាប់ ចិត្តសាស្ត្រ វប្បធម៌ និងសង្គម ដែលជាការរួមចំណែកឲ្យទទួលបាននូវ "ស្ថានភាពរូបភាពពេញលេញមួយ" នូវអ្វីដែលរហូតមកដល់ពេលបច្ចុប្បន្ននេះ នៅស្ថិតក្រោមការវិភាគស្រាវជ្រាវ និងនៅមានការយល់ដឹងតិចតួចនៅឡើយ។

ឯកសារសិក្សាស្រាវជ្រាវនេះ បានប្រើប្រាស់ការជ្រើសរើសសំណាកតាមបំណងពីក្នុងចំណោមក្រុមដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២ ដែលទទួលបទពិសោធន៍ដោយផ្ទាល់ពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងរបបខ្មែរក្រហម។ ភាគច្រើនក្នុងសំណាកនេះគឺជាអតិថិជនរបស់អង្គការធីភីអូ និងអង្គការស៊ីឌីភី ដែលជាផ្នែកមួយនៃគម្រោងរួមគ្នា[61]។ ក្នុងចំណោមអតិថិជនសរុប ៦៤នាក់ពីអង្គការធីភីអូ និងជនរងគ្រោះផ្ទាល់ពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនោះ មាន៥៩នាក់ត្រូវបានជ្រើសរើសឲ្យចូលរួមនៅក្នុងការស្ទង់មតិនេះ។ ក្នុងចំណោមអតិថិជនសរុប ៣២នាក់មកពីអង្គការស៊ីឌីភី និងជនរងគ្រោះដោយផ្ទាល់ពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ មាន៣០នាក់ត្រូវជ្រើសរើសឲ្យចូលរួមក្នុងការសិក្សានេះ។ លើសពីនេះ ភាគីដើមបណ្តឹងរដ្ឋប្បវេណី១៧នាក់ ដែលជាអ្នករងគ្រោះដោយផ្ទាល់ពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ប៉ុន្តែមិនមែនជាអ្នកទទួលផលពីគម្រោង ត្រូវបានស្នើសុំឲ្យចូលរួមផងដែរ។ អ្នកចូលរួមទាំងអស់ ត្រូវជ្រើសរើសដោយផ្អែកលើលក្ខខណៈវិនិច្ឆ័យដូចខាងក្រោម។

ភាគីដើមបណ្តឹងរដ្ឋប្បវេណីសរុប១០៦នាក់នៅក្នុងសំណាកនេះ ត្រូវបានសុំឲ្យបំពេញកម្រងសំណួរលក្ខណៈស្តង់ដារ ដែលគ្រប់គ្រងដោយអ្នកសម្ភាសន៍មានបទពិសោធន៍ និងបុគ្គលិករបស់មជ្ឈមណ្ឌលស្រាវជ្រាវជាន់ខ្ពស់ (CAS)។ ក្នុងចំណោមអ្នកផ្តល់សម្ភាសន៍ទាំង១០៦នាក់នេះ មាន៩នាក់ត្រូវបានជ្រើសរើសសម្រាប់ការធ្វើបទសម្ភាសន៍បែបគុណវិស័យលើករណីសិក្សាចំនួន ៨ ដោយក្នុងនោះមានការសម្ភាសន៍ដែលចូលរួមទាំងប្តីនិងប្រពន្ធ។ ដើម្បីកាត់បន្ថយ "ឋានៈអ្នកជនបរទេស" ក្នុងពេលសម្ភាសន៍នោះ រាល់បទសម្ភាសន៍ទាំងអស់ត្រូវធ្វើឡើងជាភាសាខ្មែរ ដោយអ្នកស្រាវជ្រាវជនជាតិខ្មែរ និងមានអ្នកស្រាវជ្រាវបរទេសជាអ្នកផ្តល់ការគាំទ្របច្ចេកទេស ក្នុងការបង្កើតឧបករណ៍សិក្សាស្រាវជ្រាវ និងការវិភាគពីលទ្ធផលនៃការសិក្សានេះ។ លទ្ធផលនៃការស្ទង់មតិ និងបទសម្ភាសលើករណីសិក្សាត្រូវបានបកប្រែពីភាសាខ្មែរទៅជាភាសាអង់គ្លេសសម្រាប់ការវិភាគ។ អ្នកផ្តល់ប្រឹក្សាអន្តរជាតិមួយរូប និងជាផ្នែកមួយនៃក្រុមស្រាវជាវ មានភារកិច្ចក្នុងការសរសេររបាយការណ៍នេះ ដោយពឹងផ្អែកទៅលើរបកគំហើញនៃការសិក្សានេះ។

បទសម្ភាសន៍លើករណីសិក្សាត្រូវបង្ហាញក្នុងទម្រង់សំយោគដើម្បីលុបបំបាត់នូវភាពច្រំដែល និងរំលេចពីភាពស្របគ្នាសំខាន់ៗទៅតាមប្រធានបទ។ កន្លែងដែលពាក់ព័ន្ធ និងអាចទៅរួច ត្រូវប្រើពាក្យសម្តីនៅក្នុងការដកស្រង់នៅក្នុងរបាយការណ៍ ដើម្បីជាការផ្តល់កិត្តិយសក្នុងការរួមចំណែករបស់អ្នកដែលបានចែករំលែករឿងរ៉ាវរបស់ពួកគាត់ផ្ទាល់ ដើម្បីជាប្រយោជន៍ឲ្យកាន់តែយល់ច្បាស់អំពីបទពិសោធន៍នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនោះ។

[61] សម្រាប់ព័ត៌មានបន្ថែមអំពីគម្រោងនេះ សូមមើល http://gbvkr.org/

ដើម្បីបញ្ចូលសំណាកដែលមានភាពជាតំណាង លក្ខណៈវិនិច្ឆ័យសម្រាប់ការជ្រើសរើសនៃអ្នកចូលរួមទាំង១០៦នាក់ មានដូចខាងក្រោម៖

ក. មនុស្សដែលត្រូវបានខ្មែរក្រហមបង្ខំឲ្យរៀបអាពាហ៍ពិពាហ៍
ខ. មនុស្សដែលរៀបអាពាហ៍ពិពាហ៍រួចហើយមុនសម័យខ្មែរក្រហម ប៉ុន្តែត្រូវបង្ខំឲ្យរៀបអាពាហ៍ពិពាហ៍ម្តងទៀតនៅក្នុងរបបខ្មែរក្រហម
គ. គូស្រករដែលរស់នៅជាមួយគ្នា ឬបែកបាក់គ្នាបន្ទាប់ពីការរំដោះចេញពីសម័យខ្មែរក្រហម :
 ១. មានកូន, គ្មានកូន
 ២. ប្រសិនបើបែកបាក់គ្នា បានរៀបអាពាហ៍ពិពាហ៍ម្តងទៀត ឬមិនបានរៀបអាពាហ៍ពិពាហ៍ម្តងទៀត
 ៣. ស្វាមីនៅបែកគ្នា បាត់ខ្លួន ត្រូវបានសម្លាប់ ឬស្លាប់ដោយសារមូលហេតុផ្សេងៗ
ឃ. មនុស្សដែលបានបដិសេធចំពោះការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ :
 ១. ដោយទទួលរងការសងសឹក (ការដាក់ទណ្ឌកម្ម ការដាក់គុក រំលោភ ជាដើម)
 ២. មិនមានការសងសឹក

លក្ខណៈវិនិច្ឆ័យសម្រាប់ការជ្រើសរើសអ្នកផ្តល់សម្ភាសន៍គុណវិស័យ លើករណីសិក្សាទាំង៨មានដូចខាងក្រោម៖

ក. បុរស ស្ត្រី ឬ ប្តីប្រពន្ធ
ខ. ករណី "សាមញ្ញ" ឬ "ធម្មតា"
គ. ករណីពិសេស ករណីដែលប្លែក ឬខុសពីធម្មតា
 ១. ករណីជ្រុលនិយម៖ ឧទាហរណ៍នៃករណីដែលមានបុគ្គលិកលក្ខណៈជ្រុលនិយម ឬមិនមែនជាករណីសាមញ្ញធម្មតា
 ២. "ក្រុមដែលនៅសល់"៖ បទពិសោធន៍ប្លែកៗនៃក្រុមផ្សេងគ្នា (យោងលើពូជសាសន៍ សាសនា ទីតាំងភូមិសាស្ត្រ ភេទ អាយុ ស្ថានភាពអាពាហ៍ពិពាហ៍ពីមុន/បច្ចុប្បន្ន ជាដើម)

ការសិក្សាស្រាវជ្រាវបានប្រើនូវការអនុវត្តតាមក្រមសីលធម៌យ៉ាងល្អបំផុតដែលផ្តោតទៅលើវិធីសាស្ត្រ យល់ដឹងអំពីការប៉ះទង្គិចផ្លូវចិត្តនៅក្នុងការសិក្សាស្រាវជ្រាវមនុស្សដែលនៅរស់ពីអំពើហិង្សាផ្លូវភេទ និងយេនឌ័រ។

អ្នកសម្ភាសន៍លើករណីសិក្សាត្រូវបានបណ្តុះបណ្តាលតាម ការណែនាំរបស់អង្គការសុខភាពពិភពលោក សម្រាប់ការស្រាវជ្រាវពីអំពើហិង្សាផ្លូវភេទ និងយេនឌ័រដែលជាមធ្យោបាយបន្ធូរបន្ថយនូវការប៉ះទង្គិចឡើងវិញ នៅពេលសាកសួរ ប្រធានបទដែលប៉ះពាល់អារម្មណ៍ខ្លាំង។ អ្នកធ្វើបទសម្ភាសន៍សម្រាប់កម្រងសំណួរស្ទង់មតិបែបបរិមាណវិស័យ ត្រូវបានបណ្តុះបណ្តាល និងត្រួតពិនិត្យមើលដោយបុគ្គលិកអង្គការធីភីអូ និងអ្នកចិត្តវិទូអន្តរជាតិមួយរូប។ ទិន្នន័យនេះ បានប្រមូលនៅចន្លោះខែកុម្ភៈ និងខែមេសាឆ្នាំ២០១៤។ អ្នកផ្តល់សម្ភាសន៍ ១០០នាក់សម្រាប់ការស្ទង់មតិ និង៧នាក់សម្រាប់ករណីសិក្សាដែលត្រូវបានសម្ភាសន៍នៅការិយាល័យអង្គការធីភីអូ នៅក្នុងទីក្រុងភ្នំពេញ ហេតុនេះពួកគាត់អាចទទួលបានការគាំទ្រផ្នែកចិត្តសាស្ត្រតាមរយៈអ្នកផ្តល់សេវាដែលអាចទុកចិត្តបាន។ មួយវិញទៀតបទសម្ភាសន៍ស្ទង់មតិចំនួន ៦ និងការសម្ភាសន៍លើករណីសិក្សាចំនួន២ ត្រូវបានធ្វើឡើងនៅក្នុងខេត្តកំពតក្នុងអំឡុងពេលការទស្សនៈកិច្ចទៀងទាត់ដោយអង្គការធីភីអូ នៅក្នុងដំណាក់កាលអនុវត្តកម្មវិធីដែលផ្តោតទៅលើអ្នកដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហម។ អ្នកផ្តល់សម្ភាសន៍ទាំងអស់ទទួលបានលេខទូរស័ព្ទរបស់អង្គការធីភីអូ ក្រែងលោពួកគេត្រូវការការគាំទ្រផ្នែកចិត្តសាស្ត្រ។ ការយល់ព្រមជាមុនត្រូវបានផ្តល់នៅក្នុងគ្រប់ករណី ដោយមានការរក្សាការសម្ងាត់យ៉ាងត្រឹមត្រូវ។ ចុងបញ្ចប់ មានតែឈ្មោះជាអក្សរកាត់ខាងដើមប៉ុណ្ណោះ ដែលត្រូវប្រើដើម្បីកំណត់អត្តសញ្ញាណអ្នកផ្តល់សម្ភាសន៍នៅក្នុងករណីសិក្សាទាំងនោះ ហើយឈ្មោះបុគ្គលដែលត្រូវចោទប្រកាន់នៅក្នុងបទសម្ភាសន៍ត្រូវបានលុបចោល។ ការបញ្ចូលទិន្នន័យ និងការវិភាគត្រូវធ្វើឡើងដោយប្រើកម្មវិធី SPSS version 16.0 ។

## ៣.៣ ព្រំដែននៃការសិក្សាស្រាវជ្រាវ

ដោយសារអ្នកផ្តល់សម្ភាសន៍ទាំងអស់ គឺជាដើមបណ្តឹងរដ្ឋប្បវេណីនៅ អ.វ.ត.ក នោះលទ្ធផលមានភាពលម្អៀងទៅរកអ្នកដែលបានលាតត្រដាងអំពីបទពិសោធន៍របស់ពួកគេចំពោះការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងអំឡុងពេលដំណើរការនៃការដាក់ពាក្យជា ភាគីដើមបណ្តឹងរដ្ឋប្បវេណីនៅ អ.វ.ត.ក ដែលពួកគាត់ភាគច្រើនចាត់ទុកថាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំជាបទឧក្រិដ្ឋ។ ការសិក្សាស្រាវជ្រាវនេះមិនបានព្យាយាមកំណត់ពីភាពរាលដាលនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំឡើយ ដោយសារវាត្រូវអនុវត្តត្រឹមតែសំណាកតូចមួយប៉ុណ្ណោះ ហើយមិនមានន័យថាការរកឃើញទាំងនេះ អាចយកមកធ្វើការសន្និដ្ឋានជាទូទៅចំពោះប្រជាជនទាំងអស់ដែរ។ ការស្រាវជ្រាវនេះ មិនបានព្យាយាមបង្ហាញពីភាពត្រឹមត្រូវនៃភាពខុសប្លែកគ្នាស៊ីជម្រៅនៅក្នុងការអនុវត្តការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងរបបនោះពាក់ព័ន្ធនឹងអត្តសញ្ញាណក្រុមជនជាតិដើម សាសនា និងតំបន់ ឬភាពខុសប្លែកគ្នារវាងប្រជាជន "ថ្មី" និងប្រជាជន "ចាស់" ទេ។

សំណាកក្នុងការស្រាវជ្រាវនេះ គឺមិនមានតុល្យភាពទៅលើសមាមាត្រនៃអ្នកផ្ដល់សម្ភាសន៍ជាស្ត្រីនិងបុរសទេ ដោយសារតែមានសំណាកស្ត្រីច្រើនជាងបុរស។ នេះដោយសារតែផ្អែក តាមចំនួនអតិថិជននៃអង្គការធីភីអូ និងស៊ីឌីភីដែលបានយកចិត្តទុកដាក់លើការខិតខំប្រឹងប្រែងជួយខ្លួនឯង និងការគាំទ្រដទៃទៀតចំពោះស្ត្រីរងគ្រោះដោយសារអំពើហិង្សាយេនឌ័រក្នុងសម័យខ្មែរក្រហម។ត្រូវតែមានការសិក្សាស្រាវជ្រាវបន្ថែមទៅលើចម្លើយរបស់បុរសចំពោះអាពាហ៍ពិពាហ៍ដោយបង្ខំ រួមមានទាំងការរំលោភដោយបង្ខំ និងផលវិបាកទៅលើអត្តសញ្ញាណភេទប្រុសនិងតួនាទីក្នុងសង្គមផងដែរ។

អ្នកចូលរួមឆ្លើយសំណួរភាគច្រើនគឺជាអតិថិជនរបស់អង្គការធីភីអូ និងអង្គការស៊ីឌីភី នៅក្នុងគម្រោងរួមមួយដែលលើកឡើងអំពីបញ្ហាអំពើហិង្សាយេនឌ័រនៅក្នុងរបបខ្មែរក្រហម។ ដូចនេះ អ្នកចូលរួមប្រហែលជាកាន់តែយល់ និងមានចំណេះដឹងពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ជាងអ្នករងគ្រោះផ្ទាល់ដោយការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំដទៃទៀត។ ម្យ៉ាងវិញទៀត អ្នកចូលរួមប្រហែលជាមានអារម្មណ៍ស្រួលឆ្លើយទៅនឹងសំណួរ ដោយសារពួកគេបានបង្កើតទំនាក់ទំនងជឿជាក់ជាមួយនឹងបុគ្គលិកអង្គការធីភីអូរួចហើយ។ ជាលទ្ធផលការរកឃើញពីការសិក្សានេះ មិនអាចយកមកសន្និដ្ឋានជាទូទៅ ចំពោះជនរងគ្រោះដោយផ្ទាល់ដោយសារការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំបានឡើយ។

តាមនិយមន័យ ការបកប្រែតែងមានដែនកំណត់ក្នុងការយល់ និងការឆ្លើយឆ្លងចំពោះអត្ថន័យដែលជាបញ្ញត្តិមួយចំនួន។ ការបកប្រែត្រូវបានផ្ទៀងផ្ទាត់ និងបញ្ញត្តិនានាត្រូវយកមកពិភាក្សាតាមភាពចាំបាច់ ក៏ដូចជាត្រូវប្រៀបធៀបនឹងការសិក្សាស្រាវជ្រាវដែលធ្លាប់បានបោះពុម្ពរួចកន្លងមក។ ការស្រាវជ្រាវស្នូល និងក្រុមវិភាគគឺមានលក្ខណៈចម្រុះវប្បធម៌ រួមមានជនជាតិអាមេរិចកាំងម្នាក់ អាល្លឺម៉ង់ម្នាក់ និងខ្មែរ ២នាក់ ទាំងអស់ជាស្ត្រី។ អ្នកធ្វើបទសម្ភាសន៍របស់មជ្ឈមណ្ឌលសិក្សាជាន់ខ្ពស់ មានទាំងបុរស និងស្ត្រីសម្រាប់បទសម្ភាសន៍ស្ទង់មតិ ហើយបុគ្គលិកជាស្ត្រីនៅអង្គការធីភីអូដែលបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវជាអ្នកធ្វើការក្នុងករណីសិក្សា។ ភាពខុសប្លែកគ្នាទៅលើអត្តសញ្ញាណ និងយេនឌ័រនេះ ជាការផ្តល់ព័ត៌មានសម្រាប់ការវិភាគ និងការបកស្រាយពីលទ្ធផល ដោយមិនអាចចៀសផុតឡើយ។

៤

# លទ្ធផល

# ៤.១ លទ្ធផលបានមកពីការស្ទង់មតិ (បរិមាណវិស័យ)

## ក. លក្ខណៈប្រជាសាស្ត្ររបស់អ្នកផ្តល់សម្ភាស

អ្នកផ្តល់សម្ភាសទាំង១០៦ នាក់បានរាយការណ៍ថា ពួកគាត់ត្រូវបានគេស្នើឲ្យរៀបការក្នុងរបបប្រល័យពូជ សាសន៍ខ្មែរក្រហម ដែលក្នុងនោះមានអ្នកផ្តល់សម្ភាសចំនួន ១០៣ នាក់ (៩៧.២%) បានរាយការណ៍ថា នៅទីបំផុត ពួកគាត់បានរៀបការ។ អ្នកផ្តល់សម្ភាសទាំងអស់សុទ្ធតែជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២ នៅ អ.វ.ត.ក។

អាយុជាមធ្យមរបស់អ្នកផ្តល់សម្ភាសគឺ ៥៨ ឆ្នាំ ដែលក្មេងបំផុតគឺ ៤៧ ឆ្នាំ និង ចាស់បំផុត គឺ ៧១ឆ្នាំ។ ពួកគាត់ភាគច្រើនកំណត់ខ្លួនជាជនជាតិខ្មែរ (៩៣.៤%) ហើយអ្នកដែលនៅសល់ ជាចាមឬខ្មែរអ៊ីស្លាម។ ក្នុងចំណោមអ្នកផ្តល់សម្ភាសទាំង ១០៦នាក់ ស្ត្រីមាន ៨៨ នាក់ បុរសមាន ១៨នាក់។ ភាគច្រើន រៀបការរួច (៦២.៣%) ប៉ុន្តែជិត មួយភាគបី និយាយថា ពោះម៉ាយ ឬ មេម៉ាយ។

តារាងទី១ លក្ខណៈប្រជាសាស្ត្ររបស់អ្នកផ្តល់សម្ភាស

| ទំហំនៃគម្រូ | ស្ត្រី (%) | មធ្យមភាគអាយុ | ក្រុមអាយុ (%) | | |
|---|---|---|---|---|---|
| **106** | **83.0** | **58** | **45-55** | **56-65** | **>65** |
| | | | 28% | 64% | 8% |

| ជនជាតិ | |
|---|---|
| ខ្មែរ | អ៊ីស្លាម |
| 93.4% | 6.6% |

| ស្ថានភាពគ្រួសារ (%) | | | |
|---|---|---|---|
| រៀបការ | លែងលះ | ចែកផ្លូវ | ពោះម៉ាយ/មេម៉ាយ |
| 62.3% | 2.8% | 3.8% | 31.1% |

## ខ. អាពាហ៍ពិពាហ៍មុនរបបប្រល័យពូជសាសន៍ខ្មែរក្រហម (គឺ មុនថ្ងៃទី ១៧ មេសា ១៩៧៥)

អ្នកផ្តល់សម្ភាស មកពីខេត្តចំនួន១៤ មុនពេលខ្មែរក្រហមចូលកាន់កាប់។

តារាងទី២ ខេត្តដែលអ្នកផ្តល់សម្ភាសរស់នៅមុនខ្មែរក្រហមកាន់កាប់




ច្រើនជាងពាក់កណ្តាលនៃអ្នកផ្តល់សម្ភាសប្រកបមុខរបរជាកសិករ (៥៨.៧%) ហើយអ្នកដទៃទៀតថា "មានមុខរបរដទៃទៀត" មុនខែមេសា ឆ្នាំ១៩៧៥ ដូចជា ធ្វើការនៅស្រែអំបិល ធ្វើស្រែ ហាលត្រី ត្បាញ ធ្វើការងារផ្ទះ និង ខ្លះទៀតបួសជាព្រះសង្ឃ។

តួលេខទី១៖ មុខរបររបស់អ្នកផ្តល់សម្ភាសមុនរបបប្រល័យពូជសាសន៍
(% នៃអ្នកផ្តល់សម្ភាស)



ភាគច្រើននៃអ្នកផ្តល់សម្ភាស (៩១.៣%) គ្មានកូនមុនពេលរបបខ្មែរក្រហមចូលកាន់កាប់ទេ ក្នុងនោះមានអ្នកផ្តល់សម្ភាស ៨២ នាក់ (៧៨.៨%) បានរាយការណ៍ថាពួកគេនៅលីវ នៅពេលដែលខ្មែរក្រហមចូលកាន់កាប់បានសម្រេច។ ក្នុងចំណោមអ្នកផ្តល់សម្ភាស ៦ នាក់ ដែលរាយការណ៍ថាមានកូនមុនរបបខ្មែរក្រហម ភាគច្រើន (៦៦.៧%) បានរាយការណ៍ថាមានកូនពីរនាក់ ។

តារាងទី៣ ស្ថានភាពគ្រួសាររបស់អ្នកផ្តល់សម្ភាសមុនរបបខ្មែរក្រហម

| ស្ថានភាពគ្រួសារ (%) | | | |
|---|---|---|---|
| នៅលីវ | រៀបការហើយ | ត្រូវបានគេស្ដីដណ្ដឹង សុំរៀបការ | លែងលះ / ចែកផ្លូវ |
| 80.8% | 9.6% | 7.7% | 1.9% |

*ស្ថានភាពគ្រួសាររបស់អ្នកផ្តល់សម្ភាស ១០៤ នាក់

ក្នុងចំណោមអ្នកផ្តល់សម្ភាស ១២ នាក់ដែលបានរៀបការមុនរបបខ្មែរក្រហមបានចូលកាន់កាប់មាន ១០ នាក់ (៨៣.៣%) រាយការណ៍ថាអាពាហ៍ពិពាហ៍របស់គាត់ជាការរៀបការដែលបានរៀបចំដោយចាស់ទុំ ហើយ មានតែ ២ នាក់ប៉ុណ្ណោះដែលបានរាយការណ៍ថា រៀបការដោយមិនមានការរៀបចំទុកដាក់ពីចាស់ទុំ។ ក្នុងចំណោមអ្នកដែលរៀបការដោយមានការរៀបចំ ៦៤.៧% ត្រូវបានរៀបចំទុកដាក់ដោយឪពុកម្តាយ និង ២៧.៣% រៀបចំដោយសាច់ញាតិ។

ក្នុងចំណោមអ្នកផ្តល់សម្ភាស១០នាក់ ដែលបានរៀបការតាមការរៀបចំដោយចាស់ទុំ ចំនួនច្រើនជាងពាក់កណ្ដាល (៦៣.៦%) បានរាយការណ៍ថាវាជាជម្រើសរបស់ខ្លួនឯងសម្រាប់ការរៀបចំនោះ ហើយអ្នកដទៃទៀតដែលរាយការណ៍ថាការរៀបការតាមការរៀបចំទុកដាក់នោះ មិនមែនជាជម្រើសរបស់គាត់នោះ ពួកគេយល់ថាមូលហេតុគឺដោយសារតែសម្ពាធគ្រួសារ។

តារាងទី៤ ជម្រើសរបស់អ្នកផ្តល់សម្ភាសក្នុងការរៀបការដែលរៀបចំដោយចាស់ទុំមុនរបបខ្មែរក្រហម

| ជម្រើសក្នុងការរៀបការ (%) | |
|---|---|
| ជាជម្រើសរបស់អ្នកផ្តល់សម្ភាស | មិនមែនជាជម្រើសរបស់អ្នកផ្តល់សម្ភាស |
| 63.6% | 36.4% |

អ្នកផ្តល់សម្ភាសភាគច្រើន (៦៤%) មានអាយុចាប់ពី១៨ ដល់៤៩ឆ្នាំ នៅពេលរៀបការ ខណៈដែល ៤០% មានអាយុពី១៣ ដល់១៧ឆ្នាំ។ សហព័ន្ធរបស់ពួកគេមានអាយុចាប់ពី១៨ ដល់៤៩ (៧៧,៨%) និងមានអាយុពី១៣ ដល់១៧ឆ្នាំ (២២,២%)។

តារាងទី៥ អាយុរបស់អ្នកផ្តល់សម្ភាស និង សហព័ន្ធនាពេលរៀបការមុនរបបខ្មែរក្រហម

| ក្រុមអាយុ(%) | | | |
|---|---|---|---|
| អាយុរបស់អ្នកផ្តល់សម្ភាសនាពេលរៀបការ | | អាយុរបស់សហព័ន្ធនាពេលរៀបការ | |
| **13-17** | **18-49** | **13-17** | **18-49** |
| 45.5% | 54.5% | 18.2% | 81.8% |

ចំពោះអ្នកដែលបានឆ្លងកាត់ការរៀបការរៀបចំដោយចាស់ទុំមុនរបបខ្មែរក្រហម ៦៣.៦% បានរាយការណ៍ថា បានស្គាល់សហព័ន្ធរបស់ខ្លួនមុនពេលរៀបការ។ យោងតាមសំណួរបើកក្នុងការស្ទង់មតិនេះ អ្នកផ្តល់សម្ភាសបានរាយការណ៍ថាចំណងអាពាហ៍ពិពាហ៍របស់គាត់មុនរបបខ្មែរក្រហម ពោរពេញទៅដោយ "សុភមង្គល" និង "ភាពសុខដុមរមនា" ជាមួយសហព័ន្ធដោយសារមានទំនាក់ទំនងល្អ និង "រស់នៅជាមួយគ្នាដោយសន្តិភាព"។

ក្នុងចំណោមអ្នកផ្តល់សម្ភាសទាំង ១២ ដែលបានរៀបការមុនពេលខ្មែរក្រហមចូលកាន់កាប់ មិនមានអ្នកណារាយការណ៍ពីអំពើហិង្សាដែលប្រព្រឹត្តឡើងដោយសហព័ន្ធនោះទេ[62]។

### គ. អាពាហ៍ពិពាហ៍ក្នុងអំឡុងពេលរបបខ្មែរក្រហមកាន់កាប់ (១៧ មេសា ១៩៧៥ ដល់ ៧ មករា ១៩៧៩)

អ្នកផ្តល់សម្ភាសបានរាយការណ៍ថារស់នៅក្នុងខេត្តចំនួន១៥ នៅពេលដែលខ្មែរក្រហមចូលកាន់កាប់។

[62] ហិង្សាក្នុងគ្រួសារពិតជាកើតមាន ប៉ុន្តែវាមិនត្រូវបានរាយការណ៍នៅក្នុងសំណាករបស់យើងទេ

## តារាងទី៦ ខេត្ត ស្រុកដែលអ្នកផ្តល់សម្ភាសរស់នៅនាពេលខ្មែរក្រហមចូលកាន់កាប់




ច្រើនជាងពាក់កណ្ដាលនៃចំនួនអ្នកផ្ដល់សម្ភាសសរុប (៥៦.៣%) រស់នៅក្នុងកងចល័ត ក្នុងអំឡុងពេលនោះ។ មានអ្នកផ្ដល់សម្ភាសតែ ១១ នាក់ប៉ុណ្ណោះដែលបានរាយការណ៍ថារស់នៅជាមួយគ្រួសារ ឬ សាច់ញាតិក្នុងរបបនោះ និង មានតែ ៦ នាក់ប៉ុណ្ណោះរាយការណ៍ថាបានរស់នៅជាមួយសហព័ន្ធ។

## តួលេខទី២ ៖ តើអ្នករស់នៅជាមួយអ្នកណាក្នុងរបបខ្មែរក្រហម ?
## (%នៃអ្នកផ្ដល់សម្ភាស)



អ្នកផ្តល់សម្ភាសភាគច្រើន (៨១.៧%) បានរាយការណ៍ថាបានធ្វើការជាកសិករក្រោមការគ្រប់គ្រងរបស់របបនេះ។ ច្រើនជាងពាក់កណ្តាល (៥៥.៨%) រាយការណ៍ថា ត្រូវបានគេចាត់ទុកថាជា "ប្រជាជនថ្មី" ក្នុងរបបនេះ។ អ្នកផ្តល់សម្ភាសដែលជាជនជាតិឥស្លាមត្រូវបានគេរាយការណ៍ថាស្ថិតនៅក្នុងចំណាត់ថ្នាក់នេះ។

តួលេខទី៣៖ ការងារដែលអ្នកផ្តល់សម្ភាសបានធ្វើក្នុងរបបខ្មែរក្រហម
(%នៃអ្នកផ្តល់សម្ភាស)




ចំពោះអ្នកដែលបានរៀបការមុនរបបខ្មែរក្រហមចូលកាន់កាប់ ដែលមានចំនួនច្រើនជាងពាក់កណ្តាល (៥១.៧%) បានរាយការណ៍ថា សហព័ន្ធរបស់ខ្លួនត្រូវបានគេសម្លាប់នៅអំឡុងពេលរបបនោះ ហើយ ១៤.៣% ទៀតបានរាយការណ៍ថា សហព័ន្ធរបស់ខ្លួនបាត់ខ្លួន។ តិចជាងមួយភាគបួន (២១.៤%) នៃចំនួនសហព័ន្ធដែលបានរៀបការមុនរបបខ្មែរក្រហមបានរាយការណ៍ថាបានរួចផុតពីការស្លាប់និងរស់រានមានជីវិត។

តារាងទី៧៖ វាសនារបស់សហព័ន្ធនៅចន្លោះឆ្នាំ ១៩៧៥ និង ១៩៧៩

| វាសនារបស់សហព័ន្ធ(%) | | | |
|---|---|---|---|
| ត្រូវបានគេសម្លាប់ | រួចផុតពីការសម្លាប់និងរស់រានមានជីវិត | បាត់ខ្លួន | ផ្សេងទៀត |
| 57.1% | 21.4% | 14.3% | 7.1% |

អ្នកផ្តល់សម្ភាសទាំង ១០៦ នាក់បានរាយការណ៍ថា ពួកគាត់ត្រូវបានគេស្នើឲ្យរៀបការក្នុងរបបខ្មែរក្រហម ហើយក្នុងនោះ មាន ១០៣ នាក់(៩៧.២%) បានរៀបការមែន។

អ្នកផ្ដល់សម្ភាសបានរាយការណ៍ថាខ្លួនត្រូវបានគេស្នើជាច្រើនលើកច្រើនសារ ដើម្បីសុំរៀបការ ដែលក្នុងនោះមាន២២.១% បានរាយការណ៍ត្រូវបានគេស្នើលើសពីបីដង។

តួលេខទី៤៖ ចំនួនដងដែលអ្នកផ្ដល់សម្ភាសត្រូវបានគេសុំដើម្បីរៀបការក្នុងរបបខ្មែរក្រហម (%នៃអ្នកផ្ដល់សម្ភាស)




ពេលខ្លះ ការបដិសេធជារឿងធម្មតា។ ក្រៅពីបាត់ចម្លើយចំនួន៩, អ្នកផ្ដល់សម្ភាសចំនួន ៧៣ នាក់ (៧០.២%) បានរាយការណ៍ថា បានបដិសេធការស្នើសុំរៀបការ។ ចំពោះអ្នកដែលបដិសេធទាំងអស់ មានអ្នកផ្ដល់សម្ភាស ២១នាក់ (២៩.៤%) បញ្ជាក់ថាបានបដិសេធតែម្ដងគត់ ២៣នាក់(៣១.៩%) បានបដិសេធពីរដង និង ប្រហែលជាមួយភាគបួន (២៣.៦%) បានរាយការណ៍ថាបដិសេធលើសពីបីដង។

តួលេខទី៥៖ ចំនួនដងដែលអ្នកផ្ដល់សម្ភាសបដិសេធមិនព្រមរៀបការ (%នៃអ្នកផ្ដល់សម្ភាស)




ភាគច្រើននៃអ្នកផ្ដល់សម្ភាសបានរាយការណ៍ពីការគំរាមកំហែង ឬ ការដាក់ទណ្ឌកម្មជាក់ស្ដែង ដោយសារការបដិសេធមិនព្រមរៀបការ។ អ្នកផ្ដល់សម្ភាស ៤៨ នាក់(៦៦.៧%) បានរាយការណ៍ថា ត្រូវបានគេគំរាមកំហែងផ្ទាល់មាត់ និង ៥ នាក់ទៀតបានរាយការណ៍ថាត្រូវបានគេចាប់ឃុំខ្លួន និង ២នាក់ទៀតត្រូវបានគេធ្វើទារុណកម្ម។

តួលេខទី៦៖ លទ្ធផលនៃការបដិសេធមិនព្រមរៀបការក្នុងរបបខ្មែរក្រហម
(%នៃអ្នកផ្ដល់សម្ភាស)




ក្នុងចំណោមអ្នកដែលបានរៀបការ អ្នកផ្ដល់សម្ភាសចំនួន ៨៥ នាក់(៨៤.២%) បានរាយការណ៍ថាពួកគាត់ស្ថិតនៅចន្លោះក្នុងអាយុពី ១៨ ទៅ ៤៩ ឆ្នាំ នៅពេលដែលពួកគាត់រៀបការ។ ១៥នាក់ ស្មើនិង ១៤.៩% រាយការណ៍ថា ស្ថិតក្នុងចន្លោះអាយុពី ១៣ ទៅ ១៧ឆ្នាំ និង អ្នកផ្ដល់សម្ភាស ១ នាក់ រាយការណ៍ថា បានរៀបការនៅអាយុ ១២ ឆ្នាំ ឬតិចជាងនេះ។

ក្នុងចំណោមអ្នកផ្ដល់សម្ភាសជាជនជាតិឥស្លាម៧នាក់ មានម្នាក់បានរាយការណ៍ថារៀបការជាមួយ ជនជាតិខ្មែរ។

អ្នកផ្ដល់សម្ភាសចំនួន៤៤ នាក់ (៤៣.៦%) រាយការណ៍ថា ត្រូវបានគេហៅឲ្យទៅចូលរួមការប្រជុំនៅមូលដ្ឋានខ្លួន ហើយបានដឹងខ្លួនថាពួកគេនិងត្រូវរៀបការ។ ចំនួនដែលគួរឲ្យកត់សម្គាល់ ដល់ទៅ ៣៤នាក់ នៃអ្នកផ្ដល់សម្ភាស ត្រូវបានគេជូនដំណឹងដោយផ្ទាល់ជាឯកជន។ មានអ្នកផ្ដល់សម្ភាសចំនួន ១៥នាក់ មិនបានដឹងមុនទេថាពួកគាត់នឹងត្រូវរៀបការ។

តួលេខទី៧៖ តើអ្នកដឹងដោយដូចម្ដេចថាអ្នកនឹងត្រូវរៀបការ?
(%នៃអ្នកផ្ដល់សម្ភាស)



ដោយបាត់ចម្លើយពីអ្នកផ្តល់សម្ភាសចំនួន៥នាក់, អ្នកផ្តល់សម្ភាសចំនួន ៤៧ នាក់ (៤៦.៥%) រាយការណ៍ថាបានស្គាល់គ្នា ឬ រៀបនឹងស្គាល់គ្នាមុនពេលរៀបការ ខណៈដែលប្រជាជន "ថ្មី" មិនសូវជាបានស្គាល់ពីបុគ្គលដែលគាត់ត្រូវរៀបការជាមួយនោះទេ (ប្រជាជនថ្មីចំនួន២៩.៧% មិនបានស្គាល់ បុគ្គលដែលត្រូវបានចាត់តាំងជាសហព័ន្ធរបស់ខ្លួនឡើយ បើធៀបទៅនឹង ២៣.៨% នៃប្រជាជនចាស់)។

អ្នកផ្តល់សម្ភាសចំនួន ៩៨ នាក់ ឬ ៩៧.០% រាយការណ៍ថា វាមិនមែនជាជម្រើសរបស់គាត់ក្នុងការរៀបការ ហើយប្រជាជនចាស់មួយចំនួនតូចរាយការណ៍ថា ជាជម្រើសរបស់គាត់ក្នុងការរៀបការ (២.១% បើប្រៀបធៀបទៅនឹង ០.០ % នៃប្រជាជនថ្មី)។

តារាងទី៨៖ ជម្រើសរបស់អ្នកផ្តល់សម្ភាសក្នុងការរៀបការតាមការរៀបចំរបស់ខ្មែរក្រហម

| ជម្រើសនៃការរៀបការ (%) | |
|---|---|
| ជម្រើសរបស់អ្នកផ្តល់សម្ភាស | មិនមែនជម្រើសរបស់អ្នកផ្តល់សម្ភាស |
| 3% | 97% |

អ្នកផ្តល់សម្ភាសចំនួន ៧២ នាក់ ស្មើនឹង ៧៥% បានរាយការណ៍ថា ត្រូវបានគេបង្ខំឲ្យរៀបការ ដែលមិនមែនជាជម្រើសរបស់ខ្លួន ដោយសារតែការគម្រាមផ្ទាល់មាត់។ ១៨ នាក់ទៀត រាយការណ៍ថា មានអារម្មណ៍ភ័យខ្លាចការដាក់ទណ្ឌកម្ម ហើយ ៥ នាក់ទៀត រាយការណ៍ថា ត្រូវបានគេបង្ខំឲ្យរៀបការដោយប្រើប្រាស់ហិង្សាលើរាងកាយ។

តួលេខទី៨៖ តើអ្នកត្រូវបានគេបង្ខំឲ្យរៀបការបែបណា?
(%នៃអ្នកផ្តល់សម្ភាស)



ដោយសារបាត់បង់ចម្លើយចំនួន៥ អ្នកដែលត្រូវបានគេសំភាសន៍បញ្ជាក់ថា ការរៀបការភាគច្រើនត្រូវបានរៀបចំឡើងដោយកម្មាភិបាលខ្មែរក្រហម (៧០,៣%)។

តារាងទី៩៖ តើអ្នកណាជាអ្នករៀបចំអាពាហ៍ពិពាហ៍?

| អ្នកទទួលបន្ទុករៀបចំអាពាហ៍ពិពាហ៍(%) | | | | |
|---|---|---|---|---|
| កម្មាភិបាលខ្មែរក្រហម | កងឈ្លប | ប្រជាជន | ប្រធានកងចល័ត | ទាហានខ្មែរក្រហម |
| 70.3% | 12.7% | 8.5% | 7.5% | 1% |

*អ្នកទទួលបន្ទុកនេះយោងទៅតាមអ្នកចូលរួមចំនួន ១០១ នាក់

អ្នកផ្តល់សម្ភាសចំនួន ៨៩ នាក់(៨៨.១%) រាយការណ៍ថា មានអារម្មណ៍ថាត្រូវបានគេបង្ខំឲ្យរួមសង្វាស់ក្រោយពេលរៀបការ ដែលក្នុងនោះមាន ចម្លើយចំនួន៥មិនត្រូវបានផ្តល់។ ៤២ នាក់ (៤៧.២%) រាយការណ៍ថា ត្រូវបានគំរាមដោយប្រើសម្តី ហើយអ្នកផ្តល់សម្ភាសចំនួន ៣០ នាក់ទៀត (៣៣.៧%) រាយការណ៍ថា មានអារម្មណ៍ត្រូវបានគេបង្ខំដោយសារកម្មាភិបាលលួចមើល។ ១៤នាក់ (១៥,៧%) រាយការណ៍ថាខ្លាចគេដាក់ទណ្ឌកម្ម និង ៣នាក់ (៣,៤%) រាយការណ៍ថាត្រូវគេបង្ខំដោយប្រើកម្លាំងកាយ។

តួលេខទី៩៖ ហេតុអ្វីបានជាអ្នកមានអារម្មណ៍ត្រូវបានគេបង្ខំឲ្យរួមសង្វាស់ក្រោយពេលរៀបការ? (%នៃអ្នកផ្តល់សម្ភាស)




អ្នកផ្តល់សម្ភាស (៤២.៨%) បានរាយការណ៍ ថាមានអារម្មណ៍ភ័យខ្លាចចំពោះជីវិតរបស់ពួកគេ ពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍របស់ខ្មែរក្រហម។ មនុស្សចំនួន ១៥.៣% បានបញ្ជាក់ថា គាត់មិនបានមានមនោសញ្ចេតនាស្នេហា ឬ ចំណង់ផ្លូវភេទជាមួយគូសហព័ន្ធរបស់ពួកគេទេ។ មនុស្សចំនួន ៣៣.៧% មានអារម្មណ៍តក់ស្លុត និងខកបំណងចំពោះអាពាហ៍ពិពាហ៍នោះ និង ៨.២%ទៀត បានលើកឡើងយ៉ាងច្បាស់ថា មិនពេញចិត្តចំពោះការរៀបការដោយបង្ខំ និងមិនមានវត្តមានឪពុកម្តាយរបស់ខ្លួន។

តួលេខទី១០៖ តើអ្នកមានអារម្មណ៍យ៉ាងណាចំពោះអាពាហ៍ពិពាហ៍នាពេលនោះ?
(%នៃអ្នកផ្តល់សម្ភាស)




អ្នកផ្តល់សម្ភាស (៣៥ នាក់ ឬ ៣៩.៣%) បានរាយការណ៍ ថាអាចជួបមុខគូសហព័ន្ធរបស់ពួកគាត់ក្រោយរៀបការក្នុងរបបខ្មែរក្រហម បានតែម្តងគត់ក្នុងមួយខែ។ ជាមួយគ្នានេះ ១៧ នាក់(១៩.១%) រាយការណ៍ថាបានជួបគ្នារាល់សប្តាហ៍ និង អ្នកផ្តល់សម្ភាស១៥ នាក់ (១៦.៩%) រាយការណ៍ថាជួបគ្នារាល់ថ្ងៃ។ អ្នកផ្តល់សម្ភាស១៣នាក់ រាយការណ៍ថាបានជួបសហព័ន្ធខ្លួន ១ ដងគត់ក្នុងមួយឆ្នាំ និង ៩ នាក់ផ្សេងទៀតរាយការណ៍ថា មិនបានជួបគ្នាទៀតឡើយ។

ក្នុងការឆ្លើយសំណួរប្រភេទបើក អ្នកផ្តល់សម្ភាសបានលើកឡើងពីចំនុចវិជ្ជមាន និងអវិជ្ជមាននៃទំនាក់ទំនងប្តីប្រពន្ធក្នុងអំឡុងពេលរបបខ្មែរក្រហម។ អ្នកខ្លះបានរាយការណ៍ថា "មានអារម្មណ៍ស្រលាញ់" និង "គោរព" ហើយ ស្វាមីត្រូវបានលើកឡើងថាបានជួយធុរៈប្រពន្ធពេលសម្រាលកូន។ ការអាណិតអាសូរ និងក្តីបារម្ភក៏ត្រូវបានលើកឡើង រួមទាំងភាពស្មើគ្នានៃអាពាហ៍ពិពាហ៍ ដូចជាចំណុចវិជ្ជមាននៃទំនាក់ទំនងដែលពួកគាត់បានលើកឡើងថា "ពួកយើងទាំងពីរនាក់ សម្របសម្រួលគ្នា និងរស់នៅជាមួយគ្នាបានយ៉ាងល្អ"។

របាយការណ៍នៃភាពអវិជ្ជមានរបស់អារម្មណ៍ មានចំនួនច្រើន រួមបញ្ចូលទាំងភាពខ្វះខាតនៃក្តីស្រលាញ់ ការប្រាស្រ័យទាក់ទង ចំណង់ផ្លូវភេទ ឬ ភាពទាក់ទាញគ្នាមានកម្រិតទាប។ "ខ្ញុំមិនចូលចិត្តគាត់" ជាចម្លើយដែល អ្នកផ្តល់សម្ភាសបានឆ្លើយ ក្នុងរូបភាពដែលមានគំលាតធំពីគូសហព័ន្ធដែលបានមកពីការរៀបការដោយបង្ខំនោះ។ "ជារឿយៗ ខ្ញុំតែងតែប្រកែកមិនព្រមរួមសង្វាសជាមួយសហព័ន្ធដែលបានមកពីការរៀបការដោយចាប់បង្ខំរបស់ខ្ញុំទេ"។ ការឆ្លើយតបដ៏ជាក់លាក់សំដៅទៅលើអំពើហិង្សាពីសំណាក់សហព័ទ្ធ "ខ្ញុំមានការភ័យខ្លាចនិងរស់នៅជាមួយសហព័ន្ធដែលបានមកពីការរៀបការដោយបង្ខំ ប្តីរបស់ខ្ញុំប្រព្រឹត្តហិង្សាមកលើខ្ញុំ វាយប្រហារទាំងផ្លូវកាយ និងផ្លូវចិត្តរបស់ខ្ញុំ និងចោទខ្ញុំថាមិនស្មោះត្រង់"។ "ខ្ញុំមិនមាន អារម្មណ៍

ល្អជាមួយប្តីរបស់ខ្ញុំទេ ដោយសារតែគាត់ ចង់បានត្រឹមតែរួមសង្វាសជាមួយខ្ញុំប៉ុណ្ណោះ"។ មានអ្នកផ្តល់សម្ភាសម្នាក់បានរាយការណ៍ពីការដាប់អន្ទាក់នៃទំនាក់ទំនងនេះ "ខ្ញុំមិនស្រលាញ់ប្តីរបស់ខ្ញុំទេ ហើយខ្ញុំចង់ចែកផ្លូវជាមួយគាត់"។

ក្នុងចំណោមស្ត្រីដែលបានរាយការណ៍ថា មានផ្ទៃពោះក្រោយការចាប់រៀបការដោយបង្ខំ មានអ្នកផ្តល់សម្ភាសចំនួន ៦៩ នាក់ (៩២%) រាយការណ៍ថាមិនដែលមានចេតនាក្នុងការរំលូតកូន។ របាយការណ៍នៃការព្យាយាមរំលូតកូនក្នុងចំណោមអ្នកផ្តល់សម្ភាស ៦ នាក់ រាប់បញ្ចូលទាំងចេតនាផ្ទាល់ខ្លួនរួមមាន លីសែងរបស់ធ្ងន់ រត់ហើយមានចេតនាដួល រួមទាំងមានមួយចំនួនបានរាយការណ៍ថាហូបថ្នាំបុរាណក្នុងន័យជំរុញឲ្យរំលូតកូន។

ប្រហែលជាមួយភាគបួននៃអ្នកផ្តល់សម្ភាសទាំងអស់ (២៤.៥%) បានរាយការណ៍ថាហិង្សាក្នុងគ្រួសារក្នុងរបបនេះ ជាផ្នែកមួយនៃការរៀបការដោយចាប់បង្ខំ។ ក្នុងចំណោមមនុស្ស ២៩នាក់ ដែលបានរាយការណ៍ថាធ្លាប់មានបទពិសោធន៍ជាមួយអំពើហិង្សា មាន ១០ នាក់ (៣៥.៧%)រាយការណ៍ពីអំពើហិង្សាលើរូបរាងកាយ ៦ នាក់ទៀត (២១.៤%) រាយការណ៍ថាត្រូវបានគេចាប់រំលោភ និងហិង្សាផ្លូវភេទ។ ចំពោះអ្នកដែលមានបទពិសោធន៍ទទួលរងការបំពាន អ្នកផ្តល់សម្ភាសចំនួនមួយភាគបួន ស្មើទៅនឹង៧នាក់ ឬ ២៥% មានបទពិសោធន៍ទទួលបានវាជារៀងរាល់ថ្ងៃ នៅពេលដែល មានអ្នកផ្តល់សម្ភាស ៦នាក់ទៀត (២១.៤%) មានបទពិសោធន៍ជួបប្រទះវាតិចជាង ១ដងក្នុងមួយឆ្នាំ ដែលជាធម្មតាបណ្តាលមកពីអ្នកដែល ត្រូវបានគេចាប់រៀបការដោយបង្ខំត្រូវបានគេបំបែកគ្នាដោយមូលហេតុការងារ។ ចំនួនអ្នកផ្តល់សម្ភាសដែលបានរាយការណ៍ថាទទួលបានហិង្សាពីសំណាក់សហព័ន្ធខ្លួន ៣ដងក្នុងមួយសប្តាហ៍៣ដងក្នុងមួយខែ និងបីដងក្នុងមួយឆ្នាំ មានចំនួនដូចគ្នាដែរក្រុមនីមួយៗមានចំនួនជាភាគរយស្មើទៅនឹង ១៧.៩%។

<u>តួលេខទី១១៖ ប្រភេទនៃហិង្សាពីសហព័ទ្ធរបស់អាពាហ៍ពិពាហ៍ចាប់បង្ខំក្នុងរបបខ្មែរក្រហម (%នៃអ្នកផ្តល់សម្ភាស)</u>



ក្នុងសំណួរប្រភេទបើកចំហ អ្នកផ្តល់សម្ភាសបានរៀបរាប់អំពីការបំពានដែលទទួលបានពីការរៀបការដោយចាប់បង្ខំក្នុងរបបនេះ។ អ្នកខ្លះបានរៀបរាប់ថា ហិង្សាផ្លូវភេទ និងការចាប់រំលោភបានចាប់ផ្តើមភ្លាមនាយប់រៀបអាពាហ៍ពិពាហ៍នោះ។ "បន្ទាប់ពីរៀបការរួច ប្តីរបស់ខ្ញុំបង្ខំឲ្យខ្ញុំដោះខោអាវ ហើយបង្ខំឲ្យខ្ញុំរួមសង្វាស់ជាមួយគាត់។ គាត់បាននិយាយថា បើខ្ញុំជំទាស់គាត់នឹងសម្លាប់ខ្ញុំចោល"។ មានមនុស្សស្រីម្នាក់បានរំលឹកថាគាត់ត្រូវបានរំលោភដោយប្តីរបស់គាត់នៅពេលគាត់អាយុ ១៥ ឆ្នាំ។ អ្នកដ៏ទៃទៀតបាននិយាយថា "គាត់តែងតែបង្ខំខ្ញុំឲ្យរួមសង្វាស់ជាមួយគាត់ ហើយប្រសិនបើខ្ញុំមិនព្រម គាត់អាចនឹងទះកំផ្លៀងខ្ញុំ ហើយខ្ញុំតែងតែមាន អាការៈទន់ខ្សោយ និង ស្លេកក្រោយការរួមសង្វាសម្តងៗ"។ អ្នកផ្សេងទៀត បានរៀបរាប់អំពីការវាយដំលើរូបរាងកាយ និងការបំពានផ្នែកពាក្យសម្តីដែលកើតមានឡើងក្នុងអំឡុងពេលរៀបការ។

អ្នកផ្តល់សម្ភាសភាគច្រើន (៧៧នាក់ ឬ ៧៦.២%) បានរាយការណ៍ថា មានកូនក្រោយពេលរៀបការដោយបង្ខំ ដែលក្នុងនោះមាន ៣៥នាក់ (៤៤.៩%) រាយការណ៍ថាមានកូនចំនួនបួននាក់ និង ២៨នាក់ទៀត (៣៥.៩%) រាយការណ៍ថាមានកូនចំនួនមួយនាក់។

<u>តារាងទី១០៖ ចំនួនកូនក្រោយការរៀបការដោយបង្ខំ</u>

| ចំនួនកូនក្រោយការរៀបការដោយបង្ខំ | | | | |
|---|---|---|---|---|
| 1 | 2 | 3 | 4 | >4 |
| 35.9% | 7.7% | 3.8% | 7.7% | 44.9% |

*ចំនួនកូនផ្អែកទៅលើចម្លើយបានពីអ្នកផ្តល់សម្ភាស១០៦នាក់

សហព័ទ្ធភាគច្រើន(៨២.០%) បានប្រាប់អ្នកដ៏ទៃពីការរៀបការដោយបង្ខំរបស់ខ្លួនក្នុងអំឡុងពេលរបបខ្មែរក្រហម។ ចំពោះអ្នកដែលលាក់ទុកការរៀបការជាសម្ងាត់ ច្រើនជាងពាក់កណ្តាល (៥២.៦%) រាយការណ៍ថាមានភាពអាម៉ាស់ចំពោះអាពាហ៍ពិពាហ៍នោះ និង ៣៦.៨%ទៀតរាយការណ៍ថាមានភាពភ័យខ្លាចចំពោះស្លាកស្នាមទុរយស និងការរើសអើង។

តារាងទី១១៖ហេតុផលរបស់អ្នកផ្តល់សម្ភាសដែលមិនប្រាប់អ្នកដទៃពីការរៀបការ ដោយបង្ខំរបស់ខ្លួន

| មូលហេតុដែលមិនប្រាប់ពីការរៀបការដោយបង្ខំ (%) | | |
|---|---|---|
| ភាពអាម៉ាស | ភ័យខ្លាចការរើសអើង និងស្លាកស្នាមទុរយស | ផ្សេងទៀត |
| 52.6% | 36.8% | 10% |

ឃ. អាពាហ៍ពិពាហ៍ក្រោយរបបខ្មែរក្រហម (ក្រោយ ខែមករា ឆ្នាំ១៩៧៩)

ចំនួនភាគច្រើននៃអ្នកផ្តល់សម្ភាស (៦៨.១%) រាយការណ៍អំពី សហព័ន្ធរបស់ពួកគេ រួចរស់រានមានជីវិតពីរបបខ្មែរក្រហម ហើយ៧នាក់ (៦.៩%) ផ្តល់ចម្លើយថា ពួកគេមិនបានដឹងថាសហព័ទ្ធរបស់ពួកគាត់នៅរស់ដែរឬអត់។ ក្នុងចំណោមអ្នកផ្តល់សម្ភាសទាំង ៦៤នាក់ដែលរាយការណ៍ថា សហព័ន្ធរបស់ពួកគាត់បានរួចរស់រានមានជីវិតពីរបបនេះ អ្នកផ្តល់សម្ភាសចំនួនច្រើនជាងពាក់កណ្តាល (៥៣.១%) នៅតែស្ថិតនៅក្នុងចំណងអាពាហ៍ពិពាហ៍របស់ពួកគេ ហើយអ្នកផ្តល់សម្ភាសច្រើនជាងមួយភាគបួនទៀត (២៦.៦%)បានរាយការណ៍ថា បានរស់នៅជាមួយសហព័ន្ធរបស់ខ្លួនបានមួយរយៈដែរ។ អ្នកផ្តល់សម្ភាសចំនួន ១២ នាក់(២០.៣%) រាយការណ៍ពីការចែកផ្លូវគ្នាដោយសារមរណភាពរបស់សហព័ទ្ធ និងបញ្ហាផ្សេងៗទៀត (មើលតួលេខទី ១២)។

តារាងទី១២៖ ស្ថានភាពគ្រួសារដែលបានរៀបការដោយបង្ខំក្រោយរបបខ្មែរក្រហម

| ស្ថានភាពគ្រួសារដែលបានរៀបការដោយបង្ខំក្រោយរបបខ្មែរ (%) | | |
|---|---|---|
| រស់នៅជាមួយគ្នា | នៅជាមួយគ្នាបានមួយរយៈ | ចែកផ្លូវ / មរណភាពរបស់សហព័ន្ធ |
| 53.1% | 26.6% | 20.3% |

*ស្ថានភាពគ្រួសារនៃការរៀបការដោយបង្ខំក្រោយរបបខ្មែរក្រហមផ្អែកទៅលើអ្នកផ្តល់សម្ភាស១០២នាក់

ក្នុងចំណោមអ្នកផ្តល់សម្ភាសដែលបានចែកផ្លូវពីគូសហព័ទ្ធរបស់ខ្លួន មានពាក់កណ្តាល (៥០%) បានធ្វើភ្លាមៗមុន ឬ ក្រោយពេលរបបខ្មែរក្រហមដួលរលំភ្លាមៗក្នុងឆ្នាំ ១៩៧៩ ក្នុងនោះមាន ១១ នាក់(៣៤.៤%) បានរាយការណ៍ថា បានចែកផ្លូវគ្នាក្នុងចន្លោះ

ឆ្នាំ ១៩៨០ និង ឆ្នាំ ១៩៩៣។ មានអ្នកផ្តល់សម្ភាស៥នាក់ទៀត (១៥.៦%) បានរាយការណ៍ពីការបែកផ្លូវគ្នាក្រោយឆ្នាំ១៩៩៣។

ចំនួនស្មើគ្នាដល់ទៅ២៩.៤% នៃអ្នកផ្តល់សម្ភាសដែលបានរាយការណ៍ថាបានបែកផ្លូវគ្នាជាមួយសហព័ន្ធនៃការរៀបការដោយបង្ខំដោយសារពួកគេមិនចុះសម្រុងគ្នា និងដោយសារមរណៈភាព។ មូលហេតុផ្សេងទៀតដែលត្រូវបានផ្តល់មានដូចជាសំពាធពីគ្រួសារ និងសាច់ញាតិ (១៧.៦%) ការបោះបង់ចោល និងបាត់ខ្លួន (៨.៨%) ស្វែងរកដៃគូថ្មី (៨.៨%) និង ផ្លាស់លំនៅទៅស្រុកកំណើតវិញ (៥.៩%)។

តួលេខទី១២៖ មូលហេតុនៃការបែកផ្លូវគូសហព័ន្ធនៃការរៀបការដោយបង្ខំ
(%នៃអ្នកផ្តល់សម្ភាស)




ក្នុងចំណោមអ្នកដែលបានបែកផ្លូវគ្នាក្រោយការរៀបការដោយបង្ខំ អ្នកផ្តល់សម្ភាសចំនួន ៧០% បានរៀបការម្តងទៀត ហើយ ៣០%ទៀតរាយការណ៍ថាមិនរៀបការទៀតឡើយ។ ជាងពាក់កណ្តាលនៃអ្នកផ្តល់សម្ភាសទាំងអស់ (៤២.៥%)បានរាយការណ៍ថា ស្នេហា ជាគឺជាកត្តានៃការលើកទឹកចិត្តដ៏សំខាន់មួយសម្រាប់ជំរុញការរៀបការជាថ្មី។ ផ្សេងពីនេះទៀតបានរាយការណ៍ថាគាត់យល់ព្រមរៀបការដោយសារសំពាធពីគ្រួសារ(២១.៤%) ការរីកចំរើននៃវិស័យសេដ្ឋកិច្ច ឬ មុខមាត់ក្នុងសង្គម (១៤.៣%) ឬ ដោយសារមូលហេតុផ្សេងទៀត។ មានអ្នកផ្តល់សម្ភាសម្នាក់បានរាយការណ៍ថារៀបការឡើងវិញដោយមានការស្នើសុំពីកូន។

តួលេខទី១៣៖មូលហេតុដែលអ្នកផ្តល់សម្ភាសយល់ព្រមរៀបការក្រោយរបបខ្មែរក្រហម
(%នៃអ្នកផ្តល់សម្ភាស)



ចំពោះអ្នកដែលមិនរៀបការជាថ្មី ភាគច្រើន (៧២%) បានរាយការណ៍ថាការសម្រេចចិត្តមិនរៀបការជាថ្មីដោយសារមានបទពិសោធន៍ជាច្រើនទទួលបានពីការរៀបការដោយបង្ខំ។ មនុស្សចំនួន៥.៦% ទៀតរាយការណ៍ថាមិនអាចស្វែងរកគូសហព័ទ្ធទៀតបានដោយសារពួកគាត់បានរៀបការរួចទៅហើយ និង ចំនួន ១១.១% រាយការណ៍ថាមិនរៀបការសារជាថ្មីដោយសារវ័យកាន់តែចាស់។ អ្នកផ្តល់សម្ភាសចំនួន ៥.៦% រាយការណ៍ថាមិនរៀបការដោយសារជាបំណងរបស់កូន។

តួលេខទី១៤៖ មូលហេតុដែលអ្នកផ្តល់សម្ភាសមិនព្រមរៀបការក្រោយរបបខ្មែរក្រហម (%នៃអ្នកផ្តល់សម្ភាស)




អ្នកផ្តល់សម្ភាសច្រើនជាងពាក់កណ្តាល (៥២.៥%) បានសុំសិទ្ធិយកកូនក្រោយការបែកផ្លូវ ឬ មរណៈភាពរបស់សហព័ន្ធនៃការរៀបការដោយបង្ខំ, ដែល៤៥.៨% បានរាយការណ៍ថាបុគ្គលដ៏ទៃដែលមិនមែនជាសហព័ទ្ធបានស្នើសុំសិទ្ធិនេះ។អ្នកផ្តល់សម្ភាសបានរៀបរាប់ពីទំនាក់ទំនងល្អជាមួយកូនដែលបានមកពីអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលត្រូវបានកំណត់ដោយថា "សេចក្តីស្រលាញ់" និង "ការអាណិតអាសូរ"។ មានអ្នកផ្តល់សម្ភាសតែម្នាក់គត់បានរាយការណ៍ពីទំនាក់ទំនងដែលមិនជិតស្និទជាមួយកូនដែលបានមកពីការរៀបការដោយបង្ខំ ហើយ២នាក់បានរាយការណ៍ថាមិនមានទំនាក់ទំនងទាល់តែសោះ ប៉ុន្តែជាសរុបរួម អ្នកផ្តល់សម្ភាសទាំងអស់ (៩២.១%) បានរៀបរាប់ពីសេចក្តីស្រលាញ់ដ៏កក់ក្តៅ និងស្និទ្ធស្នាលជាមួយកូនដែលប្រសូតចេញមកពីការរៀបការដោយបង្ខំរបស់ពួកគាត់។

ក្នុងចំណោមអ្នកដែលបានបែកផ្លូវគ្នាពាក់កណ្តាលនៃអ្នកផ្តល់សម្ភាសសរុប(៥០.៨%)រាយការណ៍ពីទំនាក់ទំនងជិតស្និទ្ធ និងកក់ក្តៅជាមួយកូននិងសហព័ន្ធនៃការរៀបការដោយបង្ខំ ហើយមួយភាគបីនៃអ្នកផ្តល់សម្ភាស (៣៤%) រាយការណ៍ពីទំនាក់ទំនងមិនជិត

ស្និទ្ធនិង ១៥.៣%ទៀត បានរាយការណ៍មានទំនាក់ទំនងធម្មតា។ ចំនួនភាគច្រើននៃអ្នកផ្តល់សម្ភាស (៧៥.០%) មិនមានទំនាក់ទំនងជាមួយសហព័ន្ធមុនរបស់គាត់ឡើយ។

អ្នកផ្តល់សម្ភាស បានរាយការណ៍ទាំងចំណុចល្អ និងចំណុចអាក្រក់ ដោយសារមរណៈភាព និងការបែកផ្លូវពីគូសហព័ន្ធនៃការរៀបការដោយបង្ខំ។ ក្នុងការស្ទង់មតិដោយប្រើប្រាស់សំណួរបើក អ្នកផ្តល់សម្ភាសបានរាយការណ៍ថាមានភាពប្រសើរឡើងទាំងសុខភាពផ្លូវចិត្ត និងផ្លូវកាយព្រោះថា "ការរៀបការត្រូវបានរៀបចំឡើងដោយបង្ខំ ដូច្នេះសហព័ន្ធរបស់ខ្ញុំមិនបានស្រលាញ់ខ្ញុំទេ។"អ្នកដទៃទៀតបានរាយការណ៍ថាសប្បាយចិត្តនៅពេលដែលមានសេរីភាពក្នុងការជ្រើសរើសគូសហព័ន្ធដោយខ្លួនឯង។ អ្នកដែលធ្លាប់មានបទពិសោធន៍ឆ្លងកាត់ការធ្វើបាបក្នុងចំណងអាពាហ៍ពិពាហ៍ដោយបង្ខំបានរាយការណ៍ថាបានធូរស្បើយ "បើគ្មានសហព័ន្ធនៃការរៀបការដោយបង្ខំរបស់ខ្ញុំទេ គ្មានអ្នកណាម្នាក់មាក់ងាយខ្ញុំ គ្មានអ្នកណាធ្វើទារុណកម្មខ្ញុំ ហើយក៏គ្មានអ្នកណាបង្ខំខ្ញុំឲ្យរួមសង្វាស់ជាមួយទៀតដែរ។"

ទោះបីជាការបែកផ្លូវគ្នាបាននាំមកនូវភាពវិជ្ជមានក៏ដោយ ក៏វានៅតែនាំមកជាមួយនូវភាពអវិជ្ជមានដែរ។ ផលប៉ះពាល់ដែលធ្ងន់ធ្ងរបំផុតគឺ ទាក់ទងទៅនឹងសេដ្ឋកិច្ច និងភាពក្រីក្រដែលគ្មានសមត្ថភាព និងជំនួយណាដែលអាចជួយក្នុងការបំពេញការងារធ្វើស្រែចំការ ភាពលំបាកក្នុងការធ្វើការងារក្នុងផ្ទះ ដែលបុគ្គលម្នាក់ត្រូវបំពេញតួនាទីជាម្តាយផង ជាឪពុកផង រួមទាំងខ្វះខាតជំនួយទូទៅដូចជា ជំនួយសេដ្ឋកិច្ច និងសង្គម។ ចម្លើយមួយចំនួនបានផ្តោតសំខាន់ទៅលើផលប៉ះពាល់លើយេនឌ័រ ដែលទទួលបានមកពីការបែកផ្លូវគ្នាពីការរៀបការដោយបង្ខំ ហើយសំដៅច្បាស់លើស្ត្រី ដែលមានតួនាទីសង្គមជាអ្នកទទួលខុសត្រូវលើភាពសុខដុមចំពោះគ្រួសារ ស្វាមី និងកូន៖ "ក្នុងនាមជាស្ត្រីមេម៉ាយ នៅពេលដែលខ្ញុំលឺពាក្យអាក្រក់ ឬ ពាក្យមាក់ងាយពីអ្នកជិតខាង ខ្ញុំមានភាពវង់ទុក្ខវេទនា និង សោកស្តាយដែលបាត់បង់ស្វាមី និងកូនក្នុងរបបខ្មែរក្រហម ខ្ញុំមានភាពវង់ទុក្ខវេទនាណាស់ ហើយគ្មានអ្នកណាជួយគាំទ្រខ្ញុំទេ ជីវិតរបស់ខ្ញុំគឺគ្មានអ្វីទាល់តែសោះ។"

ក្នុងចំណោមអ្នកផ្តល់សម្ភាស ៥២ នាក់ដែលរាយការណ៍ថាសុខចិត្តរស់នៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំ ច្រើនជាងពាក់កណ្តាល (៥២.៨%) បានរាយការណ៍ថាពួកគាត់សម្រេចចិត្តបែបនេះក៏ដោយស្នេហា និងការស្រលាញ់។ មូលហេតុបន្ទាប់ដែលជំរុញឲ្យគាត់យល់ព្រមរស់នៅជាមួយគ្នា (៣៦.៥%) ដោយសារតែពួកគាត់មានកូនជាមួយគ្នា។ សំពាធគ្រួសារ ដូចជាវប្បធម៌ប្រពៃណី (ដូចជាគោលគំនិតមួយដែលថាស្ត្រីដែលបានលែងលះ ជាស្ត្រីមិនល្អហើយគ្មានភក្តីភាពចំពោះស្វាមីរបស់ខ្លួន) ក៏ត្រូវបានលើកឡើងផងដែរ។

តារាងទី១៣៖ ការលើកទឹកចិត្តរបស់អ្នកផ្តល់សម្ភាសឲ្យបន្តរស់នៅអាពាហ៍ពិពាហ៍ដោយបង្ខំ

| ការលើកទឹកចិត្តរបស់អ្នកផ្តល់សម្ភាសឲ្យបន្តរស់នៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំ(%) | | | |
|---|---|---|---|
| ទំនាក់ទំនងជិតស្និទ្ធ សេចក្តីអាណិត សេចក្តីស្រលាញ់ | មានកូនជាមួយសហព័ន្ធនៃការរៀបការដោយបង្ខំ | សំពាធឪពុកម្តាយ គ្រួសារ | ប្រពៃណី វប្បធម៌ |
| 55.8% | 36.5% | 3.8% | 3.8% |

ក្នុងការស្ទង់មតិដោយប្រើសំណួរបើក អ្នកផ្តល់សម្ភាសដែលរស់នៅក្នុងចំណងអាពាហ៍ពិពាហ៍ដោយបង្ខំ ហើយបានលើកឡើងអំពីចំណុចវិជ្ជមាន បានរៀបរាប់ពីស្ថានភាពដែលទទួលបានការគាំទ្រ និងគោរព (គូសហព័ន្ធរបស់ខ្ញុំអាចយល់ពីអារម្មណ៍របស់ខ្ញុំ យើងយល់ពីគ្នាទៅវិញទៅមកដើម្បីបង្កើតគ្រួសារមួយដែលប្រកបទៅដោយសន្តិភាព)។ អ្នកផ្សេងទៀតរៀបរាប់ទំនាក់ទំនងថា ផ្សាភ្ជាប់ទៅនឹងបទពិសោធន៍រួមនៃរបបប្រល័យពូជសាសន៍ ("ខ្ញុំមិនបានស្រលាញ់គាត់ជ្រាលជ្រៅណាស់ណាទេ ប៉ុន្តែខ្ញុំអាណិតប្រពន្ធរបស់ខ្ញុំដោយសារតែនាងមានភាពទ្រុឌទ្រោមយ៉ាងខ្លាំងផ្នែករាងកាយ ហើយក៏បាត់បង់សាច់ញាតិអស់ហើយដែរ")។

អ្នកផ្តល់សម្ភាសខ្លះបានរាយការណ៍ពីទំនាក់ទំនងដែលមានភាពអវិជ្ជមានដូចជា៖ ការធ្វើបាប លើរូបរាងកាយ ការធ្វើបាបដោយប្រើពាក្យសម្តី និង តាមរយៈសេដ្ឋកិច្ច ការស្អប់សហព័ន្ធរបស់ខ្លួន (ភាគច្រើនសំដៅចំពោះបុរសជាស្វាមី) ក្នុងរយៈពេលមួយដ៏យូរ បានទុកឲ្យសហព័ន្ធម្ខាងទៀតទទួលរងការយកចិត្តទុកដាក់ និងទំនុកបម្រុងកូនតែឯង ការសេពគ្រឿងស្រវឹង និងការមាក់ងាយ ("ជារឿយៗ គាត់មើលងាយគ្រួសារខ្ញុំពេលគាត់ស្រវឹង សហព័ន្ធរបស់ខ្ញុំមិនបានធ្វើល្អជាមួយខ្ញុំទេ នៅពេលដែលគាត់មានដៃគូថ្មី ប្តីរបស់ខ្ញុំទុកខ្ញុំឲ្យនៅតែឯងជាមួយកូន")។ ប្រហែលជាមូលហេតុអវិជ្ជមានទាំងនេះ អាចយកមកធ្វើការសង្ខេបរបស់ពាក្យសម្តីរបស់អ្នកផ្តល់សម្ភាស "ពួកយើងមានអារម្មណ៍ថាឃ្លាតឆ្ងាយពីគ្នា"។

នៅពេលដែលត្រូវបានគេស្នើឲ្យវាយតម្លៃទៅលើទំនាក់ទំនងរបស់ខ្លួន និងសហព័ន្ធ អ្នកផ្តល់សម្ភាសចំនួន៦៥.៣% បានរាយការណ៍អំពី "ទំនាក់ទំនងដែលជិតស្និទ្ធ និងកក់ក្តៅ"។ មួយភាគបីទៀត (៣៤.៨%) បានរាយការណ៍ពីទំនាក់ទំនងអវិជ្ជមាន នៅពេលដែលមានអ្នកផ្តល់សម្ភាស ១៨.៤% បានរាយកាណ៍ថាមិនមានទំនាក់ទំនងអ្វីសោះជាមួយសហព័ន្ធ និង ៨.២% រាយការណ៍ថាប្រាស្រ័យទាក់ទងគ្នានៅពេលចាំបាច់ ឬនៅពេលទំនាក់ទំនងមានបញ្ហា។

ក្នុងចំណោមអ្នកផ្តល់សម្ភាសដែលរស់នៅបន្តជាមួយការរៀបការដោយបង្ខំនោះ មានមនុស្សច្រើនជាងពាក់កណ្តាល (៥២.៩%) រាយការណ៍អំពីការធ្វើបាបពីសំណាក់សហព័ន្ធរបស់ខ្លួន តាំងពីរបបខ្មែរក្រហមមកដល់បច្ចុប្បន្ន ហើយភាគច្រើនបានរាយការណ៍ពីការធ្វើបាបលើរាងកាយ (៤៤.៤%) ការធ្វើបាបដោយប្រើប្រាស់ពាក្យសម្តី (៤៤.៤%) និងការគំរាមដោយពាក្យសម្តី (៧.៤%)។ មានអ្នកផ្តល់សម្ភាសម្នាក់បានរាយការណ៍ពីការរំលោភ និងហិង្សាផ្លូវភេទ នៅតែបន្តក្នុងជីវិតអាពាហ៍ពិពាហ៍ដោយបង្ខំនេះ។

តួលេខទី១៥៖ ប្រភេទនៃការធ្វើបាបពីសំណាក់សហព័ទ្ធដែលនៅតែបន្តក្នុងការរៀបការដោយបង្ខំ (%នៃអ្នកផ្តល់សម្ភាស)




ចំពោះអ្នកដែលធ្លាប់មានបទពិសោធន៍ទទួលបានការធ្វើបាបបំពានពីសហព័ន្ធស្ទើរតែពាក់កណ្តាល (៤៨.១%) បានរាយការណ៍ថាត្រូវបានគេធ្វើបាប ពីមួយទៅបីដងក្នុងមួយខែ, ១១.១% ទៀតរាយការណ៍ថា ត្រូវបានគេធ្វើបាបជារៀងរាល់ថ្ងៃ។ ស្ទើរតែជិតមួយភាគបួន (២២.២%) បានរាយការណ៍ថាត្រូវបានគេធ្វើបាបថ្មីៗចុងក្រោយកាលពីខែមុន។ អ្នកផ្តល់សម្ភាសចំនួន ១៨នាក់ (៦៦.៧%) បានរាយការណ៍ថាអំពើបំពានធ្វើបាបមកលើរូបគាត់ចុងក្រោយបង្អស់បានប្រព្រឹត្តទៅកាលពីច្រើនឆ្នាំកន្លងទៅ ដែលមាន២២.២% រាយការណ៍ថាបានកើតឡើងកាលពីប៉ុន្មានខែមុននេះ ៧.៤% រាយការណ៍ថាបានកើតឡើងកាលពី ៦ ខែមុន និង៣.៧% បានរាយការណ៍ថាកើតឡើងកាលពីឆ្នាំមុន។

តួលេខទី១៦៖ ប្រេកង់នៃការធ្វើបាបដែលទទួលបានជាបន្តក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំក្រោយរបបខ្មែរក្រហម (%នៃអ្នកផ្តល់សម្ភាស)



ក្នុងការស្ទង់មតិដោយប្រើសំណួរបើក ដើម្បីស្វែងយល់ពីសភាពនៃការធ្វើបាបពីសំណាក់សហព័ន្ធ មានអ្នកផ្តល់សម្ភាសម្នាក់បានរៀបរាប់ "ស្ទើរតែជារៀងរាល់ថ្ងៃដែលខ្ញុំទទួលបានហិង្សាផ្លូវភេទពីស្វាមីរបស់ខ្ញុំ។" ទម្រង់នៃការធ្វើបាបដទៃទៀតត្រូវបានរាយការណ៍ថាជាហិង្សាលើរូបរាងកាយរាប់បញ្ចូលទាំង ការវាយនឹងដំបង ការចាក់ ការទះកំផ្លៀង ដែលមានអ្នកផ្តល់សម្ភាសម្នាក់បានទទួលរងគ្រោះរបួសក្បាលដែលជាលទ្ធផលនៃហិង្សាពីសហព័ន្ធរៀបការដោយបង្ខំ ក្រោយរបបខ្មែរក្រហម។ ការធ្វើបាបដោយប្រើពាក្យសម្តី និងធ្វើបាបលើផ្លូវអារម្មណ៍រាប់បញ្ចូលទាំងការគំរាមដោយប្រើកាំបិត ការមាក់ងាយ ការដាក់បណ្តាសា និងការចោទប្រកាន់ថាផិត។ អ្នកផ្តល់សម្ភាសរងការធ្វើបាបផ្នែកសេដ្ឋកិច្ចម្នាក់បានរាយការណ៍ថា "ប្តីរបស់ខ្ញុំមិនបានប្រគល់ប្រាក់មកឲ្យខ្ញុំទ" ហើយបញ្ហានេះជាការគួរឲ្យកត់សម្គាល់ដោយសារថា ជាទូទៅប្រពន្ធជាអ្នកគ្រប់គ្រងលុយកាក់ក្នុងសង្គមគ្រួសារខ្មែរ។

ក្នុងការរៀបរាប់អំពីគុណភាពនៃទំនាក់ទំនងរបស់ពួកគេជាមួយកូនដែលបានមកពីចំណងអាពាហ៍ពិពាហ៍ដោយបង្ខំ, ចំនួនច្រើនលើសលុប(៩៥.២%) បានរាយការណ៍ពីទំនាក់ទំនងជិតស្និទ្ធនិងកក់ក្តៅ។ ក្នុងការវាយតម្លៃទំនាក់ទំនងគ្រួសារជាមួយកូនៗនិងសហព័ទ្ធរៀបការដោយបង្ខំ ៧៦.៧% បានរាយការណ៍ពីទំនាក់ទំនងជិតស្និទ្ធ និងកក់ក្តៅ និង១៨.៦% រាយការណ៍ពីទំនាក់ទំនងធម្មតា និង ៤.៧%ទៀតរាយការណ៍ពីទំនាក់ទំនងមិនជិតស្និទ្ធ។ក្នុងការស្ទង់មតិដោយប្រើសំណួរប្រភេទបើក អ្នកផ្តល់សម្ភាសបានរៀបរាប់អំពីទំនាក់ទំនងរវាងកូន និងសហព័ទ្ធរបស់ខ្លួន ថាជាសេចក្តីស្រលាញ់ ការគោរព និងពោរពេញទៅដោយ ការគាំទ្រ ("ពួកគេស្រលាញ់គ្នាណាស់ នៅពេលដែលឪពុករបស់គេឈឺ ពួកគេមើលថែគាត់ ពួកគេមើលថែគ្នាទៅវិញទៅមក ហើយពួកគេតែងតែលេងសើចជាមួយគ្នាជារឿយៗផងដែរ។ ការរៀបរាប់ភាពអវិជ្ជមានរវាងកូន និងសហព័ទ្ធរៀបការដោយបង្ខំ រួមមានអារម្មណ៍មិនជិតស្និទ្ធជាមួយគ្នា ការដែលមិនសូវប្រាស្រ័យទាក់ទងគ្នា ហើយ "ងាយនិងខឹងគ្នា"។ អ្នក ផ្តល់សម្ភាសម្នាក់ បានរាយការណ៍ថា "កូនរបស់ខ្ញុំស្អប់ឪពុករបស់គេ ដោយសារពួកគេឧស្សាហ៍ ឃើញគាត់វាយធ្វើបាបខ្ញុំ។"

នៅពេលដែលអ្នកផ្តល់សម្ភាសត្រូវបានគេសួរសំណួរប្រភេទបើកមួយចំនួនថា តើគាត់ពេញចិត្តជាមួយនឹងការបន្តជីវិតអាពាហ៍ពិពាហ៍ដោយបង្ខំនាពេលបច្ចុប្បន្នដែរឬទេ ចម្លើយវិជ្ជមាន(ពេញចិត្ត)រួមមាន "សារៈសំខាន់ដែលប្តីប្រពន្ធចេះជួយគ្នា មើលថែគ្រួសារ និង រកប្រាក់ចំណូលឲ្យបានច្រើនដើម្បីផ្គត់ផ្គង់គ្រួសារ"។ ចម្លើយដែលមិនពេញចិត្ត មានដូចជា "ខ្ញុំមិនបានស្រលាញ់សហព័ទ្ធរបស់ខ្ញុំទេ" "ខ្ញុំមិនចង់រស់នៅជាមួយគាត់ យើងមិនដែលស្គាល់គ្នា ដូច្នេះយើងមិនចង់ជួយគ្នាទេ" "ប្តីរបស់ខ្ញុំមិនដែលយល់ពីចិត្តខ្ញុំ ហើយគាត់ចាស់ជាងខ្ញុំច្រើនណាស់"។

ចម្លើយក៏បានបង្កើបនូវការមិនពេញចិត្ត ដោយសារការមិនបានបំពេញនូវលក្ខ័ណ្ឌនៃការរៀបការតាមប្រពៃណី "ខ្ញុំមានការអាក់អន់ចិត្តដោយសារខ្ញុំមិនបានរៀបការតាមប្រពៃណី" "ឪពុកម្តាយខ្ញុំមិនបានចូលរួមមង្គលការរបស់ខ្ញុំ" "ខ្ញុំគ្មានឱកាសក្នុងការជ្រើសរើសគូស្រករដោយខ្លួនឯង" ចម្លើយទាំងនេះក៏ត្រូវបានឆ្លុះបញ្ចាំងក្នុងកិច្ចសម្ភាសនៃករណីសិក្សា ដែលអ្នកផ្តល់សម្ភាសបានភ្ជាប់ជោគជ័យនិងសំណាងល្អនៃអាពាហ៍ពិពាហ៍ ទៅនឹងពិធីរៀបអាពាហ៍ពិពាហ៍នេះឯង។

### ង. ផលប៉ះពាល់នៃការរៀបការដោយបង្ខំ

ផលប៉ះពាល់រយៈពេលវែងត្រូវបានរាយការណ៍នៅក្នុងគ្រប់ទិដ្ឋភាពទាំងអស់ ទោះបីជាការរៀបការនោះនៅតែបន្ត ឬ បានបញ្ចប់ទៅហើយ ហើយទោះបីជាការបន្តនោះមានការពេញចិត្ត ឬ មិនពេញចិត្តក៏ដោយ។

នៅពេលដែលអ្នកផ្តល់សម្ភាសភាគច្រើន (៨៧.៦%) បានរាយការណ៍ថាគ្មានបញ្ហារូបរាងកាយដែលជាលទ្ធផលទទួលបានពីការរៀបការដោយបង្ខំនោះក៏ដោយ ក៏អ្នកដែលបានរាយការណ៍ បានលើកឡើងពីរបួសទាក់ទងនឹងការបន្តពូជ និងរបួសផ្សេងៗទៀត ដោយសារតែការរំលោភបំពានផ្សេងទៀតបង្កដោយសហព័ទ្ធ ដោយសារការវាយដំ និងដោយសារការរំលោភ។ ចំនួនច្រើនជាង មួយភាគបួនបន្តិច (២៧.៨%) បានរាយការណ៍អំពីដំណើរការផ្លូវភេទមិនល្អ រាប់បញ្ចូលទាំងបញ្ហារោគស្ត្រីផងដែរ ការមិនចាប់អារម្មណ៍នឹងបញ្ហាផ្លូវភេទ ការមិនមានចំណង់ផ្លូវភេទ ការភ័យខ្លាចការរួមសង្វាស់ជាមួយសហព័ទ្ធទី២។ អ្នកផ្តល់សម្ភាសម្នាក់បានផ្តល់មតិថា "ខ្ញុំមានអារម្មណ៍មិនស្រួលក្នុងទំនាក់ទំនងផ្លូវភេទនោះទេ នៅពេលដែលខ្ញុំនឹកឃើញដល់អតីតកាលរបស់ខ្ញុំ"។

ចំនួនអ្នកផ្តល់សម្ភាសច្រើនជាងពាក់កណ្តាល (៧០.២%) បានរាយការណ៍ពីបញ្ហាសុខភាពផ្លូវចិត្ត ដោយបានរៀបរាប់ក្នុងការឆ្លើយសំណួរបើកថា "មិនពេញចិត្តនឹងជីវិត" ហើយមានការខកចិត្តយ៉ាងខ្លាំងជាមួយនឹងការរៀបការដោយបង្ខំ ពិសេសនៅពេលដែលចូលរួមកម្មវិធីមង្គលការ ឬ ឮភ្លេងប្រពៃណីនៃពិធីមង្គលការ។ អ្នកខ្លះទៀតងាយនឹងធាប់ខឹង តក់ស្លុត និងមិនងាយចាកចេញពីភាពភ័យរន្ធត់ នៅពេលដែលពួកគេនឹកឃើញកម្មវិធីនៃការរៀបការដោយបង្ខំរបស់ពួកគេ។ រោគសញ្ញាទាំងនោះរួមមាន ការតក់ស្លុត ភ័យក្នុងខ្លួន ភាពក្រៀមក្រំ ភាពលំបាកវេទនា ការយល់សុបិនអាក្រក់ ជាពិសេសសំដៅទៅលើការដែលត្រូវបានចាប់រំលោភពីសហព័ទ្ធរបស់ខ្លួន។

ចំនួនមួយភាគបីនៃអ្នកផ្តល់សម្ភាស (៣៥.៤%) ក៏បានលើកឡើងផងដែរនូវភាពលំបាកវេទនាផ្នែកសេដ្ឋកិច្ចដែលប៉ះពាល់ដោយសារការរៀបការដោយបង្ខំនេះ។ សម្រាប់អ្នកផ្តល់សម្ភាសខ្លះ ពួកគេបានរាយការណ៍ថាមានលក្ខណៈធ្ងន់ធ្ងរខ្លាំង ពិសេសនៅពេលដែលសហព័ទ្ធរបស់ខ្លួនមិនព្រមចែករំលែកក្នុងការទ្រទ្រង់គ្រួសារ ឬ នៅពេលដែលសហព័ទ្ធរូបនោះមានបែកផ្លូវគ្នាជាមួយគ្រួសារ ដូចនេះហើយការចំណាយផ្សេងៗ និងទំនួលខុសត្រូវទាំងអស់បានធ្លាក់ទៅលើសហព័ទ្ធដែលនៅជាមួយកូន និងសមាជិកគ្រួសារដទៃទៀត។ យ៉ាងហោចណាស់ក៏មានអ្នកផ្តល់សម្ភាសម្នាក់ដែរ ដែលបានរាយការណ៍ថាដកខ្លួនចេញពីការងារសហគមន៍ ម្ល៉ោះហើយទើបប្រាក់ចំណូលរបស់គាត់ធ្លាក់ចុះ ព្រោះតែអារម្មណ៍នៃការអាម៉ាស់ និងក្តីបារម្ភខ្លាចជួបនរណាម្នាក់ដែលគាត់ស្គាល់ប្រវត្តិពីរបបខ្មែរក្រហម។

តាមពិតទៅ ចំនួនច្រើនជាងមួយភាគបួននៃអ្នកផ្តល់សម្ភាស (២៥.៧%) បានរាយការណ៍ថា ធ្លាប់មានបទពិសោធន៍ជួបប្រទះបញ្ហាសង្គម ដែលជាលទ្ធផលនៃការរៀបការដោយបង្ខំ ដែលមានភាពអាម៉ាស់ដោយសារមិនបានគោរពតាមការរៀបការតាមក្បួនខ្នាតប្រពៃណី ឬ ក៏ត្រូវបានដកចេញពីកម្មវិធីរៀបការដោយសារ "បុព្វបុរសមិនបានដឹងឮអំពីពិធីមង្គលការរបស់ខ្លួន"។ អ្នកផ្តល់សម្ភាសបានរាយការណ៍ថា ប្តីប្រពន្ធនៃការរៀបការដោយបង្ខំ មិនត្រូវបានគេរាប់ចូលក្នុងសហគមន៍ឡើយ ដែលមានអ្នកផ្តល់សម្ភាសម្នាក់បាននិយាយថា "គ្រួសាររបស់ខ្ញុំត្រូវបានគេរើសអើង ដោយសារតែខ្ញុំត្រូវបានគេចាប់ឲ្យរៀបការទាំងបង្ខំក្នុងរបបខ្មែរក្រហម"។

អ្នកផ្តល់សម្ភាស ១២%លើកឡើងថាបញ្ហាសង្គមដែលជួបប្រទះគឺបញ្ហាទៅលើកូនដែលទទួលបានពីការរៀបការដោយបង្ខំនោះ ដោយកូនទាំងនោះមិនត្រូវបានគេឲ្យធ្វើជាអ្នកកំដរកូនក្រមុំឬកូនកម្លោះទេ ហើយជួបប្រទះនឹងការរើសអើងផ្សេងៗទៀតក្នុងសហគមន៍ "ដោយសារតែពួកគេគិតថាកូនរបស់ខ្ញុំមានឪពុកម្តាយដែលមិនបានរៀបការជាផ្លូវការ"។

តួលេខទី១៧៖ ផលប៉ះពាល់ដែលអ្នករស់រានមានជីវិតទទួលបានពីការរៀបការដោយបង្ខំ (%នៃអ្នកផ្តល់សម្ភាស)




## ៤.២ លទ្ធផលបានមកពីករណីសិក្សា (បែបគុណនាពវិស័យ)

បទសម្ភាសករណីសិក្សាបានផ្តល់សុពលភាព និង ពង្រីកលទ្ធផលនៃការសិក្សាទៅលើការរៀបការដោយបង្ខំក្នុងរបបខ្មែរក្រហម ដូចដែលបានបង្ហាញក្នុងការពិនិត្យឡើងវិញទៅលើការសិក្សាពីមុនៗមក និង នៅក្នុងលទ្ធផលបែបបរិមាណនៃការសិក្សានេះ ហើយដូចដែលបានបង្ហាញនៅខាងលើ៖ ការរៀបការដោយបង្ខំ និងការរួមភេទដោយបង្ខំ ភាគច្រើនដោយគ្មានជម្រើស និងគ្មានការយល់ព្រម ហើយដែលភាគច្រើនគឺប្រព្រឹត្តទៅដោយការ គំរាមកំហែង និងការដាក់ទណ្ឌកម្ម រួមបញ្ចូលទាំងហិង្សាផ្លូវភេទ។ នៅពេលដែលលទ្ធផលដែលបានរកឃើញមិនអាចតំណាងជាលក្ខណៈទូទៅបាន ដោយសារតែវាផ្តោតសំខាន់ទៅលើតែសំណាកមួយភាគតូចនៃករណីសិក្សាក៏ដោយ ក៏ពួកគេបានផ្តល់ព័ត៌មានកាន់តែស៊ីជម្រៅទៅលើនិយមន័យ និង ផលប៉ះពាល់រយៈពេលខ្លីនិងរយៈពេលវែងនៃការរៀបការទាំងនេះ។

ក្នុងពេលជាមួយគ្នានេះ ករណីសិក្សាទាំងនេះពង្រីកបន្ថែមទៅលើលទ្ធផល ដែលគេបានរកឃើញនៅក្នុងការស្រាវជ្រាវពីមុនៗមក។ ពួកគេបានឲ្យយោបល់ថា អ្នកដឹកនាំមូលដ្ឋានត្រូវបានមហិច្ឆិតានយោបាយជំរុញទឹកចិត្តក្នុងការអនុវត្តគោលនយោបាយនៃការរៀបការដោយបង្ខំ ដែលរឿងនេះក៏ត្រូវថ្នាក់ដឹកនាំជាន់ខ្ពស់ដឹង ហើយជម្រុញឲ្យមានការអនុវត្តផងដែរ។ អ្នកផ្តល់សម្ភាសបានលើកឡើងថា ស្វាមីត្រូវបានបង្ខំឲ្យរំលោភប្រពន្ធរបស់ខ្លួនដើម្បីទុកជា សក្ខីភាពនៃអាពាហ៍ពិពាហ៍របស់ពួកគេ។ ពួកគេបានផ្តល់នូវព័ត៌មានជាច្រើនដែលទាក់ទងទៅនឹងហិង្សាក្នុងគ្រួសារ នៃអាពាហ៍ពិពាហ៍បង្ខំ ការកើនឡើង ការរំលោភបំពានក្នុងចំណងអាពាហ៍ពិពាហ៍បង្ខំក្រោយពីការដួលរលំនៃរបបខ្មែរក្រហម និងរបៀបដែលការរៀបការដោយបង្ខំ

បានផ្តល់បទពិសោធន៍ និងការបន្តផលវិបាកផ្សេងគ្នាសម្រាប់បុរស និងស្ត្រីនៅបរិបទនៃសង្គមវប្បធម៌នេះ។

សំណាកសម្រាប់ករណីសិក្សាបានចាប់យកបានទម្រង់ពិសេស ដូចគ្នាទៅនឹងករណីច្រើនលើសលប់ទាំងឡាយ និងករណីជាក្រុមដែលផ្អែកលើអត្តសញ្ញាណជាតិពន្ធ-សាសនាផងដែរ។ការវិភាគបន្ទាប់មកទៀតពឹងផ្អែកទៅលើកិច្ចសម្ភាសចំនួន៨ជាមួយនឹងអ្នកផ្តល់សម្ភាសចំនួន ៩នាក់ រួមបញ្ចូលទាំងប្តីប្រពន្ធមួយគូ (ដែលផ្តល់កិច្ចសម្ភាសរួមគ្នា) ដែលរក្សាចំណងអាពាហ៍ពិពាហ៍ របស់គាត់តាំងពីពេលរបបខ្មែរក្រហមដួលរលំ។ ក្នុងចំណោមអ្នកផ្តល់សម្ភាស ៩នាក់ មានបុរសពីរនាក់រួមទាំងបុរសជាស្វាមីនៃប្តីប្រពន្ធដែលផ្តល់សម្ភាសរួម ហើយមាន ៨នាក់ជាជន ជាតិខ្មែរ និងម្នាក់ទៀតជាជនជាតិចាម។ អ្នកទាំងអស់គ្នាត្រូវបានគេឲ្យចូលរួមក្នុងការរៀបការដោយបង្ខំដែលបានរៀបចំដោយរបបនេះ ហើយមនុស្សភាគច្រើនបានប្រកែកអ្នកខ្លះគ្រោង នឹងតវ៉ាហើយមានមនុស្សស្រីតែម្នាក់គត់ដែលបានបដិសេធដាដាច់ខាត។ស្ត្រីពីរនាក់ដែលបានរៀបការមុនរបបនេះចូលកាន់កាប់ ត្រូវបានគេរៀបចំឲ្យរៀបការសារជាថ្មីក្រោយពេលដែល ស្វាមីរបស់គាត់ត្រូវបានគេយកទៅសម្លាប់ចោល។ កិច្ចសម្ភាសពីរបានបញ្ជាក់ប្រាប់ថាចំណងនៃ ការរៀបការដោយបង្ខំនៅតែបន្ត ហើយម្នាក់បានប្រាប់ថាមានសុភមង្គល និងម្នាក់ទៀតបាន ប្រាប់ថាទទួលរងការរំលោភបំពានធ្ងន់ធ្ងរ។ បន្ថែមលើនេះទៅទៀត មានអ្នកផ្តល់សម្ភាសពីរនាក់គឺជាកូនក្រមុំជាកុមារី (អាយុប្រហែល១៥ឆ្នាំ) ម្នាក់ បានរៀបការមុនពេលរបបខ្មែរក្រហម ហើយម្នាក់ទៀតរៀបការក្នុងរបបខ្មែរក្រហម។

### ក. ការរៀបការមុនរបបខ្មែរក្រហម

យោងទៅតាមកិច្ចសម្ភាសនៃករណីសិក្សា មុនពេលរបបខ្មែរក្រហមចូលកាន់កាប់ ឪពុកម្តាយ ឬញាតិផ្សេងៗទៀត ជារឿយៗស្នើសុំអនាគតកូនកំលោះ ឲ្យរៀបចំមង្គលការតាមប្រពៃណី។ គូស្រករទាំងពីរ ស្គាល់គ្នាតាមជីវិតរស់នៅក្នុងភូមិ ឬតាមរយៈទំនាក់ទំនងសង្គមនានា។ ទោះបីជាការរៀបចំមង្គលដែលមានគម្រោងត្រូវបានធ្វើឡើងដោយឪពុកម្តាយក៏ដោយក៏វានៅមានការវាយតម្លៃសមត្ថភាពនៃស្ថានភាពគ្រួសារ សេដ្ឋកិច្ច អត្តចរិត កិរិយាមាយាទដែលឪពុកម្តាយមួយចំនួនបានបដិសេធមង្គលការរបស់កូនស្រីខ្លួន ពិសេសកូនស្រី ប្រសិនបើមង្គលការនោះខុសពីគោលគំនិតរបស់ពួកគេ។

មង្គលការតាមបែបប្រពៃណីខ្មែរ បានរៀបរាប់ពីចំណងដែលនាំឲ្យមានសុពលភាព និងធ្វើឲ្យមង្គលការស្របច្បាប់ ក្នុងសង្គម គ្រួសារ និងគោរពតាមដូនតា។ អាពាហ៍ពិពាហ៍មានការចូលរួមពី កូនកំលោះ កូនក្រមុំ មេបាទាំងសងខាង វិញ្ញាណក្ខន្ធដូនតា ដោយប្រើប្រាស់

ពិធីសាសនាជាច្រើនដូចជា ការសូត្រមន្ត កាត់សក់ ចងដៃ ប្រោះព្រំ ភ្លេងការ ផ្លែឈើមួយចំនួន និង ពិសេសគឺផ្កាស្លា នំ បង្អែម។ កូនកំលោះ កូនក្រមុំស្លៀកសម្លៀកបំពាក់ដែលមើលទៅដូចជាអ្នកមានប្រាក់ស្តុកស្តម ជាច្រើនសម្រាប់ ក្នុងអំឡុងពេលបីថ្ងៃនៃពីធីនេះ។

ប្រហែលជាជាតុសំខាន់បំផុតនៃមង្គលការបែបប្រពៃណីខ្មែរ គឺជាការចូលរួម និង ការទទួលស្គាល់ពីឪពុកម្តាយ សមាជិកគ្រួសារ បុព្វបុរសដូនតា។ ក្រៅពីឪពុកម្តាយ មង្គលការប្រពៃណីខ្មែរតម្រូវឲ្យមាន មេអណ្តើក អាចារ្យ ដែលជាអ្នករើសយកថ្ងៃវេលាល្អសម្រាប់រៀបការកូនប្រុសស្រី ព្រមទាំងព្រះសង្ឃផងដែរ។ ចាស់ទុំក៏មានតួនាទីសំខាន់ផងដែរក្នុងការប្រព្រឹត្តទៅនៃបុណ្យប្រពៃណី និងសាសនាទាំងអស់នេះផងដែរ។ វត្តមានរបស់ឪពុកម្តាយមានសារៈសំខាន់ ដើម្បីបង្ហាញពីគោលបំណងនៃមង្គលការថាជាការរួមគ្នាក្នុងការបង្កើតសម្ព័ន្ធភាព ជាជាងការសម្រេចចិត្តរបស់មនុស្សតែពីនាក់[63]។

អ្នកផ្តល់សម្ភាសក្នុងករណីសិក្សាបានរៀបរាប់ពីអត្ថន័យនៃ "ស្វាមីល្អ" និង "ភរិយាល្អ" ដោយផ្អែកសំខាន់ទៅលើ "ច្បាប់ស្រី"។ "ស្វាមីល្អ" ត្រូវបានរៀបរាប់ថាជាអ្នកដែលជួយចិញ្ចឹមបីបាច់ថែរក្សាកូន ជួយទ្រទ្រង់គ្រួសារ និងស្វែងរកប្រាក់ចំណូល[64]។ គាត់មិនចេះលេងល្បែង មិនមានប្រពន្ធចុង មិនសេពសុរា និង មិនដើរលេងយប់។[66]"ភរិយាល្អ" ជាស្ត្រីដែលស្រលាញ់ស្វាមី កូន និងឪពុកម្តាយ ដែលមានតួនាទីរក្សាសុភមង្គលក្នុងគ្រួសារ។ តួនាទីនៃចំណងអាពាហ៍ពិពាហ៍ត្រូវបានបកស្រាយដោយឡែក ដែលស្ត្រីជាប្រពន្ធមានតួនាទីបន្ទាប់ហើយបុរសជាប្តីមានតួនាទី និងអំណាចធំជាង។ ការឲ្យនិយមន័យបែបប្រពៃណីនៃមង្គលការល្អ បើយោងតាមអ្នកផ្តល់សម្ភាសម្នាក់ បាននិយាយថា គឺ "នៅពេលដែលបុរសជាប្តីមិនបង្កបញ្ហានៅផ្ទះ។ពួកយើងជាមនុស្សស្រីដូចគ្នាដូច្នេះយើងត្រូវពឹងពាក់លើបុរសហើយសុភមង្គលរបស់យើងក៏ត្រូវពឹងផ្អែកលើបុរសដែរ។"[67]

អាពាហ៍ពិពាហ៍ជាធម្មតា ឬ មង្គលការ ត្រូវបានរៀបចំឡើងដើម្បីលើកតម្លៃស្ត្រី ហើយមង្គលការបានលើកកម្ពស់សមភាពយេនឌ័រដោយស្ងាត់ស្ងៀម។អ្នកផ្តល់សម្ភាសភេទប្រុសម្នាក់បាននិយាយថា "ខ្ញុំគិតថា មង្គលការមានភាពអស្ចារ្យ និងរុងរឿងណាស់សម្រាប់ស្ត្រី"។[68]

---

63 អវត្តមានរបស់ឪពុកម្តាយក្នុងការរៀបការដោយបង្ខំរបស់របបខ្មែរក្រហមត្រូវបានលើកឡើងគ្រប់ករណីនៃកិច្ចសម្ភាស
64 កិច្ចសម្ភាសករណីសិក្សាទី៤, ស្ត្រី (ថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៤)
65 កិច្ចសម្ភាសករណីសិក្សាទី៣, គូស្វាមីភរិយា (ថ្ងៃទី២៣ មេសា ២០១៤)
66 IBD
67 កិច្ចសម្ភាសករណីសិក្សាទី៨, ស្ត្រីខ្មែរឥស្លាម (ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៤)។ មើលករណីសិក្សាទី៣, គូស្វាមី "សុភមង្គលគ្រួសារ និងសំណាងរបស់ស្ត្រី និង គ្រួសារ ត្រូវពឹងផ្អែកទៅលើទង្វើរ និង អាកប្បកិរិយារបស់បុរសជាប្តី", ដែលបានលើកឡើងដោយបុរសជាប្តី។
68 កិច្ចសម្ភាសករណីសិក្សាទី៦, ស្ត្រី (ថ្ងៃទី២៨ មេសា ២០១៤)

សូម្បីអ្នកដែលមិនបានរៀបការតាមប្រពៃណី ក៏អាចយល់ដឹងអំពីតម្លៃនៃការរៀបការតាមប្រពៃណី និងទំនៀមទំលាប់ផងដែរ ភាគច្រើនយល់ដឹងដោយសារធ្លាប់ចូលរួមពិធីមង្គលការកាលពីនៅកុមារភាព។ អបជ និង សជ ត្រូវបានគេបង្ខំឲ្យរៀបការក្នុងរបបខ្មែរក្រហម ហើយបានរស់នៅជាមួយគ្នារហូតសព្វថ្ងៃ។ ការផ្តល់កិច្ចសម្ភាសជារួមរបស់ពួកគាត់ បានបង្ហាញឲ្យឃើញនូវឆន្ទៈចង់បាន និងផលប្រយោជន៍ទៅដល់បុរស និងស្ត្រីដែលបានរៀបការក្នុងមង្គលការមានចាស់ទុំផ្សំផ្គុំ។ នេះគឺជាឱកាសសម្រាប់ពួកគាត់បញ្ចេញនូវភាពសោកស្តាយក្នុងការខកខានមិនបានទទួលបានការរៀបអាពាហ៍ពិពាហ៍បែបនោះ ក្នុងសម័យកាលរៀបការដោយបង្ខំរបស់គាត់។ក្នុងមង្គលការបែបប្រពៃណីពួកគេចែករំលែកសេចក្តីស្រលាញ់ឬយ៉ាងហោចណាស់ភាពស្របគ្នា ដែលជាផ្នែកមួយនៃការគណនា ដើម្បីធ្វើការសម្រេចចិត្តទៅលើផ្នែកសេដ្ឋកិច្ច។ ចំណាប់អារម្មណ៍ភាគច្រើនដែលទទួលបានពីកិច្ចសម្ភាស គឺការរៀបចំពិធីនេះឯងដើម្បីបញ្ជាក់ពីការទទួលស្គាល់ និងភាពស្របច្បាប់នៃមង្គលការនោះ។ អ្នកផ្តល់សម្ភាសបានបកស្រាយពីបទពិសោធន៍របស់ស្ត្រីដែលទទួលបានការផ្លាស់ប្តូរក្នុងចំណងអាពាហ៍ពិពាហ៍ (ដូចជាខ្មោចដូរកាយ)ក្នុងស្ថានភាពជាអ្នកបំរើឲ្យចំណង់ដែលប្តីរបស់គាត់ត្រូវការ។ ដើម្បីជាជំនួយដល់អ្នកអានសម្រង់ខាងក្រោមនេះ ប្រើប្រាស់ពាក្យប្តីឬប្រពន្ធជំនួសការប្រើពាក្យដើមរបស់ឈ្មោះ។

**អ្នកសម្ភាស៖** តើការរៀបការត្រូវតែផ្តោតសំខាន់ទៅលើបំណងរបស់ឪពុកម្តាយឬយ៉ាងណា?

**ប្តី៖** មិនមែនទាំងស្រុងនោះទេ មង្គលការមិនអាចកើតឡើងនោះទេលុះត្រាតែមានការព្រមព្រៀងពីកូននិងឪពុកម្តាយ។

**អ្នកសម្ភាស៖** តើការព្រមព្រៀងមានសារៈសំខាន់ណាស់មែនទេ?

**ប្រពន្ធ៖** ចាស ពិតជាមានសារៈសំខាន់។

**ប្រពន្ធ៖** ឧទាហរណ៍ ប្រសិនបើឪពុកម្តាយរបស់អ្នកបង្ខំឲ្យអ្នករៀបការជាមួយបុរសដែលអ្នកមិនស្រលាញ់ តើអ្នកនឹងធ្វើយ៉ាងណា? ប្រសិនបើយើងរៀបការដោយគ្មានស្នេហា នោះយើងក៏គ្មានសុភមង្គលនៅក្នុងជីវិតដែរ ទោះបីជាមនុស្សប្រុសនោះមានលុយច្រើនប៉ុណ្ណាក៏ដោយ។

**អ្នកសម្ភាស៖** តើការរៀបការមានន័យយ៉ាងណាចំពោះបុរស?

**ប្តី៖** វាអាស្រ័យទៅតាមបុរសផ្សេងៗគ្នា។ អ្នកខ្លះយល់ថាគេមិនចង់រៀបការដោយសារខ្លាចមានកូន បាត់បង់សេរីភាព មិនអាចដើរលេងជាមួយមិត្តភ័ក្តរបស់គេបាន។ ប៉ុន្តែបុរសមួយចំនួននៅតែចង់រៀបការដោយសារគាត់ខ្លាចពេលគាត់ចាស់ទៅ ត្រូវនៅម្នាក់ឯង។

**ប្រពន្ធ៖** សម្រាប់ខ្ញុំ ជីវិតនៅលីវ ឬ នៅជាមួយឪពុកម្តាយមានភាពងាយស្រួលជាងនៅជាមួយស្វាមី។ ពេលដែលខ្ញុំមានស្វាមី ខ្ញុំគិតថាវាពិបាក។

**អ្នកសម្ភាស៖** ហេតុអ្វីបានជាអ្នកគិតថាវាមានភាពលំបាកនៅពេលដែលមានស្វាមី?
**ប្រពន្ធ៖** ខ្ញុំត្រូវមើលថែកូនរបស់ខ្ញុំ ខ្ញុំក៏ត្រូវស្វែងរកប្រាក់ដើម្បីជួយផ្គត់ផ្គង់គ្រួសារ ហើយខ្ញុំក៏ត្រូវរៀបចំអនាគតឲ្យកូនរបស់ខ្ញុំ។ ជីវិតរបស់មនុស្សស្រីត្រូវតែផ្លាស់ប្តូរទាំងស្រុងក្រោយពេលរៀបការដូចជា"ខ្មោចដូរកាយ"។យើងមិនអាចដើរលេងបានដោយសេរី យើងត្រូវតែប្រាប់ស្វាមីពីកន្លែងដែលយើងត្រូវទៅ។ ប្រសិនបើយើងមិនគោរពគ្នាទៅវិញទៅមក យើងអាចចែកផ្លូវគ្នាបានដោយងាយ។ យើងមិនអាចស្លៀកពាក់តាមចិត្តដែលយើងចង់ យើងត្រូវប្រាប់ទៅស្វាមីពីចំណាយដែលយើងចាយ។ បុរសខ្លះមិនចូលចិត្តឲ្យប្រពន្ធស្លៀកពាក់ស៊ិចស៊ី ហើយបុរសខ្លះចូលចិត្ត។ ដូច្នេះស្ត្រីត្រូវតែគិតពីចំណង់ចំណូលចិត្តរបស់ស្វាមីខ្លួន។
**អ្នកសម្ភាស៖** តើមង្គលការមានន័យយ៉ាងណាចំពោះស្ត្រី?
**ប្រពន្ធ៖** និយមន័យនៃមង្គលការគឺជាផលអាក្រក់ដែលយើងមើលមិនឃើញ។ មង្គលការមានតម្លៃចំពោះស្ត្រីព្រោះអ្នកគ្រប់រូបទទួលស្គាល់មនុស្សស្រីដែលរៀបការហើយថាជាកូនស្រីល្អ និងចេះស្តាប់បង្គាប់។ ស្ត្រីដែលចេះតុបតែងខ្លួនស្អាតបាត និងចេះរាក់ទាក់ទទួលភ្ញៀវ។ មង្គលការមានសារៈសំខាន់ណាស់សម្រាប់ស្ត្រីខ្មែរ។ ប្រសិនបើយើងស្រលាញ់គ្នាដោយគ្មានការទទួលស្គាល់ពីឪពុកម្តាយ ឬបងប្អូន ហើយយើងរត់តាមគ្នា (ពង្រត់គ្នា) វាមិនមែនជាការល្អទេ។ ក្នុងប្រពៃណីខ្មែរ កូនត្រូវតែស្តាប់បង្គាប់ឪពុកម្តាយ ហើយមង្គលការត្រូវតែមានការយល់ព្រមពីឪពុកម្តាយ ហើយគាត់ជាអ្នករៀបចំឲ្យ។ ប្រសិនបើកូនមិនគោរពឪពុកម្តាយហើយសម្រេចចិត្តរៀបការដោយខ្លួនឯង នោះគេមិនមែនជាកូនល្អឡើយ។
**ប្តី៖** សម្រាប់បុរស វាក៏ដូចគ្នាដែរព្រោះកូនប្រុសត្រូវគោរពនិងស្តាប់តាមការយល់ព្រមរបស់ឪពុកម្តាយ។ ប្រសិនបើបុរសម្នាក់ស្រលាញ់នារីម្នាក់ដែលឪពុកម្តាយមិនពេញចិត្ត ហើយគាត់នៅតែរៀបការជាមួយនារីនោះ គ្រួសារនោះនឹងមិនសប្បាយចិត្តឡើយ។[69]

ប្រសិនបើការយល់ព្រមត្រូវបានលើកឡើង ការរៀបការត្រូវបានកំណត់សំគាល់ថាជាការគោរព និងការស្តាប់ដំបូន្មានរបស់កូនចំពោះឪពុកម្តាយ ដែលបានណែនាំនូវសារៈសំខាន់នៃមង្គលការក្នុងការផ្សាភ្ជាប់គ្រួសារទាំងមូល ក៏ដូចជាសង្គម ជំនឿមិនល្អចំពោះមង្គលការណាដែលមិនប្រព្រឹត្តតាមក្បួនខ្នាត។ ចំពោះស្ត្រីការគោរពប្រណិបត្តិក៏ត្រូវបន្តចំពោះប្តី បន្ថែមពីលើឪពុកម្តាយទៅទៀត។

[69] កិច្ចសម្ភាសករណីសិក្សាទី៣, គូស្វាមីភរិយា (ថ្ងៃទី២៣ មេសា ២០១៤)

មង្គលការកុមារ[70]កើតឡើងក្នុងរូបភាពជាផ្នែកមួយនៃការយល់ព្រមដោយប្រពៃណី។ អ្នកផ្តល់សម្ភាសរបស់ករណីសិក្សាមួយ ជផ បានរៀបការនៅអាយុប្រហែល ១៥ឆ្នាំ ជាមួយស្វាមីរបស់គាត់អាយុ ៣៥ឆ្នាំ។ រឿងរបស់ ជផ បានបកស្រាយពីតួនាទីដែលគ្រប់គ្រងដោយសំពាធគ្រួសារ ហើយភាពឯករាជ្យរបស់ស្ត្រីភាគច្រើនស្ថិតនៅការរៀបការដោយផ្សំផ្គុំ។ គាត់ក៏បានរំលឹកឡើងផងដែរអំពី ការពិនិត្យពិច័យ និងការរឹតត្បិតនៃជម្រើសជីវិតដែលកូនស្រីបានជួបប្រទះ ក្នុងន័យដែលថាត្រូវរក្សាព្រហ្មចារីយ ត្រូវគេឲ្យតម្លៃថាជាប្រពន្ធល្អ។ ម្តាយគាត់បានប្រាប់កាលពីគាត់នៅជាកុមារីថា "កូនមិនចាំបាច់ទៅរៀនទេ ព្រោះថាបើកូនទៅរៀនកូននឹងចេះសរសេរ ហើយកូននឹងអាចសរសេរសំបុត្រឲ្យទៅមិត្តប្រុសរបស់កូន"។ នៅពេលដែល ជផ រៀបការដោយការផ្សំផ្គុំរបស់បងស្រី និងម្តាយគាត់ ព្រោះឪពុកគាត់បានទទួលមរណៈភាពបាត់ទៅហើយ។ ទោះជាយ៉ាងណាក៏ដោយ ក្នុងការបកស្រាយពីមូលហេតុដែលនាងព្រមទទួលយកបុរស ដែលមានអាយុប្រហាក់ប្រហែលនឹងឪពុកនាងទៅហើយ ជផ បានលើកឡើងពីការគោរពប្រណិបត្តិ និងធ្វើតាមបំណងរបស់ឪពុកគាត់ (ក្នុងន័យថាជាបុព្វបុរសជូនតាដទៃទៀតរបស់គ្រួសារ) ថាជាផ្នែកមួយនៃការសម្រេចចិត្តរបស់គាត់។

> ខ្ញុំមិនបានទៅសាលារៀនទេ ខ្ញុំមើលថៃក្របីរបស់គ្រួសារ ហើយធ្វើការសស្រាក់សស្រាំនៅក្នុងស្រែ។ ពេលដែលខ្ញុំទទួលបានគេដណ្តឹងសុំរៀបការ ខ្ញុំប្រគល់ការសម្រេចចិត្តឲ្យទៅម្តាយ និងបងស្រីជាអ្នកសម្រេច។ ខ្ញុំរៀបការនាអាយុ ១៥ ឆ្នាំ។ បងស្រីខ្ញុំប្រាប់ថា ប្រសិនបើមានបុរសអ្នកមានឯណាចង់រៀបការជាមួយខ្ញុំ គាត់នឹងយល់ព្រម។ ដោយសារតែបុរសដែលមកសុំខ្ញុំរៀបការមានគ្រួសារជាអ្នកមាន គាត់អនុញ្ញាតិឲ្យខ្ញុំរៀបការជាមួយគាត់។ ខ្ញុំមិនបានបដិសេធនោះទេ ខ្ញុំធ្វើតាមបងស្រីម្តាយ និងឪពុកខ្ញុំ។ ប្រសិនបើពួកគាត់ចង់ឲ្យខ្ញុំរៀបការជាមួយនរណាម្នាក់ ខ្ញុំនឹងយល់ព្រម។ ហើយប្រសិនបើមានបញ្ហាអ្វីកើតឡើងដោយសារជម្រើសនេះ ពួកគាត់នឹងមើលថៃខ្ញុំ។ ប៉ុន្តែបើខ្ញុំជ្រើសរើសដោយខ្លួនឯង ពួកគាត់មិនមើលថៃខ្ញុំទេប្រសិនបើមានបញ្ហាអ្វីមួយកើតឡើង។[71]

ដូចដែល ជផ និង អ្នកផ្តល់សម្ភាសដទៃទៀតបានលើកឡើង គ្រួសារដែលបានរៀប ចំមង្គលការត្រូវមានកាតព្វកិច្ចដំណើរការក្នុងនាមជាប្រព័ន្ធសុវត្ថិភាពពិសេសសម្រាប់ស្ត្រីប្រសិនបើមង្គលការបានរលាយ។ ទំនៀមទំលាប់នៃមង្គលការដោយរៀបចំត្រូវបានអ្នកផ្តល់

[70] ជាទូទៅ កុមារមិនត្រូវបានគេចាត់ទុកថាជាតំណែងមួយដែលត្រូវគេផ្តល់សិទ្ធិឲ្យមានការយល់ព្រមទេ ដោយសារតែអសមត្ថភាពក្នុងការសម្រេចចិត្តនៅក្នុងគ្រួសារ។

[71] កិច្ចសម្ភាសករណីសិក្សាទី២, ស្ត្រី (ថ្ងៃទី២៥ មេសា ២០១៤). មើលកិច្ចសម្ភាសករណីសិក្សាទី៨, ស្ត្រីខ្មែរឥស្លាម (ថ្ងៃទី២៨ មិថុនា ២០១៤)

សម្ភាសរៀបរាប់ថា ជាការយល់ព្រមប្រគល់សិទ្ធិទៅឲ្យឪពុកម្ដាយ និងសមាជិកគ្រួសារជាអ្នកចចារ ដើម្បីទាមទារនូវផលប្រយោជន៍មួយសម្រាប់គ្រួសារ ឬ ការសម្រេចបំណងអ្វីមួយ(ពិសេសកូនស្រី៖ "ពេលឪពុកម្ដាយរើសឲ្យ គាត់រើសយកអ្នកដែលល្អសម្រាប់កូនស្រីគាត់")[72]។ ស្របគ្នាទៅនឹងបំណងរបស់ឪពុកម្ដាយ ដែលត្រូវបានបកស្រាយថាជាសញ្ញានៃភាពពេញវ័យ និងការគោរពគ្រួសារព្រមទាំងសភាពល្អទាំងមូលរបស់វា។ បន្ថែមពីលើនេះទៅទៀត ក្នុងករណីជផ ដែលត្រូវបានគេផ្ដល់ការសម្រេចចិត្តតិចតួចណាស់ដោយសារតែវ័យរបស់គាត់ ការបង្ខិតបង្ខំ និង ការគម្រាមកំហែងមិនត្រូវបានគេលើកយកមកនិយាយឡើយ។ ជផ បានរៀបរាប់តំណាក់កាលនៃមង្គលការរបស់គាត់ថា "ពោរពេញទៅដោយការចុះសម្រុងគ្នា" ដោយគ្មានការធ្វើបាបក្នុងអំឡុងពេលមុនរបបខ្មែរក្រហមចូលកាន់កាប់ទេ។

គោលបំណងចំបងសំខាន់បំផុតនៃការរៀបការតាមប្រពៃណីគឺដើម្បីបង្កើតគ្រួសារមួយទៀត។ ទំនាក់ទំនងផ្លូវភេទត្រូវបានគេរំពឹងទុករួចហើយក្នុងការរៀបការ ដែលប្រពន្ធមានតួនាទីរួមសង្វាសជាមួយបុរសជាប្ដីនៅពេលដែលគេត្រូវការ ដូចដែលបានលើកឡើងក្នុងច្បាប់ស្រី។ មុនពេលរៀបការ កុមារី និងស្ត្រីមិនត្រូវបានគេឲ្យដឹងអំពីផ្លូវភេទសោះឡើយដើម្បីរក្សាទុកនូវព្រហ្មចារី។ ក្នុងការសម្ភាសជាច្រើន ស្ត្រីមួយចំនួនបានរ៉ាយរ៉ាប់ពីការប្រព្រឹត្តទៅលើកដំបូងនៃការរួមសង្វាសថាជាការភាន់ច្រឡំ ភ័យខ្លាច និងមានការប៉ះទង្គិចផ្លូវចិត្ត។ ជផ បានរៀបរាប់ពីការរួមសង្វាសលើកទីមួយជាមួយស្វាមីរបស់គាត់។ ទោះបីជាគាត់មានភាពវ័យក្មេងពេកក្នុងសំណាកនេះក៏ដោយ ក៏ចម្លើយរបស់គាត់បានបញ្ជាក់ទៅលើចំណេះដឹងរបស់មនុស្សស្រីមួយចំនួនអំពីផ្លូវភេទ និងការបន្តពូជ។ គាត់ក៏បានរៀបរាប់អំពីការគាំទ្ររបស់គ្រួសារដោយជំនះភាពតក់ស្លុតក្នុងការផ្ដល់ចម្លើយទៅនឹងទំនាក់ទំនងប្ដីប្រពន្ធ។

> ខ្ញុំធ្លាប់គិតថា ការរៀបការគឺយើងរស់នៅជាមួយគ្នាដូចបងប្អូន។ ខ្ញុំមិនដែលបានធ្លាប់ដឹងថាយើងត្រូវតែរួមសង្វាសជាមួយគ្នាក្រោយពេលរៀបការនោះទេ...។ ខ្ញុំមិនបានឲ្យស្វាមីរបស់ខ្ញុំប៉ះពាល់ខ្ញុំនោះទេ។ គ្រាមួយនៅពេលដែលគាត់ប៉ះពាល់ខ្ញុំ ខ្ញុំបានរត់ចេញដោយភាពភ័យខ្លាច។ គាត់បានសួរខ្ញុំថាហេតុអីបានជាខ្ញុំភ័យខ្លាចខ្លាំងម្ល៉េះ។ ខ្ញុំបាននិយាយថាខ្ញុំមិនបានដឹងថាមនុស្សដែលរៀបការហើយត្រូវប៉ះពាល់គ្នាបែបនេះនោះទេ ហើយបើខ្ញុំដឹងមុន ខ្ញុំនឹងមិនយល់ព្រមរៀបការនោះទេ។ រហូតថ្ងៃមួយទើបបងប្អូនរបស់គាត់បានពន្យល់ខ្ញុំថាតើអ្នកដែលរៀបការរួចគួរធ្វើចរឹតបែបណា ហើយត្រូវធ្វើអ្វី។ ដូច្នេះហើយ ទើបខ្ញុំចាប់ផ្ដើមយល់។[73]

[72] កិច្ចសម្ភាសន៍ករណីសិក្សាទី៤, ស្ត្រី (ថ្ងៃទី២ ឧសភា ២០១៩)
[73] កិច្ចសម្ភាសន៍ករណីសិក្សាទី២, ស្ត្រី (ថ្ងៃទី២៥ មេសា ២០១៩)

កិច្ចសម្ភាសលើករណីសិក្សាបានបង្ហាញនូវភាពចាំបាច់នៃវប្បធម៌នៃការរៀបការ ថាជាស្ថាប័នដែលតភ្ជាប់គ្រួសារ ហើយរឹតបន្តឹងចំណងនៃសង្គម។ មង្គលការខ្លះត្រូវបានយល់ព្រមដោយការរៀបចំទុកដាក់ដែលឪពុកម្តាយ ឬសមាជិកណាមួយនៃគ្រួសារបានផ្សំផ្គុំកូនខ្លួនដោយឆ្លងកាត់តាមការជ្រើសរើសច្រើនចំនុច។ ការយល់ព្រមទាំងសងខាងត្រូវបានគេជំរុញ ហើយការបង្ខំត្រូវប្រានចោល បើយោងទៅតាមទំនៀមទំលាប់ និងត្រូវបានរៀបរាប់ក្នុងកិច្ចសម្ភាស។ ទំនៀមទំលាប់ត្រូវបានប្រើប្រាស់ជាវិធីសាស្ត្រក្នុងការការពារ ពិសេសកូនស្រី ទោះបីជាការរៀបការតាមប្រពៃណីបានចាក់ឫសក្នុងអំណាចយេនឌ័រដែលមានភាពលំអៀងរវាងបុរស និងស្ត្រីក៏ដោយ។ ពិសេសជាងនេះទៅទៀតនោះ មង្គលការដោយការរៀបចំដែលសមរម្យត្រូវបានរៀបរាប់ដូចទៅនឹងផលប៉ះពាល់ដែលជាកម្មក្នុងកេរ្តិ៍ឈ្មោះក្នុងកម្រិតមួយ ដោយរាំងជីវិតកាលពីអតីតជាតិ ឬក៏ជីវិតក្នុងអនាគតជាតិក្នុងចំណោមអ្នកដែលកាន់សាសនាព្រះពុទ្ធ។

## ខ. ការរៀបការដោយបង្ខំ និងទំនាក់ទំនងផ្លូវភេទដោយបង្ខំក្នុងរបបខ្មែរក្រហម

អ្នកដែលផ្តល់សម្ភាសសម្រាប់ប្រើប្រាស់ក្នុងករណីសិក្សាទាំងអស់ សុទ្ធតែត្រូវបានគេស្នើឲ្យរៀបការក្នុងរបបខ្មែរក្រហម។ ជាលទ្ធផលចុងក្រោយពួកគាត់សុទ្ធតែបានឆ្លងកាត់ការរៀបការនោះគ្រប់ៗគ្នា លើកលែងតែស្ត្រីពីរនាក់ដែលទទួលបានការដាក់ទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរដោយសារការបដិសេធ។ ទាំងពីរនាក់ត្រូវបានគេចាប់រំលោភ និងមានម្នាក់ធ្វើជាទាសករតណ្ហា។ ជាទូទៅ ការរៀបការដោយបង្ខំត្រូវបានរៀបរាប់ទាំងមូលថាជាការដែលគ្មានជម្រើស គ្មានការយល់ព្រម ហើយត្រូវបានប្រព្រឹត្តទៅដោយអមជាមួយនូវការគម្រាមកំហែង និងការដាក់ទណ្ឌកម្មជាក់ស្តែង។

### i. ពិធីប្តេជ្ញាចិត្ត និងចាត់តាំងគូស្រករ

កម្មវិធី រៀបការដោយបង្ខំដែលបានរៀបចំដោយខ្មែរក្រហម ត្រូវបានគេរៀបរាប់ប្រាប់ថាមានលក្ខណៈផ្ទុយស្រឡះ ពីមង្គលការដែលប្រព្រឹត្តទៅតាមប្រពៃណីខ្មែរ។ ក.ណ ជនជាតិអ៊ីស្លាមម្នាក់បានរំលឹកឡើងក្នុងកិច្ចសម្ភាសជាមួយគាត់ថា គេហៅថា "ពិធីប្តេជ្ញាចិត្ត" ជាជាងមង្គលការ[74]។ដំណើរការនៃការរៀបការដោយបង្ខំរបស់ខ្មែរក្រហមត្រូវបានគេរៀបរាប់ឡើងដោយមានការប្រមូលផ្តុំមនុស្សប្រុសស្រីជាច្រើន។ ពិធីរៀបការទាំងអស់ ត្រូវបានរៀបចំ និងដឹកនាំដោយកម្មាភិបាលខ្មែរក្រហមក្នុងតំណែងផ្សេងៗគ្នារួមទាំងតំណែងថ្នាក់ដឹកនាំដែរ[75]។គូស្វាមី

---

[74] កិច្ចសម្ភាសន៍ករណីសិក្សាទី៨, ស្ត្រីអ៊ីស្លាម (ថ្ងៃទី២៨ មិថុនា ២០១៤)

[75] កិច្ចសម្ភាសន៍ករណីសិក្សាទី២, ស្ត្រី (ថ្ងៃទី២៥ មេសា ២០១៤) រៀបរាប់ថាត្រូវបានបញ្ជាឲ្យរៀបការដោយ "មេកង" ដែលទទួលបន្ទុកមើលក្រុមមនុស្សរាប់រយនាក់។

ភរិយាប្ដូរពាក្យសម្បថរវាងគ្នាបន្តិចបន្តួចថាស្មោះស្ម័គ្រនឹងគ្នា និងស្ម័គ្រចិត្តបម្រើអង្គការ។ ក្នុងដំណើរការនៃកម្មវិធីរៀបការមួយ អ្នកផ្ដល់សម្ភាសម្នាក់បានលើកឡើងថាគាត់ទាំងពីរនាក់សូត្រពាក្យសម្បថដែលលើកឡើងពីកាតព្វកិច្ចក្នុងការបង្កើតកូន និងបង្កបង្កើនផលបន្តទៀត[76]។ ការរៀបការដោយបង្ខំត្រូវបានប្រព្រឹត្តទៅនៅពេលយប់ក្រោយពេលធ្វើការ ហើយមានរយៈពេលតែប៉ុន្មាននាទីប៉ុណ្ណោះ[77]។

អ្នកផ្ដល់សម្ភាសភាគច្រើនមិនបានដឹង ឬ ត្រូវបានប្រាប់អំពីដំណើរការនៃការរៀបការ ឬត្រូវបានប្រាប់ដោយកម្មាភិបាល ឬភ្នាក់ងារខ្មែរក្រហម ប្រហែលជាមួយម៉ោងមុនកម្មវិធីចាប់ផ្ដើម។ មានឧទាហរណ៍មួយ ដែលមនុស្សប្រុសស្រីមួយគូត្រូវបានគេប្រាប់ប៉ុន្មានថ្ងៃមុន និងជាសាធារណៈក្នុងអង្គប្រជុំពេលយប់នៅមូលដ្ឋានការងារផ្សេងគ្នា លើកឡើងថាការរៀបការមួយចំនួន នឹងត្រូវធ្វើឡើងដោយផ្សំផ្គុំជាមួយអ្នកនៅជុំវិញក្បែរៗគ្នា។ អ្នកដែលផ្ដល់សម្ភាសភាគច្រើនចេញដំណើរពីស្រែដោយផ្ទាល់ទៅទីតាំងដែលពួកគាត់ត្រូវរៀបការ ក្នុងសម្លៀកបំពាក់រយីករយាក ដែលជាឯកសណ្ឋានរបស់ខ្មែរក្រហម អាវខ្មៅ សំពត់ខ្មៅ ខោខ្មៅ និងមានបង់កនឹងក្រមា។ អ្នកផ្សេងទៀតត្រូវបានគេកុហក និងប្រាប់ថាពួកគាត់នឹងត្រូវគេជម្លៀសទៅទីតាំងមួយផ្សេងទៀតមុនពេលគេនាំទៅចូលរួមពិធី។ ផ.ស បានរៀបរាប់អំពីវិធីដែលគាត់ដឹងថាគាត់នឹងត្រូវទៅចូលរួមពិធីរៀបការ នៅពេលដែលប្រជាជនទាំងមូលកំពុងធ្វើការលើស កម្លាំង ហើយស្រេកឃ្លាន៖

> ខ្ញុំមិនបានដឹងទាល់តែសោះថាខ្ញុំ ត្រូវគេបង្ខំឲ្យរៀបការ។ ខ្ញុំកំពុងលីជីលាមកគោដើម្បីយកទៅបាចក្នុងស្រែនាពេលថ្ងៃ។ ពួកគាត់មិនបានប្រាប់ខ្ញុំទេ ខ្ញុំបានឃើញមនុស្សជាច្រើនដើរជាគូទៅក្នុងរោង ហើយខ្ញុំក៏សួរទៅកម្មាភិបាល "មិត្តបង ហេតុអីបានជាមានមនុស្សច្រើនម្ល៉េះចូលទៅទីនោះ? "នាងបានឆ្លើយតប"អ្នកឯងក៏ត្រូវចូលទៅក្នុងទីនោះដែរ" ខ្ញុំបានសួរថាហេតុអ្វី នាងក៏បានឆ្លើយថា "ទៅទីនោះទៅអ្នកនិងបានហូបឆ្អែត"។[78]

អ្នកផ្ដល់សម្ភាសសម្រាប់ករណីសិក្សាខ្លះបានរៀបរាប់ពីកម្មវិធីផ្សេងគ្នារបស់អ្នកដែលជាប្រជាជនថ្មី និងប្រជាជនចាស់។ ហ.ក បានលើកឡើងពីភាពខុសគ្នានៅក្នុងជំរឺរបស់គាត់នៅ

---

[76] កិច្ចសម្ភាសន៍ករណីសិក្សាទី៥, ស្ត្រី (ថ្ងៃទី២៥ មេសា ២០១៤)កិច្ចសម្ភាសន៍ករណីសិក្សាទី៣, គូស្វាមីភរិយា (ថ្ងៃទី២៣ មេសា ២០១៤)

[77] កិច្ចសម្ភាសន៍ករណីសិក្សាទី៥, ស្ត្រី (ថ្ងៃទី២៥ មេសា ២០១៤) "កម្មាភិបាល x និងកម្មាភិបាល y បានពិភាក្សាគ្នាថា យើងមិនចាំបាច់ប្រើពេលមួយថ្ងៃពេញសម្រាប់ការរៀបការនោះទេ។ ឲ្យពួកគេធ្វើការដូចធម្មតាទៅ យើងនឹងរៀបការឲ្យពួកគេក្រោយពេលធ្វើការរួច។"

[78] កិច្ចសម្ភាសន៍ករណីសិក្សាទី៥, ស្ត្រី (ថ្ងៃទី២៥ មេសា ២០១៤)

បាត់ដំបងអំពីដំណើរការរៀបការរវាងប្រជាជនចាស់ និងប្រជាជនថ្មី ដែលការរៀបការប្រព្រឹត្តទៅក្រោយពេល អនុញ្ញាតិឲ្យធ្វើតាមទំនៀមទំលាប់ ("ខ្ញុំបញ្ចុកបាយប្តីខ្ញុំជាលើកទីមួយ")ហើយបានយកសត្វទាមកធ្វើម្ហូបដើម្បីឲ្យប្តីប្រពន្ធគូដំបូងក្នុងភូមិសប្បាយចិត្ត។ នៅពេលដែលសួរគាត់ថាហេតុអ្វីបានជាខ្មែរក្រហមក្នុងភូមិរបស់គាត់បង្ខំឲ្យប្រជាជនរៀបការ គាត់បានឆ្លើយថាតាមពិតទៅ ពួកគេចង់ទាក់ទាញចំណាប់អារម្មណ៍របស់ថ្នាក់ដឹកនាំរបស់គេដើម្បីឲ្យគេតម្លើងតំណែងឲ្យ។ ប្រហែលជាពួកគេអាចត្រូវបានគេឡើងតំណែងឲ្យដោយគ្រាន់តែបង្ហាញពីចំនួនមនុស្សដែលត្រូវបានរៀបការក្នុងភូមិ[79]។ នេះបង្ហាញឲ្យថ្នាក់ដឹកនាំជាន់ខ្ពស់ដឹងពីការអនុវត្តរបស់គោលការណ៍។

ចំពោះជីវិតទាំងអស់ អង្គការមានតួនាទីជាឪពុកម្តាយ ដែលទាមទារឲ្យមានការស្មោះស្ម័គ្រ និងការគោរពដ៏ខ្ពង់ខ្ពស់[80]។ តួនាទីនេះបានពង្រីកទៅដល់ការចាប់រៀបការដោយបង្ខំ នៅពេលដែលឪពុកម្តាយមិនមែនត្រឹមតែត្រូវបានគេដកចេញប៉ុណ្ណោះទេ ថែមទាំងត្រូវបានរង្គដណ្តើមយកទាំងស្រុង។ គូស្វាមីភរិយាមិនត្រូវបានគេរៀបចំទុកដាក់ធំដុំប៉ុន្មានទេ គឺគ្រាន់តែឆ្លងកាត់តាមដំណើរការនៃការប្តេជ្ញាចិត្តប៉ុណ្ណោះ។ គូមួយចំនួនដែលបានរៀបចំដោយអង្គការត្រូវបានគេផ្សំផ្គុំដោយយុត្តិធម៌គឺ "ប្រជាជនថ្មីជាមួយប្រជាជនថ្មី" និង "ប្រជាជនចាស់ជាមួយប្រជាជនចាស់"។ គូស្វាមីភរិយាត្រូវបានគេរៀបរាប់ថាជាការផ្សំផ្គុំមិនត្រឹមត្រូវ ភាគច្រើនផ្អែកទៅលើចំណេះដឹង ស្ថានភាពគ្រួសារ និងរូបសម្បត្តិ។ ក.ណ បានលើកឡើងពីការផ្សំផ្គុំ "ជនជាតិអ៊ីស្លាមជាមួយជនជាតិខ្មែរ"។

ការផ្លាស់ប្តូរទាំងស្រុងក្នុងពិធីរៀបការ ជាពិសេសការដកចេញនូវតួនាទីរបស់ឪពុកម្តាយ និងពិធីប្រពៃណី ត្រូវបានអ្នកផ្តល់សម្ភាសទាំងអស់បានលើកឡើងថាជាការដែលបាត់បង់ដ៏ធ្ងន់ធ្ងរមួយ។ ជ.ផ បានរៀបរាប់ពីបញ្ហាប្រឈមដែលគាត់មិនទទួលយកពីការរៀបការដោយបង្ខំរបស់ខ្មែរក្រហម "ខ្ញុំមិនទទួលយកដោយសារគ្មានវត្តមានឪពុកម្តាយ គ្មានភ្លេង គ្មានសាច់ញាតិ គ្មានអ្នកចេះដឹង គ្មានសម្លៀកបំពាក់ គ្មានការតុបតែងមុខ ហើយប្តីរបស់ខ្ញុំជាមនុស្សដែលខ្ញុំមិនស្គាល់។ ខ្ញុំគ្រាន់តែស្គាល់ឈ្មោះរបស់គាត់ ហើយខ្ញុំក៏ត្រូវបានគេសុំឲ្យរៀបការជាមួយគាត់។"[82]

---

79 កិច្ចសម្ភាសន៍ករណីសិក្សាទី៦, ស្ត្រី (ថ្ងៃទី២៨ មេសា ២០១៤)

80 កិច្ចសម្ភាសន៍ករណីសិក្សាទី១, បុរស (ថ្ងៃទី២៩ មេសា ២០១៤) "ពួកយើងជាកូនចៅរបស់អង្គការហើយ មិនចាំបាច់មានឪពុកម្តាយទៀតទេ។"

81 កិច្ចសម្ភាសន៍ករណីសិក្សាទី៨, ស្ត្រីខ្មែរអ៊ីស្លាម (ថ្ងៃទី២៨ មិថុនា ២០១៤) ក្នុងករណីនេះ ស្វាមីជនជាតិខ្មែរដែលកាន់សាសនាព្រះពុទ្ធត្រូវបានផ្លាស់ប្តូរទាំងស្រុងនិងចូលខ្លួនទៅក្នុងសហាគមន៍របស់នាង ប៉ុន្តែអ្នកផ្តល់សម្ភាសបានប្រាប់ពីវិធីដែលស្ត្រីជនជាតិអ៊ីស្លាមត្រូវបានគេបង្ខំឲ្យរៀបការជាមួយបុរសខ្មែរកាន់សាសនាព្រះពុទ្ធ និង សមាគមន៍សាសនារបស់ពួកគេក្នុងការរៀបការដោយច្រឡូកច្របល់។

82 កិច្ចសម្ភាសន៍ករណីសិក្សាទី២, ស្ត្រី (ថ្ងៃទី២៥ មេសា ២០១៤)

អ្នកផ្ដល់សម្ភាសភាគច្រើនបានលើកឡើងថា បុរសអាចស្នើសុំស្ត្រីណាម្នាក់មកធ្វើជាប្រពន្ធបាន ហើយដោយធ្វើត្រាប់តាមការអនុវត្តប្រពៃណី អង្គការមានអំណាចគ្រប់គ្រាន់ដើម្បីរៀបចំទុកដាក់ និងអនុម័តមង្គលការ។ ហ.អ បានប៉ាន់ស្មានឃើញថា ប្រហែលពាក់កណ្ដាលនៃស្ត្រីក្នុងកងរបស់នាងត្រូវបានអង្គការសម្រេចឲ្យរៀបការដោយឯកឯង ហើយនៅសល់ប៉ុន្មានទៀតត្រូវបានស្នើដោយបុរសដែលសុំនាងធ្វើជាប្រពន្ធដោយផ្ទាល់។ ហ.អ បានប្រាប់ថា ស្ត្រីមិនអាចស្នើសុំសំណើប្រភេទនេះបានទេ ហើយគាត់បានរៀបរាប់ថា៖

> បុរសនាពេលនោះបានស្នើសុំទៅកម្មាភិបាល។ មានកម្មាភិបាលសម្រាប់ក្រុមស្ត្រី និងកម្មាភិបាលសម្រាប់ក្រុមបុរសដែលមានគ្នាសរុបប្រមាណពី ៥០ ទៅ ១០០ នាក់។ នៅពេលដែលបុរសធ្វើសំណើ ប្រធានគ្រប់គ្រងក្រុមបានធ្វើជាបញ្ជីឈ្មោះបុរស និងស្ត្រី ហើយផ្ញើទៅប្រធានកងស្ត្រី។ នៅក្នុងអង្គប្រជុំ ប្រធានកងស្ត្រីនោះនាងនឹងប្រកាសប្រាប់ថា "មិត្ត ក មានបុរសចង់រៀបការជាមួយមិត្ត ដូច្នេះអង្គការអនុញ្ញាតិមង្គលការនេះ"។ បុរសម្នាក់មិនអាច ស្នើសុំការរៀបការពីស្ត្រីណាម្នាក់បានទេ។ អង្គការត្រូវតែអនុញ្ញាតិការស្នើសុំរៀបការ ហើយអង្គការត្រូវតែមើលប្រវត្តិគ្រួសារផងដែរមុនពេលគេអនុញ្ញាតិ។ ប្រសិនបើយើងមានសាច់ញាតិដែលត្រូវបានសម្លាប់ដោយអង្គការ ដូច្នេះយើងជា "ខ្មាំង" ហើយ។ ឧទាហរណ៍ដូចករណីខ្ញុំស្រាប់ "អង្គការបានសម្លាប់ឪពុកខ្ញុំ ដូច្នេះខ្ញុំមានប្រវត្តិដោយសារខ្ញុំបានចូលដៃជាមួយខ្មាំង។ បុរសដែលស្នើសុំខ្ញុំរៀបការជាមួយក៏មានប្រវត្តិទាក់ទងជាមួយខ្មាំងដែរ ដូចនេះគេក៏បានយល់ព្រមការស្នើនេះ។ គេហៅវាថា "ប្រវត្តិដូចគ្នា"។

ទោះជាយ៉ាងណាក៏ដោយ ទោះបីជាវាបានឲ្យឃើញថាមានឱកាសក្នុងការជ្រើសរើស ការស្នើរបស់បុរសនោះត្រូវបានគេយល់ថា ជាការសម្រេចចិត្តក្នុងបរិយាកាសមួយដែលមនុស្សម្នាក់ត្រូវបានគេបង្ខំដើម្បីផ្សំផ្គុំជាមួយមនុស្សម្នាក់ទៀត។ ពិសេសជាងនេះទៅទៀតនោះ កិច្ចសម្ភាសបានបង្ហាញឲ្យឃើញនូវអានុភាពរបស់គ្រួសារ និងការប្រាស្រ័យទាក់ទងរបស់គ្រួសារ ទោះបីជានៅក្រោមភាពលំបាកបែបនេះក៏ដោយ។ នៅពេលដែលប្ដីប្រពន្ធទាំងពីរមិនបានស្គាល់គ្នា ទំនាក់ទំនងក្រៅផ្លូវការត្រូវបានប្រើប្រាស់ដើម្បីឲ្យស្គាល់ពីសហព័ទ្ធដែលត្រូវបានគេចាត់តាំងនោះ។ ហ.អ បន្ថែមថា ប្ដីប្រពន្ធទាំងពីរប្រហែលជាធ្វើការនៅមូលដ្ឋានក្បែរគ្នា ឬនៅស្រុកភូមិជាមួយគ្នា ប៉ុន្តែ ពួកគាត់គ្រាន់តែមិនដែលបាននិយាយជាមួយគ្នា[83]។

បុរសវ័យជំទង់ប្រហែលជាបានឃើញនារីម្នាក់នោះ ឬស្គាល់ឈ្មោះរបស់នាងព្រោះ

---

[83] កិច្ចសម្ភាសន៍ករណីសិក្សាទី៣, ស្វាមីភរិយា (ថ្ងៃទី២៣ មេសា ២០១៤)

ថាគាត់បានធ្វើការជាមួយគ្នា ឬ ក៏មានបងប្អូនដែលធ្វើការនៅជិតនារីម្នាក់នោះ ហើយបងប្អូនរបស់គាត់អាចនិយាយថា "ឯងគួរតែរៀបការជាមួយស្ត្រីម្នាក់នេះនាងល្អបែបនេះ ល្អបែបនោះ...."។ បុរសស្គាល់ស្ត្រីម្នាក់ដោយការប្រើប្រាស់បណ្តាញបែបនេះ។ ករណីរបស់ខ្ញុំ បងប្អូនជីដូនមួយរបស់ស្វាមីខ្ញុំ ធ្វើការជាមួយខ្ញុំ ហើយនាងបានប្រាប់គាត់ឲ្យស្នើសុំរៀបការជាមួយខ្ញុំ"។[84]

ហ.ក រៀបរាប់ពីការស្នើសុំការរៀបការជាច្រើនពីប្តីនៃការរៀបការដោយបង្ខំរបស់គាត់។ រឿងរបស់គាត់អាចបកស្រាយពីបណ្តាញនៃទំនាក់ទំនងដែលអាចប្រើប្រាស់បានសម្រាប់ការអនុវត្ត ក៏ដូចជាវិធីដែលស្ត្រីមិនទាន់រៀបការក្តាប់អំណាចនៃការការរៀបការដោយបង្ខំ។

គ បានសុំឲ្យខ្ញុំរៀបការជាមួយក្មួយរបស់គាត់។ ខ្ញុំបានបដិសេធតែម្តងគត់ ហើយគាត់ក៏មិនបានបង្ខំខ្ញុំដែរដោយសារគាត់ក៏ជាប្រជាជនថ្មីដែរ។ នៅពេលដែលខ្ញុំដើរចូលទៅក្នុងផ្ទះបាយដើម្បីធ្វើការ ហើយបងស្រីរបស់គាត់បានចូលទៅសុំឲ្យខ្ញុំយល់ព្រមរៀបការ។ ខ្ញុំបានបដិសេធជាលើកទី២។ តែលើកទីបីមិនបានសម្រេចទេដោយសារនាងប្រាប់ថាជាសំណើដែលអង្គការជាអ្នករៀបចំឲ្យ។ នាងបានប្រាប់ទៀតថាបើខ្ញុំមិនព្រម ខ្ញុំត្រូវស្លាប់។ ដោយសារចង់វិលជួបជុំគ្រួសារ ហើយចង់ឃើញប្រទេសអភិវឌ្ឍន៍ ខ្ញុំបានយល់ព្រមដោយសារខ្ញុំគិតថាមានមនុស្សច្រើនណាស់ដែលងាយនឹងស្លាប់ ហើយខ្ញុំក៏អាចរត់ចោលប្តីរបស់ខ្ញុំបានក្រោយរបបខ្មែរក្រហមរលំ។

មិនមែនបុរសគ្រប់រូបសុទ្ធតែស្នើសុំរៀបការនោះទេ។ ស.ប.ជ រៀបរាប់ពីវិធីដែលប្រធានក្រុមរបស់គាត់ប្រាប់គាត់នៅយប់មួយថាថា"មិត្តរៀបចំអីវ៉ាន់មិត្តឯងត្រូវទៅជួយសមរភូមិមួយទៀត។ ក្រោយពីដើរអស់ប្រមាណពីរបីគីឡូ គាត់បានទៅដល់ទីតាំងនៃការរៀបចំពិធី។ ស.ប.ជ សួរ ឈ្លប "មិត្តយកខ្ញុំមកទីនេះដើម្បីរៀបការ?" ស.ប.ជ បានបដិសេធ ហើយនិយាយថា គាត់មិនបានស្គាល់អ្នកដែលគេចាត់តាំងនោះទេ។ ឈ្លបតប "ទោះបីជាអ្នកមិនស្គាល់ក៏ដោយ អង្គការបានរៀបចំមង្គលការនេះឲ្យ ហើយអ្នកត្រូវតែទទួល[85]។"

ការរស់រានមានជីវិតគឺជាការជម្រុញទឹកចិត្តឲ្យទទួលយកការរៀបការដោយបង្ខំនេះ។ ការដាក់ទណ្ឌកម្ម ឬ ការគំរាមដាក់ទណ្ឌកម្ម គឺជាធាតុពិតមួយដែលមានជីវិតរៀងរាល់ថ្ងៃ។ ហ.អ បានបន្តថា "ទោះបីជាខ្ញុំមិនយល់ព្រមក៏ដោយនៅពេលនោះ ខ្ញុំមិនមានជម្រើសទេព្រោះ

[84] កិច្ចសម្ភាសន៍ករណីសិក្សាទី៩, ស្ត្រី (ថ្ងៃទី២ ឧសភា ២០១៤)
[85] កិច្ចសម្ភាសន៍ករណីសិក្សាទី១, បុរស (ថ្ងៃទី២៩ មេសា ២០១៤)

ខ្ញុំអាចមានគ្រោះថ្នាក់បើខ្ញុំបដិសេធ ហើយខ្ញុំក៏ចេះតែបន្តទៅ ប៉ុន្តែគាត់មិនមែនជាស្វាមីដែលខ្ញុំពឹងទុកទេ[86]។ ការជម្រុញទឹកចិត្តដទៃទៀតសម្រាប់ការទទួលយកការរៀបការដោយបង្ខំគឺដោយសារបំណងក្នុងការរស់នៅបន្ត ឬ ផ្លាស់ទៅនៅជាមួយគ្រួសារវិញ។[87]

គួរឲ្យចាប់អារម្មណ៍ អ្នកផ្តល់សម្ភាស ៦នាក់ក្នុងចំណោម៨នាក់ ត្រូវបានគេបង្ខំឲ្យរៀបការក្រោយមកទៀតក្នុងរបបខ្មែរក្រហម អ្នកខ្លះត្រឹមតែ១ខែប៉ុណ្ណោះមុនការដួលរលំនៃរបបនេះ ដែលជាការកើនឡើងខ្លាំងនៃការចាត់តាំងឲ្យចូលរួមពិធីប្តេជ្ញានាចុងឆ្នាំ ១៩៧៨។[88]

ii.ទំនាក់ទំនងភេទដោយបង្ខំ និងការរំលោភ

ការរួមដំណេកដោយបង្ខំគឺជាផ្នែកមួយនៃគោលនយោបាយអាពាហ៍ពិពាហ៍ដោយបង្ខំ។ បន្ទាប់ពីបញ្ចប់ ពិធីប្តេជ្ញាចិត្តរវាងគូស្វាមីភរិយាក្នុងរបបខ្មែរក្រហម អ្នកផ្តល់សម្ភាសបានរៀបរាប់ថាគូស្វាមីភរិយានឹងនៅជាមួយគ្នាពីរបីថ្ងៃ ហើយត្រូវរួមដំណេកជាមួយគ្នា ដែលជាទូទៅមានកម្មាភិបាលឬមនុស្សរបស់ខ្មែរក្រហមផ្សេងទៀតជាអ្នកឃ្លាំមើល។ អ្នកផ្តល់សម្ភាសជាច្រើនបានរៀបរាប់អំពីខ្ទមឬបន្ទប់តូចៗ ដែលខ្វះភាពឯកជនផ្ទាល់ខ្លួន។ បន្ទប់ទាំងនោះត្រូវបានខ្មែរក្រហមសង់ឲ្យ ដើម្បីអនុវត្តគោលនយោបាយអាពាហ៍ពិពាហ៍ដោយបង្ខំ។ ហអ បានរៀបរាប់ដូចខាងក្រោម៖

> បន្ទប់ទាំងនោះជាប់ៗគ្នា មានផ្ទាំងតូចៗ ហើយពួកគេប្រើស្លឹកត្នោតយកមកធ្វើជញ្ជាំង ហើយចន្លោះផ្លូវដើរជាផ្លូវមួយវែង មានបំពង់ឬស្សីក្រាលពីក្រោម។ គេអាចមើលឃើញពីបន្ទប់មួយទៅបន្ទប់មួយទៀតតាមជញ្ជាំង ហើយបន្ទប់ទាំងនោះពុំបានសង់បិទជិតនោះទេ។ ក្រោយពិធីមង្គលការ ពួកគេបាននាំយើងមកកាន់បន្ទប់ហើយយាមកាមតាមដានសង្កេតមើលដើម្បីឲ្យច្បាស់លាស់ថាយើងទាំងពីរស្រុះស្រួលគ្នា។[89]

អ្នកផ្តល់សម្ភាសជាស្ត្រីភាគច្រើនបានលើកឡើងអំពីភាពអាម៉ាស់ ពេលគាត់នៅក្នុងបន្ទប់នោះ លាយឡំជាមួយនឹងអារម្មណ៍ភ័យខ្លាចមិនចង់រួមដំណេកក្នុងអាពាហ៍ពិពាហ៍មួយដែលស្រពិចស្រពិលនោះ។ ភាគច្រើនពួកគាត់មានចំណេះដឹងតិចតួចអំពីទំនាក់ទំនងភេទ ដោយគាត់ព្យាយាមរក្សានូវភាពបរិសុទ្ធរបស់ខ្លួនមុនពេលរៀបការ គោរពតាមក្រមវប្បធម៌ដែល

86 កិច្ចសម្ភាសន៍ករណីសិក្សាទី៤, ស្ត្រី (ថ្ងៃទី២ ឧសភា ២០១៤)
87 កិច្ចសម្ភាសន៍ករណីសិក្សាទី៣, ស្វាមីភរិយា (ថ្ងៃទី២៣ មេសា ២០១៤)
88 ត្រូវបានលើកឡើងក្នុងករណីសិក្សា ១ ២ ៣ ៤ ៥ និង ៨។
89 បទសម្ភាសន៍សម្រាប់ករណីសិក្សាទី ៤ ស្ត្រី (ថ្ងៃទី ២ ខែឧសភា ឆ្នាំ២០១៤)

ជាច្បាប់ស្ត្រី។ ហអ បានរៀបរាប់ថា "នៅពេលនោះ យើង[ជាស្ត្រី] ពុំដឹងថានឹងមានអ្វីកើតឡើងទេនៅយប់ថ្ងៃមង្គលការនោះ។ យុវវ័យក្នុងសម័យនោះពុំបានយល់ដឹងអំពីអាពាហ៍ពិពាហ៍ទេ"[90]។ ស្ត្រីជាច្រើននៅក្នុងការសិក្សាស្រាវជ្រាវរបស់យើងបានរៀបរាប់ពីអារម្មណ៍ខ្មាស់អៀន នៅពេលជួបជាមួយនឹងស្វាមីគាត់ជាលើកដំបូង ភាគច្រើនគឺពុំស្គាល់គ្នាទាល់តែសោះ ជាហេតុធ្វើឲ្យមានការលំបាកនឹងមើលមុខគ្នាចំ ឬកាន់ដៃគ្នាដែលតម្រូវក្នុងសម័យនោះ។ ហក បានកត់សម្គាល់ថា "នៅយប់នោះ ស្វាមីរបស់ខ្ញុំបានចាប់ដៃខ្ញុំ ហើយខ្ញុំពុំដឹងថាគាត់មានបំណងចង់ធ្វើអ្វីទេ"[91] ស្ត្រីជាច្រើនក្នុងការសិក្សាស្រាវជ្រាវរបស់យើងជាពិសេសនោះ បានរៀបរាប់ប្រាប់ពីអារម្មណ៍ច្របូកច្របល់និងមិនច្បាស់លាស់អំពីស្ថានភាពគ្រួសារខ្លួនថាជាស្ត្រីរៀបការឬយ៉ាងណានោះទេ។ កណ បានចែករំលែកថា "ខ្ញុំពុំដឹងថាគាត់ជាស្វាមីខ្ញុំដែរឬអត់ ហើយក៏ពុំដឹងថាត្រូវធ្វើអ្វីខ្លះទេ។ ពុំមានសេចក្តីស្រលាញ់ គ្រាន់តែជាការរួមដំណេក ប៉ុន្តែខ្ញុំពុំអាចបដិសេធបាន"[92]គាត់បានរៀបរាប់ពីយប់ទីមួយជាប្រពន្ធ និងថ្ងៃបន្តបន្ទាប់មកដូចខាងក្រោម៖

> របបនោះមានលក្ខណៈចំឡែក។ ខ្ញុំមានអារម្មណ៍ភ័យខ្លាច ដោយហេតុតែខ្ញុំពុំស្គាល់ប្តីខ្ញុំ ហើយខ្ញុំភ័យឡើងញ័រពីព្រោះខ្ញុំជាស្ត្រី ប៉ុន្តែខ្ញុំយល់ព្រមពីព្រោះខ្ញុំពុំចង់ស្លាប់។ ពួកគេបានឲ្យបន្ទប់យើងមួយនៅក្នុងរោងស្រូវ។ ពួកគេបានសង់បន្ទប់សម្រាប់យើង ដែលបន្ទប់នោះធ្វើពីឈើ ក្បែរបន្ទប់អ្នកដទៃទៀត ប៉ុន្តែមិនជិតពេករហូតអាចមើលគ្នាឃើញនោះទេ។ ប្តីរបស់ខ្ញុំបានសួរខ្ញុំថា "អ្នកបានប្តេជ្ញារួមរស់ជាមួយខ្ញុំ តើអ្នកស្រលាញ់ខ្ញុំដែរឬអត់?" យើងយល់ព្រមទៅវិញទៅមកដោយសារតែយើងពុំចង់ស្លាប់។ ប្តីរបស់ខ្ញុំបាននិយាយថា "ប្រសិនបើយើងពុំយល់ព្រម យើងនឹងត្រូវគេសម្លាប់ពីព្រោះឈ្លបកំពុងតែតាមដានយើង"។ ខ្ញុំភ័យខ្លាចចំពោះការរួមដំណេក ដោយសារខ្ញុំពុំយល់ដឹងពីការរួមដំណេកទេ។ យើងបានរួមរស់នៅជាមួយគ្នាបានមួយសប្តាហ៍ បន្ទាប់មកគេក៏បានបំបែកយើងឲ្យទៅធ្វើការនៅកន្លែងផ្សេងគ្នា ហើយយើងអាចជួបគ្នាបានម្តងក្នុងមួយខែ។[93]

យោងតាមសេចក្តីដកស្រង់ គូស្វាមីភរិយាយល់ព្រមទាំងសងខាងក្នុងការរួមដំណេកដើម្បីការរស់រានមានជីវិត។ ហអ បានពន្យល់ថា "តើឲ្យយើងបែកគ្នាយ៉ាងម៉េចទៅកើត? យើងបានយល់ព្រមនឹងគ្នាថានឹងរស់នៅជាប្តី និងប្រពន្ធ ដោយសារយើងពុំមានអ្វីផ្សេងនឹងធ្វើទេ។

90 Ibid.
91 បទសម្ភាសន៍សម្រាប់ករណីសិក្សាទី ៦ ស្ត្រី (ថ្ងៃទី ២៨ ខែមេសា ឆ្នាំ២០១៤)
92 Ibid.
93 បទសម្ភាសន៍សម្រាប់ករណីសិក្សាទី ៨ ស្ត្រីខ្មែរអ៊ីស្លាម (ថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០១៤)

មានក្ដីស្រលាញ់ ឬគ្មាន យើងបានរស់នៅជាមួយគ្នាដើម្បីចៀសវាងពីការសម្លាប់។"[94] ការមានគភ៌ជានិច្ចកាលគឺជាភាពភ័យខ្លាចសម្រាប់ស្ត្រីនៅក្នុងស្ថានភាពនៃការរួមដំណេកដោយបង្ខំ ថែមទាំងលក្ខខណ្ឌរស់នៅយ៉ាងលំបាកក្រៃលែង។ កហ បានរៀបរាប់ដូចតទៅ៖

> យើងពុំមានអ្វីញាំ ដូច្នេះហើយខ្ញុំពុំចង់មានកូន ប៉ុន្តែខ្ញុំអាចធ្វើអ្វីបានទៅ? ប្រសិនបើខ្ញុំចង់រំលូតកូន តើឲ្យខ្ញុំធ្វើដូចម្ដេច? ខ្ញុំបារម្ភថាអង្គការ នឹងរកឃើញ ហើយយើងពុំមានវេជ្ជបណ្ឌិត ពុំមានថ្នាំពន្យាកំណើត។ ខ្ញុំដឹងថាយើងនឹងមានកូន ប្រសិនបើយើងរួមដំណេក ប៉ុន្តែខ្ញុំពុំដឹងថាត្រូវធ្វើដូចម្ដេចទេ។ ខ្ញុំមានកូនបីជាមួយនឹងប្ដីខ្ញុំ។[95]

គូស្វាមីភរិយាបានព្រមព្រៀងមិនរួមដំណេក ជាល្បិចដោះទាល់មួយបែបពីការឃ្លាំមើលរបស់ខ្មែរក្រហម។ គូស្វាមីភរិយាដែលត្រូវបានសម្ភាសន៍បានរៀបរាប់ពីគ្រាដំបូងពេលដែលគេចាប់បង្ខំគាត់ឲ្យរៀបការ។ ពួកគាត់ពុំបានរួមដំណេករហូតដល់ក្រោយការដួលរលំ របបខ្មែរក្រហម ប្រឆាំងនឹងការគ្រប់គ្រងគៀបសង្កត់របស់រដ្ឋនៅពេលនោះ។ ការព្រមព្រៀងនោះធ្វើឡើងទាំងសងខាង ប៉ុន្តែគឺផ្ដើមគំនិតដោយប្រពន្ធ ដែលត្រូវប្រឈមនឹងបញ្ហាពីរផ្ទុយគ្នា គឺទំនៀមទំលាប់វប្បធម៌ដែលប្រឆាំងគ្នា គឺកូនស្រីល្អពុំត្រូវរៀបការដោយពុំមានការយល់ព្រមពីឪពុកម្ដាយ ប៉ុន្តែ ប្រពន្ធល្អក៏ត្រូវរួមដំណេកជាមួយនឹងប្ដីរបស់ខ្លួនដែរ។ ជាងនេះទៅទៀត គ្រប់គូស្វាមីភរិយាទាំងអស់ត្រូវរួមដំណេកជាមួយគ្នាទៅតាមការកំណត់ក្នុងរបបខ្មែរក្រហម ហើយបើពុំអនុវត្តតាម ត្រូវទទួលទោសទណ្ឌយ៉ាងធ្ងន់ធ្ងរ។ អក្សរកាត់ត្រូវបានផ្លាស់ប្ដូរទៅជាពាក្យថា ប្ដីប្រពន្ធវិញ ដើម្បីជួយសម្រួលការអាននូវសេចក្ដីដកស្រង់ខាងក្រោម៖

> **ប្រពន្ធ៖** ណាមួយ ខ្ញុំភ័យខ្លាចថាកម្មាភិបាលនឹងដឹងថាយើងពុំរួមដំណេកជាមួយគ្នា។ មួយទៀតខ្ញុំភ័យខ្លាចថាប្ដីរបស់ខ្ញុំនឹងបង្ខំឲ្យខ្ញុំរួមដំណេក។
> **ប្ដី៖** ខ្ញុំមិនហ៊ានគេងក្បែរប្រពន្ធខ្ញុំទេ។
> **អ្នកទៅសម្ភាសន៍៖** តើហេតុអ្វី?
> **ប្ដី៖** ដោយសារខ្ញុំពុំស្គាល់ ឬបាននិយាយជាមួយនាងពីមុនមក។
> **ប្រពន្ធ៖** បន្ទាប់មកមានប្រធានក្រុមម្នាក់ឈ្មោះ X បានចោទខ្ញុំថាពុំបានរួមដំណេកជាមួយនឹងប្ដីរបស់ខ្ញុំ។ ខ្ញុំបានឆ្លើយថា "តើលោកកំពុងតែនិយាយអំពីអ្វី?" គាត់ថាគាត់អាចដឹងបានថាខ្ញុំពុំបានរួមដំណេកជាមួយប្ដីខ្ញុំទេ ដោយមើលទៅលើរាងកាយរបស់ខ្ញុំ។

[94] បទសម្ភាសន៍សម្រាប់ករណីសិក្សាទី ៤ ស្ត្រី (ថ្ងៃទី ២ ខែឧសភា ឆ្នាំ២០១៤)
[95] បទសម្ភាសន៍សម្រាប់ករណីសិក្សាទី ៨ ស្ត្រីខ្មែរអ៊ីស្លាម (ថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០១៤)

> **ប្តី៖** ប្រធានក្រុមក៏បានសួរខ្ញុំថា "តើទំនាក់ទំនងអ្នក ជាមួយនឹងប្រពន្ធអ្នកមានលក្ខណៈយ៉ាងដូចម្តេចដែរ? "ខ្ញុំគ្រាន់តែឆ្លើយថា "ទំនាក់ទំនងល្អ"។

មនុស្សរបស់ខ្មែរក្រហមតម្រូវឲ្យប្តីជានាឲ្យមានទំនាក់ទំនងផ្លូវភេទ ហើយប្តីក៏ត្រូវដាក់សម្ពាធទៅលើប្រពន្ធខ្លួន នេះបើយោងតាមបទសម្ភាសន៍ក្នុងការសិក្សាស្រាវជ្រាវ។ សបជ បានរំលឹកអំពីភាពអៀនខ្មាស់យ៉ាងខ្លាំងរបស់ប្រពន្ធគាត់ក្នុងខែទីមួយនៃអាពាហ៍ពិពាហ៍ ទាំងអាម៉ាស់ ទាំងភ្ញាក់ផ្អើលដោយសារមានឈ្លបតាមឃ្លាំមើលរាល់យប់ ហើយត្រូវងើបឲ្យបានលឿនជាងគាត់ ដូច្នេះហើយប្តីប្រពន្ធមិនងើបឡើងពីគ្រែតែមួយ។ ក្នុងរយៈពេលប៉ុន្មានខែដំបូង ពួកគាត់មិនទាន់មានទំនាក់ទំនងផ្លូវភេទគឺគ្រាន់តែគេងជិតគ្នា។ បន្ទាប់ពីរបីខែក្រោយមក កម្មាភិបាលម្នាក់បានព្រមានថា "ខ្ញុំដឹងថាសមមិត្តមិនស្រឡាញ់ភរិយាឡើយ ហើយខ្ញុំមើលឃើញថាសមមិត្តមានកំហុសជាច្រើន។ ប្រសិនបើសមមិត្តមិនគោរពតាមមាគ៌ារបស់អង្គការ សមមិត្តឯងត្រូវប្រយ័ត្ន"។ នៅពេលដែល សបជ ទទួលការព្រមានជាលើកទីពីរគាត់ក៏ "និយាយដោយស្មោះត្រង់" ជាមួយប្រពន្ធរបស់គាត់ក្នុងការរួមភេទដើម្បី "ជីវិតរស់របស់ពួកគាត់"។ ប្រពន្ធគាត់ក៏នៅតែបដិសេធដាច់ខាត ប៉ុន្តែពួកគាត់នៅទីបំផុតក៏បានរួមដំណេក។ សបជ ចាំថា៖ "ខ្ញុំគិតថាប្រពន្ធរបស់ខ្ញុំអាចនឹងមិនរួមដំណេកជាមួយខ្ញុំទេ លុះត្រាតែគាត់ស្រឡាញ់ខ្ញុំ។ ខ្ញុំគ្មានអារម្មណ៍រួមដំណេកជាមួយនាងឬសូម្បីតែរក្សាទុកនាងជាប្រពន្ធខ្ញុំក៏គ្មានដែរ ពីព្រោះខ្ញុំមិនបានស្រឡាញ់នាងទេ"។

ក្នុងការសិក្សារបស់យើង ៥០% នៃការសម្ភាសន៍ជាមួយស្ត្រីបានពិពណ៌នាអំពីការដែលត្រូវប្តីរំលោភ។ នៅក្នុងករណី បស ការរំលោភសេពសន្ថវៈមកលើរូបគាត់គឺមានកម្មាភិបាលខ្មែរក្រហមសមគំនិត និងជួយជំរុញ ។ កូនក្រមុំជាកុមារីម្នាក់ ត្រូវបានបង្ខំឱ្យរៀបការនៅអាយុប្រហែល ១៥ ឆ្នាំ មុនពេលដែលនាងមានរដូវទៅទៀត។ ប្តីគាត់មានអាយុបងគាត់ស្ទើរតែពីរដងគឺអាយុ ២៨ ឬ ២៩ ឆ្នាំ។ ឪពុកនិងពូរបស់គាត់ធ្លាប់ធ្វើជាទាហានឲ្យរដ្ឋាភិបាលមុនហើយត្រូវបានសម្លាប់នៅពេលដែលរបបខ្មែរក្រហមឡើងកាន់អំណាចថ្មីៗ ដូច្នេះហើយ បស ត្រូវបានគេចាត់ទុកថាជាប្រជាជន "ថ្មី" ដែលជាប់ពាក់ព័ន្ធនឹងខ្មាំង។ នាងបានរៀបរាប់អំពីអាពាហ៍ពិពាហ៍ដោយបង្ខំនិងយប់ ដំបូង ដូចខាងក្រោម៖

> នៅពេលដែលខ្ញុំឃើញមនុស្សចាប់ផ្តើមកាន់ដៃគ្នា ខ្ញុំព្យាយាមដើរឆ្ងាយ។ ខ្ញុំបានប្រាប់គេថាខ្ញុំមិនចង់ធ្វើដូច្នោះទេ ខ្ញុំគ្មានម្តាយ ខ្ញុំនៅក្មេងខ្ញុំមិនចង់ធ្វើដូច្នោះទេ។ ខ្ញុំបានព្យាយាមរត់គេច ហើយកម្មាភិបាលម្នាក់បានបាញ់កាំភ្លើងឡើងលើ។ ពួកគេ

[96] បទសម្ភាសន៍សម្រាប់ករណីសិក្សាទី ១ ប្រុស (ថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០១៤)

> បានប្រាប់ខ្ញុំថា "ទុកក៏មិនចំណេញ ដកចេញក៏មិនខាត។" ខ្ញុំត្រូវ បានគេបញ្ជាឲ្យទៅអង្គុយទល់មុខប្ដីរបស់ខ្ញុំប៉ុន្តែខ្ញុំមិនស្គាល់គាត់ទេ គាត់មានវ័យចំណាស់ជាងខ្ញុំច្រើនហើយមានមាឌធំ។ ខ្ញុំមិនហ៊ានសម្លឹងមើលគាត់ទេ។ ពួកគេបានបញ្ជាឱ្យពួកយើងកាន់ដៃគ្នាហើយខ្ញុំបានបដិសេធ ពួកគេបានគំរាមខ្ញុំម្ដងទៀតជាមួយនឹងកាំភ្លើង។ ខ្ញុំយំនិងសុំអង្វរពួកគេថាខ្ញុំនៅក្មេងណាស់ ហើយខ្ញុំពុំទាន់គ្រប់អាយុរៀបការទេ។ ខ្ញុំពុំយល់ថាអ្វីជាស្នេហាទេ ហើយខ្ញុំក៏គ្មានម្ដាយនៅជិតដើម្បីពន្យល់អំពីការមានរដូវនោះទេ។ ខ្ញុំគ្មានឪពុកម្ដាយនៅជិតដើម្បីមើលថែនិងការពារឡើយ... "ក្រោយពិធីអាពាហ៍ពិពាហ៍ចប់" គេក៏បាននាំយើងទៅកាន់ផ្ទះមួយដែលមានបន្ទប់តូចៗ ខ្ញុំមិនចង់និយាយអំពីរឿងនេះទេ។ ប្ដីរបស់ខ្ញុំបានព្យាយាមបង្ខំខ្ញុំឲ្យរួមដំណេកក្នុង ៣ យប់ដំបូង ប៉ុន្តែខ្ញុំបានបដិសេធ។ ប្ដីខ្ញុំព្យាយាមដោះខោអាវខ្ញុំប៉ុន្តែខ្ញុំបានតដៃ ហើយទាត់គាត់មួយជើងនៅពេលដែលគាត់ព្យាយាមដោះខោអាវខ្ញុំ។ យប់ទីមួយបានកន្លងផុតទៅបែបហ្នឹង ... នៅយប់ទី៣ ខ្ញុំបានរត់គេចទៅសហករណ៍ផ្សេងទៀត ប៉ុន្តែឈ្លបបាននាំប្ដីរបស់ខ្ញុំមករកខ្ញុំ... អ្នកឃ្លាំមើលយើងនោះថាអស់ពេលមួយសប្ដាហ៍ហើយដែលយើងមិនបានរួមដំណេកជាមួយគ្នា ដូច្នេះយប់នេះយើងត្រូវតែរួមដំណេក។ ខ្ញុំពុំយល់ព្រមទៀត។ ខ្ញុំបាននិយាយថាខ្ញុំមិនខ្វល់ថាខ្ញុំត្រូវស្លាប់ទេ។ ឈ្លបពីរនាក់ដែលឃ្លាំមើលនោះ មានម្នាក់នៅរស់រានដល់សព្វថ្ងៃ។ ពួកគេបានចងជើងនិងដៃខ្ញុំទៅនឹងគ្រែ ហើយពួកគេបានដើរចេញ។ បន្ទាប់មកប្ដីថោកទាបនោះបានចាប់រំលោភខ្ញុំ វាបានហែកខោរបស់ខ្ញុំ ហើយឈ្លបពីរនាក់នោះជាអ្នកឈរមើល។ ប្ដីខ្ញុំបានរំលោភខ្ញុំហើយបានធ្វើអ្វីៗតាមចំណង់របស់វា។ វាបានហែកខោអាវខ្ញុំ។ ខ្ញុំមានអារម្មណ៍អាម៉ាស់ជាខ្លាំង។ ពូរបស់ខ្ញុំនៅបន្ទប់ជាប់នោះ គាត់បានឃើញនូវអ្វីដែលគេធ្វើមកលើខ្ញុំ ហើយគាត់ក៏គ្រវីក្បាល។ គាត់ពិបាកនឹងទ្រាំមើលខ្ញុំក្នុងស្ថានភាពបែបនោះ ប៉ុន្តែគាត់ពុំអាចធ្វើអ្វីបានឡើយ។ ក្រោយដែលប្ដីខ្ញុំរំលោភខ្ញុំហើយ វាមិនចង់ដោះលែងខ្ញុំទៀត វានៅចង់ចងខ្ញុំជាប់ពីព្រោះវាចង់រំលោភខ្ញុំម្ដងទៀត... ខ្ញុំបានយំរកគេជួយនិងសុំអង្វរវាកុំចាប់ខ្ញុំអី! ប៉ុន្តែ "ប្ដីខ្ញុំ" និយាយថា វាមិនអាចជួយខ្ញុំបានទេពីព្រោះវាត្រូវគោរពតាមអង្គការ។ ពួកគេបានរៀបការឲ្យយើងដើម្បីឲ្យយើងកើតកូនឲ្យអង្គការ។[97]

ការរំលោភនោះបានបណ្ដាលឲ្យប្រដាប់ភេទចេញឈាមយ៉ាងច្រើន ដែល បស ត្រូវវេជ្ជបណ្ឌិតប្រឹក្សាក្រៅផ្លូវការឲ្យប្រើថ្នាំធ្វើពីរុក្ខជាតិ ដោយសារតែគ្មានមន្ទីរពេទ្យធ្វើការទេ។ ឃ្លាចុងក្រោយនៃសេចក្ដីដកស្រង់នោះបានសន្និដ្ឋានថា ប្ដីរបស់គាត់អាចមានអារម្មណ៍ត្រូវគេបង្ខំ

[97] បទសម្ភាសន៍សម្រាប់ករណីសិក្សាទី ៥ ស្ត្រី (ថ្ងៃទី ២៥ ខែមេសា ឆ្នាំ២០១៤)

ឲ្យរំលោភប្រពន្ធ ក្នុងពេលមានវត្តមានរបស់កម្មាភិបាលដើម្បីជីវិតរស់ ឬយ៉ាងហោចណាស់ ប្តីនោះបានប្រើគោលនយោបាយរដ្ឋជាលេសដើម្បីចាប់រំលោភ។

កល ក៏ត្រូវប្តីខ្លួនរំលោភនៅយប់ថ្ងៃអាពាហ៍ពិពាហ៍ដោយបង្ខំដែរ ហើយគាត់បានប្រឈមនឹង "ការវាយតប់ និងការឈ្លោះប្រកែក" តាំងពីរបបនោះរហូតមកដល់សព្វថ្ងៃ។ រឿងរ៉ាវរបស់គាត់បានបង្ហាញអំពីគោលនយោបាយគាបសង្កត់នៃរបបខ្មែរក្រហមអាចត្រូវបានប្រើប្រាស់ដើម្បីបន្ត និងពង្រឹងការរំលោភបំពានផ្លូវភេទនៅក្នុងចំណងអាពាហ៍ពិពាហ៍

> ឈ្លបតែងតែតាមសង្កេតប្តីខ្ញុំ និងខ្ញុំជារៀងរាល់យប់។ ប្រសិនបើខ្ញុំពុំព្រមរួមដំណេកជាមួយប្តីខ្ញុំទេ ខ្ញុំនឹងត្រូវបញ្ជូនទៅ "កសាង" ដូច្នេះហើយខ្ញុំមិនដែលបដិសេធនឹងប្តីខ្ញុំទេ ហើយឲ្យប្តីខ្ញុំធ្វើអ្វីតាមតែគាត់ចង់ទៅ។ ទំនាក់ទំនងរវាងប្តីខ្ញុំនិងខ្ញុំពុំល្អទេ ដោយសារប្តីខ្ញុំជាបុរស មិនបើកចិត្តទូលាយទេ ហើយគាត់មិនយល់អ្វីទៅជាជីវិតជាដៃគូដែរ។ ខ្ញុំរស់នៅជាមួយគាត់ ដោយគ្មានសុភមង្គល ហើយយើងរស់នៅជាមួយគ្នារហូតដល់សព្វថ្ងៃ។ ខ្ញុំនៅតែបន្តរស់នៅជា មួយគាត់ ដោយសារតែខ្ញុំអាណិតកូនរបស់ខ្ញុំ ហើយខ្ញុំមិនចង់ឲ្យកូនខ្ញុំក្លាយជាក្មេងកំព្រា។[98]

យោងតាមសេចក្តីដកស្រង់ពីអ្នកផ្តល់សម្ភាសនៅក្នុងការសិក្សារបស់យើង អាពាហ៍ពិពាហ៍ដោយបង្ខំ និងទំនាក់ទំនងភេទដែលបង្កើតឡើងនៅក្នុងរបបខ្មែរក្រហម បានបង្កើតឲ្យមានវប្បធម៌រំលោភដោយប្តី ត្រូវរងសំពាធឲ្យធ្វើការរំលោភបំពានផ្លូវភេទ និងធ្វើបាប លើរាងកាយប្រពន្ធ ជាមួយនឹងវប្បធម៌និរទណ្ឌភាព គ្រប់ពេលដែលមានកម្មាភិបាលខ្មែរក្រហម គាំទ្រដោយផ្ទាល់ និងក្នុងករណីខ្លះអាចត្រូវបានគេសន្មត់ថាជាទង្វើដើម្បីជីវិតរស់។ ប្រពន្ធពុំអាចពឹងពាក់លើមន្ទីរពេទ្យ លើប៉ូលីស ឬច្បាប់របស់រដ្ឋដើម្បីការពារសិទ្ធិរបស់ខ្លួនឡើយ។ មានអ្នកខ្លះប៉ុនប៉ងនឹងប្រកែក មានប្តីប្រពន្ធខ្លះធ្វើបន្លំថាបានរួមដំណេក ហើយខ្លះផ្សេងទៀតបានចុះចាញ់ព្រមតាមការទាមទាររបស់ខ្មែរក្រហមក្រោមការឃ្លាំមើលគ្រប់ជំហាន។កត្តាជំរុញទឹកចិត្តភាគច្រើនគឺដើម្បីរស់បន្តទៀត។

### iii.ការតស៊ូប្រឆាំង និងទោសទណ្ឌ

គ្រប់ករណីដែលយើងសិក្សាខាងលើ គឺមានការតស៊ូប្រឆាំង និងឧបាយដោះខ្លួនក្នុងទម្រង់ផ្សេងៗគ្នា ចំពោះអាពាហ៍ពិពាហ៍ដោយបង្ខំនោះ។ ក្នុងបទសម្ភាសន៍ខ្លះ គឺមានករណី

[98] បទសម្ភាសន៍សម្រាប់ករណីសិក្សាទី ៦ ស្ត្រី (ថ្ងៃទី ២៨ ខែមេសា ឆ្នាំ២០១៤)

បដិសេធនឹងអាពាហ៍ពិពាហ៍ដែលបង្ខំ ដោយភ្នាក់ងារខ្មែរក្រហម ជាច្រើនលើកច្រើនសារ ប៉ុន្តែគឺសុទ្ធតែមានការគំរាមដាក់ទោសទណ្ឌ ឬសម្លាប់ចំពោះករណីប្រកែកដាច់ខាត។ កណ បានពន្យល់ថា "ខ្ញុំបាននិយាយពីរដងថាខ្ញុំនឹងមិនរៀបការទេ ប៉ុន្តែចុងក្រោយនៅពេលដែលខ្ញុំយល់ព្រម ពួកគេថា "បដិសេធពីរដងមិនអីទេ ប៉ុន្តែមិនអាចបដិសេធលើកទី ៣ ឡើយ។" ហអ បានរៀបរាប់ថា "កម្មាភិបាលប្រាប់ខ្ញុំថា សមមិត្ត ថ្ងៃនេះមិត្តត្រូវរៀបការ ហើយដៃគូរបស់សមមិត្តគឺបុរសម្នាក់នេះ។ មិត្តពុំអាចបដិសេធទេ។ ទោះបីជាមិត្តពុំចង់រៀបការ មិត្តក៏ត្រូវរៀបការដែរ។ ដោយសារអង្គការបានរៀបចំមង្គលការនេះឲ្យមិត្ត មិត្តមិនអាចបដិសេធទេ"[99]

វប្បធម៌រំលោភនេះក៏អាចឈានដល់ការធ្វើទារុណកម្ម ដែលអាចបង្កនូវអំពើហឹង្សាផ្លូវភេទផងដែរ។ ស្ត្រីពីរនាក់ដែលយើងសម្ភាសធ្លាប់រៀបការនៅមុនរបបខ្មែរក្រហមសង្ស័យថា ការសម្លាប់ប្តីរបស់គាត់គឺពាក់ព័ន្ធនឹងបុរសផ្សេងទៀត គឺមនុស្សរបស់ខ្មែរក្រហម ដែលចង់រៀបការជាមួយគាត់។[100]ស្ត្រីទាំងពីរនោះត្រូវបានដាក់គុកនិងរំលោភសេពសន្ថវៈដោយសារគាត់បដិសេធពុំព្រមរៀបការ។ ប្តីរបស់ សអ ត្រូវបានប្អូនថ្លៃរបស់នាងដែលជាទាហានខ្មែរក្រហមសម្លាប់ដោយសារប្តីគាត់ជាកងទ័ពនៃរដ្ឋាភិបាលរបបមុន។ គាត់មានគភ៌នៅពេលនោះ។ នៅពេលដែលកូនទីមួយរបស់គាត់មានអាយុបាន ៦ ខែ ប្អូនថ្លៃម្នាក់ទៀតដែលជាប្តីរបស់ខ្មោចប្អូនស្រីគាត់ បានស្នើសុំរៀបការ។ គាត់សង្ស័យថាប្អូនប្រុសថ្លៃទាំងពីររបស់គាត់គឺជាប់ពាក់ព័ន្ធនឹងរឿងសមគំនិតគ្នា។ប្អូនប្រុសថ្លៃដែលស្នើសុំគាត់រៀបការគឺជានាយកផ្នែកភស្តុភារថ្នាក់ស្រុកជាតួនាទីមានអំណាចមួយទទួលខុសត្រូវពិនិត្យលើការងារកំណត់បរិមាណអាហារនិងស្រូវ។នៅពេលដែលគាត់បដិសេធនឹងសំណើនោះ គាត់ត្រូវបានគេចាប់ដាក់គុក។ គាត់បានរួចខ្លួន ៥ខែក្រោយមកដោយសារប្អូនប្រុសថ្លៃដដែលនោះបានដោះលែងគាត់ ហើយបានបញ្ជូនទៅផ្ទះម្តាយគាត់។ នៅទីនោះ ប្អូនប្រុសថ្លៃនោះប៉ុនប៉ងចាប់រំលោភគាត់ ហើយនៅពេលដែលមានពាក្យចចាមអារ៉ាមបានលេចលឺពេញភូមិនោះ ប្អូននោះបានស្នើសុំរៀបមង្គលការម្តងទៀត (នេះបង្ហាញថាពួកខ្មែរក្រហមនៅក្នុងឋានៈដាក់លាក់មួយមានសិទ្ធិជ្រើសរើសដៃគូដើម្បីរៀបការបាន) ។ គាត់បានបដិសេធបីដង ដោយយោងជាសំខាន់លើហេតុផលថា គាត់ទើបតែក្លាយជាមេម៉ាយថ្មីៗ ហើយបុរសនោះជាមន្ត្រីខ្មែរក្រហមដែលពុំមានការចេះដឹង ("ហើយខ្មែរក្រហមសម្លាប់ប្រជាជនកម្ពុជា)។ម្តាយរបស់គាត់ព្យាយាមបញ្ចុះបញ្ចូលគាត់ឲ្យយល់ព្រមរៀបការដើម្បីរក្សាជីវិត និងកូនតូចរបស់ខ្លួន។ នៅពេលស្នើសុំជាលើកទីបួននោះ ប្អូនថ្លៃនោះបាននាំបុរសពីរនាក់ទៀតមក ក្នុងនោះម្នាក់ជាមន្ត្រីភូមិ។ សអ រៀបរាប់ថា៖

---

[99] បទសម្ភាសន៍សម្រាប់ករណីសិក្សាទី ៤ ស្ត្រី (ថ្ងៃទី ២ ខែឧសភា ឆ្នាំ២០១៤)
[100] បទសម្ភាសន៍សម្រាប់ករណីសិក្សាទី ២ ស្ត្រី (ថ្ងៃទី ២៥ ខែមេសា ឆ្នាំ២០១៤) បទសម្ភាសន៍សម្រាប់ករណីសិក្សាទី ៧ ស្ត្រី (ថ្ងៃទី ២៨ ខែមេសា ឆ្នាំ២០១៤)

> "សូមនាងរៀបការជាមួយខ្ញុំ ហើយសមមិត្តនឹងអាចរស់នៅបានស្រួល" ប្អូនថ្លៃនោះបាននិយាយមកកាន់គាត់។ ខ្ញុំឆ្លើយថា "...ប្តីរបស់ខ្ញុំទើបនឹងស្លាប់ ដូច្នេះខ្ញុំពុំអាចរៀបការជាមួយនឹងសមមិត្តបានទេ"។ ប្អូននោះក៏បន្តទៀតថា "សមមិត្តនឹងជួបបញ្ហាច្រើនប្រសិនបើមិនព្រមរៀបការជាមួយខ្ញុំទេ"។ បុរសនោះក៏បានសួរខ្ញុំថា "តើសមមិត្តពុំខ្លាចស្លាប់ទេឬ?" ខ្ញុំបានឆ្លើយថា "ខ្ញុំពុំខ្លាចស្លាប់ទាល់តែសោះ។ ខ្ញុំមិនខ្វល់ពីអ្វីទាំងអស់។ ប្រសិនបើខ្ញុំស្លាប់ ហើយគ្មាននរណាមើលថែកូនប្រុសខ្ញុំទេ ទុកឲ្យកូនខ្ញុំស្លាប់ទៅតាមខ្ញុំចុះ"។ នៅយប់នោះ ប្អូនប្រុសនោះបានបញ្ជាឲ្យទាហានក្មេងពីរនាក់មកផ្ទះខ្ញុំ ហើយចងខ្ញុំជាប់។ ពេលនោះគឺម៉ោង ៨ ល្ងាច នៅពេលដែលខ្ញុំកំពុងរៀបចូលគេង។ នៅពេលដែលម្តាយខ្ញុំសួរ [តើហេតុអ្វីបានជាពួកគេចាប់ខ្ញុំទៅ] ពួកគេក៏ឆ្លើយថា "កូនស្រីរបស់សមមិត្តបានប្រព្រឹត្តកំហុស"។ ម្តាយខ្ញុំក៏បានសួរបន្តថា "តើកូនខ្ញុំខុសអ្វី?" ពួកគេឆ្លើយថា "នាងបដិសេធពុំព្រមរៀបការ"។ ខ្ញុំដឹងច្បាស់ថាប្អូនប្រុសថ្លៃខ្ញុំជាអ្នកទទួលខុសត្រូវក្នុងរឿងនេះ។ ក្រោយពីពួកគេចាប់ខ្ញុំចងហើយ ពួកគេក៏បាននាំខ្ញុំមកដាក់ក្នុងត្រាក់ទ័រ ក្នុងនោះគឺមានស្ត្រីប៉ុន្មាននាក់ស្រាប់។[101]

ពួកគេបាននាំស្ត្រីទាំងនេះទៅដាក់នៅវត្តក្បែរនោះដែលគេប្រើប្រាស់ជាគុក ដោយដាក់ខ្នោះទុកក្នុងបន្ទប់មួយ ដែលមានប្រុសស្រីចំនួន ១០ នាក់ស្រាប់។

> មានទាហានក្មេងៗប្រហែល ៥ ទៅ ៧ នាក់ មកចាប់រំលោភអ្នកទោសថ្មីៗរួមទាំងខ្ញុំផងដែរ ដោយប្រើមេដើងរបស់ពួកគេ។ ទាហានទាំងនោះមានអាយុប្រហែល ២០ ឆ្នាំឬក្មេង ជាងនេះ។ ពួកគេស្រែកឲ្យខ្ញុំនិងស្ត្រីផ្សេងទៀតដោះសំពត់ ហើយពួកគេបានយកមេដើងគេដាក់ចូលក្នុង "ប្រដាប់ភេទយើង"។ ពួកគេតែងតែធ្វើដូច្នេះចំពោះអ្នកទោសថ្មីៗ។[102]

ចប់ បានជួបប្រទះនូវបទពិសោធទទួលរងទារុណកម្មធ្ងន់ធ្ងរខ្លាំងជាងនេះទៀត ដោយបានរៀបរាប់នូវស្ថានភាពដែលគាត់ត្រូវបានខ្មែរក្រហមចាប់គាត់ទុកធ្វើជាទាសករផ្លូវភេទក្នុងផ្ទះបន ដោយសារតែគាត់បដិសេធរៀបការជាមួយជនដែលបានសម្លាប់ប្តីរបស់គាត់។ គាត់មានគភ៌បីខែនាពេលនោះ។ គាត់បានរៀបរាប់ដូចខាងក្រោម៖

---

101 បទសម្ភាសន៍សម្រាប់ករណីសិក្សាទី ៧ ស្ត្រី (ថ្ងៃទី ២៨ ខែមេសា ឆ្នាំ២០១៤)
102 Ibid.

ចាស អនុសេនីយឯក J ស្រលាញ់ខ្ញុំ ហើយប្តីរបស់ខ្ញុំត្រូវបានសម្លាប់ដោយសារហេតុផលនេះ...នៅពេលដែលខ្ញុំដឹងរឿងនេះ ខ្ញុំបានស្រែកខ្លាំងៗ ហើយបាននិយាយថា "ឲ្យ ប្តីខ្ញុំមកវិញមក!"។ បន្ទាប់មកខ្ញុំត្រូវបានចងជាប់នឹងច្រវាក់ ហើយដាក់គុកនៅយប់នោះ។ ព្រឹកស្អែកឡើង អនុសេនីយឯក J បានដោះលែងខ្ញុំ។ មានកម្មាភិបាលមកយកខ្ញុំទៅសាលាចិនហើយប្រាប់ខ្ញុំថាខ្ញុំត្រូវទៅដាំដំឡូង ។នៅពេលដែលទៅដល់ មានប្រុសស្រី ៩គូ រួមទាំងខ្ញុំផង ។ ខ្ញុំបានសួរថា "សមមិត្តយកខ្ញុំមកទីនេះដើម្បីដាំដំឡូងមែន ?"កម្មាភិបាលឆ្លើយ"ទេ សមមិត្តមកទីនេះដើម្បីរៀបការជាមួយអនុសេនីយឯក J ។ ខ្ញុំឮហើយ ខ្ញុំក៏យំ ។ ខ្ញុំបានប្តេជ្ញា ថាមិនរៀបការទេ ។ មួយគូៗត្រូវបានគេប្រាប់ឲ្យកាន់ដៃគ្នា ហើយពេលដល់វេលាខ្ញុំ ខ្ញុំបាន ប្រកែក "ទេ ខ្ញុំពុំស្គាល់ថាជាប្តីនរណាទេ ! ខ្ញុំមិនព្រមរៀបការទេ ទោះបីជាខ្ញុំស្លាប់ពេលនេះ ក៏ខ្ញុំពុំរៀបការដែរ ! ខ្ញុំពុំដឹងថាឪពុកម្តាយ បងប្អូនខ្ញុំនៅទីណាទេ !" អនុសេនីយឯក J បានទះខ្ញុំមួយដៃចំមុខ ហើយវាបានប្រើស្បែកជើងវាយក្បាលខ្ញុំច្រើនដង ។ វាសួរខ្ញុំថា "រៀបការឬមិនរៀបការ ?" ខ្ញុំនៅតែនិយាយថា "ទេ ទេ !".... អនុសេនីយឯក J បានប្រាប់ទៅអ្នកយាមថា "យកនាងទៅទុកកន្លែងនោះ [ត្រឡប់ទៅគុកវិញ ] ហើយយើងនឹងរំលោភនាងពេលក្រោយ ។"

នៅក្នុងគុក ពួកគេបានដោះខោអាវខ្ញុំចេញអស់ និងបានចងច្រវាក់ខ្ញុំជាប់ ... ខ្ញុំកាន់តែរើ ច្រវាក់កាន់តែតឹង ... បន្ទាប់មកទាហានក្មេងៗអាយុប្រហែល ១៥ ឬ ១៦ ឆ្នាំ បានប្រើស្បែកជើងមកប៉ះប្រដាប់ភេទរបស់ខ្ញុំ ហើយពួកគេប្រចាប់ដោះខ្ញុំ និងថើបខ្ញុំរហូតខ្ញុំសន្លប់លែងដឹងខ្លួន ...នៅពេលខ្ញុំភ្ញាក់ឡើងពេលព្រឹក ខ្ញុំឃើញអនុសេនីយឯក J នៅក្បែរខ្ញុំ ។ វាបាននិយាយថា "ឃើញទេ ? ប្រសិនបើសមមិត្តសុខចិត្តរៀបការជាមួយខ្ញុំ សមមិត្តនឹងមិនមានបញ្ហាដូចពេលនេះឡើយ ។ ប៉ុន្តែទោះបីជាសមមិត្តមិនព្រមជាមួយខ្ញុំ ក៏ខ្ញុំបានខ្លួនសមមិត្តរួចហើយដែរ" ។ ហើយរាល់យប់ ខ្ញុំពុំដឹងថាទាហានក្មេងៗទាំងនោះមកពីណាទេ ប៉ុន្តែពួកគេមកវាយ និងចាប់រំលោភខ្ញុំរហូតដល់ខ្ញុំបាត់បង់ស្មារតី ហើយពេលខ្ញុំងើបឡើង ខ្ញុំឃើញអនុសេនីយឯក J នៅជិតខ្ញុំ ។

បទសម្ភាសន៍ជាមួយ ចប៉ បានបង្ហាញថាការទទួលរងទារុណកម្មបែបនេះពុំមែនមានតែម្នាក់ឯងទេ ហើយហិង្សាផ្លូវភេទជាផ្នែកមួយនៃទារុណកម្មចំពោះរាល់ការបដិសេធអាពាហ៍ពិពាហ៍ដោយបង្ខំ ។

នៅមានស្ត្រីផ្សេងៗទៀតក្រៅពីខ្ញុំ ។មានស្ត្រីទាំងអស់ប្រហែលជាពី២០ទៅ៥០នាក់ ហើយក្នុងនោះករណីខ្លះគឺដូចខ្ញុំ ដោយសារតែពួកគេបដិសេធពុំរៀបការ ។ ពួកគេ

បានចាប់រំលោភស្ត្រីទាំងអស់នោះហើយពេលខ្លះគេប្រើលិង្គដាក់ចូលក្នុងមាត់របស់យើង ឬយកមកដាក់មុខយើង។ ខ្ញុំមិនដឹងថាមានប៉ុន្មាននាក់ទេដែលចាប់រំលោភខ្ញុំក្នុងមួយយប់ៗនោះ។ ពួកវាបានចាប់រំលោភនារីផ្សេងៗទៀតនៅនឹងមុខយើង ហើយខ្ញុំក៏បិទភ្នែកទៅ។រាងកាយខ្ញុំញាប់ញ័រ ខ្ញុំយំទាំងយប់ទាំងថ្ងៃ។នារីផ្សេងទៀតនៅទីនោះក៏ស្រែកទ្រហោយំ។មាននារីម្នាក់ស្អាតណាស់ប៉ុន្តែនាងបានស្លាប់ក្រោយយប់ទីមួយ ដោយសារពួកវាបានចាប់រំលោភនាងដល់ស្លាប់។[103]

អាពាហ៍ពិពាហ៍ដោយបង្ខំដែលអនុវត្តក្នុងរបបខ្មែរក្រហម គឺពោរពេញដោយភាពឈឺចាប់បំផុតក្នុងគ្រប់ករណីដែលយើងបានសិក្សា។ ប្រជាជនគ្មានជម្រើសទាល់តែសោះ លើកលែងក្នុងករណីដែលប្តីអាចជ្រើសរើសថាតើត្រូវរំលោភបំពានលើប្រពន្ធឬអត់ ក្នុងវប្បធម៌រំលោភស្តែងៗនិងវប្បធម៌និរទណ្ឌភាព។ ការយល់ព្រមគឺគ្មានតម្លៃទេក្នុងបរិយាកាសពោរពេញដោយការធ្វើទារុណកម្មពិតនិងការគំរាមកំហែងនោះ។ ហិង្សាផ្លូវភេទ ជាពិសេសទៅលើស្ត្រី ត្រូវបានប្រើដើម្បីរួមដំណេកក្រោយអាពាហ៍ពិពាហ៍ និងដើម្បីដាក់ទោសអ្នកដែលមិនគោរពតាមអាពាហ៍ពិពាហ៍ដោយបង្ខំ និងគោលនយោបាយទំនាក់ទំនងភេទដោយបង្ខំរបស់អង្គការ។ ការអនុវត្តនូវអាពាហ៍ពិពាហ៍ដោយបង្ខំខាងលើនេះគឺជាការប្រមាថដ៏ធ្ងន់ធ្ងរចំពោះសេចក្តីថ្លៃថ្នូរមនុស្សជាតិ និងជាការប្រមាថដល់គោលការណ៍វប្បធម៌ចាំបាច់។

### គ. អាពាហ៍ពិពាហ៍ក្រោយរបបខ្មែរក្រហម

ក្នុងឆ្នាំ ១៩៧៩ ខ្មែរក្រហមបានចាញ់ក្រោមការវាយលុករបស់កងទ័ពវៀតណាម។ ទិដ្ឋភាពពេលនោះគឺពោរពេញដោយក្តីឈឺចាប់ខ្លោចផ្សាពន់ពេក គឺគ្រួសារស្វែងរកសមាជិកគ្រួសារដែលនៅរស់ និងភូមិកំណើតនិងទ្រព្យសម្បត្តិដែលបាត់បង់។ ជាងនេះទៅទៀតនោះគឺសង្គ្រាមស៊ីវិលនៅមិនទាន់បញ្ចប់ ដោយកងកំលាំងសន្តិសុខរបស់រដ្ឋបានរកវិធីសាស្ត្រដើម្បីបញ្ចប់នូវសកម្មភាពអូសបន្លាយរបស់ក្រុមឧទ្ទាមខ្មែរក្រហម។ បទសម្ភាសន៍បានបង្ហាញពីភាពច្របូលច្របល់ក្នុងសម័យនោះអំពីស្ថានភាពគ្រួសារដែលមានតាំងពីរបបខ្មែរក្រហម។ គូស្វាមីភរិយាពិបាកសម្រេចថាតើគួរបន្តនៅជាមួយគ្នាឬចែកផ្លូវគ្នាទៅតាមករណីជាក់ស្តែងមួយៗនិងត្រូវគិតអំពីថាតើត្រូវរស់នៅក្នុងភាពខ្វេចខ្វាំក្រោយរបបខ្មែរក្រហមយ៉ាងដូចម្តេច។បទសម្ភាសន៍ពីរបីក្នុងការសិក្សារបស់យើងជាមួយនឹងអ្នកដែលត្រូវបង្ខំឲ្យរៀបការនោះ បានរៀបរាប់អំពីជីវិតអាពាហ៍ពិពាហ៍ដែលនៅបន្តរស់នៅជាមួយគ្នាថែមមួយរយៈពេលទៀត ក្រោយការដួលរលំនៃរបបខ្មែរក្រហម។ មានស្វាមីភរិយាពីរគូដែលនៅបន្តរស់នៅជាមួយគ្នាដល់សព្វថ្ងៃ មួយគូ

[103] បទសម្ភាសន៍សម្រាប់ករណីសិក្សាទី ២ ស្ត្រី (ថ្ងៃទី ២៥ ខែមេសា ឆ្នាំ២០១៤)

រស់នៅដោយភាពចុះសម្រុង និងមួយគូទៀតក្នុងជីវិតអាពាហ៍ពិពាហ៍ដោយបង្ខំនិងពុំអាចរត់គេចទៅណាបានឡើយ។អាពាហ៍ពិពាហ៍ដោយបង្ខំផ្សេងទៀតត្រូវបញ្ចប់ដោយមរណភាពការលែងលះ ការបែកបាក់ ឬការបោះបង់។

ស្វាមីភរិយាដែលចូលរួមក្នុងបទសម្ភាសន៍ ដំបូងគាត់ពុំមានផែនការរស់នៅជាមួយគ្នាទេ ហើយបទសម្ភាសន៍ជាមួយគាត់បានបង្ហាញពីលទ្ធភាពដែលគូស្វាមីភរិយានោះអាចបន្តរស់នៅជាមួយគ្នាដោយហេតុផលតាមស្ថានភាពជាក់ស្តែងក្នុងការដែលត្រូវប្រឈមនឹងការរស់នៅក្រោយរបបដែលពោរពេញដោយភាពខ្វះខាតខ្លាំបាត់បង់បណ្តាញគ្រួសារ និងសង្គម។ អបច និង សច បានរៀបរាប់អំពីការរស់នៅក្រោយការដួលរលំនៃរបបខ្មែរក្រហមថ្មីៗ នៅពេលដែលប្រជាពលរដ្ឋកំពុងស្វែងរកសមាជិកគ្រួសារដែលនៅរស់ លាក់ខ្លួនក្នុងព្រៃ គេចពីកម្មាភិបាលខ្មែរក្រហម ឬមានការភ័យខ្លាចកងទ័ពវៀតណាមដែលបានវាយលុកចូលមកទឹកដីកម្ពុជា។ សមាជិកគ្រួសារជំបានដើរតួនាទីរក្សាអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលនេះបានបង្ហាញថាទំនៀមទំលាប់អាពាហ៍ពិពាហ៍បែបប្រពៃណី គឺចាប់ផ្តើមមានសារៈសំខាន់ឡើងវិញបន្តិចម្តងៗក្នុងសម័យនោះ។ នៅក្នុងបទសម្ភាសន៍ជាច្រើន រួមទាំងមួយនេះផង បានលើកឡើងពីការឆ្លងកាត់សោកនាដកម្មជាមួយគ្នា ហើយការជួយគ្នាទៅវិញទៅមកបានក្លាយជាកំណើតនៃចំណងមនោសញ្ចេតនា -- អបច និង សច ជាឧទាហរណ៍ស្រាប់ គឺពួកគាត់បានប្រាប់យើងអំពីអំពើល្អដែលពេលខ្លះគឺពាក់ព័ន្ធនឹងភាពខុសគ្នារវាងស្លាប់និងរស់ គឺការចែករំលែកអាហារបរិភោគ ឬជួយគ្នាបង្ហើយការងារ។ ពាក្យប្តី និងប្រពន្ធ ត្រូវប្រើក្នុងសេចក្តីដកស្រង់ខាងក្រោមដើម្បីជួយសម្រួលការអាន។

**ប្តី៖** ម្តាយខ្ញុំពុំចង់ឲ្យខ្ញុំចាកចេញពីប្រពន្ធខ្ញុំទេ ហើយគាត់មានរទេះគោ។ ដូច្នេះហើយគាត់បានឲ្យខ្ញុំទៅយកប្រពន្ធខ្ញុំ ដើម្បីមករស់នៅជាមួយពីព្រោះគាត់ពុំចង់ឲ្យប្រពន្ធខ្ញុំរស់នៅតែជាមួយម្តាយរបស់នាង។ ខ្ញុំក៏បានទៅរកប្រពន្ធខ្ញុំ ហើយនាំនាងមកជួបម្តាយខ្ញុំ។
**ប្រពន្ធ៖** នៅពេលនោះ ខ្ញុំពុំមានរទេះគោទេ ម្តាយខ្ញុំបានធ្លាក់ខ្លួនឈឺខ្លាំង ហើយយើងមានរបស់របរខ្លះដូចជាស្រូវ ចាន ឆ្នាំងដែលខ្ញុំត្រូវយកតាមខ្លួននៅពេលយើងធ្វើដំណើរ។
**ប្តី៖** ខ្ញុំបានទៅយកនាងនៅម៉ោង ១២ រសៀល... ជាការពិតខ្ញុំក៏ចង់ឱ្យនាងរស់នៅជាមួយយើងដែរ គឺយើងអាចថែរក្សាគ្នានៅតាមផ្លូវនៅក្នុងព្រៃនោះ។ [ក្រោយមក] នៅពេលដែលយើងបានរស់នៅក្នុងព្រៃជាមួយគ្នាយើងបានជួបប្រទះការលំបាកហើយយើងបានជួយគ្នាទៅវិញទៅមក។ យើងបានចាប់ផ្តើមមានអារម្មណ៍ល្អចំពោះគ្នានៅពេលនោះទៅ។

**ប្រពន្ធ៖** ថ្ងៃនោះបងប្រុសរបស់ខ្ញុំបាននិយាយមកកាន់ខ្ញុំថា "តើអ្នកណាកំពុងជិះរទេះគោនោះ?" ខ្ញុំបានបែរទៅមើលប្ដីរបស់ខ្ញុំហើយឆ្លល់ថាហេតុអ្វីបានជាគាត់មកភូមិរបស់ខ្ញុំ។ ខ្ញុំបានរៀបចំបន្តដំណើរជាមួយម្ដាយ ហើយខ្ញុំមិនខ្វល់ថាគាត់ទៅណាជាមួយគ្រួសារគាត់ទេ។

**អ្នកផ្ដល់សម្ភាស៖** តើអ្នកមានគម្រោងទៅជួបប្ដីរបស់អ្នក?

**ប្រពន្ធ៖** ទេ។ ម្ដាយរបស់គាត់បានឲ្យគាត់មកយកម្ដាយរបស់ខ្ញុំនិងខ្ញុំ។ គាត់បាននិយាយថា "ម្ដាយខ្ញុំបានឲ្យខ្ញុំមកទទួលយកអ្នកដូច្នេះយើងអាចស្នាក់នៅជាមួយគ្នានិងថែរក្សាគ្នាទៅវិញទៅមកបាន។" ខ្ញុំគិតថាខ្ញុំមិនមានមធ្យោបាយដឹកជញ្ជូន ហើយខ្ញុំមានការភ័យខ្លាចថាខ្ញុំមិនអាចរត់គេចខ្លួនបានទេ [បើខ្មែរក្រហមចាប់យើង] បើគ្មានគាត់។ ដូច្នេះប្ដីខ្ញុំបានយកឥវ៉ាន់តបស់របបនិងជូនម្ដាយខ្ញុំឡើងរទេះគោ ហើយយើងបានទៅរស់នៅជាមួយក្រុមគ្រួសារប្ដីខ្ញុំទៅ។[104]

ពួកគាត់នៅទីបំផុតមានកូនប្រាំពីរនាក់ជាមួយគ្នា កូនទីមួយកើតក្នុងឆ្នាំ ១៩៨០។ ដោយក្រីក្រពេកពុំអាចធ្វើពិធីអាពាហ៍ពិពាហ៍បែបប្រពៃណីក្នុងកាលៈទេសៈនោះ ទើបតែនៅក្នុងឆ្នាំ២០០០ ពួកគាត់បានត្រឹមថតរូបអាពាហ៍ពិពាហ៍ក្នុងសំលៀកបំពាក់ប្រពៃណី។

មានករណីអាពាហ៍ពិពាហ៍ដោយបង្ខំមួយដែលពុំទាន់បញ្ចប់ គឺជាអាពាហ៍ពិពាហ៍ដោយបង្ខំនិងមានការរំលោភបំពានដោយប្រពន្ធពុំអាចរត់គេចរួច។ អាពាហ៍ពិពាហ៍នេះអាចចាត់ ទុកថាជាអាពាហ៍ពិពាហ៍ដែលពិបាកបំផុតក្នុងការរំលាយ ដោយមានហេតុផលច្រើនទាក់ទងនឹងគំនុំ ការពឹងអាស្រ័យផ្នែកសេដ្ឋកិច្ច ភាពភ័យខ្លាចនៃការបោះបង់កូន និងជំងឺផ្លូវចិត្តដែលបណ្ដាលមកពីការរំលោភបំពាន។ ដំបូង ហាក បានព្យាយាមគេចពីប្ដីដែលរៀបការដោយបង្ខំនិងប្រមាថភ្លាមៗក្រោយពីការដួលរលំនៃរបបខ្មែរក្រហមក្នុងឆ្នាំ ១៩៧៩។ ដោយបានគិតថាគាត់អាច"រួចផុតពីប្ដីរបស់គាត់"ហើយអាពាហ៍ពិពាហ៍លែងមានសុពលភាពទៀតហើយគាត់បានធ្វើដំណើរតែម្នាក់ឯងទៅកាន់ភូមិកំណើត។ ពីរខែក្រោយមកស្រាប់តែប្ដីគាត់បានរកគាត់ឃើញ គឺនៅពេលដែលគាត់មានគភ៌ចំនួនប្រាំខែ។ហាក បានពន្យល់អំពីការសម្រេចចិត្តបន្តរស់នៅក្នុងជីវិតអាពាហ៍ពិពាហ៍ "គឺដោយសារខ្ញុំមានគភ៌ ហើយខ្ញុំពុំមានបងប្អូន និងខ្ញុំពុំមានលុយហើយខ្ញុំពុំចង់ឲ្យកូនខ្ញុំធំដឹងក្ដីឡើងជួបបញ្ហា ដោយគ្នាគ្មានគ្រួសារនោះទេ"។ គាត់បន្តរៀបរាប់អំពីជីវិតរួមរស់របស់គាត់ ៣០ ឆ្នាំក្រោយមកដូចតទៅ៖

នៅពេលដែលខ្ញុំប្ដឹងសុំលែងលះជាមួយគាត់ ហើយប៉ូលីសបានចាប់និងអប់រំគាត់

---

[104] បទសម្ភាសន៍សម្រាប់ករណីសិក្សាទី ៣ ស្វាមីភរិយា (ថ្ងៃទី ២៣ ខែមេសា ឆ្នាំ២០១៤)

> គាត់នៅតែវាយដំខ្ញុំនៅពេលគាត់មកដល់ផ្ទះ។ ខ្ញុំនៅមានស្នាមរបួសនៅកែងដៃនៅឡើយ ដោយសារគាត់បានចាក់ខ្ញុំនៅឆ្នាំ ២០១២ ពេលដែលខ្ញុំកំពុងគេងមុខទូរទស្សន៍ គាត់បានចាក់សោរហើយបានចាក់ខ្ញុំ ខ្ញុំបានស្រែកឲ្យកូនខ្ញុំជួយ។ កូនរបស់ខ្ញុំស្ទើរតែមិនអាចជួយខ្ញុំបាននៅពេលនោះដោយសារទ្វារបិទចាក់សោរជាប់... ក្នុងរបបនោះខ្ញុំទទួលយកអាពាហ៍ពិពាហ៍និងរួមដំណេកជាមួយប្ដី គឺដើម្បីជីវិតរស់។ បន្ទាប់មកខ្ញុំមានកូនជាមួយប្ដីខ្ញុំ នេះជាហេតុផលដែលខ្ញុំបន្តរស់នៅជាមួយគាត់។[105]

ក្នុងបទសម្ភាសន៍របស់យើង កូនត្រូវបានចាត់ទុកជាកត្តាជំរុញចំបងចំពោះអាពាហ៍ពិពាហ៍ដែលពុំទាន់រំលាយ ក្រោយរបបខ្មែរក្រហមដួលរលំថ្មីៗ។

ក្នុងបទសម្ភាសន៍ ក៏មានការរំលោភបំពានខ្លាំងក្នុងអាពាហ៍ពិពាហ៍ដែលពុំទាន់រំលាយក្រោយរបបខ្មែរ។ក្រៅពីហកស្ត្រីបីនាក់ទៀតបានលើកឡើងពីការរំលោភបំពានក្នុងគ្រួសារក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំជាពិសេសគឺក្រោយការដួលរលំនៃរបបខ្មែរក្រហម។ កណ ទទួលបានជោគជ័យក្នុងការសុំលែងលះ ដោយមូលហេតុចំបងគឺគាត់អាចរកជម្រកការពារខ្លួននៅក្នុងសហគមចាមអ៊ីស្លាមរបស់គាត់ (ប្ដីរបស់គាត់ជាពុទ្ធសាសនិកខ្មែរ)។គាត់បានរៀបរាប់ដូចតទៅ៖

> គាត់ផឹកស៊ីជាមួយប្រុសៗផ្សេងទៀតក្នុងភូមិ ហើយគាត់វាយដំខ្ញុំ។ ក្នុងឆ្នាំ ២០០៦ ខ្ញុំសម្រេចចិត្តលែងលះគ្នា។ ខ្ញុំគឺជាអ្នកសម្រេចចិត្ត។ ខ្ញុំបានរាយការណ៍ទៅមេឃុំសុំឲ្យគាត់ជួយខ្ញុំ ដោយសារខ្ញុំជួបការលំបាកខ្លាំងណាស់ក្នុងការរស់នៅជាមួយគាត់... នៅពេលដែលគាត់ដឹងពីរឿងលែងលះ ប្ដីខ្ញុំបានយកកាំបិតមកគំរាមខ្ញុំ ហើយខ្ញុំត្រូវរត់ទៅផ្ទះអ្នកភូមិផ្សេងទៀតដើម្បីលាក់ខ្លួន។[106]

អ្នកផ្ដល់សម្ភាសក៏បានលើកឡើងអំពីហិង្សាក្នុងគ្រួសារ និងការបែកបាក់ ក្រោយពេលដែលប្ដីរបស់ពួកគាត់ត្រូវបានគេកែនឲ្យធ្វើទាហានក្នុងឆ្នាំ១៩៩៣។ចំនុចនេះគឺបានបញ្ជាក់ពីវិវាទលើជម្រើសនិងឥរិយាបទរបស់បុរសនិងអារម្មណ៍ភ័យខ្លាចខ្វះសុវត្ថិភាពរបស់ស្ត្រីជាពិសេសគឺអ្នកដែលជាប់ខ្លួនដកមិនរួចពីអាពាហ៍ពិពាហ៍ដោយបង្ខំនិងប្រមាថ ឬមិនចេះជួយគ្នា ក្នុងរយៈពេលប៉ុន្មានឆ្នាំនោះដែលពោរពេញដោយភាពចលាចលនៃសង្គ្រាមស៊ីវិលដែលនៅបន្ត។ កណ បាននិយាយថា "ដំបូងគាត់មិនអីទេ គាត់ស្ដាប់ខ្ញុំ ប៉ុន្តែចាប់តាំងពីឆ្នាំ ១៩៩៣ (នៅពេលដែលគាត់ចូលធ្វើទាហាន) គាត់ចាប់ផ្ដើមផឹកស៊ី និងក្លាយជាបុរសដែលកំណាញ់។ គាត់វាយខ្ញុំ

[105] បទសម្ភាសន៍សម្រាប់ករណីសិក្សាទី ៦ ស្ត្រី (ថ្ងៃទី ២៨ ខែមេសា ឆ្នាំ២០១៨)
[106] បទសម្ភាសន៍សម្រាប់ករណីសិក្សាទី ៨ ស្ត្រី (ថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០១៨)

ហើយលែងស្តាប់ខ្ញុំទៀតហើយ។"[107]បស បានរៀបរាប់"គាត់បានទៅធ្វើទាហាន ហើយមានស្រីផ្សេងទៀតនៅក្រៅផ្ទះ។ គាត់ជាទាហាន ដូច្នេះគាត់មានស្រីជាច្រើន"[108]ហអ បានពន្យល់ថា "មុនពេលដែលគាត់ចេញទៅធ្វើទាហាន គាត់នៅល្អធម្មតាទេ។ គាត់បានធ្វើស្រែ និងធ្វើស្ករជួយចិញ្ចឹមកូន។ គាត់ល្អ ប៉ុន្តែពេលគាត់ក្លាយជាទាហាន គាត់បានផ្លាស់ប្តូរ។"[109]

ដូចដែលបានរៀបរាប់នៅក្នុងផ្នែកទី២តាមរយៈការស្រាវជ្រាវផ្សេងៗទៀតបានបង្ហាញអំពីចំនួនលើសលប់នៃ "ស្ត្រីមេម៉ាយ" ជាពាក្យប្រើដើម្បីពណ៌នាពីស្ត្រីដែលបានរៀបការហើយគ្មានប្តី ទោះដោយសារកត្តាអ្វីក៏ដោយ។ តាមបទសម្ភាសន៍ក្នុងការសិក្សារបស់យើង អាពាហ៍ពិពាហ៍ដោយបង្ខំគឺមានទំនាក់ទំនងទៅនឹងការកើនឡើងនៃការចុះចោលប្រពន្ធ និងអគ្រាពហុពន្ធភាព ដោយប្រពន្ធជាអ្នកថែរក្សាកូន និងមនុស្សចាស់នៅក្នុងគ្រួសារ។ បស បានបកស្រាយថា ប្តីគាត់បានរត់តាមស្រីក្មេងម្នាក់ទៅព្រំដែនប្រទេសថៃ ដោយមិនត្រលប់មកវិញនោះទេ។ ចំណែកឯកូនៗតែងតែសម្លឹងទៅឪពុករបស់ក្មេងដទៃដែលវិលត្រលប់មករកកូនរបស់ខ្លួនវិញ ប៉ុន្តែ មានតែប្តីរបស់ខ្ញុំទេដែលមិនបានត្រលប់មករកយើងវិញ។"[110]ហអ បានរៀបរាប់អំពីអាពាហ៍ ពិពាហ៍ជាច្រើនដងរបស់ប្តីនាង៖

> យើងបានបែកគ្នានៅពេលដែលប្តីរបស់ខ្ញុំក្លាយជាទាហាន។ គាត់ត្រូវឈរជើងនៅក្រុងកំពត ហើយគាត់ក៏លួចមានស្រី។ គាត់មានស្រីច្រើនណាស់ ហើយនៅពេលដែលគាត់មានលុយមួយចំនួន គាត់ក៏បានរៀបការជាមួយប្រពន្ធផ្សេងទៀតដោយទុកឲ្យខ្ញុំនៅផ្ទះដើម្បីថែរក្សាម្តាយក្មេក។ យើងមានកូនចំនួនបីនាក់។ ខ្ញុំបានដឹងអំពីអាពាហ៍ពិពាហ៍នេះដោយសារតែនៅខេត្តកំពតបញ្ហានេះមិនមែនជាការសម្ងាត់នោះទេ។ ខ្ញុំក៏មិនដឹងថាត្រូវធ្វើយ៉ាងដូចម្តេចដែរ។ ខ្ញុំមិនអាចចាកចេញពីផ្ទះរបស់ខ្ញុំដើម្បីទៅស្វែងរកប្តីរបស់ខ្ញុំនោះទេ ព្រោះខ្ញុំមានផ្ទះ កូន និងគោដែលត្រូវមើលថែ។ នៅពេលដែលខ្ញុំបានដឹងថាគាត់រៀបការ ខ្ញុំបានត្រឹមតែនៅផ្ទះដោយពុំអាចធ្វើអ្វីសោះ។ នៅពេលណាដែលគាត់នឹកឃើញខ្ញុំ ទើបគាត់ត្រលប់មក ខ្ញុំគិតថា...គាត់ប្រាកដជាមានប្រពន្ធច្រើន។ ទីបំផុតខ្ញុំក៏បានទៅកន្លែងដែលគាត់រៀបការ។ ខ្ញុំបានធ្វើដំណើរតាមរថភ្លើង។ កូនស្រីបងរបស់ខ្ញុំមានអាយុ ប្រហែលដប់ឆ្នាំ។ ខ្ញុំបានជួប ចៅហ្វាយរបស់គាត់ហើយខ្ញុំបានដាក់ពាក្យបណ្តឹងមួយដើម្បីបញ្ឈប់អាពាហ៍ពិពាហ៍នោះដោយបាននិយាយថា គាត់មិនបានបំពេញកាតួកិច្ចជាស្វាមីចំពោះខ្ញុំ។នៅពេលព្រឹកនៃថ្ងៃ

107 Ibid.
108 បទសម្ភាសន៍សម្រាប់ករណីសិក្សាទី ៥ ស្ត្រី (ថ្ងៃទី ២៥ ខែមេសា ឆ្នាំ២០១៤)
109 បទសម្ភាសន៍សម្រាប់ករណីសិក្សាទី ៤ ស្ត្រី (ថ្ងៃទី ២ ខែឧសភា ឆ្នាំ២០១៤)
110 បទសម្ភាសន៍សម្រាប់ករណីសិក្សាទី ៥ ស្ត្រី (ថ្ងៃទី ២៥ ខែមេសា ឆ្នាំ២០១៤)

> រៀបការនោះ ចៅហ្វាយគាត់បាននាំគាត់ទៅកន្លែងបោះជំរំនិងមិនអនុញ្ញាតឲ្យគាត់ចូលទៅកាន់សាលរៀបអាពាហ៍ពិពាហ៍នោះទេ ដូច្នេះប្រពន្ធថ្មីរបស់គាត់បានរៀបការជាមួយត្រឹមសម្លៀកបំពាក់ជំនួសវិញ។[111]...បន្ទាប់ពីមួយខែក្រោយមកគាត់នៅតែមិនត្រលប់មកផ្ទះវិញដោយសារតែគាត់ខឹងខ្ញុំដែលបានបញ្ឈប់ពិធីរៀបការរបស់គាត់។ ខ្ញុំបានរង់ចាំគាត់អស់រយៈពេលមួយខែ បន្ទាប់មកខ្ញុំក៏បានសុំលាឪពុកម្តាយក្មេកទៅរស់នៅជាមួយម្តាយរបស់ខ្ញុំវិញ។ ខ្ញុំមានកូនបីនាក់ ហើយគ្មាននរណាម្នាក់ជួយចិញ្ចឹមទេ។ ខ្ញុំបានសង់ផ្ទះដែលយើងរស់នៅនេះ ដូច្នេះនៅពេលដែលខ្ញុំចេញ ខ្ញុំរុះរើផ្ទះយកទៅជាមួយខ្ញុំដែរ។[112]...ក្រោយមកមានបុរសជាច្រើនសុំខ្ញុំរៀបការប៉ុន្តែខ្ញុំបដិសេធ។ ខ្ញុំបានសម្រេចចិត្ត និងតាំងចិត្តថាខ្ញុំមិនរៀបការម្តងទៀតទេ។ ខ្ញុំជួបប្រទះការឈឺចាប់ក្នុងជីវិតរបស់ខ្ញុំជាខ្លាំងជាមួយនឹងបទពិសោធន៍នេះដែលបង្ហាញថាខ្ញុំត្រូវខិតខំធ្វើការចិញ្ចឹមកូនតែម្នាក់ឯង ហើយជីវិតរបស់ខ្ញុំនៅពេលនេះពិតជាលំបាកណាស់។[113]

បើទោះបីជាមានការសម្រេចយ៉ាងមុតមាំថានឹងពឹងផ្អែកលើខ្លួនឯងយ៉ាងណាក៏ដោយ ជីវិតរបស់ ហអ និងកូនក៏នៅតែមានការលំបាកខ្លាំង ដោយសារលទ្ធផលនៃការចុះចោលរបស់ប្តីនាង និងការលែងលះចុងក្រោយរបស់នាង។ នាងបានរៀបរាប់អំពីការលំបាកជាច្រើនដែលនាងបានប្រឈមមុខៈ

> ក្នុងរដូវវស្សា ខ្ញុំធ្វើស្រែដោយពុំមានប្តីជួយការងារប្រើកម្លាំងពលកម្មធ្ងន់ៗទេ។ ខ្ញុំមានកូនតូចៗហើយខ្ញុំក៏ត្រូវចេញទៅធ្វើស្រែនិងចំការទៀត។ នៅពេលនោះ យើងមានក្របីហើយខ្ញុំត្រូវថែរក្សាក្របីនៅពេលយប់។ នៅពេលដែលខ្ញុំត្រលប់មកផ្ទះវិញកូនៗរបស់ខ្ញុំទាំងអស់បានគេងលក់អស់ទៅហើយ។ វាយប់ជ្រៅទៅហើយ បន្ទាប់ពីខ្ញុំបានចម្អិនអាហារឲ្យកូនៗរបស់ខ្ញុំ។[114]

ក្នុងការសម្ភាសន៍របស់យើង ការរៀបម្តងទៀតជាពិសេសសម្រាប់ស្ត្រី សម្ពាធនៃការរៀបការម្តងទៀតបន្ទាប់ពីការលែងលះដោយសារអាពាហ៍ពិពាហ៍ដោយបង្ខំ គឺជារឿងពិតដែលកើតឡើង។

---

111 ខ្មែរអនុវត្តបានចំពោះអាពាពិពាហ៍កំបាំងមុខ

112 សូមពិនិត្យមលើ Bricknell, "'ចានក្នុងកន្រ្តក'" ស្តីអំពីស្ត្រីរុះផ្ទះចោលក្រោយពេលលែងលះ

113 បទសម្ភាសន៍សម្រាប់ករណីសិក្សាទី ៩ ស្ត្រី (ថ្ងៃទី ២ ខែឧសភា ឆ្នាំ២០១៩)

114 Ibid.

ក្នុងចំណោមប្រាំបីករណី មានប្រាំករណី គឺការរៀបការម្តងទៀតតាមការជ្រើសរើសក្រោយការដួលរលំនៃរបបខ្មែរក្រហម ក្នុងនោះមានបុរសដែលត្រូវបានសម្ភាសន៍ (ករណីសិក្សាទី១) និងស្ត្រីម្នាក់ដែលត្រូវបានគេបង្ខំជាទាសករផ្លូវភេទ (ករណីសិក្សាទី២) ។ នេះបង្ហាញថាជំនឿវប្បធម៌និងការមានទំនុកចិត្តលើស្ថាប័នអាពាហ៍ពិពាហ៍នៅមានឥទ្ធិពលយ៉ាងខ្លាំង ក្រោយរបបខ្មែរក្រហមជាពិសេសគឺបញ្ហាគ្រួសារ និងការប្រារព្ធពិធីសាសនា។ ការរៀបការម្តងទៀតគឺអាចកែតម្រូវឬយ៉ាងហោចណាស់អាចជួសជុលនូវភាពអាម៉ាស់ក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំជាពិសេសនៅពេលដែលយកពិធីប្រពៃណីមកអនុវត្ត។

ផ្ទុយទៅវិញ ក្តីសង្ឃឹមក្នុងការរៀបការម្តងទៀតក្រោយរបបខ្មែរក្រហម គឺនៅជាប់ ទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ ជាពិសេសចំពោះស្ត្រី បង្ហាញថាច្បាប់ស្រី នៅតែបន្តមានឥទ្ធិពលខ្លាំងក្នុងការឲ្យតម្លៃស្ត្រីដោយផ្អែកលើភាពបរិសុទ្ធ និងផ្ទះសម្បែងមួយប្រកបដោយការចុះសម្រុងនិងភាពជិតស្និត។ ដូចបានរៀបរាប់ក្នុងបទសម្ភាសន៍ ស្ត្រីត្រូវប្រឈមមុខនឹងស្ថានភាពលំបាកទ្វេ៖ មិនរៀបការក្រោយអាពាហ៍ពិពាហ៍ដោយបង្ខំ ឬមាន "ប្តីច្រើន" ដោយត្រូវរៀបការម្តងទៀត។ បុរសដែលប្រកាន់បទដ្ឋានយេនឌ័រខុសពីស្ត្រី និងមានឋានៈខ្ពស់ហួសពីត្រឹមតែការរៀបអាពាហ៍ពិពាហ៍នោះ ពុំប្រឈមផលវិបាកដូចស្ត្រីទេ នេះបើយោងតាមការសម្ភាសន៍។ ទំនាក់ទំនងបែបពហុពន្ធភាព បានបង្ហាញពីការអនុគ្រោះដល់បុរសឲ្យមានប្រពន្ធលើសពីមួយក្នុងពេលដំណាលគ្នា ឬបន្តបន្ទាប់ ដោយគ្មានការភ័យខ្លាចពីការមានឈ្មោះអាស្រូវ ឬធ្លាក់តម្លៃជាបុរសឡើយ។ចំនួន"ដីលើសលប់"នៃស្ត្រីធៀបនឹងបុរសក្នុងពេលនោះក៏បានគុណប្រយោជន៍ដល់បុរសក្នុងបរិបទនៃការរៀបការម្តងទៀតផងដែរ។

ការមានឈ្មោះអាស្រូវ ជាពិសេសចំពោះស្ត្រី គឺមានសភាពធ្ងន់ធ្ងរខ្លាំងចំពោះអាពាហ៍ពិពាហ៍ដោយបង្ខំដែលបានបញ្ចប់រួចទៅហើយនោះ។ តាមរយៈការរៀបរាប់ក្នុងបទសម្ភាសន៍ ទោះបីជាអាពាហ៍ពិពាហ៍ប្រភេទនេះបានកើតឡើងចំពោះមនុស្សភាគច្រើនក៏ដោយ ក៏អាពាហ៍ពិពាហ៍ដោយបង្ខំចំពោះស្ត្រីត្រូវបានចាត់ទុកថាអាពាហ៍ពិពាហ៍ដែលមិនល្អ៖ អាពាហ៍ពិពាហ៍នេះមិន មានការអនុញ្ញាតពីឪពុកម្តាយ ក៏ដូចជាមិនត្រឹមត្រូវតាមប្រពៃណី និងស្របច្បាប់តាមពិធីតាមបែបប្រពៃណី។ បញ្ហានេះមានផលប៉ះពាល់អវិជ្ជមានជាពិសេស នៅពេលដែលអាពាហ៍ពិពាហ៍ ដោយបង្ខំបានបញ្ចប់។ កេរ្តិ៍ឈ្មោះគ្រួសារបានខូចខាត ហើយគ្រួសារមិនអាចធានាបាំងសុវត្ថិភាពនៅពេលអាពាហ៍ពិពាហ៍នេះបែកបាក់ទេ ដែលនេះខុសពីអាពាហ៍ពិពាហ៍រៀបចំដោយឪពុក ម្តាយតាមបែបប្រពៃណី។ កហ បានពន្យល់ពីលទ្ធផលនៃអាពាហ៍ពិពាហ៍ដោយបង្ខំជាមួយនឹង ស្វាមីដ៏ឃោរឃៅ (នាងបានលែងលះកាលពីឆ្នាំ ២០០៦) ទៅលើឆាកជីវិតនាពេលអនាគត របស់នាងដូចខាងក្រោម៖

ដោយសារអាពាហ៍ពិពាហ៍ដោយបង្ខំ ទើបខ្ញុំមិនអាចរៀបការជាមួយបុរសល្អម្នាក់បាន។ ខ្ញុំមិនបានរៀបការម្តងទៀតទេ ក្រោយពេលលែងលះ ព្រោះខ្ញុំខ្លាចប្តីក្រោយធ្វើបាបខ្ញុំទៀត ហើយមិនល្អនឹងកូនៗរបស់ខ្ញុំ។ ខ្ញុំដឹងថាលើកនេះ ខ្ញុំអាចជ្រើសរើសដោយខ្លួនឯង ហើយម្តាយខ្ញុំអាចរៀបចំអាពាហ៍ពិពាហ៍ឲ្យខ្ញុំ។ ខ្ញុំតូចចិត្តដែរព្រោះខ្ញុំមិនមានពិធីរៀបការដូចគេសម័យបច្ចុប្បន្ន។ ខ្ញុំកាន់តែតូចចិត្តដែលប្តីរបស់ខ្ញុំប្តូរទៅជាឃោរឃៅ ប៉ុន្តែខ្ញុំមិនអាចខឹងនឹងម្តាយខ្ញុំបានទេ ព្រោះគាត់មិនបានរៀបចំដោយបង្ខំឡើយ។ ខ្ញុំខឹង ប៉ុល ពត ហើយខ្ញុំគិតថាអាពាហ៍ពិពាហ៍ដោយបង្ខំនៅសម័យ ប៉ុល ពត គឺជាឧក្រិដ្ឋកម្មដ៏អាក្រក់បំផុត។[115]

បស ដែលរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក្រោមចុងកាំភ្លើងឲ្យធ្វើជាកូនក្រមុំទាំងនៅវ័យក្មេង ហើយបន្ទាប់មកត្រូវបានប្តីនាងរំលោភយ៉ាងព្រៃផ្សៃ ដោយមានការផ្សំគំនិតពីទាហានខ្មែរក្រហម បានរំលឹកការរើសអើង ដែលនាងបានជួបប្រទះ នៅពេលនាងព្យាយាមរៀបការម្តងទៀតក្រោយរបបនេះដួលរលំ។ ជាពិសេស នាងបានរៀបរាប់ដោយត្រួសៗនូវសម្ពាធសហគមន៍ក្នុងការកែតម្រូវឋានៈជា "ស្ត្រីមេម៉ាយ" នៃអាពាហ៍ពិពាហ៍ដោយបង្ខំតាមរយៈអាពាហ៍ពិពាហ៍ត្រឹមត្រូវមួយ៖

ខ្ញុំសម្រេចចិត្តរៀបការម្តងទៀតនៅពេលខ្ញុំបានឮចាស់ៗនៅក្នុងភូមិមកប្រាប់ម្តាយខ្ញុំថា ខ្ញុំគួរតែរៀបការតាមប្រពៃណី...។ នៅពេលរបបនេះដួលរលំ មានបុរសម្នាក់ស្រលាញ់ខ្ញុំ។ យើងស្រលាញ់គ្នា។ ហើយគាត់បានសុំម្តាយគាត់ឲ្យមកជួបនិយាយជាមួយម្តាយខ្ញុំ។ នៅពេល ម្តាយគាត់មកដល់ គាត់ខ្សឹបប្រាប់កូនប្រុសគាត់ថា "នាងធ្លាប់រៀបការកាលសម័យខ្មែរក្រហមម្តងហើយកូន។ នាងជាស្ត្រីមេម៉ាយ។ ដូច្នេះម៉ែមិនយល់ព្រមឲ្យកូនការជាមួយនាងទេ។" គាត់បានព្យាយាមបញ្ចុះបញ្ចូលម្តាយគាត់ថា គាត់មិនគិតថា ខ្ញុំជាមេម៉ាយឬអត់ទេ។ គាត់ចង់រៀបការជាមួយខ្ញុំ។ ម្តាយគាត់នៅតែមិនព្រមដូចនេះគាត់បបួលខ្ញុំរត់។ ខ្ញុំគិតថាកាលសម័យខ្មែរក្រហមខ្ញុំរងគ្រោះច្រើនណាស់ ហើយពេលនេះខ្ញុំមិនគួររត់តាមគេទេ ព្រោះវានឹងបំផ្លាញកិត្តិយសគ្រួសារខ្ញុំ។ ក្រោយមក គាត់បានរៀបការជាមួយស្រីម្នាក់ផ្សេងទៀត។ ខ្ញុំបានតែយំម្នាក់ឯង។[116]

115 បទសម្ភាសន៍សម្រាប់ករណីសិក្សាទី ៨ ស្ត្រីខ្មែរអ៊ីស្លាម (ថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០១៤)
116 បទសម្ភាសន៍សម្រាប់ករណីសិក្សាទី ៥ ស្ត្រី (ថ្ងៃទី ២៥ ខែមេសា ឆ្នាំ២០១៤)

ត្រូវគេកំណត់ជា"ទំនិញដែលខូចហើយ"ដោយសារអាពាហ៍ពិពាហ៍លើកទី១(ដោយបង្ខំ) បស ទីបំផុត រៀបការជាមួយប្ដីឃោរឃៅម្នាក់ទៀត។ នាងបានរៀបរាប់ពីគោលការណ៍ដ៏តឹងរ៉ឹងរបស់ច្បាប់ស្រី ឲ្យសម្ងំស្ងៀម អត់ធ្មត់ទៅនឹងការបំពាន ដើម្បីការពារកិត្តិយសគ្រួសារ ជាជាងការលែងលះជាលើកទីពីរថា៖

បន្ទាប់មក ខ្ញុំបានសម្រេចថាមិនឲ្យនរណាម្នាក់ដឹងពីអាពាហ៍ពិពាហ៍ទីមួយរបស់ខ្ញុំទេ។ សូម្បីកូនៗខ្ញុំក៏មិនដឹងដែរ...។ ក្រោយមក នៅពេលដែលកងទ័ពវៀតណាមដកចេញពីប្រទេសកម្ពុជាទៅ មានទាហានម្នាក់បានស្រលាញ់ខ្ញុំ។ ឪពុកម្ដាយរបស់គាត់ បានមកជួបនិយាយជាមួយម្ដាយខ្ញុំ។ គាត់ជាពោះម៉ាយកូនមួយ។ ដូច្នេះខ្ញុំគិតថា យើងជាមេម៉ាយដូចគ្នា គាត់ប្រហែលជាមិនមើលងាយខ្ញុំទេ។ គាត់មិនបានដឹងពីអ្វីដែលបានកើតឡើងចំពោះខ្ញុំក្នុងសម័យខ្មែរក្រហមទេ ហើយគាត់ក៏មិនបានសួរដែរ។ ប៉ុន្តែជីវិតមិនងាយស្រួលឡើយ។ គាត់មានស្រីច្រើនណាស់។ គាត់វាយខ្ញុំ។ គាត់បង្ខំឲ្យខ្ញុំរួមដំណេក ដែលនេះជាទម្លាប់របស់មនុស្សប្រុស ហើយ (ក្នុងនាមជាប្រពន្ធ) ខ្ញុំគ្មានសិទ្ធិឆ្លើយថាទេ ឬសម្រេចឡើយ។ សម្រាប់ខ្ញុំ ខ្ញុំគ្រាន់តែចង់បានគ្រួសារដែលរីករាយមួយ ដូច្នេះខ្ញុំមិនបាននិយាយអ្វីពីរឿងនេះទេ។ ខ្ញុំបានព្យាយាមរកប្រាក់ឲ្យកូនៗទៅរៀន។ ចំពោះគាត់ គាត់មិនបានជួយរកប្រាក់ទេ។ គាត់មករកខ្ញុំ ហើយទៅបាត់វិញ។

ខ្ញុំគិតថា ប្ដីក្នុងសម័យខ្មែរក្រហមវាខុសដោយសារយើងមិនបានស្រលាញ់ និងព្រមព្រៀងជាមួយគ្នា។ ពេលខ្ញុំរៀបការម្ដងទៀត ខ្ញុំបានព្រមព្រៀងដោយផ្អែកលើការសម្រេចចិត្តខ្លួនខ្ញុំផ្ទាល់ ហើយឪពុកម្ដាយក៏យល់ព្រមដែរ។ ប្រសិនបើខ្ញុំចង់លែងលះម្ដងទៀត វានឹងខូចកិត្តិយសរបស់ខ្ញុំ។ ប្រសិនបើខ្ញុំរត់ពីគាត់ ខ្ញុំនឹងរងភាពអាម៉ាស់ពីអ្នកជិតខាងម្ដងទៀត។ ដូច្នេះខ្ញុំត្រូវអត់ធ្មត់។ ខ្ញុំមានកូនៗ ប្រសិនបើខ្ញុំចាកចេញពីប្ដីម្នាក់នេះ តើខ្ញុំគួរទៅណា? ភាពអាម៉ាស់ពីសម័យខ្មែរក្រហមនៅមិនទាន់បាត់នៅឡើយ ហើយប្រសិនបើខ្ញុំចេញពីប្ដីម្នាក់នេះ តើគេនឹងវិនិច្ឆ័យខ្ញុំជាស្រីបែបណា? ខ្ញុំបានគិតច្រើនណាស់ ហើយខ្ញុំក៏មិនបានរៀនសូត្រច្រើនដែរ។ ខ្ញុំខំប្រឹងធ្វើការនិងអត់ធ្មត់រស់នៅជាមួយគាត់ ដូច្នេះកូនៗរបស់ខ្ញុំអាចមានឪពុក...ខ្ញុំមានកូន ៦ នាក់ជាមួយគាត់និងកូនចុងម្នាក់។[117]

[117] Ibid.

កេរតំណែលខ្មែរក្រហម រួមទាំងការបំពានផ្លូវភេទ និងអំពើហិង្សាលើស្ត្រី ដូចជាការរំលោភ និងអាពាហ៍ពិពាហ៍ដោយបង្ខំ បានអន្ទោលតាមជាប់ស្ត្រីយ៉ាងយូរក្រោយរបបនេះដួលរលំ។ ចំពោះស្ត្រីដែលមិនបានរៀបការ ឬស្ត្រីដែលត្រូវបានគេបោះបង់ចោលក្រោយរបបនេះ ពួកគាត់ជារឿយៗបានបន្តរស់នៅក្នុងសម្ពាធនៃវប្បធម៌រំលោភផ្លូវភេទ និងការស្តីបន្ទោស។ ត្រលប់ទៅរឿងរបស់ ចប់ ដែលត្រូវបានទទួលរងការរំលោភជាក្រុមរាល់ថ្ងៃ និងវាយដោយកម្មាភិបាល និងការរំលោភពេលយប់ដោយពួកមេដឹកនាំខ្មែរក្រហមវិញ នាងបានរៀបរាប់ថានាងមានជម្រើសតិចតួចក្នុងការរៀបការម្តងទៀតដើម្បីការពារខ្លួនឯង។ នៅពេលត្រលប់មកភូមិវិញក្រោយរបបនេះដួលរលំ នាងត្រូវទទួលរងការបៀតបៀនផ្លូវភេទម្តងហើយម្តងទៀត និង ត្រូវបំពានក្នុងនាមជាស្ត្រីមិនបានរៀបការនិងការដាស់តឿនឲ្យនាងរៀបការម្តងទៀតថា៖

> ជីវិតកាលពីពេលនោះពិតជាពិបាកណាស់។ បុរសដែលមានប្រពន្ធរួចហើយបានមកផ្ទះខ្ញុំនៅពេលយប់ និងរុកគួនខ្ញុំ ចំអន់ខ្ញុំ ព្យាយាមបញ្ចុះបញ្ចូលខ្ញុំឲ្យដេកជាមួយពួកគេ។ ជួនកាល នៅពេលខ្ញុំទៅផ្សារ ឬចូលរួមពិធីបុណ្យក្នុងភូមិ ពួកគេមករាំងផ្លូវខ្ញុំ និងព្យាយាមអោប ប៉ះខ្ញុំ ហើយខ្ញុំបានព្យាយាមគេច។ ខ្ញុំបានប្រាប់ម្តាយរបស់ខ្ញុំ និងសាច់ញាតិ ហើយពួកគាត់បានណែនាំឲ្យខ្ញុំរៀបការជាមួយបងប្អូនជីដូនមួយរបស់ខ្ញុំ។ ខ្ញុំយំ ថាបើនៅសម័យខ្មែរក្រហមទៅ...ខ្ញុំយំព្រោះខ្ញុំអាណិតខ្លួនឯង... ជីវិតរបស់ខ្ញុំពិតជាវេទនាណាស់។ ខ្ញុំបានប្រាប់ទៅប្រពន្ធរបស់បុរសទាំងនោះថា ខ្ញុំមិនបានស្រលាញ់ប្តីរបស់ពួកគេទេ ហើយខ្ញុំបានសុំឲ្យពួកគេមើលប្តីកុំឲ្យមករំខានខ្ញុំ។ បងស្រីរបស់ខ្ញុំបានណែនាំឲ្យខ្ញុំរៀបការ បើមាននរណាសុំខ្ញុំរៀបការ ព្រោះជីវិតខ្ញុំឆ្លងកាត់ទុក្ខវេទនាច្រើនណាស់។ ខ្ញុំបានសម្រេចចិត្តរៀបការម្តងទៀតដើម្បីមានអ្នកការពារ និងចៀសផុតពីបុរសទាំងនោះដែលព្យាយាមយាយីខ្ញុំ។ បើកុំតែដូច្នោះខ្ញុំមិនរៀបការម្តងទៀតទេ ព្រោះខ្ញុំមិនចង់ឲ្យមនុស្សម្នានិយាយថាខ្ញុំមានប្តីច្រើននោះទេ។ ប៉ុន្តែបងប្អូនរបស់ខ្ញុំមិនអាចការពារខ្ញុំបានទេនៅពេលយប់ ពេលដែលប្រុសៗព្យាយាមបំពានមកលើខ្ញុំ។[118]

ហអ មិនបានរៀបការម្តងទៀតទេ ក្រោយពីប្តីរៀបការដោយបង្ខំបានបោះបង់នាងចោល ហើយនាងអាចមានលទ្ធភាពជ្រើសរើសរស់នៅដោយឯករាជ្យ និងពឹងផ្អែកលើខ្លួនឯងនិងកូន។ នាងបាននិយាយថា គ្មានគោលការណ៍ថ្នាក់ជាតិណាផ្តល់ការគាំទ្រដល់នាងផ្នែកសង្គមនិងសេដ្ឋកិច្ច បន្ទាប់ពីនាងបាត់បង់ជីវិតអាពាហ៍ពិពាហ៍ដោយបង្ខំទេ។

---

[118] បទសម្ភាសន៍សម្រាប់ករណីសិក្សាទី ២ ស្ត្រី (ថ្ងៃទី ២៥ ខែមេសា ឆ្នាំ២០១៤)

> សម្រាប់ខ្ញុំ មានប្តីគឺគ្មានប្រយោជន៍អ្វីទេ។ ខ្ញុំមិនចង់មានប្តីពីរ...ប្តីទីមួយរបស់ខ្ញុំគឺជាកំហុសមួយហើយដូច្នេះខ្ញុំមិនចង់ខុសជាលើកទីពីរទេហើយខ្ញុំខ្លាចគេមិនល្អចំពោះកូនៗខ្ញុំ។ ខ្ញុំបានរកប្រាក់ដោយខ្លួនឯង និងសម្រេចចិត្តចាយ និងឲ្យកូនៗរបស់ខ្ញុំតាមតែខ្ញុំចង់គ្មាននរណាគ្រប់គ្រងលើទង្វើនិងការសម្រេចចិត្តរបស់ខ្ញុំទេ។ខ្ញុំរកប្រាក់និងសម្រេចគ្រប់យ៉ាងដោយខ្លួនឯង ហើយផ្លូវនេះងាយស្រួលជាងសម្រាប់ខ្ញុំ។[119]

សរុបសេចក្តីទៅ អាពាហ៍ពិពាហ៍ដោយបង្ខំរបស់ខ្មែរក្រហម បានបន្តផ្តល់ផលប៉ះពាល់ជាច្រើន ទោះបីជារបបនេះដួលរលំហើយក៏ដោយ និងប៉ះពាល់ខ្លាំងបំផុតក្នុងសម័យអន្តរកាល (រយៈពេលអភិវឌ្ឍន៍) ក្នុងទសវត្សឆ្នាំ ២០០០ រហូតដល់សព្វថ្ងៃ។ មានស្វាមីភរិយាខ្លះរស់ នៅជាមួយគ្នាដោយគ្មានក្តីស្រលាញ់ រស់នៅជាមួយគ្នាគ្រាន់តែដើម្បីកូន ឬដោយសារកាតព្វកិច្ច។អាពាហ៍ពិពាហ៍ខ្លះទៀតត្រូវបានរំលាយដោយសារការស្លាប់ការលែងលះឬការបោះបង់ចោល។អាពាហ៍ពិពាហ៍ដែលនៅបន្តបាននោះ បើទោះបានតែមួយរយៈកាលក៏ដោយ សុទ្ធតែអាចមានករណីរំលោភបំពាន នេះបើយោងតាមបទសម្ភាសន៍ក្នុងការសិក្សារបស់យើង(និងដោយមានលទ្ធផលនៃការសិក្សាបែបស្ថិតិមកបញ្ជាក់)។ សម្រាប់ស្ត្រីនៅក្នុងគ្រួសារដែលមានស្ត្រីជាមេគ្រួសារ ផលប៉ះពាល់ចំពោះសេដ្ឋកិច្ចនិងសង្គមគឺខ្ពស់ ប៉ុន្តែអាចពុះពារបានដោយសារកំលាំង និងភាពធន់នឹងការប៉ះទង្គិចរបស់ស្ត្រីខ្លួនឯងផ្ទាល់។

### ឃ. ផលប៉ះពាល់នៃការរៀបការដោយបង្ខំ

ទាំងបុរសនិងស្ត្រី គឺជាជនរងគ្រោះដោយសារការៀបការដោយបង្ខំនិងទំនាក់ទំនងផ្លូវភេទដោយបង្ខំនៅក្នុងរបបខ្មែរក្រហម។ ជាពិសេស អ្នកផ្តល់សម្ភាសន៍ជាស្ត្រី បានលើកឡើងអំពីការដែលគោលនយោបាយនេះនាំឲ្យមានភាពអាម៉ាស់និងការផាត់ចេញ ក្រោយការដួលរលំនៃរបបនេះ ដោយសារបញ្ហាកម្មផលសម្រាប់ប្រជាជនដែលគោរពព្រះពុទ្ធសាសនា។ ផ្ទុយទៅវិញ បុរសមិនត្រូវបានគេកំណត់ថាអ្វីក្នុងសង្គមដោយសារតែការរៀបការដោយបង្ខំនេះទេ ហើយបុរសហាក់ដូចជារួចផុតពីការផាត់ចេញពីសង្គម ដែលបង្កឡើងដោយសារស្លាកស្នាមទុរយសនិងការរើសអើងក្នុងសង្គម ដែលអ្នកផ្តល់សម្ភាសន៍ជាស្ត្រីបានលើកឡើង។

ការខកចិត្ត គឺជាអារម្មណ៍ឆ្លើយតបដែលលេចចេញមកច្រើនជាងគេក្នុងចំណោមអ្នកផ្តល់សម្ភាសន៍ក្នុងករណីសិក្សាទៅលើការរៀបការដោយបង្ខំ ចំពោះការបាត់បង់ឱកាសត្រួត

---

[119] បទសម្ភាសន៍សម្រាប់ករណីសិក្សាទី ៤ ស្ត្រី (ថ្ងៃទី ២ ខែឧសភា ឆ្នាំ២០១៤)

ត្រាលើការសម្រេចចិត្តសំខាន់ៗក្នុងជីវិតរបស់ខ្លួនដូចជាការរៀបការនេះហើយដែលការសម្រេចចិត្តក្នុងជីវិតនេះ មិនបានទទួលសុពលភាពនិងភាពស្របច្បាប់ពីក្រុមគ្រួសារនិងបុព្វបុរសរបស់ខ្លួន។ ពិធីរៀបការត្រូវបានគេចាត់ទុកថាជា "ភាពគ្មានន័យខ្លឹមសារ" សោះ ដោយសារតែមិនមានពិធីបែបប្រពៃណីវប្បធម៌និងសាសនា។ក្នុងករណីជាច្រើនភាពគ្មានន័យនេះពង្រីកទៅដល់ជីវិតអាពាហ៍ពិពាហ៍ទាំងមូល។ ហូ ដែលត្រូវបានប្តីរបស់គាត់បោះបង់ចោលនោះបាននិយាយថា៖

> ក្នុងរបបខ្មែរក្រហម ការរៀបការ គ្មានន័យអ្វីទេ ព្រោះយើងគ្មានផ្កាស្លា គ្មានអាចារ្យ គ្មានចាស់ទុំទទួលស្គាល់អាពាហ៍ពិពាហ៍របស់យើងទេ។ យើងរៀបការដោយគ្រាន់តែនិយាយពាក្យមួយម៉ាត់ឬពីរម៉ាត់ គឺគ្មានន័យអ្វីទាំងអស់ ... គឺវាទទេ។ ៥០ ទៅ ៦០គូរៀបការពេលជាមួយគ្នាក្នុងពិធីតែមួយ ហើយគ្រាន់តែនិយាយពាក្យពីរបីម៉ាត់នោះ តើវាមានន័យយ៉ាងម៉េចទៅ[120]?

ការរៀបការដោយបង្ខំ ត្រូវបានរៀបរាប់ជាទូទៅថា "ការរៀបការមិនល្អ" គឺគ្រាន់តែមើលទៅហាក់ដូចជាស្របច្បាប់ ដោយសារតែមិនមានការចូលរួមពីឪពុកម្តាយ និងមិនមានការផ្តល់សុពលភាពដោយពិធីតាមវប្បធម៌។ ដូច្នេះ ការយល់ព្រមរៀបការបែបនេះ បង្ហាញអំពីទ្វេគ្រោះមួយ ក្នុងការមិនស្តាប់បង្គាប់។ ហូ ពន្យល់ថា "អង្គការបង្ខំខ្ញុំ ... ហើយប្រសិនបើឪពុកម្តាយរបស់ខ្ញុំដឹងពួកគាត់នឹងបន្ទោសខ្ញុំដោយសារតែពួកគាត់មិនដឹងអំពីការរៀបការនេះ"[121]។ ការខកចិត្តក្នុងខ្លួនដោយសារតែការរៀបការ និងការបន្ទោសអំពីការមិនស្តាប់បង្គាប់ គឺជាបរាជ័យបុគ្គល។ ហូ បន្តរៀបរាប់ថា៖

> ខ្ញុំមានអារម្មណ៍ថា ការប្តេជ្ញានេះ មិនមាននរណាទទួលស្គាល់ទេ ... ខ្ញុំមានអារម្មណ៍ខកចិត្តនឹងខ្លួនឯងណាស់ ខកចិត្តដោយសារខ្ញុំមិនទទួលបានការរៀបការជាធម្មតាមួយ ខកចិត្តដោយសារឪពុកម្តាយខ្ញុំមិនបានដឹងថាខ្ញុំរៀបការទេ បងប្អូនបង្កើតរបស់ខ្ញុំមិនបានដឹងទេ។ ខ្ញុំរៀបការតែដោយខ្លួនឯង ក្នុងចំណោមមនុស្សប្លែកមុខដែលខ្ញុំមិនស្គាល់ ដូចនេះ ខ្ញុំមានអារម្មណ៍ខកចិត្តណាស់ ... ប៉ុន្តែ ខ្ញុំយល់ព្រមរៀបការដើម្បីឲ្យបានរស់។

---

120 ដដែល

121 ការសម្ភាសន៍ជាមួយករណីសិក្សាទី៤ (២ ឧសភា ២០១៤)

អ្នកផ្តល់សម្ភាសន៍សម្រាប់ករណីសិក្សាជាច្រើន ទាំងបុរសនិងស្ត្រី មិនបាននិយាយចែករំលែកបទពិសោធន៍នៃការរៀបការដោយបង្ខំនេះជាមួយអ្នកផ្សេងឡើយ សូម្បីតែជាមួយកូនរបស់ពួកគេ។ សបច ដែលមានប្រពន្ធចាត់តាំងដោយរបបនោះ បានបែកពីគាត់ ក្រោយពេលរបបខ្មែរក្រហមដួលរលំភ្លាម ទោះបីជាកំពុងមានផ្ទៃពោះក៏ដោយនោះ បានលាក់បទពិសោធន៍នេះទុកក្នុងចិត្តអស់រយៈកាលជិត៤០ឆ្នាំ។ សម្តីរបស់គាត់ស្រដៀងនឹងការឆ្លើយតបរបស់អ្នកផ្តល់សម្ភាសន៍ផ្សេងទៀតដែរថា៖ "ខ្ញុំមិនបានប្រាប់រឿងនេះដល់កូនណាមួយរបស់ខ្ញុំអំពីការរៀបការដោយបង្ខំនោះទេ ពីព្រោះខ្ញុំមិនចង់ឲ្យពួកគេមានអារម្មណ៍ថាខុសនោះទេ"[122]។ គំនាបសង្កត់ដែលកើតឡើងដោយសារការលាក់ "រឿងសម្ងាត់គ្រួសារ" នេះ អាចមានផលប៉ះពាល់ដល់ទំនាក់ទំនងរវាងឪពុកម្តាយនិងកូន ហើយវាក៏អាចជាការផាត់ជនរងគ្រោះចេញពីប្រភពនៃការគាំទ្រផ្លូវអារម្មណ៍និងផ្លូវចិត្តដ៏សំខាន់។

យោងតាមការសម្ភាសន៍ជាមួយករណីសិក្សាជាច្រើន ការប៉ះទង្គិចផ្លូវចិត្តដោយសារការរៀបការដោយបង្ខំនេះ មានផលប៉ះពាល់ដោយផ្ទាល់ទៅលើអត្តសញ្ញាណយេនឌ័រនិងតម្លៃយេនឌ័រ។ វាហាក់ដូចជា ស្ត្រីបានបន្តជាប់មកជាមួយ នូវភាពអាម៉ាស់និងស្លាកស្នាមទុរយសពាក់ព័ន្ធនឹងការរៀបការដោយបង្ខំ ដែលត្រូវគេបកស្រាយទៅជាការមិនឲ្យតម្លៃជាទូទៅមួយទៅលើឋានៈសង្គមរបស់ស្ត្រី។ ភស បានពន្យល់អំពីការប៉ះទង្គិចផ្លូវចិត្តមិនដាច់ ដែលជាលទ្ធផលដែលនាងបានទទួលរងថា៖

> ខ្មែរក្រហមមិនឲ្យតម្លៃស្ត្រីទេ ស្ត្រីជាបងប្អូនស្រី ជាម្តាយរបស់ពួកគេដែរ ប៉ុន្តែពួកគេមិនចាត់ស្ត្រីថាមានតម្លៃនៅក្នុងសង្គមទេ។ មនុស្សដែលរៀបការនៅពេលនោះ ត្រូវបានគេប្រព្រឹត្តមកលើដូចសត្វអញ្ចឹង។ យើងមិនអាចការពារខ្លួន (កេរ្តិ៍ភេទ) របស់យើង ដូចដែលឪពុកម្តាយរបស់យើងការពារខ្លួនរបស់យើងទេ។ ពួកវារំលោភខ្ញុំ ហើយពួកវានៅឈរមើល។ ... យើងត្រូវគេបង្ខំឲ្យស្និទ្ធស្នាលដូចឆ្កែដូចឆ្មា។ ពេលដែលខ្ញុំរំលឹករឿងនេះ មាត់ខ្ញុំស្ងួតអស់ហើយ បេះដូងលោតញាប់។ ត្រូវហើយ ការរៀបការនោះ នៅតែមានផលប៉ះពាល់មកលើខ្ញុំ ដូចខ្ញុំស្លៀកខោរហែកអញ្ចឹង (ខ្មាសគេ)។ ខ្ញុំកម្រទៅផ្ទះអ្នកដទៃណាស់។ ភាគច្រើន ខ្ញុំនៅផ្ទះតែឯង[123]។

សន្តិសុខពីរនាក់ដែលជួយក្នុងការរំលោភនោះនៅមានជីវិតនៅឡើយទេ។ភសបានឃើញពួកគេម្តងនៅវត្តមួយ ហើយចាប់ពីពេលនោះមក ភស ជៀសវាងមិនទៅធ្វើបុណ្យនិង

[122] ការសម្ភាសន៍ជាមួយករណីសិក្សាទី១ (២៩ មេសា ២០១៤)
[123] ការសម្ភាសន៍ជាមួយករណីសិក្សាទី៥, ស្ត្រី (២៥ មេសា ២០១៤)

បន់ស្រន់នៅវត្តនោះទៀតទេ។ ភស ក៏បានជួបប្ដីដែលបានរៀបការដោយបង្ខំ ហើយដែលបានរំលោភគាត់ពេលរៀបការ នោះម្ដងដែរ ពេលដែលបុរសនោះដើរតាមផ្លូវជាមួយប្រពន្ធថ្មីរបស់គាត់។

ភាពអាម៉ាស់និងការស្ដីបន្ទោសដែលត្រូវបានសហគមន៍ទម្លាក់ទៅលើស្ត្រីនោះ ត្រូវបានលើកឡើងដោយអ្នកផ្ដល់សម្ភាសន៍ជាស្ត្រីភាគច្រើន នៅក្នុងសំណាក។ ភស រៀបរាប់អំពីរបៀបដែលភាពអាម៉ាស់ទាំងនោះ (នៅពេលដែលចូលមកក្នុងខ្លួនហើយ) ធ្វើឲ្យខ្លួនឯងមានភាពឯកោ។

ខ្ញុំមានអារម្មណ៍អាម៉ាស់ អាម៉ាស់ខ្លាំងណាស់ ហើយខ្ញុំមិនចង់ឲ្យនរណាម្នាក់ដឹងអំពីអតីតកាលរបស់ខ្ញុំទេ។ ពេលខ្ញុំលក់ព្រលិតនៅផ្សារ ហើយខ្ញុំឃើញមនុស្សក្នុងពេលនោះ ខ្ញុំគេចចេញពីពួកគេហើយ។ ខ្ញុំមិនចង់ជួបពួកគេទេ ហើយខ្ញុំមានអារម្មណ៍អាម៉ាស់ជាទីបំផុត។ ជួនកាល មានគេសួរសំណួរទោះជាខ្ញុំមិនចង់ឮក៏ដោយថា "អូ ប្ដីរបស់អ្នកនៅឯណា? ប្ដីដែលរៀបការក្នុងជំនាន់ខ្មែរក្រហមនោះ តើនៅរស់នៅជាមួយគ្នាឬអត់?" ដូច្នេះ ឥឡូវខ្ញុំទៅលក់នៅផ្សារផ្សេងមួយ ដែលមិនមានអ្នកណាស្គាល់ខ្ញុំ។ អាម៉ាស់ណាស់។ អាម៉ាស់ហួសពីការនិយាយ[124]។

ការបន្ទោសខ្លួនឯង ភាពឯកោ ការបាត់បង់ព្រលឹងដូចតាសំរាប់សក្ការៈសេចក្ដីស្រលាញ់ និងទំនៀមទំលាប់នៃសេចក្ដីស្រលាញ់ ការបាត់បង់ការគាំទ្រខាងផ្លូវអារម្មណ៍ និងឱកាសផ្នែកសេដ្ឋកិច្ច គឺជាចំណែកនៃការខាតបង់របស់ស្ត្រីដោយសារតែស្លាកស្នាមទុរយសដែលភ្ជាប់ទៅនឹងការរៀបការដោយបង្ខំក្នុងរបបខ្មែរក្រហម។

ផលប៉ះពាល់នៃការរៀបការដោយបង្ខំ លាតសន្ធឹងដល់កូន។ សហព័ន្ធដែលនៅតែស្ថិតក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំនិងមានការរំលោភបំពាន បានលើកឡើងអំពីការប៉ះទង្គិច ឆ្លងជំនាន់នៃការរៀបការនិងការបំពានមិនដាច់។ ហក បាននិយាយថា "ខ្ញុំខ្លាចកូនស្រីខ្ញុំរៀបការជាមួយបុរសអាក្រក់ (ដូចដែលខ្ញុំបានឆ្លងកាត់) ហើយខ្ញុំខ្លាចកូនប្រុសរបស់ខ្ញុំទៅវាយកូនប្រសារស្រីរបស់ខ្ញុំ(ដូចឪពុករបស់ពួកគេបានវាយដំមកលើខ្ញុំ)"[125]។កូនៗទាំងឡាយក៏ប្រឈមមុខនឹងស្លាកស្នាមទុរយសនិងការរើសអើងក្នុងសហគមន៍ដែរ។ ភស បាននិយាយអំពីកូនរបស់គាត់ថា "មនុស្សមួយចំនួនក្នុងភូមិមិនចង់ឲ្យកូនរបស់គេរៀបការជាមួយកូនរបស់ខ្ញុំទេ។ ខ្ញុំបានឮគេនិយាយដោយផ្ទាល់ត្រចៀករបស់ខ្ញុំ"[126]។ ហអ រំលឹកថា៖

---

[124] ដដែល

[125] ការសម្ភាសន៍ជាមួយករណីសិក្សាទី៦, ស្ត្រី (២៨ មេសា ២០១៩)

[126] ការសម្ភាសន៍ជាមួយករណីសិក្សាទី៥, ស្ត្រី (២៥ មេសា ២០១៩)

សព្វថ្ងៃនេះ អ្នកឃើញទេ? ខ្ញុំមិនមានអ្វីៗដូចអ្នកដទៃទេ។ ខ្ញុំមិនបានរៀបការដូចស្ត្រីដទៃទេ ហើយសម្រាប់កូនរបស់ខ្ញុំវិញ គេតែងនិយាយថា "អូ ម្ដាយរបស់ឯងជាស្រីមេម៉ាយ និងមិនបានរៀបការតាមប្រពៃណីទេ"។ ត្រូវហើយ សង្គមនេះរើសអើងមកលើខ្ញុំ ពីព្រោះខ្ញុំជាស្ត្រីមេម៉ាយ។ ទោះបីជាឥឡូវនេះ ខ្ញុំជាមនុស្សចាស់ហើយក៏ដោយ ក៏គេមិនអនុញ្ញាតឲ្យខ្ញុំចូលរួមក្នុងពិធីរៀបការមួយចំនួន ដូចជាពិធីហូបស្លានោះទេ។ សហគមន៍មិនអនុញ្ញាតឲ្យខ្ញុំចូលរួមទេ ហើយគេហៅខ្ញុំថាជា "ដើមឈើបាក់មែក"។ ហើយគេក៏ហៅកូនខ្ញុំយ៉ាងដូច្នោះដែរ។កូនប្រុសនិងកូនស្រីរបស់ខ្ញុំក៏មិនដែលត្រូវបានគេអញ្ជើញឲ្យទៅធ្វើជាអ្នកកំដរដែរ ដោយសារតែពួកគេគ្មានឪពុក។ សូម្បីតែនៅក្នុងពិធីរៀបការកូនស្រីផ្ទាល់របស់ខ្ញុំ ក៏ខ្ញុំមិនអាចចូលរួមក្នុងពិធីនោះដែរ។ ឪពុកម្ដាយរបស់ខ្ញុំ បំពេញកិច្ចជាឪពុកម្ដាយរបស់កូនស្រីខ្ញុំ ហើយគេមិនឲ្យខ្ញុំទទួលផ្កាស្លាទេ។ខ្ញុំមិនចង់រំលឹករឿងនេះទេ។ខ្ញុំតូចចិត្តនឹងខ្លួនឯងខ្លាំងណាស់។គិតពីរឿងនេះ វាហាក់ដូចជានៅថ្មីៗណាស់។ ទាំងអស់នេះគឺដោយសារតែខ្ញុំបានធ្វើខុសរឿងរៀបការនេះ គឺយើងមិនអាចជ្រើសរើសបានទេ យើងមិនបានស្គាល់គ្នាមុនទេ យើងមិនបានសួរឪពុកម្ដាយទេ ឬមិនបានស្គាល់ឪពុកម្ដាយរបស់ប្ដីយើងទេ យើងមិនបានដឹងអ្វីទាំងអស់ យើងមិនអាចជ្រើសរើសបានទេ។ រឿងនេះ វាប៉ះពាល់ដល់ទាំងកូននិងម្ដាយពេញមួយជីវិតរបស់យើង។ ប្រសិនបើប៉ុលពត មិនបង្ខំខ្ញុំឲ្យរៀបការទេនោះ ខ្ញុំអាចរៀបការតាមប្រពៃណី ហើយឥឡូវនេះ ខ្ញុំនិងកូនរបស់ខ្ញុំក៏មានកិត្តិយសល្អដែរ[127]។

ហអ មិនមែនជាមនុស្សតែម្នាក់ដែលប្រឈមនឹងស្លាកស្នាមទុរយសនោះទេ ហើយក៏មិនមែនជាមនុស្សតែម្នាក់កំពុងយកឈ្នះលើបញ្ហាប្រឈមទាំងនោះផងដែរ (ដែលអ្នកផ្ដល់សម្ភាសន៍ជាស្ត្រីភាគច្រើនបំផុត ហើយដែលអាពាហ៍ពិពាហ៍របស់ខ្លួនបានរលាយក្រោយរបបក្រហមនេះកំពុងជួបប្រទះ)។ រឿងរ៉ាវរបស់ ហអ ក៏រំលេចឡើងនូវការផ្លាស់ប្ដូរយ៉ាងខ្លាំងអំពីតួនាទីយេនឌ័រ ដោយសារតែការកើតមានឡើងយ៉ាងច្រើននូវគ្រួសារដែលមានមេគ្រួសារជាស្ត្រីរំលាយអាពាហ៍ពិពាហ៍ដោយបង្ខំទាំងនោះ។ ហអ ពន្យល់ថា៖

ខ្ញុំព្យាយាមខ្លាំងណាស់ដើម្បីចិញ្ចឹមកូនរបស់ខ្ញុំ និងឲ្យកូនទៅសាលារៀន។ កូនខ្ញុំទាំងអស់បានរៀនចប់វិទ្យាល័យ ហើយកូនប្រុសរបស់ខ្ញុំ ឥឡូវនេះកំពុងបន្តការសិក្សានៅភ្នំពេញ។ ខ្ញុំខំប្រឹងណាស់ ប្រឹងខ្លាំងណាស់។ ខ្ញុំមានកង់កញ្ចាស់មួយ ហើយខ្ញុំធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយដើម្បីរកថ្នាំឫសឈើយកទៅលក់នៅផ្សារក្នុងក្រុងភ្នំពេញ។ តាមការធ្វើបែបនេះ ខ្ញុំអាចរកលុយល្មមឲ្យកូនខ្ញុំទៅរៀនបាន។ត្រូវហើយ ខ្ញុំមើលទៅកូនរបស់ខ្ញុំ ហើយមើលឃើញកូនអ្នកដទៃដែលមានឪពុកជាអ្នកចិញ្ចឹម ហើយគិតអញ្ចឹងទៅវាស្រួលជាង។ ប៉ុន្តែ

127 ការសម្ភាសន៍ជាមួយករណីសិក្សាទី៤, ស្ត្រី (២ ឧសភា ២០១៤)

ស្ត្រី មេម៉ាយមួយចំនួន មិនអាចជួយឧបត្ថម្ភកូនរបស់ពួកគេបានទេ ដូច្នេះ ខ្ញុំក៏មានមោទនភាពចំពោះខ្លួនឯងដែរ។ ឥឡូវនេះ សូម្បីតែអ្នកក្នុងភូមិក៏សរសើរខ្ញុំដែរ។ "អូ អ្នកជាស្ត្រីមេម៉ាយម្នាក់ ប៉ុន្តែកូនរបស់អ្នកសុទ្ធជាកូនល្អ ស្តាប់ដំបូន្មានម្តាយនិងមានការងារល្អៗ"។ ដូច្នេះ ខ្ញុំឃើញថាការប្រឹងប្រែងរបស់ខ្ញុំមិនអត់ប្រយោជន៍ទេ[128]។

ទោះបីជាប្តីប្រពន្ធរៀបការដោយបង្ខំរស់នៅជាមួយគ្នាឬរំលាយអាពាហ៍ពិពាហ៍ចោលក៏ដោយ ក៏ការរៀបការដោយបង្ខំមានផលវិបាកច្រើនទៅលើអត្តសញ្ញាណនិងការឲ្យតម្លៃខ្លួនឯង ឋានៈសង្គម និងស្ថិរភាពហិរញ្ញវត្ថុរបស់ពួកគេដែរ។ អ្នកផ្តល់ការសម្ភាសន៍ជាស្ត្រីបានរៀបរាប់ជាញឹកញាប់អំពីការប៉ះទង្គិចផ្លូវចិត្ត ភាពអាម៉ាស់ និងស្លាកស្នាមទុរយស ដែលលាតសន្ធឹងទៅដល់មនុស្សជំនាន់ក្រោយ។ ដោយសារតែឋានៈរបស់ស្ត្រីកើតឡើងទៅតាមជីវិតអាពាហ៍ពិពាហ៍និងជីវិតគ្រួសារដ៏សុខដុមរមនាតាមលក្ខណៈប្រពៃណីនោះ ស្ត្រីទាំងឡាយនៅក្នុងសំណាកនេះ បានរៀបរាប់អំពីការស្តាយជាប់តាមខ្លួននូវភាពសោកសៅនៃផលវិបាកសង្គមដ៏ធ្ងន់ធ្ងរពីគោលនយោបាយរបស់របបខ្មែរក្រហម។ ជាផលវិបាកនៃការរំលោយចំណងអាពាហ៍ពិពាហ៍ដោយបង្ខំនោះ តួនាទីយេនឌ័រក៏ត្រូវបានតម្រឹមឡើងវិញយ៉ាងខ្លាំងដែរ ដោយស្ត្រីត្រូវទទួលយកតួនាទីពីរក្នុងនាមជាអ្នកទំនុកបម្រុងនិងជាអ្នកថែទាំ។ ប៉ុន្តែ ទោះបីជាជនរងគ្រោះដោយសារការរៀបការដោយបង្ខំត្រូវបានគេផាត់ចេញពីសង្គមនិងរើសអើងក្នុងពិធីសាសនា កន្លែងទីផ្សារសេដ្ឋកិច្ច និងបណ្តាញក្នុងសហគមន៍យ៉ាងណាក្តី ក៏ស្ត្រីមួយចំនួននៅតែអាចងើបឡើងជាអ្នកធ្វើការសម្រេចចិត្តដោយខ្លួនឯង ដែលជាការបើកចំហរនូវលំហថ្មីសម្រាប់ភាពរីកចម្រើននិងជោគជ័យរបស់ស្ត្រីនៅក្នុងជីវិតពេលនេះនិងក្នុងពេលអនាគត តាមរយៈល័ក្ខខណ្ឌដែលកាន់តែមានការបើកទូលាយនិងកាន់តែមានការផ្តល់សិទ្ធិអំណាច។

128 ដដែល

៥

# ការពិភាក្សា
# និងការផ្តល់អនុសាសន៍

ការវិភាគខាងក្រោម ពិចារណាទៅលើលទ្ធផលបែបគុណវិស័យនិងបរិមាណវិស័យ ដែលបានបង្ហាញនៅក្នុងផ្នែកទី៤ ពាក់ព័ន្ធគ្នាទៅវិញទៅមក និងនៅក្នុងបរិបទនៃការស្រាវជ្រាវ ដែលមានរៀបរាប់ក្នុងផ្នែកទី២។

## ៥.១. លទ្ធផលសំខាន់ៗ

លទ្ធផលសំខាន់បំផុតដែលកើតចេញពីការសិក្សានេះ គឺថា ក្នុងនាមជាគោលនយោបាយក្នុងប្រព័ន្ធមួយដែលមានការរីកសាយភាពរបស់របបខ្មែរក្រហម ការរៀបការដោយបង្ខំ និងការរួមភេទដោយបង្ខំ បានដកហូតសិទ្ធិជាមូលដ្ឋានរបស់មនុស្សក្នុងការជ្រើសរើសនិងក្នុងការយល់ព្រម។ ក្នុងការធ្វើបែបនេះ វាបានបន្តឲ្យកើតមាននូវវប្បធម៌រំលោភនិងការបំពានជាពិសេសទៅលើស្ត្រី ដោយសារអំពីហិង្សាយេនឌ័រផ្លូវភេទជាពិសេសតាមរយៈការរៀបការនិងការដាក់ទណ្ឌកម្ម ដែលបានក្លាយទៅជារឿងធម្មតា ដោយសារតែគោលនយោបាយរដ្ឋនិងនិរទណ្ឌភាព។ ផលប៉ះពាល់នៃអំពើហិង្សាទាំងនេះ នៅតែបន្តកើតមានទៅលើជនរងគ្រោះរហូតដល់សព្វថ្ងៃនេះ។

លទ្ធផលសំខាន់ៗដទៃទៀតដែលចេញមកពីការស្រាវជ្រាវនេះមានដូចខាងក្រោម។

*ការរៀបការមុនរបបខ្មែរក្រហម*

- ការរៀបការជាប្រពៃណីក្នុងប្រទេសកម្ពុជា ភាគច្រើនត្រូវបានរៀបចំដោយមានការយល់ព្រមពីឪពុកម្តាយសម្រាប់កូនរបស់ពួកគេ។ សម្រាប់បុរស ដែលជាអ្នកចូលដណ្តឹង ត្រូវបានផ្តល់ឲ្យនូវជម្រើស។ ជាទម្លាប់ គេសុំការយល់ព្រមពីបុរសនិងស្ត្រីសម្រាប់ការផ្គូផ្គងមុនពេលរៀបអាពាហ៍ពិពាហ៍។ ទោះបីជាអ្នកឆ្លើយតបពាក់កណ្តាលបានរៀបការមុនរបបខ្មែរក្រហមរៀបរាប់ថាការរៀបការដែលរៀបចំឡើងតាមប្រពៃណីមិនមែនជាជម្រើសរបស់ពួកគេក៏ដោយ ក៏មិនមានអ្នកឆ្លើយណារៀបរាប់ថាការរៀបការនោះធ្វើឡើងដោយបង្ខំឡើយ សូម្បីតែគំនាបគ្រួសារមានឥទ្ធិពលខ្លាំងក៏ដោយ។

- ការរៀបការតាមប្រពៃណីខ្មែរ គឺជាមធ្យោបាយមួយសម្រាប់ផ្តល់សុពលភាពនិងភាពស្របច្បាប់ដល់សហព័ន្ធក្នុងភ្នែករបស់សហគមន៍ គ្រួសារ និង ក្នុងបុព្វបុរសសម្រាប់ពុទ្ធសាសនិកភាគច្រើន។ ជាប្រពៃណី ពិធីនិងជីវិតអាពាហ៍ពិពាហ៍ គឺជាមធ្យោបាយមួយដើម្បីបង្ហាញអំពីការគោរព និងការស្តាប់ដំបូន្មានរបស់កូនចំពោះ

ឪពុកម្តាយ ហើយទាំងជីវិតនិងពិធីអាពាហ៍ពិពាហ៍ មានអត្ថន័យបែបព្រលឹងនិយមទៀតផង។ សម្រាប់ពុទ្ធសាសនិក នេះរួមមានទាំងផលកម្មពាក់ព័ន្ធនឹងជីវិតក្នុងពេលអតីតកាលនិងអនាគត។

*ការរៀបការដោយបង្ខំក្នុងរបបខ្មែរក្រហម*

- ការអនុវត្តរបស់រដ្ឋនៅគ្រប់កន្លែងនិងជាលក្ខណៈប្រព័ន្ធ អំពីការរៀបការដោយបង្ខំ និងការរួមភេទដោយបង្ខំដូចដែលអ្នកឆ្លើយសំនួរបានរៀបរាប់ រួមជាមួយនឹងផលប៉ះពាល់ធ្ងន់ធ្ងរទៅលើសុខមាលភាពរាងកាយ និងផ្លូវចិត្តរបស់ជនរងគ្រោះផងនោះ បង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

- យោងតាមការសម្ភាសសម្រាប់ករណីសិក្សា "ការរៀបការដោយបង្ខំ" ត្រូវអ្នកឆ្លើយតបយល់ថាយ៉ាងហោចណាស់មានបទល្មើសច្បាស់ចំនួនបី៖ ការបាត់បង់ជម្រើស និងការយល់ព្រម, ការបាត់បង់ពិធីរៀបការបែបប្រពៃណីជាមួយគ្រួសារនិងការចូលរួមពីព្រលឹងបុព្វបុរស ព្រមទាំង ការបង្ខំឲ្យរួមភេទក្នុងអំឡុងពេលនៃរបបនោះ។

- ពិធីរៀបការរបស់ខ្មែរក្រហម គឺជាការប្រាសចាកទាំងស្រុងមួយ ពីពិធីនិងជីវិតរៀបការដែលធ្លាប់បានរៀបចំតាមប្រពៃណីដោយមានការព្រមព្រៀងគ្នា។ អង្គការយកតួនាទីជាឪពុកម្តាយរបស់ប្រជាជន។អង្គការចាត់តាំងប្តី/ប្រពន្ធឲ្យហើយកម្មាភិបាលខ្មែរក្រហមបានបង្ខំដោយហិង្សាឲ្យចូលរួមក្នុងពិធីរៀបការនិងក្នុងការរួមភេទដែលជារឿយៗជាមួយអ្នកស្ទើរមិនដែលធ្លាប់បានស្គាល់គ្នាសោះ។គេមិនឲ្យមានការចូលរួមពីឪពុកម្តាយនិងពិធីជូនតាទៀយ ហើយនេះនាំឲ្យមានផលកម្ម។

- ការជំទាស់នឹងការរៀបការដោយបង្ខំនិងការរួមភេទដោយបង្ខំ ជារឿងធម្មតា។ អ្នកឆ្លើយភាគច្រើន (៧០,២%) បដិសេធសំណើរៀបការយ៉ាងហោចណាស់ម្តង ប៉ុន្តែចុងក្រោយ ស្ទើរតែទាំងអស់ (៩៧,២%) ត្រូវគេបង្ខំឲ្យរៀបការ ហើយស្ទើរតែទាំងអស់ (៩៧,០%) លើកឡើងថាការរៀបការនេះមិនមែនជាជម្រើសរបស់ខ្លួនឡើយ។

- ទណ្ឌកម្មសម្រាប់ការបដិសេធមិនរៀបការឬមិនព្រមរួមភេទដោយបង្ខំ រួមមានការគំរាមដោយពាក្យសម្តី ការដាក់ទណ្ឌកម្មលើរាងកាយ ដូចជាការវាយដំ ការរំលោភ ការឲ្យធ្វើទាសករផ្លូវភេទ និងការស្លាប់។

- ពិធីរៀបការដោយបង្ខំទាំងហ្វូង (រួមមានពីបីទៅរាប់រយគូ) ត្រូវបានរៀបចំឡើងមានលក្ខណៈជាប្រព័ន្ធ និងមាននៅគ្រប់កន្លែង ដូចមានរៀបរាប់ដោយអ្នកឆ្លើយក្នុងករណីសិក្សា។

- ការសម្ភាសជាករណីសិក្សាបង្ហាញថា បុរសជាច្រើនមានឱកាសស្នើសុំសហព័ន្ធក្នុងរបបនោះហើយមានអ្នកឆ្លើយតបពាក់កណ្តាលបានលើកឡើងដូច្នេះ។ពាក់កណ្តាលទៀតលើកឡើងថាការផ្គូផ្គងធ្វើឡើងដោយការចាត់តាំងតាមទំនើងចិត្ត។

- ស្ទើរពាក់កណ្តាល (៤៦,៥%) នៃការស្ទង់មតិបានរៀបរាប់ថាបានស្គាល់គ្នាឬបានស្គាល់អំពីគ្នានៅពេលរៀបចំពិធីការនេះ ហើយករណីសិក្សាបានលើកឡើងថា ការស្គាល់គ្នានេះគឺមិនស្គាល់ដោយផ្ទាល់ទេ គឺស្គាល់តាមរយៈអ្នកដទៃនៃបណ្តាញក្នុងសហគមន៍ឬតាមសាច់ញាតិ។ ប្រជាជន "ចាស់" មានគុណសម្បត្តិច្រើនជាងប្រជាជន "ថ្មី" ពាក់ព័ន្ធនឹងការមានបណ្តាញនេះ ដោយមានការរៀបរាប់ក្នុងករណីសិក្សាផងដែរថាការប្រព្រឹត្តលើប្រជាជនចាស់ មានភាពប្រសើរជាងទៅលើប្រជាជនថ្មីពាក់ព័ន្ធនឹងពិធីរៀបការនេះផ្ទាល់។

- ជម្រើសយុទ្ធសាស្ត្រដើម្បីរស់ ជារឿងធម្មតាក្នុងរបបខ្មែរក្រហម ដោយរួមមានទាំងការអនុលោមតាមការរៀបការដោយបង្ខំនិងការរួមភេទដោយបង្ខំដោយសារតែការភ័យខ្លាចទណ្ឌកម្មឬការស្លាប់។ ជម្រើសទាំងនោះមានផលវិបាកផ្នែកសម្ភារៈនិងចិត្តសាស្ត្រដែលមានលក្ខណៈប៉ះទង្គិចផ្លូវចិត្តជាពិសេសទៅលើស្ត្រី ដោយសារតែច្បាប់វប្បធម៌បានហាមប្រាម និងឋានៈយេនឌ័រទាបជាងបុរស។

- ការរៀបការដោយបង្ខំនិងការរួមភេទដោយបង្ខំគឺជាទម្រង់នៃអំពើហិង្សាយេនឌ័រផ្លូវភេទ។ ដូចនេះ ប្រព័ន្ធនៃការរៀបការក្នុងរបបខ្មែរក្រហមត្រូវបានពណ៌នាថា ធ្វើឲ្យមានវប្បធម៌រំលោភផ្លូវភេទពង្រឹងដោយរដ្ឋ គឺថា ការរំលោភត្រូវបានចាត់ទុកជាការធម្មតានិងត្រូវបានប្រព្រឹត្តល្មើសដោយមិនមានទោសពៃរ៍ ជាពិសេសការរំលោភក្នុងអាពាហ៍ពិពាហ៍និងរំលោភជាការដាក់ទណ្ឌកម្ម។ ប្រភេទនៃការរំលោភដែលត្រូវបានពណ៌នានេះរួមមាន ការរំលោភក្នុងអាពាហ៍ពិពាហ៍ ការរំលោភបូក ទាសភាពផ្លូវភេទ និងការរំលោភដែលមានការជ្រោមជ្រែងឬល្មើសដោយតួអង្គរដ្ឋ។

- ការរៀបការដោយបង្ខំក្នុងរបបខ្មែរក្រហមអាចជាករណីពិសេសផ្សេងពីគេ តាមរយៈការបង្ខំឲ្យប្តីរំលោភប្រពន្ធរបស់ខ្លួន ជាមធ្យោបាយធានាជីវិតរបស់ខ្លួន។ ករណី

សិក្សាមួយពណ៌នាអំពីកម្មាភិបាលខ្មែរក្រហមដែលបានជួយនិងជំរុញឲ្យប្ដីដែលគេបានរៀបចំឡើងនោះឲ្យរំលោភប្រពន្ធ។

- ប្រហែលមួយភាគបួន(២៤,៥%)នៃការរៀបការដោយបង្ខំទាំងអស់ត្រូវគេរៀបរាប់ថាមានការពាក់ព័ន្ធនឹងការបំពានពីសហព័ន្ធ។ ការរៀបការទាំងនេះកើតមានក្នុងអំឡុងពេលដែលមានការលំបាកជាទីបំផុតនៃវិនាសកម្មក្នុងរបបនោះដែលមានរយៈពេលក្រោយរបបនោះ ហើយខ្លះទៀតនៅបន្តកើតមានដល់សព្វថ្ងៃ។

- ការរៀបការដោយបង្ខំភាគច្រើន (៧៦,២%) ត្រូវបានគេរាយការណ៍ថា បានផ្ដល់កំណើតកូនទៀតផង ដោយក្នុងនោះ អ្នកឆ្លើយតបជិតពាក់កណ្ដាល (៤៤,៩%) មានកូនបួននាក់ឬច្រើនជាងបួននាក់។ប្ដីគឺជាអ្នកផ្ដល់ការគាំទ្រជីវិតយ៉ាងសំខាន់ក្នុងអំឡុងពេលប្រពន្ធមានគភ៌។

- ករណីសិក្សាបានលើកឡើងនូវការកើនឡើងខ្លាំងនៃការរៀបការដោយបង្ខំនេះក្នុងរយៈពេលប្រាំមួយខែចុងក្រោយ ក្នុងឆ្នាំ១៩៧៨។

- ករណីសិក្សាលើកឡើងថា ការបង្កើតមនុស្សគឺជាកត្តាជំរុញឲ្យមានការរៀបការដោយបង្ខំនេះ។ ប្រការគួរឲ្យកត់សម្គាល់នោះ គឺ អ្នកឆ្លើយតបក្នុងករណីសិក្សាមួយបានលើកឡើងអំពីមហិច្ឆតានយោបាយរបស់មេដឹកនាំខ្មែរតាមមូលដ្ឋាន ជាកត្តាជំរុញឲ្យមានការរៀបការដោយបង្ខំនិងការរួមភេទដោយបង្ខំ ដោយបានលើកឡើងថាមេដឹកនាំថ្នាក់លើបានដឹងអំពីការអនុវត្តគោលនយោបាយនេះ និងបានផ្ដល់ការលើកទឹកចិត្តសម្រាប់ការអនុវត្តគោលនយោបាយនេះទៀតផង។

*ការរៀបការក្រោយការដួលរលំនៃរបបខ្មែរក្រហម*

- បន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហម មិនមានគោលនយោបាយជាតិទូទៅណាមួយសម្រាប់ដោះស្រាយស្ថានភាពនិងផលវិបាកដោយសារការរៀបការដោយបង្ខំនេះទេ។ ក៏ប៉ុន្តែ ការរៀបការដែលខ្មែរក្រហមបានបង្ខំ មានផលប៉ះពាល់យ៉ាងខ្លាំងទៅលើការអនុវត្តផ្នែកអាពាហ៍ពិពាហ៍ ភ្លាមបន្ទាប់ពីការដួលរលំនៃរបបនេះ និងច្រើនទសវត្សក្រោយមកទៀត។

- ការស្រាវជ្រាវនេះបង្ហាញថា ការរៀបការដោយបង្ខំគឺជាកត្តាមួយក្នុងចំណោមកត្តា

រួមចំណែកជាច្រើនទៅដល់ការបំពានក្នុងគ្រួសារដែលមានកើតឡើងច្រើន (នៅក្នុងបរិបទនៃការបន្តកើតឡើងនៃសង្គ្រាមស៊ីវិល និងការកែនប្តី) និងទៅដល់អាត្រាខ្ពស់នៃការរត់ចោលគ្នា ពហុព័ន្ធភាព ការរៀបការឡើងវិញ និងមេគ្រួសារជាស្ត្រី ក្រោយការដួលរលំរបបនេះ។

- អ្នកឆ្លើយច្រើនជាងពាក់កណ្តាល (៥៣,១%) បន្តរស់នៅជាមួយគ្នាបន្ទាប់ពីការដួលរលំនៃរបបនេះ ភាគច្រើនគឺដោយសារតែមានកូនកើតក្នុងអាពាហ៍ពិពាហ៍នោះ។ កត្តាជំរុញផ្សេងទៀតក្នុងការរស់នៅជាមួយគ្នានេះ គឺដោយសារការអាណិតអាសូរ ផលកម្មពីជាតិមុន ភាពសំខាន់នៃបទពិសោធន៍ប៉ះទង្គិចផ្លូវចិត្តរួមគ្នាក្នុងរបបនោះ និងសំខាន់បំផុតនោះគឺការស្រលាញ់។ ការរៀបការដោយបង្ខំដែលមិនអាចបំបែកបានមួយចំនួនដែលបន្តរស់នៅជាមួយគ្នា គឺដោយសារតែការបំពាន ដោយសហព័ន្ធមួយមិនអាចគេច ទៅណាបាន។

- ការរៀបការដោយបង្ខំជាច្រើនដែលនៅមិនអាចព្រាត់គ្នាបានគឺដោយសារតែការខូចខាតមុខងារ ដោយក្នុងនោះច្រើនជាងពាក់កណ្តាល (៥២,៩%) ក្នុងសំណាកស្ទង់មតិនេះលើកឡើងអំពីការបំពានរបស់សហព័ន្ធ ដូចមានពិភាក្សាក្នុងការវិភាគករណីសិក្សា មានម្នាក់ទទួលរងការរំលោភពីប្តីជាបន្តរហូតមកដល់សព្វថ្ងៃនេះ។

- ភាគច្រើន (៧០,០%) នៃអ្នកដែលបានរំលាយការរៀបការដោយបង្ខំបន្ទាប់ពីរបបនោះ បានរៀបការឡើងវិញម្តងទៀត។ ក្នុងចំណោមអ្នកដែលមិនបានរៀបការឡើងវិញក្រោយរបបខ្មែរក្រហម មាន៧២,២% បានលើកឡើងថាពួកគេមិនចង់រៀបការម្តងទៀតទេដោយសារតែមានបទពិសោធន៍ក្នុងការរៀបការដោយបង្ខំនោះ។ ខណៈដែលអ្នកឆ្លើយមានទាំងបុរសនិងស្ត្រី លទ្ធផលនៃការស្រាវជ្រាវមានភាពគួរឲ្យចាប់អារម្មណ៍ខ្លាំង នៅពេលប្រៀបធៀបទៅនឹងការរៀបការរបស់ស្ត្រីស្ទើរតែទាំងអស់មុនរបបខ្មែរក្រហម ដូចមានរៀបរាប់ក្នុងការសិក្សាស្រាវជ្រាវមុនៗ

*ផលប៉ះពាល់នៃការរៀបការដោយបង្ខំក្នុងរបបខ្មែរក្រហម*

- ប្រព័ន្ធរៀបការដោយបង្ខំក្នុងរបបខ្មែរក្រហម បង្កឲ្យមានការផ្តាច់ចេញពីសង្គមនិងការរើសអើងក្នុងសង្គម ជាពិសេសសម្រាប់ស្ត្រីដែលត្រូវបានគេបោះបង់ចោល ត្រូវបានលែងលះ រស់នៅក្នុងអាពាហ៍ពិពាហ៍ពហុព័ន្ធភាព ឬជាស្ត្រីមេម៉ាយ។ ករណីសិក្សាបង្ហាញថា ផលប៉ះពាល់ទាំងនេះ បន្តឲ្យមានផលប៉ះពាល់ឆ្លងជំនាន់ និងបង្ក

ឲ្យមានភាពលំបាកផ្នែកសេដ្ឋកិច្ចនៅក្នុងករណីជាច្រើន។

- អ្នកឆ្លើយភាគច្រើន (៧០,២%) បានរៀបរាប់អំពីបញ្ហាសុខភាពផ្លូវចិត្តជាប់ជានិច្ច ដោយសារតែការរៀបការដោយបង្ខំនោះ ដោយមានរៀបរាប់អំពីការតានតឹងចិត្តនិងកំហឹងដែលត្រូវគេបង្ខំឲ្យរៀបការ។ ជាងនេះទៀត ច្រើនជាងមួយភាគបី (៣៥,៤%) បានរៀបរាប់អំពីផលវិបាកសេដ្ឋកិច្ចធ្ងន់ធ្ងរដោយសារតែការរៀបការដោយបង្ខំនេះ។

- ទោះបីជាអ្នកឆ្លើយតបភាគច្រើនលើកឡើងថាមិនបានលាក់រឿងរៀបការដោយបង្ខំនោះមិនឲ្យអ្នកដទៃដឹងក៏ដោយ ក៏ករណីសិក្សាបានរកឃើញថាជនរងគ្រោះជាច្រើនមានការខកចិត្តនិងភាពអាម៉ាស់ជាប់ខ្លួន ដោយសារតែការផ្គូផ្គងដែលគេបានចាត់តាំងឡើងនោះ។ ជាពិសេសឪពុកម្ដាយ បានលើកឡើងក្នុងករណីសិក្សាជាច្រើនអំពីការលំបាកក្នុងការនិយាយប្រាប់ការពិតអំពីការរៀបការដោយបង្ខំនេះឲ្យកូនដែលបានកើតមកដោយសារចំណងនៃការរៀបការដោយបង្ខំនេះបានដឹងណាស់។ ក្នុងចំណោមអ្នកដែលមិនបាននិយាយអំពីបទពិសោធន៍នេះប្រាប់អ្នកដទៃ ច្រើនជាងពាក់កណ្ដាល (៥២,៦%) លើកឡើងអំពីអារម្មណ៍អាម៉ាស់ ខណៈដែលមានច្រើនជាមួយភាគបី (៣៦,៨%) លើកឡើងអំពីការភ័យខ្លាចស្លាកស្នាមទុរយសនិងការរើសអើង។

- ការរៀបការដោយបង្ខំបន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហម បានរួមចំណែកបង្កឲ្យមានការផ្លាស់ប្ដូរទាំងស្រុងចំពោះតួនាទីនិងការទទួលខុសត្រូវយេនឌ័រ។ជាពិសេសស្ត្រីក្នុងគ្រួសារដែលមានមេគ្រួសារជាស្ត្រីទទួលបន្ទុកបន្ថែមសូម្បីតែនៅពេលចរចារអំពីការលំបាកខាងផ្នែកសង្គមនិងសេដ្ឋកិច្ច ការចិញ្ចឹមកូន និងការថែទាំមនុស្សចាស់។

- លទ្ធផលនៃការស្រាវជ្រាវនេះបង្ហាញថាជនរងគ្រោះនៅតែត្រូវការការគាំទ្រនិងសេវាសង្គមរយៈពេលវែង។ ការប្ដេជ្ញាចិត្តរបស់ម្ចាស់ជំនួយ និងសហគមន៍អន្តរជាតិ នៅតែជាសេចក្ដីត្រូវការយ៉ាងសំខាន់សម្រាប់គម្រោងកម្មវិធីនិងគម្រោងផ្អែកលើការស្រាវជ្រាវដើម្បីគាំទ្រដល់អង្គការមិនមែនរដ្ឋាភិបាលនិងអ្នកផ្ដល់សេវានានា។

# ៥.២ អនុសាសន៍

ការរៀបការគឺជាស្ថាប័នបំពេញមុខងារមួយ គឺវាផ្លាស់ប្ដូរឋានៈ តួនាទី សិទ្ធិ និងការទទួលខុសត្រូវ តាមរយៈការកំណត់ដោយការអនុវត្តតាមប្រពៃណី និងអត្តសញ្ញាណយេនឌ័រ។ ការរៀបការដោយបង្ខំដែលបង្កើតឡើងដោយរបបខ្មែរក្រហម តំណាងឲ្យអំពើហិង្សាយេនឌ័រផ្លូវភេទដែលបង្កផលប៉ះពាល់ធំទូលំទូលាយ។ គោលនយោបាយខ្មែរក្រហមគឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ សម្រាប់ អ.វ.ត.ក យកមកកាត់សេចក្ដី និងតាមរយៈការផ្ដល់សំណងប្រកបដោយប្រសិទ្ធភាព។ ជាងនេះទៀត ការរៀបការដោយបង្ខំគឺជាទ្វេគ្រោះខាងផ្នែកអភិវឌ្ឍន៍សម្រាប់រដ្ឋាភិបាលកម្ពុជា ដោយសារតែការរៀបការដោយបង្ខំទាំងបំពាននោះ បន្តជាប់មកមិនដាច់ដូច ដែលស្រីមេម៉ាយនិងគ្រួសារដែលមានមេគ្រួសារជាស្ត្រីបន្សល់ពីការរៀបការដោយបង្ខំនោះកំពុងមានវ័យចំណាស់ដោយគ្មានបណ្ដាញសន្តិសុខគ្រប់គ្រាន់ឡើយហើយដូចដែលកូនដែលបានកើតមកពីការរៀបការដោយបង្ខំនោះ ទទួលរងការប៉ះទង្គិចផ្លូវចិត្តឆ្លងជំនាន់ និងផលវិបាកខាងផ្នែកសង្គមសេដ្ឋកិច្ចធ្ងន់ធ្ងរផ្សេងៗទៀត។

### ក. រាជរដ្ឋាភិបាលកម្ពុជា

- បង្កើតឲ្យមានសំណងសម្រាប់ជនរងគ្រោះដោយសារការរៀបការដោយបង្ខំ ដោយរាប់បញ្ចូលទាំងសំណងជាលុយ និងសេវាចិត្តសង្គមនិងសេវាគាំទ្រដទៃទៀតសម្រាប់ជននៅរស់ជីវិតពីការរៀបការដោយបង្ខំក្នុងរបបខ្មែរក្រហម ឲ្យស្របតាមគោលការណ៍មូលដ្ឋាននិងការណែនាំរបស់អង្គការសហប្រជាជាតិស្ដីពីសិទ្ធិក្នុងការទទួលបានដំណោះស្រាយនិងសំណងសម្រាប់ជនរងគ្រោះនៃការរំលោភបំពានធ្ងន់ធ្ងរទៅលើច្បាប់សិទ្ធិមនុស្សអន្តរជាតិនិងការរំលោភបំពានធ្ងន់ធ្ងរទៅលើច្បាប់មនុស្សធម៌អន្តរជាតិ ក៏ដូចជាសេចក្ដីប្រកាសក្រុងណៃរ៉ូប៊ីស្ដីពីសិទ្ធិស្ត្រីនិងកុមារីក្នុងការទទួលបានដំណោះស្រាយនិងសំណង។

- ចងក្រងឯកសារអំពីការវិវត្តន៍ក្នុងការធ្វើរបាយការណ៍សម្រាប់អនុសញ្ញាស្ដីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងទៅលើស្ត្រី (ស៊ីដ) និងរបាយការណ៍សម្រាប់អនុសញ្ញាសិទ្ធិមនុស្សដទៃទៀត អំពីការរីកចម្រើនទាក់ទងនឹងឋានៈស្ត្រីកម្ពុជានិងសមភាពយេនឌ័រ ជាពិសេសពាក់ព័ន្ធនឹងការលុបបំបាត់ការវាយតម្លៃខុសឆ្គងលើយេនឌ័រតាមប្រពៃណីដែលមានការរឹតបន្តឹង ព្រមទាំងក្នុងការអនុវត្តសំណង ដូចមានអំពាវនាវក្នុងសេចក្ដីសង្កេតសន្និដ្ឋានរបស់គណៈកម្មការស៊ីដ ឆ្នាំ២០១៣។

- ប្ដេជ្ញាចិត្តកុំឲ្យមានការកើតឡើងវិញនូវឧក្រិដ្ឋកម្មយេនឌ័រក្នុងពេលមានជម្លោះនិងក្រោយពេលជម្លោះ តាមរយៈការបង្កើតឲ្យមានផែនការសកម្មភាពជាតិស្ដីពីស្ត្រី សន្តិភាព និងសុវត្ថិភាព ស្របតាមសេចក្ដីសម្រេចរបស់អង្គការសហប្រជាជាតិលេខ ១៣២៥ និងសេចក្ដីសម្រេចស្រដៀងគ្នានោះ ព្រមទាំងប្ដេជ្ញាចិត្ត ដូចដែលបានអំពាវនាវក្នុងសេចក្ដីសង្កេតសន្និដ្ឋានរបស់គណៈកម្មការស៊ីដ ឆ្នាំ២០១៣។

- ធ្វើសមាហរណកម្មការរៀបការដោយបង្ខំនេះចូលទៅក្នុងវិស័យស្នូលក្នុងផែនការអភិវឌ្ឍន៍ ដោយរាប់បញ្ចូលទាំងផែនការសកម្មភាពជាតិស្ដីពីការរីកចម្រើនរបស់ស្ត្រី និងផែនការសកម្មភាពជាតិស្ដីពីអំពីហិង្សាទៅលើស្ត្រីដែរ។ ត្រូវសង្កត់ធ្ងន់ទៅលើការគាំទ្រចិត្តសង្គមនិងសេដ្ឋកិច្ចសម្រាប់ក្រុមជនរងគ្រោះវ័យចំណាស់និងកូនរបស់ពួកគេ។

*ទាំងក្នុងកម្មវិធីសំណង និងយុទ្ធសាស្ត្រអភិវឌ្ឍន៍បន្តបន្ទាប់៖*

- ត្រូវពង្រឹងសេវាចិត្តសង្គមនិងសេវាគាំទ្រសង្គមនានា និងកសាងសមត្ថភាពរបស់អ្នកផ្ដល់សេវា ដោយធ្វើសមាហរណកម្មអំពើហិង្សាយេនឌ័រនិងការរៀបការដោយបង្ខំក្នុងរបបខ្មែរក្រហមចូលទៅក្នុងការអប់រំដល់វេជ្ជបណ្ឌិត ចិត្តវិទូ សង្គមកិច្ចវិទូ និងមេធាវី។

- ត្រូវសម្រួលឲ្យមានការជ្រើសរើសបុគ្គលិកក្នុងមន្ទីរពេទ្យនិងមណ្ឌលសុខភាពដែលជាអ្នកចិត្តសាស្ត្រ អ្នកប្រឹក្សាយោបល់ស្ដីពីការប៉ះទង្គិចផ្លូវចិត្ត និងសង្គមកិច្ចវិទូ ក្នុងការផ្ដល់ការព្យាបាលដល់បុគ្គល ក្រុម និងគ្រួសារដល់ជនរងគ្រោះដោយសារការរៀបការដោយបង្ខំក្នុងរបបខ្មែរក្រហមនិងដល់គ្រួសាររបស់ពួកគេ។

- ត្រូវផ្ដល់សេវាផ្នែកច្បាប់និងសេវាគាំទ្រដទៃទៀត ដល់ជនរងគ្រោះឲ្យបានចំនួនច្រើនតាមដែលអាចធ្វើទៅបាន ជាពិសេសដល់ស្ត្រី ដែលមានសេចក្ដីប្រាថ្នាចង់បញ្ចប់ការរៀបការដោយបង្ខំ ប៉ុន្តែជួបឧបសគ្គក្នុងការធ្វើបែបនេះ ដូចជាដោយសារតែការពឹងផ្អែកខាងផ្នែកសេដ្ឋកិច្ច ការគាបសង្កត់ពីគ្រួសារនិងបុព្វហេតុដទៃមួយចំនួនទៀត។

- ត្រូវប្រើប្រព័ន្ធផ្សព្វផ្សាយឲ្យមានប្រសិទ្ធភាពក្នុងការលើកកម្ពស់ការយល់ដឹងអំពីការរៀបការដោយបង្ខំក្នុងរបបខ្មែរក្រហម អំពីសិទ្ធិមនុស្សរបស់បុរសនិងស្ត្រីក្នុងការទទួលបានការរៀបការនិងការរួមភេទដោយមានការព្រមព្រៀង និងអំពីផលប្រយោជន៍នៃទំនាក់ទំនងដែលមានស្ថានភាពល្អនិងមានភាពស្មើគ្នា។

## ខ. អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

- សម្រាប់អង្គជំនុំជម្រះសាលាដំបូង ត្រូវធានាថាមានការពិភាក្សាពេញលេញអំពីលក្ខណៈ ការអនុវត្ត និងទំហំនៃការរៀបការដោយបង្ខំក្នុងរបបខ្មែរក្រហម ក្នុងសំណុំរឿង០០២/០២ របស់អ.វ.ត.ក ដូចមានចែងក្នុងសាលក្រមនៃសំណុំរឿង០០២/០១។

- សម្រាប់ការិយាល័យសហចៅក្រមស៊ើប ត្រូវស៊ើបអង្កេតឧក្រិដ្ឋកម្មទាំងនេះ ឲ្យបានពេញលេញសម្រាប់យកមកកាត់សេចក្ដី ដូចមាននៅក្នុងដីកាសំណុំរឿង០០៣ និង០០៤។

- សម្រាប់សហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណីនិងផ្នែកគាំទ្រជនរងគ្រោះ ត្រូវរៀបចំក្នុងភាពជាដៃគូជាមួយអង្គការសង្គមស៊ីវិលនិងតំណាងជនរងគ្រោះ បង្កើតគម្រោងសំណងដ៏មានអត្ថន័យនិងទូលំទូលាយ ដើម្បីដោះស្រាយផលប៉ះពាល់ផ្នែកសម្ពារៈចិត្តសង្គម និងផលប៉ះពាល់ធ្ងន់ធ្ងរដទៃទៀតដោយសារការរៀបការដោយបង្ខំនិងការរួមភេទដោយបង្ខំនេះឲ្យបានគ្រប់វិសាលភាពពេញលេញ។ ត្រូវផ្ដល់អាទិភាពដល់កម្មវិធីនិងគំនិតផ្ដួចផ្ដើមទាំងឡាយដែលសំដៅលើកូនដែលកើតចេញមកពីការរៀបការដោយបង្ខំនេះ។

- សម្រាប់គ្រប់ផ្នែកទាំងអស់នៃតុលាការ ត្រូវធ្វើសមាហរណកម្មចូលទៅក្នុងផែនការកេរដំណែលរបស់ខ្លួន នូវស្នូលអាទិភាពទៅលើការផ្ទេរការអនុវត្តល្អបំផុតសម្រាប់ដោះស្រាយអំពើហិង្សាយេនឌ័រនិងអំពើហិង្សាផ្លូវភេទទៅក្នុងប្រព័ន្ធយុត្តិធម៌អន្តរកាលជាតិរបស់ប្រទេសកម្ពុជា ជាមធ្យោបាយមួយសម្រាប់ធ្វើឲ្យសម្រេចបាននូវការមិនកើតឡើងវិញ តាមរយៈការផ្លាស់ប្ដូរការអនុវត្តលក្ខណៈប្រពៃណីដែលធ្វើឲ្យបន្តកើតឡើងនិងចាត់ទុកអំពើហិង្សាយេនឌ័រនិងសមភាពយេនឌ័រជាការធម្មតា។

- សម្រាប់អង្គភាពគាំទ្រជនរងគ្រោះ ត្រូវរៀបចំក្នុងភាពជាដៃគូជាមួយអង្គការសង្គមស៊ីវិលនិងតំណាងជនរងគ្រោះ បង្កើតវិធានការមិនពាក់ព័ន្ធបច្ចេកទេសតុលាការដែលស្វែងរកឲ្យមានការពង្រឹងសិទ្ធិអំណាចអ្នកនៅមានជីវិត និងទទួលស្គាល់បទពិសោធន៍នៃការរៀបការដោយបង្ខំ និងការរួមភេទដោយបង្ខំដែលកើតឡើងទៅលើពួកគេ។ គម្រោងគួរត្រូវរចនាបង្កើតឡើងដោយមានការពិគ្រោះយោបល់ជាមួយអ្នកនៅរស់រានមានជីវិតផ្ទាល់ និងគួរប្រើជាមធ្យោបាយសម្រាប់លើកកម្ពស់ការយល់ដឹងអំពីអំពើហិង្សាយេនឌ័រនៅថ្នាក់ជាតិនិងថ្នាក់មូលដ្ឋាន។

- សម្រាប់ផ្នែកកិច្ចការសាធារណៈរបស់តុលាការ ត្រូវផ្ដល់ព័ត៌មានដល់សាធារណជនអំពីរបៀបដែលតុលាការឆ្លើយតបចំពោះឧក្រិដ្ឋកម្មយេនឌ័រក្នុងរបបខ្មែរក្រហមជាទូទៅនិងជាពិសេសចំពោះការរៀបការដោយបង្ខំ និងការរួមភេទដោយបង្ខំ។ ត្រូវបញ្ចូលការពន្យល់ច្បាស់លាស់និងត្រឹមត្រូវមួយអំពីឧក្រិដ្ឋកម្មយេនឌ័រដែលត្រូវកាត់សេចក្ដីនៅតុលាការ ក៏ដូចជាព័ត៌មានលម្អិតអំពីឧក្រិដ្ឋកម្មទាំងនោះដែលកំពុងត្រូវបានកាត់សេចក្ដី ព្រមជាមួយនឹងមូលហេតុ ទាំងផ្នែកច្បាប់និងមូលហេតុផ្សេងទៀតអំពីករណីនេះ។ ការចែករំលែកព័ត៌មានបែបនេះ នឹងឈានទៅដល់ការបង្កន់ការយល់ឃើញជាសាធារណៈអំពីនិរទណ្ឌភាពចំពោះឧក្រិដ្ឋកម្មទាំងនោះ ជាពិសេសក្នុងចំណោមជនរងគ្រោះនៃអំពើហិង្សាយេនឌ័រក្នុងរបបខ្មែរក្រហម ហើយវានឹងបង្កើតជាឧទាហរណ៍ដ៏សំខាន់មួយអំពីរបៀបដោះស្រាយអំពើហិង្សាយេនឌ័រក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន ដោយតុលាការ រដ្ឋាភិបាល និងអ្នកធ្វើគោលនយោបាយ។

### គ. អង្គការមិនមែនរដ្ឋាភិបាលនិងអ្នកអនុវត្ត

- ត្រូវលើកទឹកចិត្តឲ្យមានការអភិរក្សនិងផ្សព្វផ្សាយចំណេះដឹងអំពីការរៀបការដោយបង្ខំនិងផលប៉ះពាល់របស់វា តាមរយៈការធ្វើសមាហរណកម្មឲ្យបានពេញលេញទៅក្នុងការពិភាក្សាប្រវត្តិសាស្ត្រនៃវិនាសកម្មក្នុងរបបខ្មែរក្រហម នៅថ្នាក់ជាតិ។ ត្រូវបញ្ចូលយុវជនក្នុងកិច្ចខំប្រឹងប្រែងបែបនេះជាពិសេសក្នុងការចងក្រងឯកសារសាច់រឿងពិតនិងក្នុងការដឹកនាំ ការពិភាក្សាក្នុងសហគមន៍អំពីសិទ្ធិមនុស្សជាសកលនិងសមភាពយេនឌ័រក្នុងពេលមានសន្តិភាពនិងក្នុងពេលមានជម្លោះ។

- ទទួលស្គាល់និងដោះស្រាយបញ្ហាប្រឈមពិសេសរបស់ជនរងគ្រោះដោយសារការរៀបការដោយបង្ខំនិងការរួមភេទដោយបង្ខំ ដូចជា ការបំពានក្នុងគ្រួសារ ការដកហូតផ្នែកសេដ្ឋកិច្ច និងការផ្ដាច់ចេញពីសង្គមជាដើមនោះ ក្នុងការផ្ដល់សេវានិងការការពារជនរងគ្រោះនៃអំពើហិង្សាយេនឌ័រ។

- ពង្រឹងសិទ្ធិអំណាចជនរងគ្រោះ តាមរយៈការបង្កើតក្រុមជួយខ្លួនឯងនៅតាមសហគមន៍សម្រាប់អ្នករស់រានមានជីវិតពីការរៀបការដោយបង្ខំក្នុងរបបខ្មែរក្រហម ដើម្បីជួយឲ្យពួកគេដោះស្រាយជាមួយនឹងផលប៉ះពាល់ចិត្តសាស្ត្រនិងសង្គមដោយសារឧក្រិដ្ឋកម្មនេះ។ កសាងសមត្ថភាពរបស់អ្នករស់រានមានជីវិតពីការរៀបការដោយបង្ខំនិងការរួមភេទដោយបង្ខំ ដើម្បីឲ្យពួកគេអាចកំណត់រកឃើញនិងតស៊ូមតិសម្រាប់

ផលប្រយោជន៍របស់ខ្លួនក្នុងដំណើរការយុត្តិធម៌អន្តរកាលក្នុងប្រទេសកម្ពុជា។

- លើកកម្ពស់ការយល់ដឹងក្នុងសហគមន៍ដែលមានសេចក្ដីត្រូវការក្នុងការបញ្ចប់ការបន្ទោសជនរងគ្រោះ សម្រាប់ការកើតឡើងនូវអំពើហិង្សាយេនឌ័រ ដោយរាប់បញ្ចូលទាំងការរៀបការដោយបង្ខំ ការកែទម្រង់ការអនុវត្តតាមបែបប្រពៃណីដែលរឹតបន្តឹងសេរីភាពក្នុងការធ្វើស្វ័យសម្រេចនិងសមភាពយេនឌ័រនិងដើម្បីពង្រឹងការទទួលស្គាល់ការចូលរួមចំណែករបស់ស្ត្រីក្នុងការធ្វើឲ្យមានគ្រួសារនិងសង្គមមានស្ថិរភាព។

- ស្រាវជ្រាវបន្ថែមអំពីផលប៉ះពាល់និងជាតុខុសគ្នាទាំងឡាយនៃការរៀបការដោយបង្ខំដោយរាប់បញ្ចូលទាំងតាមរយៈការផ្ដល់ការយកចិត្តទុកដាក់ឲ្យកាន់តែច្រើនទៅលើបទពិសោធន៍របស់បុរសដែលទទួលរងឧក្រិដ្ឋកម្មទាំងនេះ និងការរំខានដែលកើតឡើងទៅលើតួនាទីនិងអត្តសញ្ញាណយេនឌ័រ ភាពជាបុរស និងការប៉ះទង្គិចផ្លូវចិត្តទៅលើមនុស្សប្រុស។

៦

# ការខ្វិនិស
# និងសេចក្តីថ្លែងអំណរគុណ

## អ្នកផ្តល់សម្ភាសន៍

របាយការណ៍នេះសូមរំលឹកដល់បុរសនិងស្ត្រីចំនួន១០៦នាក់ដែលបានចូលរួមនៅក្នុងការស្រាវជ្រាវនេះ តាមរយៈការចែករំលែកនូវរឿងរ៉ាវដ៏ឈឺចាប់អំពីការប៉ះទង្គិចផ្លូវចិត្តនិងការបាត់បង់នានា ក៏ដូចជារឿងរ៉ាវនៃការរស់ឡើងវិញដ៏មិនគួរឲ្យជឿ ព្រមទាំងអំពីភាពថ្លៃថ្នូរជាមនុស្ស។ សេចក្តីក្លាហាននេះ បានរួមចំណែកឲ្យមានការយល់ដឹងកាន់តែប្រសើរអំពីគោលនយោបាយនៃការរៀបការដោយបង្ខំនិងការរួមភេទដោយបង្ខំក្នុងរបបខ្មែរក្រហម ដែលមានភាពសំខាន់សម្រាប់កំណត់ត្រាប្រវត្តិសាស្ត្រនៃវិនាសកម្មក្នុងប្រទេសកម្ពុជា ក៏ដូចជាមានសារៈសំខាន់ដល់កិច្ចប្រឹងប្រែងជាអន្តរជាតិក្នុងការបញ្ចប់អំពើហិង្សាយេនឌ័រក្នុងពេលមានជម្លោះក្នុងសកលលោកផងដែរ។

## អ្នកនិពន្ធ

បណ្ឌិត Theresa de Langis ដែលជាអ្នកឯកទេសជាន់ខ្ពស់ផ្នែកសិទ្ធិមនុស្សរបស់ស្ត្រីក្នុងពេលមានជម្លោះនិងក្នុងកាលៈទេសៈអន្តរកាល គឺជាអ្នកនិពន្ធដំបូងនៃរបាយការណ៍នេះ។ សហអ្នកនិពន្ធរួមមានបណ្ឌិត Judith Strasser ដែលជាទីប្រឹក្សាអន្តរជាតិរបស់អង្គការធីភីអូ,ធីតា គីមដែលជាជំនួយការបច្ចេកទេសសម្រាប់គម្រោងអំពើហិង្សាយេនឌ័ររបស់អង្គការធីភីអូ, និង តាំង សុភាព ដែលជាអ្នកសម្របសម្រួលផ្នែកស្រាវជ្រាវ តាមដាន និងវាយតម្លៃរបស់អង្គការធីភីអូ។

## ក្រុមស្រាវជ្រាវ

បណ្ឌិត Judith Strasser ដែលជាទីប្រឹក្សាអន្តរជាតិរបស់អង្គការធីភីអូ ដើរតួនាទីជាអ្នកស្រាវជ្រាវនាំមុខសម្រាប់ផ្នែកបរិមាណវិស័យនៃការស្រាវជ្រាវនេះ ដោយរាប់ទាំងការរចនាបង្កើតសំណួរស្ទង់មតិនិងការវិភាគទិន្នន័យ។ តាំង សុភាព ដែលជាអ្នកសម្របសម្រួលផ្នែកស្រាវជ្រាវ តាមដាន និងវាយតម្លៃរបស់អង្គការធីភីអូ ពិនិត្យមើលការងារប្រមូលទិន្នន័យនិងការរៀបចំការសម្រាប់ការវិភាគលទ្ធផលផ្នែកបរិមាណវិស័យ។ បណ្ឌិត Theresa de Langis ដើរតួនាទីជាអ្នកស្រាវជ្រាវនាំមុខខាងផ្នែកគុណវិស័យសម្រាប់ការស្រាវជ្រាវនេះ។ ធីតា គីម ដែលជាជំនួយការបច្ចេកទេសសម្រាប់គម្រោងអំពើហិង្សាយេនឌ័ររបស់អង្គការធីភីអូ ធ្វើការសម្ភាសករណីសិក្សានិងផ្តល់ការបកប្រែពីភាសាខ្មែរទៅភាសាអង់គ្លេសសម្រាប់ការវិភាគ។ ធីតា ក៏បានមើលការខុសត្រូវទៅលើការងារភស្តុភារជាច្រើន និងផ្តល់ការគាំទ្រចាំបាច់ដល់អ្នកផ្តល់សម្ភាសន៍សម្រាប់ការធ្វើដំណើរមកភ្នំពេញដើម្បីចូលរួមក្នុងការស្រាវជ្រាវនេះ។ សូមថ្លែងអំណរគុណ

ដល់អ្នកស្រាវជ្រាវនៅមជ្ឈមណ្ឌលសិក្សាជាន់ខ្ពស់សម្រាប់ការគ្រប់គ្រងការស្ទង់មតិបែបបរិមាណវិស័យ។ សូមអរគុណដល់ សុខ លាំង ដែលបានធ្វើការបកប្រែរបាយការណ៍នេះពីភាសាអង់គ្លេសទៅជាភាសាខ្មែរ។

## *ការគាំទ្រពីម្ចាស់ជំនួយ*

គម្រោងស្រាវជ្រាវនេះមិនអាចធ្វើឡើងបានទេប្រសិនបើគ្មានថវិកាតាមរយៈអង្គការ Civil Peace Service of Deutsche Gesellschaft für Internationale Zusammenarbeit (GIZ)។ សូមថ្លែងអំណរគុណជាពិសេសចំពោះ GIZ សម្រាប់ការទទួលស្គាល់អំពីតម្រូវការក្នុងការចងក្រងជាឯកសារអំពីការរៀបការដោយបង្ខំក្នុងរបបខ្មែរក្រហមនេះ។

## *ការរចនា*

Melon Rouge ក្នុងក្រុងភ្នំពេញ ផ្តល់នូវការរៀបចំរចនាក្របនិងរចនារបាយការណ៍នេះ។

សន្ធានុក្រម